## ថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៩

## លោក វង សូត ជួបសំណេះសំណាលនិងចែកអំណោយដល់ប្រជាពលរដ្ឋក្រីក្រចំនួន៤០០គ្រួសារ

http://ppt-news.net/ ចេញផ្សាយ ថ្ងៃទី 31/01/2019

ខេត្តបន្ទាយមានជ័យ ៖ នៅព្រឹកថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៩នេះ ឯកឧត្តម វង សូត រដ្ឋមន្ត្រីក្រសួង សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានអញ្ជើញជាអធិបតីភាពក្នុងពិធីសំណេះសំណាល និងចែកអំណោយសង្គ្រោះបន្ទាន់ដល់ប្រជាពលរដ្ឋក្រីក្រដែលរងគ្រោះដោយគ្រោះធម្មជាតិ ចំនួន ៤០០គ្រួសារនៅមជ្ឈមណ្ឌលសំចត ស្ថិតក្នុងភូមិប្រជាធម្ម សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។ លោក វង សូត បាននាំមកនូវអំណោយចែកជូនប្រជាពលរដ្ឋក្រីក្រដែល រងគ្រោះដោយគ្រោះធម្មជាតិចំនួន ៤០០គ្រួសារ ក្នុងមួយគ្រួសារទទួលបាន ភួយ១ កន្ទេល១ មុង១ មី ១កេះ អង្ករមួយបាវទម្ងន់ ២០គីឡូក្រាម រួមនឹងថវិកាចំនួន ៤០,០០០រៀល។ ជាមួយគ្នានេះដែរ គណៈអធិបតីបានផ្តល់ជូនថវិកាដល់សង្កាត់ទាំង៣ (សង្កាត់ប៉ោយប៉ែត សង្កាត់ផ្សារកណ្តាល និងសង្កាត់និមិត្ត) ក្នុងក្រុងប៉ោយប៉ែត ក្នុងមួយសង្កាត់ទទួលថវិកាចំនួន ១លានរៀល និងផ្តល់ជូនមជ្ឈមណ្ឌលសំចតថវិកាចំនួន ១លានរៀល សរុបជាថវិកាទាំងអស់ចំនួន ២០លានរៀល។

គួរបញ្ជាក់ដែរថា មជ្ឈមណ្ឌលសំចតជួយជនរងគ្រោះនៅច្រកព្រំដែនប៉ោយប៉ែត បានកសាងលើផ្ទៃដីទំហំ ១ ហិកតា ស្ថិតនៅក្នុងភូមិប្រជាធម្ម សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។ គោលបំណងក្នុងការរៀបចំឱ្យមានអគារមជ្ឈមណ្ឌលសំចតជួយជនរងគ្រោះនៅច្រកព្រំដែនប៉ោយប៉ែតនេះធ្វើឡើងគឺជាការគិតគូរ និងការទទួលខុសត្រូវខ្ពស់របស់អាជ្ញាធរ និងរាជរដ្ឋាភិបាលកម្ពុជាក្រោមការដឹកនាំដ៏ឈ្លាសវៃប្រកបដោយគតិបណ្ឌិតរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ជាប្រមុខដឹកនាំក្នុងការសម្រួលនឹងរៀបចំសម្រាប់ប្រជាពលរដ្ឋ ពិសេសចំពោះពលករឆ្លងដែនខុសច្បាប់ដែលអាជ្ញាធរថៃចាប់បញ្ជូនត្រលប់មកវិញយ៉ាងគំហុកឱ្យមានកន្លែងស្នាក់នៅបានល្អប្រសើរ សមរម្យ និងមានសុខសុវត្ថិភាព។

ជំហានដំបូងនៃការរៀបចំមជ្ឈមណ្ឌលសំចតនេះជាបន្តបន្ទាប់នឹងមានរៀបចំឱ្យបានល្អសមរម្យនឹងក្លាយទៅជាមជ្ឈមណ្ឌលពហុវិស័យពាក់ព័ន្ធទាំងអស់សម្រាប់ជួយសម្រួលដល់ពលករ និងប្រជាពលរដ្ឋកម្ពុជា។ គម្រោងសម្រាប់សាងសង់មជ្ឈមណ្ឌលមានផ្នែកស្នាក់នៅអចិន្ត្រៃយ៍បណ្តោះអាសន្នមាន កន្លែងម្ហូបអាហារ កន្លែងអប់រំបណ្តុះបណ្តាលថៃទាំ និងបម្រើជូនសេវាពាក់ព័ន្ធផ្សេងៗទៀតក្រោមការគ្រប់គ្រងច្បាស់លាស់៕

## ឯកឧត្តម អ៊ិត សំហេង៖ ជប៉ុននឹងជួយពង្រឹងសមត្ថភាពបន្ថែមដល់ពលករកម្ពុជាលើផ្នែកសំណង់

http://www.mlvt.gov.kh/index.php Friday, 01 February 2019 12:04

ទីស្តីការក្រសួង៖ ឯកឧត្តមបណ្ឌិត អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ អនុញ្ញាតឱ្យលោក Fumio Yamada ប្រធានអង្គការសមាគមសហប្រតិបត្តិការកម្ពុជា-ជប៉ុន ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារនៅព្រឹកថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៩ នៅទីស្តីការក្រសួង។ នៅក្នុងជំនួបនោះ លោក Yamada បាននាំវិនិយោគទុនខាងក្រុមហ៊ុនសំណង់ផ្នែកត្រួតពិនិត្យដីដែលមានក្រុមហ៊ុនជាង ៤០០នៅជប៉ុន ដែលក្រុមហ៊ុននេះបានសិក្សាលើប្រភេទដី បង្កើតបាតគ្រឹះមុននឹងសាងសង់ និងយកសំណាកដីធ្វើការពិសោធន៍នៅប្រទេសជប៉ុន។ ក្រុមហ៊ុនសំណង់នេះបានទទួល ពលករខ្មែរ ដែលអាចទៅធ្វើការផ្នែកសំណង់នេះជាង៣០០នាក់ហើយ នៅឯប្រទេសជប៉ុន ។ ពលករខ្មែរនឹងមានជំនាញពិតប្រាកដខាងផ្នែកសំណង់នេះ បន្ទាប់ពីគាត់ទៅធ្វើកម្មសិក្សានៅជប៉ុន ហើយនាំជំនាញ

នេះមកអភិវឌ្ឍវិស័យសំណង់នេះនៅកម្ពុជាវិញ ។ ជាមួយគ្នានេះដែរ លោក Yamada នឹងធ្វើយ៉ាងណាទាក់ទាញ អ្នកវិនិយោគទុនជប៉ុនថ្មីៗអោយមកវិនិយោគនៅលើទឹកដីកម្ពុជាអោយកាន់តែច្រើនបន្ថែមទៀត។

ជាការឆ្លើយតប ឯកឧត្តមរដ្ឋមន្ត្រី ពេញចិត្តនូវអ្វីដែលជាការលើកឡើងរបស់លោកប្រធានអង្គការសមាគមសហប្រតិបត្តិការកម្ពុជា-ជប៉ុន ដែលណែនាំអ្នកវិនិយោគផ្នែកសំណង់មកកម្ពុជា។ ឯកឧត្តមមានប្រសាសន៍ថា បច្ចុប្បន្ននេះ វិស័យសំណង់របស់កម្ពុជា កំពុងមានការរីកចម្រើនជាខ្លាំង ក្នុងនោះមានក្រុមហ៊ុនសំណង់របស់ជប៉ុនបានរួមចំណែកក្នុងការអភិវឌ្ឍលើវិស័យសំណង់នេះផងដែរ។ ឯកឧត្តមថា៖«សំណង់មិនអាចប្រហែសបានទេ ប៉ះពាល់ដល់អាយុជីវិតរបស់មនុស្ស បើបច្ចេកទេសមិនល្អគឺមានហានិភ័យដល់ជីវិតរបស់មនុស្ស ដូច្នេះត្រូវយកចិត្តទុកដាក់ខ្ពស់ក្នុងរៀបចំដំណើរការសាងសង់អោយទៅតាមបទដ្ឋានស្តង់ដាសំណង់» ។

អង្គការសមាគមសហប្រតិបត្តិការកម្ពុជា-ជប៉ុន មានបំណងចង់បង្កើតភូមវិប្បធ៌មខ្មែរមួយនៅប្រទេសជប៉ុន ហើយសង្ឃឹមថា ភាគីកម្ពុជានឹងឯកភាពតាមសំណើនេះ។ ភូមិវប្បធ៌មនេះ ជាការជួបប្រជុំគ្នារវាងប្រជាជនខ្មែរនៅជប៉ុន ក្នុងការធ្វើពិធីបុណ្យផ្សេងៗតាមប្រពៃណី ម្យ៉ាងវិញទៀតសាច់ញាតិពលករ ឬពលរដ្ឋខ្មែរអាចទៅជួបប្រជុំនៅទីនោះ បានដើម្បីបង្ហាញពីវប្បធ៌មរបស់ខ្មែរ។ ឆ្លើយតបទៅនឹងសំណើនេះ ឯកឧត្តមរដ្ឋមន្ត្រីបានឯកភាពនូវការបង្កើតភូមិវប្បធ៌មនេះ ដើម្បីបង្កលក្ខណៈងាយស្រួលដល់ការជួបជុំសាច់ញាតិរបស់បងប្អូនពលករ និងប្រជាជនខ្មែរទូទៅនៅទីនោះ។

នៅក្នុងជំនួបនោះដែរ ឯកឧត្តមរដ្ឋមន្ត្រី បានលើកឡើងថា ក្នុងខែមិនា ក្នុង២០១៩នេះ រដ្ឋកម្ពុជានឹងត្រូវចុះហត្ថលេខាជាមួយនឹងភាគីជប៉ុន នៅឯប្រទេសជប៉ុន លើកិច្ចព្រមព្រៀងសហប្រតិបត្តិការ ស្តីពីពលកនាញ។ ឯកឧត្តមរដ្ឋមន្ត្រីថា៖«ពលករដែលធ្វើការនៅជប៉ុន គឺមានចំនួន៩ពាន់នាក់ជាង សង្ឃឹមថា នៅឆ្នាំក្រោយនឹងមានការកើនចំនួនឡើងទ្វេរមួយជាពីរ ដូច្នេះ ពលករក៏ត្រូវការពេលវេលាក្នុងការបណ្តុះបណ្តាលអោយមានជំនាញច្បាស់លាស់ក្នុងការបំពេញកិច្ចការងាររបស់ពួកគេរឹតតែល្អប្រសើរថែមទៀត»។ គួរបញ្ជាក់ថា បច្ចុប្បន្ន ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បាននឹងកំពុងសហការជាមួយមន្ត្រីជំនាញនៃប្រទេសជប៉ុន ដើម្បីពិនិត្យ និងរៀបចំឱ្យមានកិច្ចព្រមព្រៀងសហប្រតិបត្តិការជាមួយគ្នា ក្នុងគោលបំណងដើម្បីបង្កើនទីផ្សារការងារ និងឱកាសការងារដល់ប្រជាជនកម្ពុជា។ ដោយជប៉ុន បានចាប់ផ្តើមរៀបចំបង្កើតឱ្យមានគម្រោងថ្មីសម្រាប់បង្កើនលំហូរនៃកម្លាំងពលកម្មពីប្រទេសផ្សេងៗនិងសម្រាប់អនុវត្តនៅអំឡុងខែមេសា ឆ្នាំ២០១៩ខាងមុខនេះ ដើម្បីដោះស្រាយបញ្ហាកង្វះកម្លាំងពលកម្មជំនាញនៅជប៉ុន៕

**អង្គការសិទ្ធិមនុស្ស HRW ស្វាគមន៍ការផ្តល់សច្ចាប័នរបស់ថៃលើអនុសញ្ញាស្តីពីការងារនេសាទ**

https://khmer.voanews.com/ 01 កុម្ភៈ 2019 សាយ មុន្នី

**អនុសញ្ញាអន្តរជាតិមួយនេះ ដែលបានចូលជាធរមាននៅខែវិច្ឆិកា ឆ្នាំ២០១៧ មានគោលដៅការពារលក្ខខណ្ឌការងារនិងការរស់នៅរបស់ពលករក្នុងវិស័យនេសាទ។**

វ៉ាស៊ីនតោន៖ អង្គការឃ្លាំមើលការរំលោភសិទ្ធិមនុស្សអន្តរជាតិ Human Rights Watch ដែលមានមូលដ្ឋាននៅទីក្រុងញ៉ូវយ៉ក សហរដ្ឋអាមេរិក បានសម្តែងការសាទរក្នុងលក្ខណៈប្រយ័ត្នប្រយែងចំពោះការសម្រេចចិត្តរបស់ប្រទេសថៃ ក្នុងការផ្តល់សច្ចាប័នលើអនុសញ្ញាអង្គការពលកម្មអន្តរជាតិ ហៅកាត់ថា ILO ស្តីពីការងារក្នុងវិស័យនេសាទ។ នេះបើយោងតាមបណ្តាញព័ត៌មាន Reuters ដែលបានចេញផ្សាយនៅថ្ងៃព្រហស្បតិ៍ទី៣១ ខែមករា ឆ្នាំ២០១៩។ ការស្វាគមន៍ចំពោះវិធានការថ្មីរបស់ប្រទេសថៃនេះ កើតឡើងក្រោយពីថៃ បានក្លាយជាប្រទេសដំបូងគេក្នុងតំបន់អាស៊ី ដែលបានផ្តល់សច្ចាប័នលើអនុសញ្ញាអន្តរជាតិស្តីពីការងារក្នុងវិស័យនេសាទ (Work in Fishing Convention) នេះ

កាលពីថ្ងៃពុធ។ អនុសញ្ញាអន្តរជាតិមួយនេះ ដែលបានចូលជាធរមាននៅខែវិច្ឆិកា ឆ្នាំ២០១៧ មានគោលដៅការពារលក្ខខណ្ឌការងារនិងការរស់នៅរបស់ពលករក្នុងវិស័យនេសាទ។

លោក Phil Robertson នាយករងទទួលបន្ទុកតំបន់អាស៊ីនៃអង្គការ Human Rights Watch បានថ្លែងប្រាប់បណ្ដាញព័ត៌មាន Thomson Reuters Foundation តាមសារអេឡិចត្រូនិកថា ខណៈដែលប្រទេសថៃ សមនឹងទទួលបានការស្ងើចសរសើរចំពោះការផ្ដល់សច្ចាប័នលើអនុសញ្ញានេះ ប្រទេសថៃ ចាំបាច់ត្រូវបង្កើតនិងអនុម័តបទបញ្ញត្តិដើម្បីអនុវត្តតាមអនុសញ្ញានេះ។ លោកមានប្រសាសន៍ថា៖ «យើងបានឃើញម្ចាស់ទូកនេសាទថៃដ៏មានឥទ្ធិពលជាច្រើនប្រឆាំងនឹងអនុសញ្ញានេះយ៉ាងខ្លាំងក្លាតាំងពីដំបូងទីមក ដូច្នេះយើងរំពឹងថា នឹងមានការប្រឆាំងគ្នាខ្លាំងទម្រាំអាចចេញជាច្បាប់មួយ ដែលអាចឈានទៅដល់ការការពារសិទ្ធិប្រកបដោយអត្ថន័យនិងការធ្វើឱ្យល្អប្រសើរឡើងនូវជីវភាពរស់នៅរបស់ពលករនេសាទ»។

ប្រទេសថៃ គឺជាប្រទេសនាំចេញម្ហូបអាហារសមុទ្រដ៏ច្រើនសន្ធឹកសន្ធាប់ជាងគេបំផុតមួយលើពិភពលោក ដោយទំហំពាណិជ្ជកម្មនៃឧស្សាហកម្មនេសាទ និងម្ហូបសមុទ្ររបស់ថៃ រួមចំណែកប្រមាណ៦ពាន់លានដុល្លារអាមេរិកដល់ទំនិញនាំចេញសរុបរបស់ប្រទេសក្នុងតំបន់អាស៊ីអាគ្នេយ៍មួយនេះ។ នេះបើផ្អែកតាមអង្គការពលកម្មអន្តរជាតិ។ វិស័យនេសាទ និងវេចខ្ចប់គ្រឿងសមុទ្ររបស់ថៃ ផ្ដល់ការងារដល់កម្មករជាង៦សែននាក់នៅឆ្នាំ២០១៧ ដែលក្នុងនោះប្រមាណពាក់កណ្ដាលគឺជាពលករចំណាកស្រុក ដែលបានចុះបញ្ជីត្រឹមត្រូវ។ នេះបើយោងតាមអង្គការ ILO ដដែល។

ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ប្រទេសថៃបានរងការរិះគន់យ៉ាងខ្លាំងចំពោះការចោទប្រកាន់ពីអំពើទាសភាព ការជួញដូរមនុស្ស និងអំពើហិង្សាដែលត្រូវបានប្រព្រឹត្តទៅលើពលករនេសាទចំណាកស្រុកមកពីប្រទេសជិតខាងរួមទាំងពលករខ្មែរផងដែរ ដែលធ្វើការនៅលើទូកនេសាទ និងកន្លែងវេចខ្ចប់គ្រឿងសមុទ្រថៃ។ ប៉ុន្តែថ្មីៗនេះ សហភាពអឺរ៉ុប បានដកការគំរាមរបស់ខ្លួន ដែលចង់ហាមឃាត់ការនាំចូលគ្រឿងសមុទ្រថៃ ទៅកាន់ទីផ្សារសហភាពអឺរ៉ុប ក្រោយពីសហគមន៍អឺរ៉ុបនិយាយថា ប្រទេសនេះ បានកែលម្អបញ្ហានេសាទនេះ៕

## រដ្ឋាភិបាលថៃ រៀបចំលក្ខខណ្ឌការងារ ដើម្បីជួយពលករនេសាទ

https://www.postkhmer.com/ ឧន សារ៉ៃ | Publication date 01 February 2019 | 11:45 ICT

ភ្នំពេញៈ រដ្ឋាភិបាលថៃបានប្ដេជ្ញាជួយធ្វើឲ្យមានលក្ខខណ្ឌការងារ និងការរស់នៅសមស្របដល់ពលករនេសាទក្រោយពីប្រទេសនេះ បានផ្ដល់សច្ចាប័នលើអនុសញ្ញាស្ដីពីការងារក្នុងវិស័យនេសាទរបស់អង្គការពលកម្មអន្តរជាតិ (ILO)។ នេះបើតាមការផ្សាយរបស់អង្គការ ILO កាលពីថ្ងៃ ៣០ មករា។ ប៉ុន្តែសង្គមស៊ីវិលយល់ថា អនុសញ្ញានេះមិនទាន់អាចការពារពលករនេសាទនៅថៃបានទាំងស្រុងទេ។ អនុសញ្ញាស្ដីពីការងារក្នុងវិស័យនេសាទ គឺតម្រូវឱ្យមានលក្ខខណ្ឌមួយចំនួន ដូចជាការការពារសុវត្ថិភាព សុខុមាលភាព ការផ្ដល់សេវាព្យាបាល ការឈប់សម្រាកការចុះកិច្ចសន្យាការងារ និងការការពារអំពីសន្តិសុខសង្គមដើម្បីធានាថា ទូកនេសាទទាំងអស់ត្រូវតែផ្ដល់លក្ខខណ្ឌរស់នៅសមរម្យដល់ពលករ។

លោក Adul Sangsingkeo រដ្ឋមន្ត្រីក្រសួងការងារថៃបានបញ្ជាក់ថា ការផ្ដល់សច្ចាប័ននេះ គឺដើម្បីធានាឱ្យលក្ខខណ្ឌការងារផ្នែកនេសាទសមស្របនឹងស្ដង់ដាររបស់ ILO។ លោកថា៖ «វាបង្ហាញអំពីការប្ដេជ្ញាចិត្តដ៏ពេញលេញរបស់ថៃ ដើម្បីលើកកម្ពស់ស្ដង់ដានៃការការពារសម្រាប់ពលករនេសាទថៃ និងពលករនេសាទជាជនអន្តោប្រវេសន៍ដើម្បីបន្ថយការបង្ខំលើកម្លាំងពលកម្ម»។

អង្គការ ILO បានបង្ហាញថា កាលពីឆ្នាំ ២០១៧ អ្នកបម្រើការក្នុងវិស័យផលិតកម្មគ្រឿងសមុទ្រ និងពលករនេសាទនៅថៃមានជាង ៦ សែននាក់ក្នុងនោះ ៣ សែន ២ ពាន់នាក់គឺជាពលករជនអន្តោប្រវេសន៍ ហើយបើគិតតែជនអន្តោប្រវេសន៍ចុះទូកនេសាទមានសរុប ៥ ម៉ឺន ៧ ពាន់នាក់ ដែលបម្រើការងារលើទូកចំនួន ១០៥៥។

យ៉ាងណាក្តី លោក មុំ សុខចា នាយកអង្គការជំនួយផ្លូវច្បាប់ដល់កុមារ និងស្ត្រីបានថ្លែងកាលពីម្សិលមិញថា ការចុះអនុសញ្ញានេះគ្រាន់តែជាការចាប់ផ្តើមរបស់ថៃប៉ុណ្ណោះ ហើយអ្វីដែលលោកចង់ឃើញនោះគឺថៃត្រូវបង្កើតច្បាប់ និងគោលនយោបាយផ្សេងៗ ដើម្បីអនុវត្តការពារដល់ពលករលើទូកនេសាទ។ លោកថា៖ «ថ្វីដ្បិត EU ផ្តល់កាតលឿងឱ្យថៃក៏ដោយ ប៉ុន្តែយើងនៅតែសង្កេតឃើញថា ពលករនេសាទនៅតែជួបបញ្ហា ដូចជា ការកាត់ប្រាក់ឈ្នួលឬក៏ការមិនបើកប្រាក់ឈ្នួល មានការកេងប្រវ័ញ្ចជាដើម ដែលថៃគួរយកចិត្តទុកដាក់បន្ថែមទៀត»។ លោក មុំ សុខចា បន្តថា កន្លងមកតាមការចុះទៅសម្ភាសផ្ទាល់គឺពលករនេសាទខ្មែរនៅថៃប្រាប់ថា ពួកគេខ្លះត្រូវបានថៅកែប្រើហិង្សាវាយដំរាងកាយដើម្បីបង្ខំឱ្យធ្វើការចាប់ពី ១២ ទៅដល់ ១៤ ម៉ោង និងខ្លះទៀតត្រូវបង្ខំឱ្យប្រើគ្រឿងញៀន ដើម្បីមានកម្លាំងធ្វើការទាំងយប់ ថ្ងៃ ដែលបញ្ហានេះ ច្រើនកើតលើពលករចេញនេសាទឆ្ងាយៗ និងយូរថ្ងៃ។ ថ្វីដ្បិតមិនមានតួលេខបង្ហាញច្បាស់ក្តី ប៉ុន្តែលោក មុំ សុខចា បញ្ជាក់ថា តាមតួលេខមិនផ្លូវការគឺមានពលករនេសាទខ្មែរនៅថៃអាចច្រើនជាងពី ២ ទៅ ៣ ម៉ឺននាក់។

ចំណែកលោក ឌី ថេហូយ៉ា មន្ត្រីកម្មវិធីផ្នែកសិទ្ធិពលករចំណាកស្រុកនៃមជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្សបានលើកឡើងដែរថា តាមការស្រាវជ្រាវគឺពលករនេសាទបរទេសនៅថៃរួមទាំងមកពីកម្ពុជាផងគឺសុទ្ធតែមិនស្របច្បាប់ និងប្រឈមការជួញដូរមនុស្ស។ លោក ថេហូយ៉ា បន្ថែមទៀត ដោយសារគេស្រាវជ្រាវឃើញបញ្ហានេះទើបថៃរងសម្ពាធពីសហភាពអឺរ៉ុប ហើយថ្មីៗនេះថៃក៏បង្កើតការិយាល័យផ្តល់ភាពស្របច្បាប់ដល់ពលករនេសាទ។ លោកថា៖ «ខាង EU គេចេញកាតលឿងដាក់ពិន័យហ្នឹងបានធ្វើឱ្យថៃខាតបង់ប្រហែល ៤០% នៃការនាំគ្រឿងសមុទ្រចេញ អ៊ីចឹងហើយចាប់ផ្តើមឃើញថៃកែប្រែអាច្បាប់បុរាណទៅជាច្បាប់សម័យទំនើបគឺច្បាប់ស្តីអំពីឧស្សាហកម្មនេសាទ ហើយក្នុងហ្នឹងឃើញថា គេ (ថៃ) កំណត់ឱ្យទូកដែលចុះទៅសមុទ្រជ្រៅៗមិនលើសពី ៣០ ថ្ងៃទេ ត្រូវត្រឡប់មកវិញ ហើយក្នុងហ្នឹងគេមានគណៈកម្មការតាមដានមុនទូកចេញទៅ គេតាមដានមានចំនួនមនុស្សប៉ុន្មានពិនិត្យមើលទាំងសុខភាព និងមានទូកចំនួនប៉ុន្មាន»។

បើតាម ILO ថៃនឹងបញ្ចូលអនុសញ្ញានេះទៅក្នុងច្បាប់ជាធរមាននៅថ្ងៃទី ៣០ ខែមករា ឆ្នាំ ២០២០ ក្រោយពីផ្តល់សច្ចាប័ន ១ ឆ្នាំ។ ភ្នំពេញប៉ុស្តិ៍មិនទាន់អាចសុំការបកស្រាយបន្ថែមពីលោក ហេង សួរ អ្នកនាំពាក្យក្រសួងការងារជុំវិញស្ថានភាពពលករនេសាទខ្មែរនៅថៃបាននៅឡើយទេនៅថ្ងៃម្សិលមិញ៕ Contact author: ខន សារី

## ថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៩

## ឃាត់រថយន្ត១គ្រឿងដែលដឹកពលករបម្រុងឆ្លងដែនខុសច្បាប់ទៅប្រទេសថៃ

http://www.rasmeinews.com/ 4, 2019, 8:57 AM55

ដោយ៖គ្រញូង/បាត់ដំបង៖ កម្លាំងនគរបាលប៉ុស្តិ៍ច្រកទ្វារអន្តរជាតិដូង បានធ្វើការឃាត់រថយន្ត ១គ្រឿង កាលពីរសៀលថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០១៩ដែលបានដឹកពលករឆ្លងដែនខុសច្បាប់ចំនួន៧នាក់យកមកអប់រំរួចឱ្យវិលត្រឡប់ទៅផ្ទះវិញ។

លោក ហម សំខាន់ ប្រធានច្រកទ្វារអន្តរជាតិបានឱ្យដឹងថារថយន្តដែលត្រូវបានឃាត់ទុកនោះមានម៉ាក lexus 300 ពណ៌ខ្មៅ ស្លាកលេខ 2AG 3961 ដឹកពលករឆ្លងដែនខុសច្បាប់៧នាក់ មាន ១.ឈ្មោះ ស៊ួរ ហួរ ភេទស្រី អាយុ៤៩ឆ្នាំ, ២.ឈ្មោះ ឈក់ សម័យ ភេទស្រី អាយុ២៤ឆ្នាំ, ។ ៣.ឈ្មោះ ហែម ហ៊ាន់ ភេទស្រី អាយុ២១ឆ្នាំ, ៤.ឈ្មោះ សុខ ហ៊ាង ភេទស្រី អាយុ២៣ឆ្នាំ, ៥.ឈ្មោះ ព្រឹក អ៊ាង ភេទប្រុស អាយុ២១ឆ្នាំ, ៦.ឈ្មោះ ឈក់ មាស ភេទប្រុស អាយុ២៥ឆ្នាំ និង៧.ឈ្មោះ Itsaradamgeng sanit ជនជាតិថៃ អាយុ៤២ឆ្នាំ។កម្លាំងនគរបាលប៉ុស្តិ៍ បានយកពលករទាំង ៧នាក់ មកធ្វើការអប់រំ និងធ្វើកិច្ចសន្យា រួចឲ្យត្រលប់ទៅស្រុកកំណើតវិញ។S/

## អ្នកទោសខ្មែរ២នាក់ក្រុមអាជ្ញាធរថៃដោះលេងជាបន្តបន្ទាប់

https://www.facebook.com/ សារព័ត៌មាន ចក្រភពព័ត៌មាន CPN News **February 2 at 1:55 PM** ·

ឧត្តរមានជ័យ: អ្នកទោសខ្មែរ២នាក់ត្រូវបានក្រុមអាជ្ញាធរថៃធ្វើការដោះលេងឱ្យមានសេរីភាពវិញជាបន្តបន្ទាប់ តែរយៈពេល២ថ្ងៃដាច់ដោយឡែកពីគ្នា នាំខ្លួនប្រគល់ឱ្យក្រុមអាជ្ញាធរកម្ពុជា តាមមាត់ច្រកទ្វារអន្តរជាតិជាំ ស្ថិតនៅក្នុងភូមិជាំ ឃុំត្រពាំងប្រីយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ អ្នកទោសខ្មែរដែលក្រុមអាជ្ញាធរថៃដោះលេង ឈ្មោះ ជា ច្រឹង ភេទប្រុស អាយុ:៣០ឆ្នាំ រស់នៅភូមិផ្អាវ ឃុំផ្អាវ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ថៃចាប់ខ្លួនកាលពីថ្ងៃទី៤ ឧសភា ២០១៥ ជាប់ពន្ធនាគារខេត្តស៊ីសាកេតដោះលេងនៅថ្ងៃទី១ កុម្ភៈ ២០១៩ នឹងម្នាក់ទៀតឈ្មោះ ឃឹម លុន ភេទប្រុស អាយុ២៧ឆ្នាំ រស់នៅភូមិព្រៃពោល ឃុំអណ្ដើក ស្រុករតៈនមណ្ឌល ខេត្តបាត់ដំបង ជាប់គុកនៅខេត្តណាតស្រើន ប្រទេសថៃ ចាប់ខ្លួននៅថ្ងៃទី១៩ កុម្ភៈ ២០១៦ ដោះលេងថ្ងៃទី១ កុម្ភៈ ២០១៩ ទាំង២នាក់ក្រុមអាជ្ញាធរចោទពីបទឆ្លងដែនខុសច្បាប់កាប់ឈើក្រញ៉ូងក្នុងទឹកដីថៃ។ មន្ត្រីដែលបម្រើការងារនៅមាត់ច្រកទ្វារអន្តរជាតិជាំបានឱ្យដឹងថា អ្នកទោសខ្មែរទាំង២នាក់ ត្រូវបានក្រុមអាជ្ញាធរថៃបញ្ជូនខ្លួនជាបន្តបន្ទាប់ក្នុងរយៈពេល ២ថ្ងៃ ក្រោយពីបានទទួលទោសពីក្រុមអាជ្ញាធរថៃសមត្ថកិច្ចបានធ្វើការណែនាំនឹងធ្វើកិច្ចសន្យាឱ្យឈប់ឆ្លងដែនខុសច្បាប់រួចឱ្យវិលត្រឡប់ទៅស្រុកកំណើតជួបជុំក្រុមគ្រួសារនៅក្នុងថ្ងៃដដែល។ ដោយ:សាន់រិទ្ធ

## បុរសអាមេរិកម្នាក់ត្រូវជាប់គុកមួយជីវិតករណីរំលោភក្មេងខ្មែរក្នុងមណ្ឌលដែលខ្លួនគ្រប់គ្រង

https://www.rfa.org/khmer/ 2019-02-03 ដោយ ថន ថារ៉ូ

បុរសជនជាតិអាមេរិក លោក Daniel Stephen Johnson អាយុ៤០ឆ្នាំ ត្រូវបានតុលាការអាមេរិកក្នុងរដ្ឋអរីហ្គ្រេន សហរដ្ឋអាមេរិក កាត់ទោសឱ្យជាប់ពន្ធនាគារអស់មួយជីវិតករណីរំលោភផ្លូវភេទកុមារខ្មែរចំនួន៦ករណី។ កាលពីថ្ងៃទី១៨ ខែមករា កន្លងទៅ បុរសរូបនេះត្រូវបានកាត់ទោសឱ្យជាប់ពន្ធនាគារចំនួន ៣០ឆ្នាំក្នុងករណី រួមភេទខុសច្បាប់នៅបរទេស និងជាប់គុកអស់មួយជីវិតករណីរួមភេទ និងអនីតិជន។ យ៉ាងហោចណាស់មានជនរងគ្រោះចំនួន ១០នាក់ អាយុចាប់ពី៧ដល់១៨ឆ្នាំ ចោទប្រកាន់ លោក Daniel ថាបានបំពានផ្លូវភេទពួកគេ។

តាមឯកសារតុលាការអាមេរិកដែលបានចែកផ្សាយក្នុងអំឡុងពេលសវនាការបានឱ្យដឹងថា បុរសរូបនេះបានរំលោភផ្លូវភេទកុមារកម្ពុជាជាច្រើននាក់ផ្សេងៗគ្នា ក្នុងមជ្ឈមណ្ឌលកុមារកំព្រាដែលគាត់ជាអ្នកគ្រប់គ្រង ដែលអំពើនេះបានប្រព្រឹត្តិទៅក្នុងរវាងអំឡុងខែវិច្ឆិកា ឆ្នាំ២០០៥ និងមុនការចាប់ខ្លួនគាត់ក្នុងឆ្នាំ២០១៣។ ការិយាល័យព្រះរាជអាជ្ញារបស់អាមេរិកបានអោយដឹងថា បុរសអាមេរិករូបនេះ បានទទួលជំនួយថវិកាពីក្រុមវិហារសាសនាគ្រឹះ ក្នុងរដ្ឋ អរីហ្គ្រេន (Oregon) កាលីហ្វូនីញ៉ា (Calforina) តិចសាស (Texsas) និងកន្លែងផ្សេងៗទៀតជាច្រើន ដើម្បីជួយឧបត្ថម្ភដល់មជ្ឈមណ្ឌលកុមារកំព្រារបស់លោកក្នុងក្រុងភ្នំពេញ។ លោក Daniel ក៏ធ្លាប់ជាប់គុកមួយឆ្នាំនៅកម្ពុជា

ដោយបទបៀតបៀនកេរ្តិ៍ខ្មាសកុមារ។ ហើយក្រោយត្រូវបានដោះលែង លោកត្រូវបានអាជ្ញាធរអាមេរិកបញ្ជូនខ្លួនទៅអាមេរិកដើម្បីកាត់ទោសបន្ថែមទៀត៕

## ជប៉ុនខ្វះកម្លាំងពលកម្មកាន់តែខ្លាំងមិនធ្លាប់មានក្នុងរយៈពេល ៤៥ឆ្នាំចុងក្រោយ

https://thmeythmey.com/ 02, Feb 2019 , 12:13 pm ដោយ: អ៊ឹម ម៉េងស៊ាង

មានការងារច្រើន តែបែរជាខ្វះមនុស្សធ្វើ។ នេះជាបញ្ហាដែលរដ្ឋអាស៊ីខាងកើតជប៉ុនកំពុងជួបប្រទះដោយសារគ្មានកម្លាំងពលកម្មគ្រប់គ្រាន់។ ក្រសួងការងារជប៉ុននៅថ្ងៃសុក្រទី ១ ខែកុម្ភៈ បានចាត់ទុកថា វិបត្តិខ្វះខាតកម្លាំងពលកម្មស្ថិតកើនឡើងកាន់តែខ្លាំងមិនធ្លាប់មានចាប់ពីឆ្នាំ ១៩៧៣ មក។

បើតាមទិន្នន័យរបស់ក្រសួងការងារជប៉ុន ភាគរយនៃការកង្វះកម្លាំងពលកម្មនៅជប៉ុនកើនខ្ពស់បំផុតមិនធ្លាប់ជួបក្នុងរយៈពេល ៤៥ឆ្នាំចុងក្រោយ ដោយជាមធ្យមប្រជាជនជប៉ុនត្រឹមតែ ១០០នាក់ប៉ុណ្ណោះដែលស្វែងរកការងារធ្វើស្របពេលដែលការងារមានរហូតទៅដល់ ១៦៣ កន្លែងឯណោះ។ ហើយមូលហេតុដែលបណ្តាលឲ្យខ្វះកម្លាំងពលកម្មនេះគឺមកកត្តាចំនួនពីរ។ មួយគឺអត្រាកំណើតរបស់ប្រជាជនថយចុះ និងមួយទៀត គឺអត្រាប្រជាជនចាស់ជរាកើនឡើងយ៉ាងរហ័ស។ ទន្ទឹមនឹងគ្នានេះដែរ អត្រានិកម្មភាព (ភាពគ្មានការងារធ្វើ) របស់ជប៉ុនក៏ស្ថិតនៅកម្រិតទាបដដែល គិតត្រឹមខែធ្នូ ដែលមានត្រឹមតែ ២,៤ ភាគរយប៉ុណ្ណោះ។ នេះបើយោងតាមការចុះផ្សាយរបស់ទីភ្នាក់ងារព័ត៌មាន AFP ដោយដកស្រង់ទិន្នន័យជាច់ដោយឡែកមួយពីក្រសួងមហាផ្ទៃជប៉ុន។

ដោយមើលឃើញពីគម្លាតចំនួនការងារនៅទំនេរ និងអ្នករកការងារធ្វើកាន់តែធំ រដ្ឋាភិបាលជប៉ុនដែលធ្លាប់តែមានប្រពៃណីរឹតត្បិតលើគោលនយោបាយអន្តោប្រវេសន៍ បែរជាយល់ព្រមអនុម័តច្បាប់ថ្មីមួយដែលនឹងបើកទ្វារខ្លួនកាន់តែធំទូលាយដើម្បីទទួលយកពលករបរទេស។ ហើយចំពោះប្រព័ន្ធទទួលពលករបរទេសថ្មីនេះ គេមើលឃើញថាវាជាការផ្លាស់ប្តូរដ៏ធំមួយរបស់ក្រុងតូក្យូទាក់ទងនឹងគោលនយោបាយអន្តោប្រវេសន៍របស់ជប៉ុន។

គួរបញ្ជាក់ដែរថា ច្បាប់ថ្មីដែលត្រូវបានបង្កើតឡើងក្រោមអាណត្តិលោក ស៊ីនហ្សូ អាបេ នាយករដ្ឋមន្ត្រីបច្ចុប្បន្ននឹងជ្រើសរើសពលករមានជំនាញពីបរទេស ៣៤៥០០០នាក់ក្នុងរយៈពេលប្រាំឆ្នាំ ហើយ ច្បាប់នេះនឹងចូលជាធរមានចាប់ពីខែ មេសាឆ្នាំ ២០១៩ ខាងមុខនេះ។ ច្បាប់នេះក៏នឹងផ្តល់ទិដ្ឋាការប្រភេទថ្មីចំនួនពីរសម្រាប់ពលករបរទេស។ ទីមួយគឺមានសុពលភាព៥ឆ្នាំសម្រាប់ពលករបរទេស ដែលអាចនិយាយភាសាជប៉ុនបានល្អ និងស្ថិតក្នុងវិស័យកំពុងខ្វះខាតខាងលើ។

ហើយទីពីរវិញនោះគឺសម្រាប់ពលករមានជំនាញខ្ពស់ ដែលពួកគេក៏ត្រូវបានអនុញ្ញាតឲ្យនាំគ្រួសារទៅរស់នៅជាមួយថែមទៀតផង។ ជាពិសេស សម្រាប់ទិដ្ឋាការប្រភេទទីពីរនេះ រដ្ឋាភិបាលពុំបានកំណត់ចំនួនការផ្តល់ចំនួនទិដ្ឋាការជាថ្មីឡើយ។ នេះមានន័យថា ពួកគេអាចមានសិទ្ធិរស់នៅក្នុងប្រទេសជប៉ុនជារៀងរហូតថែមទៀតផង៕

# ថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៩

## សកម្មជនស្នើអ្នកនេសាទខ្មែរនៅទូកសមុទ្រថៃបន្តប្រយ័ត្នប្រយែង

https://khmer.voanews.com/ 05 កុម្ភៈ 2019 ម៉ែន គឹមសេង

សហភាពអឺរ៉ុបបានដដែកគ្នាជាមួយនឹងអាជ្ញាធរថៃ ពីការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរនិងពលកម្មដោយបង្ខំនៅក្នុងវិស័យឧស្សាហកម្មនេសាទថៃ ហើយប្រទេសថៃបានយល់ព្រមផ្តល់សច្ចាប័នលើកតិការសញ្ញារបស់អង្គការពលកម្មអន្តរជាតិដើម្បីការពារសិទ្ធិរបស់កម្មករ។

វ៉ាស៊ីនតោន៖ សកម្មជនសិទ្ធិមនុស្សស្នើឱ្យពលករកម្ពុជាបន្តប្រយ័ត្នប្រយែង ពេលធ្វើការងារនៅក្នុងវិស័យនេសាទនិងគ្រឿងសមុទ្រថៃ បើទោះបីជាសហភាពអឺរ៉ុបបានលើកលែងការព្រមានដាក់ទណ្ឌកម្មក៏ដោយ។ សហភាពអឺរ៉ុបបានលុបចោលការព្រមានកាតលឿងនេះកាលពីដើមខែមករា បន្ទាប់ពីដាក់លើប្រទេសថៃតាំងពីខែមេសា ឆ្នាំ២០១៥ ដោយ សារតែការនេសាទខុសច្បាប់ មិនបានចុះបញ្ជីនិងគ្មានច្បាប់កំណត់។ ការណ៍នេះមានន័យថា ប្រទេសថៃត្រូវធ្វើការកែលម្អចំណុចខ្វះខាត បើមិនដូច្នេះទេនឹងត្រូវហាមឃាត់មិនឱ្យនាំផលិតផលចូលទីផ្សាររបស់សហភាពអឺរ៉ុបទេ ហើយទទួលទណ្ឌកម្មផ្សេងមួយចំនួនទៀត។

លោកឌី ថេហូយ៉ា ប្រធានកម្មវិធីនៃមជ្ឈមណ្ឌលសម្ព័ន្ធការងារនិងសិទ្ធិមនុស្ស ហៅថាសង់ត្រាល់ បានបញ្ជាក់ថា អាជ្ញាធរថៃបានប្រើប្រាស់នយោបាយការទូតទន់ភ្លន់និងយល់ព្រមធ្វើកំណែទម្រង់នានា តាមការស្នើសុំរបស់សហភាពអឺរ៉ុប ប៉ុន្តែលោកបានដាស់តឿនពលករកម្ពុជាឱ្យបន្តការប្រុងប្រយ័ត្ន៖ «បញ្ហាទាំងអស់នេះយើងមិនអាចអះអាងថា ពួកគាត់មានសុវត្ថិភាព១០០ភាគរយទេព្រោះគោលនយោបាយនៅតែជាគោលនយោបាយ ព្រោះឥឡូវប្រសិទ្ធភាពវាឃើញខ្លះហើយ។ អ្វីដែលសហភាពអឺរ៉ុបបានដកទណ្ឌកម្មឬដកកាតលឿងចេញនេះក៏ដោយសារមានការត្រួតពិនិត្យសារដើមច្រើនដង»។ ការលុបចោលនេះដោយសារតែប្រទេសថៃបានធ្វើការកែទម្រង់ក្របខណ្ឌច្បាប់នេសាទឱ្យស្របតាមច្បាប់អន្តរជាតិក្នុងការប្រើប្រាស់ឧបករណ៍នេសាទ ពង្រឹងការគោរពតាមកាតព្វកិច្ចរបស់ខ្លួនជារដ្ឋដែលមានទង់ជាតិ ផែ ដែនសមុទ្រ និងទីផ្សារ។ ក្នុងនោះមានការកំណត់ក្នុងច្បាប់និងបង្កើតការដាក់ទណ្ឌកម្មអ្នកល្មើស ពង្រឹងយន្តការត្រួតពិនិត្យក្រុមនេសាទជាតិ និងពង្រឹងប្រព័ន្ធតាមដាន ត្រួតពិនិត្យនិងគ្រប់គ្រង។ ទាំងនេះបូករួម ការតាមឃ្លាំមើលពីចម្ងាយនូវសកម្មភាពនេសាទ និងការធ្វើអធិការកិច្ចនៅកំពង់ផែ ដូចជាត្រួតពិនិត្យចំនួនអ្នកចេញនិងចូល (PIPO)។

លោកឌី ថេហូយ៉ា បានបន្ថែមថាក្នុងពេលកន្លងមកថៅកែទូកនេសាទមិនបានកំណត់អត្តសញ្ញាណអ្នកនេសាទឱ្យបានច្បាស់លាស់ទេ ហើយការចេញទៅសមុទ្រក៏មិនកំណត់ពេលវិលត្រឡប់មកវិញជាក់លាក់ដែរ ដោយអ្នកនេសាទខ្លះត្រូវនៅលើផ្ទៃសមុទ្រជាច្រើនខែ។ ប៉ុន្តែទណ្ឌកម្មរបស់សហភាពអឺរ៉ុបបានធ្វើឱ្យមានការកែប្រែទម្លាប់នេះ។ លោកហូយ៉ា បានបន្ថែមថា៖ «ឥឡូវនេះយើងឃើញថាមានការចុះបញ្ជីបានភាគច្រើនសឹងថាបាន៩៩ភាគរយហើយខាងផ្នែកនេសាទ។ អីចឹងគាត់ចុះបញ្ជីនៅថៃច្រើន អត្តសញ្ញាណច្បាស់លាស់មកពីប្រទេសណាទៅប្រទេសណាហើយមុននឹងចេញទូកមានមនុស្សប៉ុន្មាននាក់នៅក្នុងទូកហ្នឹង គឺគណៈកម្មការពីប៉ូ (PIPO) ពិនិត្យហើយកំណត់ទៅតែ៣០ថ្ងៃត្រឡប់មកកន្លែងចំណតវិញ។ អីចឹងយើងឃើញថា មានយន្តការដាក់លាក់ច្រើនកន្លងមក ក៏ប៉ុន្តែបន្ទាប់ពីហ្នឹងទៅអនុវត្តឬមិនអនុវត្ត ក៏ប៉ុន្តែក្នុងអំឡុងពេលនេះថៃកំពុងតែធ្វើបានល្អ»។

ទំហំនៃការនាំចេញផលិតផលនេសាទសមុទ្រថៃមានចំនួន៨ពាន់លានដុល្លារក្នុងឆ្នាំ២០១៧ ក្នុងនោះការនាំចូលទីផ្សារសហភាពអឺរ៉ុបមានជាង៧០០លានដុល្លារក្នុងមួយឆ្នាំៗ។ ស្នងការទទួលបន្ទុកជលផលរបស់សហភាពអឺរ៉ុប គឺលោក Karmenu Vella បានថ្លែងថា សហភាពអឺរ៉ុបបានជជែកគ្នាជាមួយនឹងអាជ្ញាធរថៃពីការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ និងពលកម្មដោយបង្ខំនៅក្នុងវិស័យឧស្សាហកម្មនេសាទថៃ ហើយប្រទេសថៃបានយល់ព្រមផ្តល់សច្ចាប័នលើកតិកាសញ្ញារបស់អង្គការពលកម្មអន្តរជាតិដើម្បីការពារសិទ្ធិរបស់កម្មករ។

មានពលរដ្ឋខ្មែរជាង១លាននាក់ត្រូវបានគេរាយការណ៍ថា បានធ្វើចំណាកស្រុកទៅប្រទេសថៃដោយធ្វើការនៅរោងចក្រ ចម្ការ និងក្នុងឧស្សាហកម្មនេសាទថៃ។ ពួកគេមួយចំនួនបានចាញ់បោកក្រុមហ៊ុនជ្រើសរើសពលករ ហើយបានក្លាយជាទាសករសម័យទំនើប ដោយធ្វើការហួសកម្លាំងច្រើនម៉ោង មិនទទួលបានប្រាក់ខែសមរម្យ ស្ថានភាពរស់នៅលំបាកនិងធ្លាក់ខ្លួនជំពាក់បំណុល។ អង្គការឃ្លាំមើលសិទ្ធិមនុស្ស (Human Rights Watch) បានបញ្ជាក់ថា នៅតែមានករណីបង្ខំឱ្យធ្វើការហួសកម្លាំង ការជួញដូរមនុស្ស មិនបើកប្រាក់ខែ និងគ្រោះថ្នាក់លើទូកនេសាទដោយមិនទទួលប្រាក់សំណង។ ករណីទាំងនេះកើតមានលើពលរដ្ឋកម្ពុជានិងភូមាដែលធ្វើការលើទូកនេសាទទាំងនោះ។

លោកហ្វីល រ៉ូប៊ឺតសុន អនុប្រធានប្រចាំតំបន់អាស៊ីនៃអង្គការឃ្លាំមើលសិទ្ធិមនុស្សបញ្ជាក់ថា លោកនៅតែមានការព្រួយបារម្ភ បើទោះបីជាមានការកែទម្រង់របស់អាជ្ញាធរថៃ។ លោកស្នើឱ្យសហភាពអឺរ៉ុបនិងសហរដ្ឋអាមេរិកដែលទទួលទិញផលិតផលគ្រឿងសមុទ្រថៃបន្តតាមដាន និងគាបសង្កត់ដើម្បីធានាសិទ្ធិដល់អ្នកនេសាទទាំងនោះ។ លោកហ្វីល រ៉ូប៊ឺតសុន បានបន្ថែមថា៖ «ប្រទេសថៃមិនបានធ្វើការងារបានល្អនៅឡើយទេក្នុងការធានាឱ្យប្រាកដថា អ្នកគ្រប់គ្រងទូកនេសាទ និងថៅកែទូកសងសំណងសមរម្យដល់កម្មករពេលដែលមានរបួសឬគ្រោះថ្នាក់ពីការធ្វើពលកម្មដោយបង្ខំទាំងនេះ។ នេះគឺជាឧស្សាហកម្មដែលព្យាយាមទទួលយកផលអតិបរិមាពីកម្មករ ប៉ុន្តែបើកប្រាក់ឬផ្តល់សំណងតិចតួចឱ្យពួកគេ»។ លោកបន្ថែមថា មន្ត្រីដែលនៅត្រួតពិនិត្យមើលនៅផែចេញចូលក៏មិនសាកសួរកម្មករជើរទូកឱ្យបានលម្អិតពីស្ថានភាពការងាររបស់ពួកគេពេលនៅសមុទ្រដែរ គឺគ្រាន់តែពិនិត្យចំនួនអ្នកចេញចូលដើម្បីធានាថាមិនមានអ្នកបាត់ខ្លួនតែប៉ុណ្ណោះ។

លោកស្រីមូរ សុខហួរ អនុប្រធានគណបក្សសង្គ្រោះជាតិសម្តែងក្តីបារម្ភថា ពលករខ្មែរអាចនឹងនៅតែរងគ្រោះ៖ «ទោះបីជាកាតពណ៌លឿងត្រូវគេដកចេញក៏ដោយ ក៏ប៉ុន្តែស្ថានការណ៍នៅតែតឹងនៅឡើយទេ។ ជាពិសេសអីចឹងហើយបានជាខ្ញុំមានការព្រួយបារម្ភណាស់។ ខ្ញុំមិនជឿថាបងប្អូនខ្មែរយើងធ្វើការនៅនេសាទថៃបានរួចខ្លួនទាំងអស់ទេ ពីព្រោះបងប្អូនខ្មែរយើងនៅកណ្តាលសមុទ្រថៃនៅច្រើនរាប់ពាន់នាក់ដែរ»។ សកម្មជនផ្តល់យោបល់ថា បើមានបញ្ហាពលរដ្ឋខ្មែរត្រូវតែទៅរកស្ថានទូតខ្មែរ អង្គការ និងយន្តការរបស់រដ្ឋាភិបាលថៃដើម្បីជួយពួកគេ។ លោកស្រីមូរ សុខហួ បានបន្ថែមថា៖ «ទោះបីជាប្រទេសថៃបានធ្វើការងារល្អក៏ដោយ ក៏ប៉ុន្តែនៅមិនទាន់គ្រប់ជ្រុងជ្រោយទេនៅមានការងារមួយចំនួនទៀតដូចជាការបាត់ខ្លួន ការចាញ់បោក និងការបោកប្រាស់ ពលករចំណាកស្រុកនៅឡើយទេ»។

អង្គការសហប្រជាជាតិបានស្នើឱ្យរដ្ឋាភិបាលកម្ពុជា «បង្កើនយន្តការការពារសម្រាប់ពលរដ្ឋកម្ពុជាដែលធ្វើចំណាកស្រុកនៅក្រៅប្រទេសដោយតាមដានទីភ្នាក់ងារជ្រើសរើសពលករនិងយកពួកគេទៅធ្វើការនៅបរទេស»។ នេះបើយោងតាមរបាយការណ៍របស់ក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ ដែលបានចេញផ្សាយនៅក្នុងសម័យប្រជុំលើកទី៣២ កាលពីថ្ងៃទី២១មករាដល់ទី១ខែកុម្ភៈ។

រដ្ឋាភិបាលកម្ពុជាបានឆ្លើយតបវិញដោយបញ្ជាក់ថា ខ្លួនយកចិត្តទុកដាក់លើបញ្ហានេះដោយចុះលើអនុស្សារណៈមួយចំនួនជាមួយនឹងប្រទេសដែលទទួលយកពលករកម្ពុជា ក្នុងនោះមានប្រទេសថៃផងដែរដែលកម្ពុជាបានចុះអនុស្សារណៈតាំងពីចុងឆ្នាំ២០១៦។ របាយការណ៍របស់រាជរដ្ឋាភិបាលកម្ពុជាដែលដាក់ជូនក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិបានបន្ថែមថា៖ «រាជរដ្ឋាភិបាលកម្ពុជាយកចិត្តទុកដាក់យ៉ាងខ្លាំងចំពោះការរកឃើញនេះនិងផ្តល់ការងារធ្វើដល់ពលរដ្ឋទាំងនៅក្នុងនិងក្រៅប្រទេស ដោយបានចេញគោលនយោបាយស្តីពីការងារចំណាកស្រុកដែលផ្តោតលើការការពារសិទ្ធិនិងផលប្រយោជន៍របស់ពលរដ្ឋដែលធ្វើការនៅក្រៅប្រទេស»៕

## ការរំលោភសិទ្ធិមនុស្សលើពលករចំណាកស្រុកនៅតែបន្តកើតមានក្នុងប្រទេសថៃ

https://www.rfa.org/khmer/news/ 2019-02-01 ដោយ ម៉ៅ សុជានី

របាយការណ៍ស្រាវជ្រាវរបស់អង្គការអន្តរជាតិផ្នែកទេសន្តរប្រវេសក៍ (International Organization for Migration-IOM) បានបង្ហាញថា ពលរដ្ឋចំណាកស្រុករាប់លាននាក់ ដែលកំពុងធ្វើការក្នុងប្រទេសថៃ នៅតែបន្តរងគ្រោះ ដោយសារការរំលោភបំពានសិទ្ធិមនុស្ស និងការកេងប្រវ័ញ្ចពលកម្ម ជាដដែល។ ការលើកឡើងនេះ ក្រោយអាជ្ញាធរថៃ ធ្វើឱ្យប្រសើរឡើងនូវលក្ខខណ្ឌការងារខ្លះៗ នៃអំពើទាសភាពលើទូកនេសាទ ដើម្បីដកបម្រាមការនាំចេញផលិតផលគ្រឿងសមុទ្ទ ដែលមានតម្លៃរាប់ពាន់លានដុល្លារក្នុងមួយឆ្នាំៗ ទៅលក់នៅសហគមន៍អឺរ៉ុបឡើងវិញ។ របាយការណ៍ស្រាវជ្រាវរបស់អង្គការ IOM រកឃើញថា ជនចំណាកស្រុកប្រមាណ ៥លាននាក់ ធ្វើការនៅប្រទេសថៃ ក្នុងនោះមានពលរដ្ឋខ្មែរ ដែលធ្វើការផ្នែកវិស័យសំណង់ កសិកម្ម និងរោងចក្រ នៅតែបន្តរងគ្រោះពីការកេងប្រវ័ញ្ចពលកម្ម និងរំលោភសិទ្ធិមនុស្សដដែល។ ការរំលោភបំពានទាំងនោះ រួមមាន ថៅកែរោងចក្រខ្លះ នៅតែមិនព្រមផ្តល់អោយប្រាក់ខែអប្បបរមា ឬប្រាក់ខែទាបបំផុត បង្ខំឱ្យធ្វើការលើសម៉ោងមិនបានប្រាក់កម្រៃបន្ថែម បញ្ហាសុវត្ថិភាពនៅកន្លែងធ្វើការ និងស្ថានភាពរស់នៅដ៏លំបាក របស់ពលករជាដើម។

ប្រធានអង្គការសម្ព័ន្ធ ការងារនិងសិទ្ធិមនុស្ស (ហៅកាត់ថា សង់ត្រាល់) លោក មឿន តុលា មានប្រសាសន៍ប្រាប់អាស៊ីសេរី តាមទូរស័ព្ទថា ស្ថានភាពកម្មករចំណាកស្រុកទាំងនោះមិនថាតែពលករខ្មែរទេ គឺនៅតែជួបបញ្ហាលំបាកខ្លាំងនៅកន្លែងធ្វើការ និងការបង្ខំឱ្យធ្វើការលើសម៉ោង ជាដើម។ ប៉ុន្តែលោកទទួលស្គាល់ថា មានថៅកែរោងចក្រមួយចំនួន ក៏បានប្រឹងប្រែងកែលម្អលក្ខខណ្ឌការងារបានខ្លះៗដែរ៖ «និយាយរួម អ្វីដែលរកឃើញរបស់អង្គការ IOM គឺវាពិតជាត្រឹមត្រូវមែន។ បញ្ហាពលករចំណាកស្រុកទាំងខ្មែរ ឡាវក៏ដោយនៅប្រទេសថៃ គឺអត់ទាន់បានល្អប្រសើរទាំងស្រុងទេ មានរោងចក្រមួយចំនួន បានអនុវត្តស្តង់ដារការងារបានល្អ ដែលយើងដឹង។ ក៏ប៉ុន្តែ រោងចក្រមួយចំនួននៅមានបញ្ហានៅឡើយ គឺធ្វើការលើសម៉ោង ទាំងបង្ខំ និងអត់បើកប្រាក់ឈ្នួលអោយ»។

របាយការណ៍ IOM បន្តថា អាជ្ញាធរថៃផ្តោតការយកចិត្តទុកដាក់និងកែលម្អ ទៅលើតែបញ្ហាទាសភាពរបស់ពលករធ្វើការនៅលើទូកនេសាទទេ ដើម្បីទទួលបានការលើកបម្រាមនាំចេញផលិតផលគ្រឿងសមុទ្រ ក៏ប៉ុន្តែអាជ្ញាធរថៃ មិនបានយកចិត្តទុកដាក់ ដោះស្រាយស្ថានភាពលំបាកជាច្រើន របស់ជនចំណាកស្រុករាប់លាននាក់ ដែលកំពុងធ្វើការផ្នែកវិស័យផ្សេងៗនោះឡើយ។ របាយការណ៍សង្កត់ធ្ងន់ថា ជនរងគ្រោះដែលរងការរំលោភបំពានទាំងនោះច្រើនជាកម្មករសំណង់ កម្មករផ្នែកកសិកម្ម នៅកន្លែងចិញ្ចឹមសត្វ និងនៅតាមរោងចក្រកាត់ដេរសំលៀកបំពាក់។

គណៈកម្មការសហភាពអឺរ៉ុបកាលពីដើមខែមករា ឆ្នាំ២០១៩ កន្លងមកនេះបានអនុញ្ញាតឱ្យក្រុមហ៊ុនថៃ នាំចេញផលិតផលគ្រឿងសមុទ្រដែលមានតម្លៃរាប់ពាន់លានដុល្លារអាមេរិកក្នុងមួយឆ្នាំៗ ទៅលក់នៅទីផ្សារសហភាពអឺរ៉ុបឡើងវិញ។ ការសម្រេចនេះធ្វើឡើង ក្រោយដែលគណៈកម្មការនេះ បានទទួលស្គាល់នូវកិច្ចប្រឹងប្រែងរបស់អាជ្ញាធរថៃក្នុងការទប់ស្កាត់ការជួញដូរមនុស្ស និងលក្ខខណ្ឌការងារប្រសើរឡើង របស់ពលករលើកទូកនេសាទ ក្រោយពីមានរបាយការណ៍ជាច្រើន លើកឡើងអំពីការជួញដូរកម្លាំងពលកម្ម និងអំពើទាសភាពលើទូកនេសាទ នៅក្នុងប្រទេសថៃ។

អង្គការអន្តរជាតិមួយចំនួន រួមមាន អង្គការលើកលែងទោសអន្តរជាតិ (Amnesty International) និងអង្គការសហព័ន្ធកម្មករវិស័យដឹកជញ្ជូនអន្តរជាតិ (Fisheries at the International Transport Workers' Federation) រិះគន់ជាខ្លាំងថា សហភាពអឺរ៉ុប មិនបានត្រួតពិនិត្យច្បាស់លាស់ ពីស្ថានភាពពិតប្រាកដ របស់ពលករធ្វើការនៅលើទូកនេសាទនោះទេ ដោយគ្រាន់តែពិនិត្យលើរបាយការណ៍របស់អាជ្ញាធរថៃប៉ុណ្ណោះ។

ប្រធានជលផលនៃសហព័ន្ធកម្មករវិស័យដឹកជញ្ជូនអន្តរជាតិ លោក ហ្សូននី ហានសេន (Johnny Hansen) បានប្រាប់កាសែត ដឹហ្គាឌៀន អង់គ្លេស (The Guardian) កាលពីថ្ងៃទី២៤ ខែមករា ថា លោកមិនដឹងថា តើសហភាពអឺរ៉ុប ទទួលបានទិន្នន័យបែបណាពីអាជ្ញាធរថៃ ទើបបានជាលើកលែងការហាមនាំចូលទំនិញផលិតផលគ្រឿងសមុទ្រ ដែលបានអនុវត្តចាប់ពីខែមេសា ឆ្នាំ២០១៥ កន្លងមកនោះ។ លោក Hansen អះអាងថា សេចក្តីរាយការណ៍ជាច្រើនដែលបានជួបសម្ភាសន៍ផ្ទាល់ជាមួយពលករលើទូកនេសាទ ឱ្យដឹងថា ពួកគេភាគច្រើន រងការកេងប្រវ័ញ្ចពលកម្ម រំលោភសិទ្ធិមនុស្ស និងជំពាក់ប្រាក់បំណុលថៅកែយ៉ាងច្រើន ជាដដែល។

ចំណែកអង្គការលើកលែងទោសអន្តរជាតិ (Amnesty International) វិញ ក៏បានចេញផ្សាយរបាយការណ៍ស្រាវជ្រាវមួយកាលពីពេលថ្មីៗនេះដែរ បង្ហាញថា ពលករនេសាទ ជិត ៤០% ដែលបានជួបសម្ភាសន៍កាលពីអំឡុងឆ្នាំ២០១៨ អះអាងថា ពួកគេគឺជាជនរងគ្រោះនៃការជួញដូរមនុស្ស ហើយថាការត្រួតពិនិត្យផ្នែកពលកម្មនេសាទ នៅកំពង់ផែ គឺធ្វើឡើងគ្រាន់តែសំពែងឱ្យឃើញតាមការចង់បានរបស់សហភាពអឺរ៉ុបប៉ុណ្ណោះ។ របាយការណ៍ដដែល ក៏បង្ហាញនូវការងឿងឆ្ងល់ថា តើហេតុដូចម្តេច បានជាអាជ្ញាធរថៃ មិនបានរកឃើញករណីជួញដូរ ឬកេងប្រវ័ញ្ចពលកម្មណាមួយ របស់ពលករទូកនេសាទ នៅពេលដែលអាជ្ញាធរថៃ ត្រួតពិនិត្យស្ថានភាពការងាររបស់ពួកគេ សរុបជិត ៥០ម៉ឺននាក់។

លោក មឿន តុលា ដែលបានតាមដានក្នុងរឿងនេះដែរ ក៏បានបញ្ជាក់ប្រាប់អាស៊ីសេរីថា ហេតុផលដែលសហភាពអឺរ៉ុប សម្រេចលើកបម្រាមការនាំចេញផលិតផលគ្រឿងសមុទ្រពីប្រទេសថៃ នោះ គឺដោយសារថៃ បានប្រឹងប្រែងកែលម្អចំណុច ៣សំខាន់ៗ ដែលជំរុញឱ្យសហភាពអឺរ៉ុប គិតថា ស្ថានការណ៍ទេសភាពនៅលើទូកនេសាទ បានប្រសើរជាងមុន៖ «រដ្ឋាភិបាលថៃប្រឹងធ្វើកិច្ចការមួយចំនួនដើម្បីកែលម្អ។ ទី១ តម្រូវឱ្យក្រុមហ៊ុនទូកនេសាទ ចុះសមុទ្រយ៉ាងយូរ២អាទិត្យមិនមែនរាប់ឆ្នាំដូចមុនទេ។ ទី២ ចុះធ្វើអធិការកិច្ចទៅលើទូកនេសាទ។ ទី៣ ថ្មីៗនេះ រដ្ឋាភិបាលថៃ ក៏បានផ្តល់បត្យាប័នអនុសញ្ញា ILO ក្នុងកិច្ចការពារសិទ្ធិទៅដល់ពលករលើទូក។ បញ្ហានេះហើយ ជាហេតុនាំឱ្យសហគមន៍អឺរ៉ុបដកបម្រាមនេះ ឬដកកាតលឿងនោះចេញ»។ ក៏ប៉ុន្តែលោក មឿន តុលា អះអាងថា ការអនុវត្តន៍ជាក់ស្តែងវិញ គឺពលករនេសាទ នៅតែរងការកេងប្រវ័ញ្ចពលកម្ម នៅឡើយ ដោយសារពួកគេភាគច្រើនមិនចេះអក្សរ អាយុក្រោម ១៨ឆ្នាំ ហើយលិខិតឆ្លងដែន ឬលិខិតផ្លូវច្បាប់មួយចំនួន គឺម្ចាស់ទូកជាអ្នកទុកអោយ។ លោកបន្តថា នៅពេលក្រុមអធិការកិច្ចថៃចុះពិនិត្យលើទូកម្តងៗ ទើបប្រគល់ឱ្យពលករវិញ៖ «រឿងលក្ខខណ្ឌការងារ គឺគាត់ធ្វើការច្រើនម៉ោង ហើយមិន

ដាក់លាក់ ព្រោះធម្មតានៅលើទូក ពេលបោះអួន ឬមង ចូលក្នុងសមុទ្រអ៊ីចឹង ពេលត្រូវលើកពេលណាគេត្រូវដាស់ឱ្យគាត់ធ្វើការទាំងយប់។ អ៊ីចឹងនៅមានការរំលោភបំពានច្រើនណាស់ គ្រាន់តែសម្លឹងមើលអ្វីដែលរដ្ឋាភិបាលថៃធ្វើកន្លងមកគឺចំណុចទី៣ ប៉ុន្តែឱ្យថាមានលក្ខខណ្ឌការងារប្រសើរឡើង គឺអត់ទេ»។

ស្ថិតិផ្លូវការរបស់ក្រសួងការងារបង្ហាញថា ពលករខ្មែរស្របច្បាប់ដែលកំពុងធ្វើការនៅប្រទេសថៃ មានចំនួន ១លាន ២សែននាក់ ប៉ុន្តែប្រធានអង្គការសម្ព័ន្ធ ការងារនិងសិទ្ធិមនុស្ស លោក មឿន តុលា បញ្ជាក់ថា តាមការប៉ាន់ប្រមាណរបស់អង្គការលោក មានពលករខ្មែរចំណាកស្រុក ជិត ២លាននាក់ ក្នុងនោះ ៨០% ជាពលករស្របច្បាប់៕

# ថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០១៩

## នៅបន្ទាយកងល្បាតទី២ ច្រកអន្តរជាតិដាំមានការណាត់ជួបប្រជុំថ្នាក់កងអនុសេនាធំជួរមុខរវាងកងកម្លាំងកម្ពុជា និងកងកម្លាំងថៃ

https://www.facebook.comhttps:// 06-02-2019 សារព័ត៌មាន ចក្រភពព័ត៌មាន CPN News

ឧត្តរមានជ័យ៖ ថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៩នៅវេលាម៉ោង០៩និង៤០នាទី នៅបន្ទាយកងល្បាតទី២ ទល់មុខច្រកអន្តរជាតិដាំមានការណាត់ជួបប្រជុំថ្នាក់កងអនុសេនាធំជួរមុខរវាងកងកម្លាំងកម្ពុជានិងកងកម្លាំងថៃ។ សមាសភាពចូលរួមមានៈ ខាងកម្ពុជា កម្លាំងនគរបាលការពារព្រំដែនប៉ុស្តិ៍ដាំចំនួន០៥នាក់ដឹកនាំដោយលោកអនុសេនីយ៍ឯក ហេង ចាន់រ៉ាវី នាយរងប៉ុស្តិ៍ដាំ នឹងលោកអនុសេនីយ៍ត្រី អាង រ៉ានី នាយរងប៉ុស្តិ៍ភ្នំត្បាល់។ ទំនាក់ទំនងព្រំដែនកម្ពុជាថៃប្រចាំច្រកអន្តរជាតិដាំ ១ នាក់។ កម្លាំងកងរាជអាវុធហត្ថចំនួន ១ នាក់។ មេបញ្ជាការកងល្បាតទី,២,៣,៤,និងទី៥ ដឹកនាំរួមដោយលោកវរសេនីយ៍ទោ ឃី យូរ៉ា មេបញ្ជាការវរៈ៤០៣ យោធភូមិភាគទី៤។ ខាងភាគីថៃទាហានឈុតខ្មៅចំនួន០៩នាក់ ប៉ារ៉ា០៧នាក់ ទំនាក់ទំនងថៃកម្ពុជាចំនួន២នាក់ ដឹកនាំដោយ លោកអនុសេនីយ៍ឯក គៀរចាន់សុវណ្ណ ជំនួយការកងអនុសេនាធំទិសទី៣ប៉ារ៉ា។ ខ្លឹមសារ : បង្កើនកិច្ចសហប្រតិបត្តិការឱ្យកាន់តែស្និទ្ធស្នាលថែមទៀតរវាងកងកម្លាំងអង្គភាពដែលនៅទល់មុខគ្នា។ ខាងកម្ពុជាសំណូមពរ ខាងថៃបើឃើញប្រជាជនឆ្លងដែនខុសច្បាប់សូមកុំបាញ់ឲ្យចាប់បញ្ជូនមកវិញ ខាងថៃឯកភាព។ ខាងកម្ពុជាស្នើរខាងថៃពេលដើរល្បាតត្រូវផ្តល់ដំណឹងខាងកម្ពុជាជាមុន ខាងថៃឯកភាព។ ខាងថៃស្នើរខាងកម្ពុជាឲ្យជួយទប់ស្កាត់នូវភ្លើងឆេះព្រៃទាំងអស់គ្នា ខាងកម្ពុជាឯកភាព។ ពេលមានអ្នកជំងឺចូលទៅពេទ្យថៃនៅម៉ោង ៨ យប់ត្រូវចាំឡានពេទ្យថៃមកទទួលទើបចូលបាន៕ ដោយៈសាន់រិទ្ធ

## ទិវាសុវត្ថិភាពអ៊ីនធឺណិតៈ យូនីសេហ្វអំពាវនាវឱ្យមានសកម្មភាពរួមគ្នាទប់ស្កាត់ការរករឿងឈ្លោះ និងបៀតបៀនលើយុវជនកម្ពុជាដែលកំពុងប្រើប្រាស់អ៊ីនធឺណិត

http://www.rasmeinews.com/ February 5, 2019, 3:43 PM

ដោយៈបញ្ញាសាស្ត្រ/ភ្នំពេញៈអង្គការយូនីសេហ្វបានប្រកាសនៅថ្ងៃទី៥ខែកុម្ភៈនេះថា៣០ឆ្នាំ ក្រោយពីការអនុម័តលើអនុសញ្ញាស្តីពីសិទ្ធិកុមារ និងការបង្កើតប្រព័ន្ធអ៊ីនធឺណិតគឺដល់ពេលវេលាក្នុងការពិនិត្យមើលឡើងវិញនូវការយកចិត្តទុកដាក់អំពីសិទ្ធិប្រើប្រាស់ប្រព័ន្ធឌីជីថលរបស់កុមារ។ អង្គការនេះបានបញ្ជាក់ថា នៅថ្ងៃនេះយូនីសេហ្វបានប្រកាសឲ្យដឹងជាមុនអំពីគ្រោះថ្នាក់ដែលបង្កឡើងដោយអំពើហិង្សា ការរករឿងឈ្លោះ និងការបៀតបៀនតាមប្រព័ន្ធអ៊ីនធឺណិត ចំពោះយុវជន ៨៥,៧ ភាគរយ ដែលមានអាយុចាប់ពី១៥ទៅ២៥ឆ្នាំដែលកំពុងប្រើប្រាស់អ៊ីនធឺណិតនៅកម្ពុជានិងបានអំពាវនាវឱ្យមានសកម្មភាពរួមគ្នា ដើម្បីឆ្លើយតប និងទប់ស្កាត់អំពើហិង្សាលើកុមារ និងយុវជននៅតាមប្រព័ន្ធអ៊ីនធឺណេត។

សេចក្តីប្រកាសក្នុងទិវាសុវត្ថិភាពអ៊ីនធឺណិតនេះ គឺបានធ្វើឡើងបន្ទាប់មានការស្ទាបស្ទង់មតិដែលយូនីសេហ្វបានរៀបចំ កាលពីពេលថ្មីៗនេះជាមួយនឹងយុវជន ដោយទទួលបានការឆ្លើយតបពីមនុស្សជាងមួយលាននាក់មកពីប្រទេសជាង១៦០ ក្នុងរយៈពេល៥សប្តាហ៍ រួមទាំងសំណូមពរជាច្រើនដែលបានលើកឡើងក្នុងកម្មវិធីជជែកពិភាក្សារបស់យុវជន អំពីការបញ្ចប់អំពើហិង្សា (#ENDviolence Youth Talks) ដែលដឹកនាំរៀបចំដោយសិស្សនិស្សិតនៅទូទាំងសកលលោក។ នៅក្នុងការស្ទាបស្ទង់មតិនោះយុវជនបានផ្តល់នូវការឆ្លើយតប្រកបដោយគំនិតគិតគូរវែងឆ្ងាយអំពីសកម្មភាពដែលពួកគេ និងឪពុកម្តាយ គ្រូបង្រៀន និងអ្នកតាក់តែងគោលនយោបាយ អាចធ្វើបានដើម្បីរក្សាសុវត្ថិភាពយុវជន។ សកម្មភាពប្រកបដោយក្តីមេត្តា គឺជាទង្វើដែលត្រូវបានលើកឡើងថា ជាមធ្យោបាយមួយ ក្នុងចំណោមមធ្យោបាយដែលមានប្រសិទ្ធភាពជាងគេបំផុត ដើម្បទប់ស្កាត់ការរឿងរឿងឈ្លោះ និងបៀតបៀនយុវជនតាមប្រព័ន្ធអ៊ីនធឺណិត។ យោងតាមសេចក្តីប្រកាសដដែលនេះលោកស្រី ណាតាសា ផាឌីសុន នាយិកាស្តីទីយូនីសេហ្វប្រចាំប្រទេសកម្ពុជា បានមានប្រសាសន៍ថា "យើងបានដឹងពីកុមារ និងយុវជននៅទូទាំងសកលលោកយ៉ាងច្បាស់ថា ប្រព័ន្ធអ៊ីនធឺណិតបានក្លាយជាប្រព័ន្ធគ្មានក្តីមេត្តា។ ដូច្នេះបានជាក្នុងទិវាសុវត្ថិភាពអ៊ីនធឺណិតនៅថ្ងៃនេះ យូនីសេហ្វបានចូលរួមជាមួយកុមារនិងយុវជនសំណូមពរឱ្យគ្រប់គ្នាមានក្តីសណ្តាសប្រណីដល់គ្នាទៅវិញទៅមកនៅតាមប្រព័ន្ធអនឡាញ និងអំពាវនាវឱ្យចាត់វិធានកាន់តែម៉ឺងម៉ាត់បន្ថែមទៀត ដើម្បីធ្វើឱ្យអ៊ិនធឺណេតក្លាយទៅជាប្រព័ន្ធកាន់តែមានសុវត្ថិភាពសម្រាប់គ្រប់គ្នា។"

បើតាមទិន្នន័យពីយូណេស្កូអំពីប្រេវ៉ាឡង់នៃការបៀតបៀនតាមប្រព័ន្ធអ៊ីនធឺណិតនៅក្នុងប្រទេស ដែលមានចំណូលខ្ពស់ភាគរយនៃកុមារនិងក្មេងជំទង់ដែលរងផលប៉ះពាល់ពីការរករឿងឈ្លោះតាមប្រព័ន្ធអ៊ីនធឺណិត មានចាប់ពី៥ រហូតដល់២១ភាគរយ ហើយកុមារីហាក់បីដូចជាទទួលរងគ្រោះពីការធ្វើបាបតាមប្រព័ន្ធអ៊ីនធឺណិតច្រើនជាងកុមារា។

នៅកម្ពុជា ក្នុងចំណោមក្មេងស្រីអាយុពី១៥ ទៅ ២៤ឆ្នាំទាំងអស់មាន៨៤,៤ ភាគរយ កំពុងប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិតហើយសម្រាប់កុមារាដែលស្ថិតក្នុងក្រុមអាយុដូចគ្នានេះគឺមាន៩១,៥ភាគរយ។ នៅក្នុងសកលលោក ភាគរយនៃយុវជនអាយុចន្លោះពី ១៥ ទៅ ២៤ឆ្នាំ ដែលកំពុងប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិតគឺ៧០,៦ ភាគរយ។ ក្រុមប្រជាពលរដ្ឋដែលប្រើប្រាស់អ៊ីនធឺណិតនៅកម្ពុជា គឺមានអាយុកាន់តែតិចទៅៗ ដោយក្នុងចំណោមកុមារអាយុ១៥ឆ្នាំទាំងអស់គឺមាន ៤,៥ ភាគរយកំពុងប្រើប្រាស់អ៊ីនធឺណិត។ ខណៈពេលដែលសិស្សដែលមានអាយុកាន់តែច្រើន កាន់តែងាយប្រឈមនឹងការសម្លុតគំរាមតាមប្រព័ន្ធអ៊ីនធឺណិត បើធៀបនឹងសិស្សដែលមានអាយុតិចជាង ហើយកុមារគឺជាក្រុមដែលងាយរងគ្រោះពីព័ត៌មានគ្រោះថ្នាក់ ការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទ និងការសម្លុតគំរាមតាមប្រព័ន្ធអ៊ិនធឺណេតផងដែរ។

ការបៀតបៀនតាមប្រព័ន្ធអ៊ិនធឺណិតអាចបង្កឱ្យមានការឈឺចាប់យ៉ាងធ្ងន់ធ្ងរ ហើយវាអាចកើតលើមនុស្សជាច្រើននាក់។ សកម្មភាព និងព័ត៌មានបៀតបៀនទាំងនោះនៅតែមានវត្តមាននៅលើប្រព័ន្ធអនឡាញដោយគ្មានពេលកំណត់ ពោលគឺវា "នៅតែតាមធ្វើបាប" ជនរងគ្រោះតាមប្រព័ន្ធអនឡាញពេញមួយជីវិត។ ការរករឿងឈ្លោះនៅខាងក្រៅ និងការបៀតបៀនតាមប្រព័ន្ធអ៊ិនធឺណិត គឺជាសកម្មភាពអាក្រក់ពីរបំពេញគ្នាទៅវិញទៅមក ដោយបង្កើតជាឥរិយាបថបង្កការឈឺចាប់ និងខូចខាតតគ្នាពីមួយទៅមួយមិនចេះចប់។ ជនរងគ្រោះដោយសារការបៀតបៀនតាមប្រព័ន្ធអ៊ីនធឺណិតអាចរងផលប៉ះពាល់ដោយទំនងជាឈានទៅប្រើប្រាស់គ្រឿងស្រវឹង គ្រឿងញៀន និងគេចមិនចូលរៀនជាងសិស្សដទៃទៀត។ ពួកគេក៏ច្រើនតែទទួលបានពិន្ទុទាប និងផ្តល់តម្លៃឱ្យខ្លួនឯងទាប ក៏ដូចជាជួបប្រទះនឹងបញ្ហាសុខភាពជាច្រើន។ ក្នុងស្ថានភាពធ្ងន់ធ្ងរ ការបៀតបៀនតាមប្រព័ន្ធអ៊ីនធឺណិត អាចនាំឱ្យមានការធ្វើអត្តឃាតក៏មាន។

លោកស្រី ណាតាសា ផាឌីសុន នាយិកាស្តីទីយូនីសេហ្វប្រចាំប្រទេសកម្ពុជាបានបន្តទៀតថា "៣០ឆ្នាំក្រោយការអនុម័តលើអនុសញ្ញាស្តីពីសិទ្ធិកុមារ និងការបង្កើតប្រព័ន្ធអ៊ីនធឺណិត គឺដល់ពេលដែលរដ្ឋាភិបាល គ្រួសារ ស្ថាប័នសិក្សាស្រាវជ្រាវ និងជាពិសេសវិស័យឯកជន គិតពិចារណាពីកុមារ និងយុវជន ដោយចាត់ទុកពួកគេជាស្នូលនៃគោលនយោបាយឌីជីថល។ តាមរយៈការការពារពួកគេពីហេតុការណ៍អាក្រក់បំផុតដែលកើតចេញពីការប្រើប្រាស់អ៊ីនធឺណិត និងពង្រីកការប្រើប្រាស់អ៊ីនធឺណិតរបស់ពួកគេ យើងម្នាក់ៗអាចជួយឱ្យមានតុល្យភាព ដើម្បីឧត្តមប្រយោជន៍របស់កុមារ និងយុវជន។" យូនីសេហ្វ លើកកម្ពស់សិទ្ធិ និងសុខុមាលភាពរបស់កុមារគ្រប់រូប នៅក្នុងរាល់សកម្មភាពនៅគ្រប់ការងាររបស់យើង។ រួមគ្នាជាមួយដៃគូ យើងធ្វើការងារនៅក្នុងប្រទេស និងដែនដីចំនួន១៩០ ដើម្បីប្រែក្លាយការប្តេជ្ញាចិត្តនេះទៅជាចំណាត់ការជាក់ស្តែង ដោយផ្តោតលើកិច្ចខិតខំពិសេសលើកុមារងាយរងគ្រោះបំផុត និងកុមារដែលត្រូវបានផាត់ចេញពីសង្គម ក្នុងគោលបំណងផ្តល់ជាប្រយោជន៍ដល់កុមារគ្រប់រូប នៅគ្រប់កន្លែងទាំងអស់៕សរន

## ថៃលេខមែនទែន ចេញច្បាប់ថ្មីបើក្រុមហ៊ុនណាមិនគោរពច្បាប់ការងារច្បាស់ធ្ងន់.ក

https://kohsantepheapdaily.com.kh/ ថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០១៩ ម៉ោង ០៩:១២ ណៃ ដាលីន

ប្រទេសថៃ ៖ យោងតាមភ្នាក់ងារសារព័ត៌មាន Bangkok Post កាលពីថ្ងៃចន្ទ កន្លងមកបានឲ្យដឹងថា ការធ្វើវិសោធនកម្មច្បាប់ការពារការងារក្នុងប្រទេសថៃនឹងបន្តពង្រឹងដល់ការការពារពលករ ធ្វើឲ្យបរិស្ថានការងារកាន់តែល្អប្រសើរ និងដាក់ទណ្ឌកម្មលើក្រុមហ៊ុនដែលមិនគោរពតាមជាដើម ។ ការធ្វើវិសោធនកម្មថ្មីនឹងចាប់ចូលជាធរមានក្នុងរយៈពេល៣០ថ្ងៃបន្ទាប់ពីរដ្ឋាភិបាលប្រកាសដែលប្រហែលជានឹងកើតឡើងនៅដើមឆ្នាំ២០១៩ នេះ ។ ការផ្លាស់ប្តូរសំខាន់ៗរួមមានដូចខាងក្រោម ៖ បុគ្គលិកត្រូវអនុញ្ញាតឲ្យបុគ្គលិកឈប់សម្រាកក្រោយពេលសម្រាលកូនបាន ៩៨ថ្ងៃ ឬច្រើនជាងច្បាប់មុន ៨ថ្ងៃ ។ លើសពីនេះទៀត ថ្ងៃឈប់សម្រាកសម្រាលកូននឹងរាប់បញ្ចូលថ្ងៃឈប់សម្រាកដើម្បីពិនិត្យផ្ទៃពោះមុនពេលសម្រាលកូនផងដែរ ហើយក្រុមហ៊ុនត្រូវតែផ្តល់ប្រាក់បៀវត្សរ៍ដល់ទៅ ៤៥ថ្ងៃក្នុងកំឡុងពេលឈប់សម្រាកនេះ ។

ក្រៅពីនេះហើយ ច្បាប់ថ្មីនឹងអនុញ្ញាតឲ្យបុគ្គលិកមានថ្ងៃឈប់សម្រាកសម្រាប់ធុរៈចាំបាច់ដល់ទៅ ៣ថ្ងៃក្នុងមួយឆ្នាំ ប៉ុន្តែមិនបានឲ្យនិយមន័យច្បាស់លាស់ពីពាក្យថាធុរៈចាំបាច់ទេ ។ ប្រសិនបើក្រុមហ៊ុនផ្លាស់ប្តូរបុគ្គលិកខ្លួនឲ្យទៅកន្លែងធ្វើការថ្មី ក្រុមហ៊ុនមានភារកិច្ចក្នុងការប្រកាសប្រាប់ទុកមុនយ៉ាងតិចក៏៣០ថ្ងៃដែរមុនថ្ងៃប្តូរទីតាំង ។ ប្រសិនបើបុគ្គលិកគិតថាពួកគេទទួលរងការប៉ះពាល់ពីការផ្លាស់ប្តូរនេះនិងចង់បដិសេធ បុគ្គលិករូបនោះអាចប្រាប់ដល់ក្រុមហ៊ុនក្នុងរយៈពេល៣០ថ្ងៃក្រោយពេលប្រកាស។ ក្នុងករណីនេះ ក្រុមហ៊ុនមានភារកិច្ចក្នុងការផ្តល់ថវិកាលើកទឹកចិត្ត ។ ជាមួយគ្នានេះផងដែរ ក្រុមហ៊ុនត្រូវតែផ្តល់ប្រាក់បៀវត្សរ៍ ប្រាក់ធ្វើការថែមម៉ោង និងការធ្វើការក្នុងកំឡុងពេលឈប់សម្រាកផ្សេងៗក្នុងចំនួនស្មើគ្នាទាំងសម្រាប់បុគ្គលិកប្រុសនិងស្រី។

ការធ្វើវិសោធនកម្មថ្មីនេះផ្តោតសំខាន់លើការការពារពលករ ខណៈដែលដាក់សម្ពាធដល់ក្រុមហ៊ុនឲ្យគោរពតាម ។ រាល់ការល្មើសនឹងជួបជាមួយនឹងទណ្ឌកម្មធ្ងន់ធ្ងរ ដូច្នេះវាពិតជាសំខាន់ណាស់សម្រាប់ក្រុមហ៊ុនក្នុងការត្រួតពិនិត្យកិច្ចសន្យាការងាររបស់ខ្លួនឡើងវិញ និងចេញវិធានការដើម្បីធានាថាពួកគេអាចគោរពតាមច្បាប់ថ្មីបានពេលដែលវាចូលជាធរមាន ៕

# ថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៩

## មជ្ឈមណ្ឌលបណ្តុះបណ្តាល ភាសាជប៉ុនស៊ីអិល បោកលុយសិស្សក្រីក្រជាច្រើននាក់ តាមរយៈការប្រើល្បិចសន្យា បញ្ជូនទៅធ្វើការនៅជប៉ុន

https://www.dap-news.com/ ByID:114 Posted on 08 February 2019 | 13:55

ភ្នំពេញ៖ មជ្ឈមណ្ឌបណ្តុះបណ្តាល ភាសាជប៉ុនស៊ីអិល បោកប្រាស់និស្សិតក្រីក្រ មកពីតាមបណ្តាខេត្តជាច្រើននាក់ គិតជាទឹកប្រាក់រាប់ម៉ឺនដុល្លារ តាមរយៈការសន្យាបញ្ជូន ទៅធ្វើការនៅប្រទេសជប៉ុន ប៉ុន្តែមិនធ្វើតាមពាក្យសន្យានោះឡើយ។ ជនរងគ្រោះជាច្រើននាក់ បានដាក់ពាក្យបណ្តឹង ទៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីឲ្យជួយអន្តរាគមន៍ចាត់វិធានការ ទៅលើមជ្ឈមណ្ឌលបណ្តុះបណ្តាល ភាសាជប៉ុនស៊ីអិល ដែលបានបោកប្រាស់យកលុយរបស់ពួកគេក្នុងម្នាក់ៗអស់រាប់ពាន់ដុល្លារ។

យោងតាមពាក្យបណ្តឹង របស់ក្រុមជនរងគ្រោះ ប្តឹងទៅកាន់សាលាដំបូងរាជធានីភ្នំពេញ និងស្នើទៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឲ្យជួយអន្តរាគមន៍ករណីខាងលើនេះ បានឲ្យដឹងថាសុំប្តឹងឈ្មោះ ឈាង ធុំ ភេទប្រុសកើតថ្ងៃទី២១ ខែ កក្កដា ឆ្នាំ១៩៨០ កាន់លិខិតឆ្លងដែន លេខN1719605 និងឈ្មោះជី អ៊ឹងគឹមលាង ភេទស្រី (ត្រូវជាប្រពន្ធឈ្មោះ ឈាង ធុំ) ព្រមទាំងបក្ខពួកមានអាសយដ្ឋាន នៅភូមិម៍ល សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ ពាក់ព័ន្ធនឹងករណីឆបោក។

តំណាងជនរងគ្រោះ បានឲ្យដឹងថា ពួកគេទាំងអស់គ្នា បានបំពេញបែបបទចូលរៀនដំបូង តម្រូវឲ្យបង់ប្រាក់ចំនួន ៣០០ដុល្លារ ដើម្បីទៅធ្វើការនៅប្រទេសជប៉ុន ហើយបន្ទាប់ពីបានសិក្សា អស់រយៈពេលជាច្រើនខែ ឈ្មោះ ឈាង ធុំ បានឲ្យជនជាតិជប៉ុនម្នាក់ មកធ្វើកិច្ចសម្ភាសន៍ពួកខ្លួនទាំងអស់គ្នា ដោយអះអាងថា ខ្លួនជានិយោជកនៅប្រទេសជប៉ុន ប៉ុន្តែជាក់ស្តែងជនជាតិជប៉ុនរូបនេះ គ្រាន់តែជាបុគ្គលិកឯកជនមួយប៉ុណ្ណោះ។ ក្រោយមកឈ្មោះ ឈាង ធុំ បានប្រើឧបាយកលទុច្ចរិត និងបានប្រាប់ពួកខ្លួនជានិស្សិត ដែលកំពុងសិក្សា នៅក្នុងមជ្ឈមណ្ឌលបណ្តុះបណ្តាល ភាសាជប៉ុនស៊ីអិលខាងលើថា បានជាប់ទៅធ្វើការនៅប្រទេសជប៉ុនហើយ ដោយតម្រូវ ឲ្យជនរងគ្រោះទាំងអស់បង់ប្រាក់ ដើម្បីរៀបចំឯកសារទិដ្ឋាការ (Visa) ដើម្បីទៅធ្វើការនៅប្រទេសជប៉ុន។ ពេលនោះឈ្មោះ ឈាង ធុំ បានឲ្យជនរងគ្រោះ បង់ប្រាក់ក្នុងម្នាក់ៗ ១,៧០០ដុល្លារ និងមានខ្លះទៀត អស់រហូតដិត ៥,០០០ដុល្លារ តែលទ្ធផលអ្វីៗទាំងនោះ អត់មានបានប្រយោជន៍អ្វីបន្តិចសោះ រង់ចាំមួយទៅមួយថ្ងៃ រហូតជាច្រើនខែ ទើបដឹងថា ពួកគេចាញ់បោកឈ្មោះ ឈាង ធុំ ដែលតាំងខ្លួន ជាអគ្គនាយកមជ្ឈមណ្ឌល បណ្តុះបណ្តាលភាសាជប៉ុនស៊ីអិល។

បើតាមប្រភពព័ត៌មានខាងលើ បានឲ្យដឹងថា ឈ្មោះ ឈាង ធុំ បានដើរតួនាទីខ្លួនឯង ជាអគ្គនាយកផង និងជាប្រធានក្រុមប្រឹក្សាភិបាលផង ហើយពេលក្រសួងការងារ កោះអញ្ជើញ មិនដែលឃើញវត្តមានចូលខ្លួននោះទេ ស្រាប់តែលេចមុខអ្នកផ្សេងទៅវិញ។ ជនរងគ្រោះបានសំណូមពរឲ្យ លោក អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវ មេត្តាជួយពិនិត្យ លើទីតាំងមជ្ឈមណ្ឌលបណ្តុះបណ្តាលភាសាជប៉ុនស៊ីអិលខាងលើនេះ និងទាមទារ ឲ្យខាងមជ្ឈមណ្ឌលបណ្តុះបណ្តាល ភាសាជប៉ុនស៊ីអិល សងប្រាក់ទៅពួកគាត់ទាំងអស់គ្នាវិញ។

ចំណែក បុគ្គលឈ្មោះ ជា វីរៈ ក៏បានប្តឹង ទៅកាន់សាលាដំបូងរាជធានីភ្នំពេញ លើឈ្មោះ ឈាង ធុំ ភេទប្រុសកើតថ្ងៃទី២១ ខែ កក្កដា ឆ្នាំ១៩៨០ កាន់លិខិតឆ្លងដែន លេខN1719605 និងឈ្មោះជី អ៊ឹងគឹមលាង ភេទស្រី (ត្រូវជាប្រពន្ធរបស់ឈ្មោះ ឈាង ធុំ) ពាក់ព័ន្ធបទបរិហារកេរ្តិ៍ជាសាធារណៈ និងប្រើប្រាស់ឯកសារក្លែងក្លាយផងដែរ៕

# ថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៩

## នាយឧត្តមសេនីយ៍ ណឹម សុវត្ថិ៖សន្តិភាពជាសម្បត្តិសាធារណៈរកបានដោយកម្រ និងថែរក្សាដោយលំបាក

http://bayontv.com.kh/ 11/02/2019

ភ្នំពេញ៖ នាយឧត្តមសេនីយ៍ ណឹម សុវត្ថិ អគ្គនាយកនយោបាយ និងកិច្ចការបរទេស នៃក្រសួងការពារជាតិ បានថ្លែងទៅកាន់អ្នកចូលរួមប្រមាណជាង១.៥០០នាក់ មកពីបណ្តាប្រទេសលើពិភពលោកនៅក្នុងកិច្ចប្រជុំកំពូលពិភពលោកឆ្នាំ២០១៩ នៅទីក្រុងសេអ៊ូល ប្រទេសកូរ៉េខាងត្បូងថា សន្តិភាពជាសម្បត្តិសាធារណៈរកបានដោយកម្រ និងថែរក្សាដោយលំបាក ខណៈកម្ពុជាទើបតែទទួលបាននូវសុខសន្តិភាពនេះ ក្នុងរយៈពេល២០ចុងក្រោយក្រោមការដាក់ចេញនូវនយោបាយ ឈ្នះ ឈ្នះរបស់សម្តេចតេជោ ហ៊ុន សែននាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។ នាយឧត្តមសេនីយ៍ ណឹម សុវត្ថិបានលើកឡើងថា«វត្តមាន ពិភពលោកប្រព្រឹត្តទៅបានគឺដោយសារសន្តិភាព។ សន្តិភាពជាសម្បត្តិសាធារណៈដែលរកបានដោយកម្រ និងថែរក្សាដោយលំបាកជាមួយនឹងតម្រូវការគ្រប់ដង្ហើមចេញចូលរបស់មនុស្សលោក មិនថា សាសន៍ណា ជំនឿអ្វីឬក៏វ័យណានោះទេ។ ភាពសុខក្សេមក្សាន្តនៃការអភិវឌ្ឍ មិនអាចធ្វើទៅបានដោយគ្មានសន្តិភាពនោះឡើយ»។

ជាមួយគ្នានោះដែរឯកឧត្តមនាយឧត្តមសេនីយ៍ ណឹម សុវត្ថិ ក៏បានប្រាប់ដល់សមាជិក-សមាជិកា នៃកិច្ចប្រជុំទៀតថា ប្រទេសណាដែលធ្លាប់ឆ្លងកាត់សង្គ្រាម ភ្លក់រសជាតិនៃសង្គ្រាម គ្រោះថ្នាក់នៃសង្គ្រាម ទើបអាចស្គាល់នូវតម្លៃសន្តិភាព និងសេចក្តីត្រូវការសន្តិភាពជាងអ្នក ទាំងអស់ មានតែអ្នកធ្លាប់ត្រូវរបួស ទើបស្គាល់ការឈឺចាប់ដោយគ្រាប់រំសេវ អ្នកដែលបាត់បង់ កាយសម្បទាដោយសារសង្គ្រាម ទើបស្គាល់នូវតម្លៃពិតប្រាកដនៃភាពគ្មានសង្គ្រាម ស្ថិរភាព និងការអភិវឌ្ឍ។ ឯកឧត្តមបានបញ្ជាក់បន្ថែមថា «ទិដ្ឋភាព និងជីវិតបែបនោះហើយ ដែលប្រជាជនកម្ពុជា បានឆ្លងកាត់ និងស្គាល់រសជាតិក្នុងអំឡុងទសវត្សរ៍១៩៦០ដល់១៩៩០រហូតដល់ថ្ងៃទី២៩ ខែ ធ្នូ ឆ្នាំ១៩៩៨ទើបកម្ពុជាបានទទួលបានសុខសន្តិភាពពេញលេញដោយនយោបាយ ឈ្នះ ឈ្នះ របស់សម្តេចតេជោ ហ៊ុន សែននាយករដ្ឋមន្ត្រី»។ ក្រោយកម្ពុជាទទួលបាននូវសុខសន្តិភាព ពេញលេញត្រឹមតែរយៈពេល២០ឆ្នាំមកនេះ ឯកឧត្តមនាយឧត្តមសេនីយ៍ ណឹម សុវត្ថិ បានប្រាប់ដល់អ្នកចូលរួមទៀតថា កម្ពុជាបានសម្រេច កសាងនូវសំណង់វិមាន ឈ្នះ ឈ្នះមួយជាតឹកតាងបង្ហាញនូវគុណតម្លៃនៃសន្តិភាព គុណប្រយោជន៍នៃដំណើរការស្វែងរកសន្តិភាព និងសម្រាប់បន្តថែរក្សាសន្តិភាពទៅមុខទៀត ហើយ សំណង់ដ៏ប្រវត្តិសាស្ត្រមួយនេះក៏នឹងក្លាយទៅជាពហុមជ្ឈមណ្ឌល ពហុវិស័យសម្រាប់ផ្ទុករាល់ឯកសារប្រវត្តិសាស្ត្ររបស់កម្ពុជាផងដែរ។

នាយឧត្តមសេនីយ៍ ណឹម សុវត្ថិ បានឲ្យដឹងផងដែរថា កិច្ចប្រជុំ កំពូលពិភពលោកឆ្នាំ២០១៩នេះគឺបានពិភាក្សា និងធ្វើបទបង្ហាញជាច្រើនទាក់ទង និងសន្តិសុខ វប្បធម៌.សន្តិភាព.សាសនា និងការអភិវឌ្ឍធនធានមនុស្សជាដើម។ កិច្ចប្រជុំនេះបានផ្តល់ឱកាសឲ្យកម្ពុជាផ្តល់បទបញ្ហាញជាច្រើនទាក់ទង និងដំណើរការបច្ចុប្បន្ន នៅកម្ពុជាជាពិសេសជុំវិញដែលកម្ពុជាទទួលបានសុខសន្តិភាព និងការអភិវឌ្ឍនេះតែម្តង៕

## នាយកដ្ឋាន ប្រឆាំងការ ជួញដូរមនុស្សបើកវគ្គបណ្តុះបណ្តាលដល់មន្ត្រីនគរបាលដើម្បីពង្រឹងសមត្ថភាពឆ្លើយតបសកម្មភាពបទល្មើស

http://cambodiapolice.com/policekh/ 10:12 am 11 កុម្ភៈ 2019

ភ្នំពេញ៖ឯកឧត្តម ឧត្តមសេនីយ៍ឯក ប៉ុល ភិធេយ្យ ប្រធាននាយកដ្ឋាន ប្រឆាំងការ ជួញដូរមនុស្សនិងការពារអនីតិជនបានលើកឡើងថា សកម្មភាពជួញដូរមនុស្សនិងអាជីវកម្មផ្លូវភេទ លើស្ត្រីនិងកុមារនៅកម្ពុជានៅតែជាបញ្ហា

ដែលត្រូវយកចិត្តទុកដាក់រួមគ្នាដើម្បីប្រយុទ្ធប្រឆាំងក្នុងនោះរួមមាន បញ្ហាពេស្យាចារ ជួញដូរព្រហ្មចារី អាជីវកម្មផ្លូវភេទ ការពពោះជំនួសនិងការជួញដូរសរីរាង្គជាដើម។

មានប្រសាសន៍ខណៈដែលឯកឧត្តម ឧត្តមសេនីយ៍ឯក ប៉ុល ភិធេយ្យ ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន តំណាង អោយឯកឧត្តមនាយឧត្តមសេនីយ៍សន្តិបណ្ឌិតនេត សាវឿន អគ្គស្នងការនគរបាលជាតិ អញ្ជើញជាអធិបតីភាព ក្នុងពិធីបើកវគ្គបណ្តុះបណ្តាលស្តីពីយុទ្ធវិធីប្រតិបត្តិការនិងការប្រើប្រាស់អាវុធដល់នគរបាលរាជធានី នៅព្រឹកថ្ងៃទី១១ កុម្ភៈ ឆ្នាំ២០១៩នេះ នៅនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ។ ឯកឧត្តម ឧត្តមសេនីយ៍ឯក ប៉ុល ភិធេយ្យបានបន្ថែមអោយដឹងថា៖ ការធ្វើចំណាកស្រុកស្វែងរកការងារនៅក្រៅប្រទេសដោយខុសច្បាប់ក៏នៅតែជាបញ្ហាប្រឈមដូចជា សុំទាន នេសាទសមុទ្រ បំរើការងារតាមផ្ទះ និងអាពាហ៍ពិពាហ៍ផ្ទុយពីធន្ទៈ។ ក្នុងនោះបុរសត្រូវបានគេនាំចេញទៅធ្វើការងារខុសច្បាប់នៅប្រទេសថៃ ចិន ម៉ាឡេស៊ី ឥណ្ឌូនេស៊ី សឹង្ហបុរី ប៉ាគីស្ថាន សូម៉ាលី ជប៉ុននិង អារ៉ាប់ប៊ីសាអូឌីតជាដើម។ឯកឧត្តមបន្ថែមអោយដឹងថាវគ្គបណ្តុះបណ្តាល នៅពេលនេះមានគោលបំណងសំខាន់គឺដើម្បីពង្រឹងសមត្ថភាពមន្ត្រីជំនាញបន្ថែមទៀតក្នុងពេលប្រតិបត្តការបង្ក្រាបបទល្មើសលើបច្ចេកទេស ចាប់ជនសង្ស័យ ការកាពារខ្លួននិងការប្រើប្រាស់អាវុធ រួមទាំងការសង្គ្រោះបឋមពេលដែលមានការទទួលរងរបួស។តាមរយៈវគ្គបណ្តុះបណ្តាលនេះឯកឧត្តមសង្ឃឹមថានិងផ្តល់នៅបទពិសោធន៍និងចំណេះដឹងបន្ថែមទៀតសំដៅរកភាពរីកចម្រើនក្នុងការប្រយុទ្ធប្រឆាំងការជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មលើផ្លូវភេទនិងស្ត្រីនិងកុមារ។

គួរបញ្ជាក់ថា វគ្គបណ្តុះបណ្តាលមានរយៈពេល៥ថ្ងៃចាប់ពីថ្ងៃទី១១ ដល់ថ្ងៃទី១៥ ខែកុម្ភៈ មានការចូលរួមពីសំណាក់អង្គការចំនួនពីរ គឺអង្គការមេត្រីអន្តរជាតិ (AIM SWAT) (SUMMIT CHURCH) ដែលមានគ្រូឧទ្ទេសនាមដែលមានបទពិសោធខ្ពស់មកពីសហរដ្ឋអាមេរិក ព្រម ទាំងមានការចូលរួមពីសិក្ខាកាមជា នាយ នាយរងនគរបាលមកពីនាយកដ្ឋាននិងស្នងការដ្ឋានរាជធានីផងដែរ៕

## សមត្ថកិច្ចជំនាញក្នុងមូលដ្ឋាន ឃុំអូរស្វាយ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ បើកដៃឲ្យមេឈ្មួញជើងខ្លាំងឈ្មោះ លាង វុធ និងពួកឈ្មួញជាច្រើនទៀតដាក់កម្លាំងឡើង ចូលទៅលួចកាប់ឈើគ្រញូង នៅក្នុងទឹកដីប្រទេសថៃ!!!

https://www.facebook.com/cpnnews.info/ សារព័ត៌មានចក្រភពព័ត៌មាន CPN News 10-02-2019

ឧត្តរមានជ័យ៖ សមត្ថកិច្ចជំនាញក្នុងឃុំអូរស្វាយ បានឃុបឃិតគ្នាជាប្រព័ន្ធ បើកដៃឲ្យមេឈ្មួញឈើគ្រញូងជើងខ្លាំងឈ្មោះ លាង វុធ ដែលមានតួនាទីជាទាហានយោធាស័ក្តបី និងពួកមេឈ្មួញជុះស្លែជើងខ្លាំងជាច្រើនទៀតទាំងនៅក្នុងស្រុកអន្លង់វែង និងស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ប្រមូលគៀងគរប្រជាពលរដ្ឋ ឲ្យលួចឆ្លងដែនចូលទៅលួចកាប់ឈើគ្រញូងនៅក្នុងទឹកដីប្រទេសថៃយកមកលក់ឲ្យពួកខ្លួនដើម្បីដឹកបន្តយកទៅលក់នៅប្រទេសវៀតណាម ដោយមិនខ្លាចកោតញញើត នូវអនុសាសន៍របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ឡើយ។ ដាក់ស្តែងជារៀងរាល់យប់រាល់ថ្ងៃ គេតែងតែសង្កេតឃើញមេឈ្មួញឈ្មោះ លាង វុធ និងពួកឈ្មួញជាច្រើនទៀត បានដាក់កម្លាំងឆ្លងដែនចូលទៅលួចកាប់ឈើគ្រញូង នៅក្នុងទឹកដីប្រទេសថៃ ដោយធ្វើដំណើរឆ្លងចូលតាមច្រកដូចជា ច្រកក្បាលអូរស្វាយ ច្រកថ្មប្រេះ ច្រកឈើទាលជ្រុំ ច្រកចំបក់កោង និងច្រកអូរខ្សាច់ ស្ថិតនៅក្នុងភូមិអូរស្វាយ ឃុំអូរស្វាយ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ហើយចំណុចទីតាំងភូមិសាស្ត្រទាំងអស់នេះផងដែរ ក៏ស្ថិតនៅក្នុងតំបន់សិកទ័រនៃការគ្រប់គ្រងរបស់លោក វរៈសេនីយទោ ស៊ុន បូរ៉ាន់ នាយបញ្ជាការផ្នែកសឹករងស្រុកត្រពាំងប្រាសាទដែរ តែមិនដែលឃើញលោកធ្វើការចាប់បង្ក្រាបសោះ។

សូមបញ្ជាក់ផងដែរថា ជាច្រើនឆ្នាំកន្លងមកនេះ មានប្រជាពលរដ្ឋជាច្រើននាក់ បានទទួលរងនូវគ្រោះថ្នាក់ ដោយសារតែការលួចឆ្លងដែន ចូលទៅក្នុងទឹកដីថៃ លួចកាប់និងស្ពាយឈើគ្រញូង ខ្លះត្រូវទាហានថៃចាប់ដាក់គុក អ្នកខ្លះទៀតត្រូវបានបាត់ខ្លួនរកមិនឃើញ និងអ្នកខ្លះទៀតត្រូវបានទាហានថៃបាញ់សម្លាប់ ស្លាប់បាត់បង់ជីវិតយ៉ាងអាណោចអាធម្មជាទីបំផុត ចោលសាច់ញាតិ ក្រុមគ្រួសារ ឪពុកម្តាយ បងប្អូន ប្រពន្ធកូន ឲ្យរស់នៅកំព្រាវេទនាខ្លោចផ្សា ខ្លាំងណាស់ តើករណីទាំងអស់នេះ កើតឡើងមកពីដោយសារតែអ្វី? សូមសម្តេច ទ្រង់ឯកឧត្តម លោកជំទាវ ព្រមទាំងពុកម៉ែបងប្អូន ប្រជាពលរដ្ឋទាំងអស់គ្នា ទូទាំងប្រទេសជួយគិតពិចារណាទៅតាមការគួរផង។

ជាចុងក្រោយខ្ញុំ ព្រមទាំងប្រជាពលរដ្ឋស្លូតត្រង់ទាំងអស់ សូមអំពាវនាវទៅដល់ ឯកឧត្តម នាយឧត្តមសេនីយឯក សៅ សុខា និង ឯកឧត្តម ប៉ែន កុសល្យ អភិបាលនៃគណៈអភិបាលខេត្តឧត្តរមានជ័យ សូមឯកឧត្តមមេត្តាមានចំណាត់ការណ៍ក្តៅ ចំពោះអាជ្ញាធរមូលដ្ឋាន សមត្ថកិច្ច និងមន្ត្រីជំនាញ នៅក្នុងឃុំអូរស្វាយ ដែលតែងតែមិនបង្ក្រាប និងបណ្តោយឲ្យមេឈ្មួញជើងខ្លាំងឈ្មោះ លាង វុធ និងពួកឈ្មួញដុះស្លែជាច្រើនទៀត ធ្វើការប្រព្រឹត្តរកស៊ីបទល្មើសឈើគ្រញូង ដែលជាបទល្មើសឧក្រិដ្ឋតាមតែអំពើចិត្ត ដោយមិនខ្វល់ពីអនុសាសន៍នៃបទបញ្ជាដ៏ក្តៅគគុករបស់សម្តេច ហ៊ុន សែន និងមិនគិតពីសុខទុក្ខលំបាក និងអាយុជីវិតរបស់ប្រជាពលរដ្ឋ ដែលលួចចូលទៅកាប់និងស្ពាយឈើគ្រញូងឡើយ។ខ្ញុំព្រមទាំងប្រជាពលរដ្ឋទាំងអស់គ្នា សង្ឃឹមថាឯកឧត្តម និងមានចំណាត់ការណ៍ ចំពោះអស់លោកមន្ត្រី ដែលអសមត្ថភាពទាំងអស់នោះ ដើម្បីកុំឲ្យប្រជាពលរដ្ឋ មានគ្រោះថ្នាក់ដោយប្រការណាទៀត៕ ដោយៈ សាន់រិទ្ធ

## លោក សុខ សុគន្ធៈ កម្ពុជាមានសន្តិភាព ទើបពលរដ្ឋទទួលបានសិទ្ធិធ្វើការនៅកូរ៉េខាងត្បូង

http://www.freshnewsasia.com/index.php/ 11-2-2019

**(ភ្នំពេញ)៖** អ្នកអត្ថាធិប្បាយលើបញ្ហាសង្គម និងនយោបាយរបស់កម្ពុជាដ៏មានប្រជាប្រិយភាពលើបណ្តាញសង្គម លោក សុខ សុគន្ធ បានក្រើនរំលឹកពលករខ្មែរដែលកំពុងបម្រើការងារ នៅប្រទេសកូរ៉េខាងត្បូងប្រមាណជាង ៦ម៉ឺននាក់ថា បើប្រទេសកម្ពុជាគ្មានសុខសន្តិភាព និងគ្មានចំណងមេត្រីភាពផ្នែកការទូតល្អប្រសើរជាមួយកូរ៉េខាងត្បូងទេនោះ ប្រជាពលរដ្ឋមិនអាចទទួលបានច្បាប់ និងសិទ្ធិទៅធ្វើការនៅក្នុងប្រទេសកូរ៉េខាងត្បូងនោះឡើយ។ លោក សុខ សុគន្ធ ឬហៅថា ដេម សុខ ពលរដ្ឋខ្មែររស់នៅអាមេរិក គឺជាអ្នកអត្ថាធិប្បាយមួយរូបដែលតែងផ្តល់គំនិត និងទស្សនៈជាការពិចារណាដល់ប្រជាពលរដ្ឋ និងជាអ្នកដែលតែងតែបាន ដាស់តឿនឲ្យខ្មែរ ជាពិសេសគឺយុវជនជំនាន់ថ្មីឲ្យប្រឹងប្រែងសិក្សារៀនសូត្រ ប្រឹងរកស៊ី និងចេះសន្សំសំចៃប្រាក់កាកដែលរកបាន។ ការអត្ថាធិប្បាយរបស់លោកទទួលបានការពេញចិត្តពេញថ្លើម និងគាំទ្រជាខ្លាំងពីប្រជាពលរដ្ឋខ្មែរ។ តែលោកក៏តែងតែរងការរិះគន់ពីក្រុមមនុស្សគាំទ្រទណ្ឌិត សម រង្ស៊ី ផងដែរ ព្រោះតែលោកតែងតែអត្ថាធិប្បាយបើកកកាយពីល្បិចកិច្ចកល និងពុតត្បុតខិលខូចពិសពុលរបស់លោក សម រង្ស៊ី។

ការដែលលោក សុខ សុគន្ធ ក្រើនរំលឹកពលករខ្មែរនៅកូរ៉េខាងត្បូងឲ្យស្គាល់ពីតម្លៃនៃសន្តិភាព និងថាមានតែកម្ពុជាមានសន្តិភាពទើបពួកគេអាចមានសិទ្ធិទទួលបានទិដ្ឋាការ ទៅធ្វើការនៅកូរ៉េខាងត្បូងនេះ គឺបន្ទាប់ពីក្រុមទណ្ឌិត សម រង្ស៊ី បានព្យាយាមទៅកៀរគរពលករខ្មែរនៅកូរ៉េខាងត្បូងឲ្យដង្ហែខ្លួនចូលក្នុងប្រទេសកម្ពុជា។ លោក សុខ សុគន្ធ បុរសដែលធ្លាប់បានប្រឡូកក្នុងចលនាតស៊ូពេលកម្ពុជាជួបវិបត្តិភ្លើងសង្គ្រាមនោះ បានប្រាប់ពលករខ្មែរនៅកូរ៉េខាងត្បូង កុំឲ្យជឿតាមការញុះញង់ កុំជឿតាមការល្បួងលួងលោមរបស់ទណ្ឌិត សម រង្ស៊ី ព្រោះនោះសុទ្ធតែជាការភូតកុហកទាំងអស់។ លោក សុខ សុគន្ធ បានលើកទឹកចិត្តដល់ពលករខ្មែរនៅកូរ៉េខាងត្បូងទាំងអស់ ត្រូវប្រឹងប្រែងធ្វើការសន្សំលុយកាក់ ដើម្បីចិញ្ចឹមជីវិត និងផ្ញើជូនឪពុកម្តាយនៅឯស្រុកទើបជាការប្រសើរ។ អ្នកអត្ថាធិប្បាយនាយសមុទ្រដ៏មានប្រជាប្រិយភាពរូបនេះ បានគូសបញ្ជាក់ទៅកាន់ពលករនៅកូរ៉េខាងត្បូងថា ប្រទេសកម្ពុជា មានសុខសន្តិភាព

ហើយ ខ្មែរកំពុងរស់នៅបានសុខហើយ កុំនាំគ្នាលុងជឿតាមការអូសទាញ ការញុះញង់របស់អ្នកនយោបាយជើងមិនជាប់ដីទណ្ឌិត សម រង្ស៊ី បង្កវិនាសកម្ម ឬនាំមកការចលាចលសម្រាប់ប្រទេសជាតិនោះឡើយ។

បើតាមលោក សុខ សុគន្ធ បើកម្ពុជាគ្មានសុខសន្តិភាព នឹងគ្មានទូតកូរ៉េខាងត្បូងនៅកម្ពុជាអង្គុយវាយទិដ្ឋាការផ្ដល់សិទ្ធិឲ្យពលរដ្ឋខ្មែរទៅធ្វើការនៅកូរ៉េខាងត្បូងនោះឡើយ។ មួយវិញទៀតបើកូរ៉េខាងត្បូងគ្មានចំណងមេត្រីភាពផ្នែកការទូតដែលភ្ជាប់ឡើងកាលពីឆ្នាំ១៩៩៩ ក្រោមការផ្ដួចផ្ដើមដោយផ្ទាល់របស់សម្ដេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជាទេនោះ ពលរដ្ឋខ្មែរក៏មិនមានឱកាសបានទៅធ្វើការនៅកូរ៉េខាងត្បូងនោះដែរ។ ទន្ទឹមនឹងការក្រើនរំលឹកដល់ពលរដ្ឋខ្មែរនៅកូរ៉េខាងត្បូងហើយ លោក សុខ សុគន្ធ ក៏បានសម្ដែងការសោទរផងដែរ ចំពោះការបែកបាក់ចលនាយុវជននៅក្នុងប្រទេសកូរ៉េខាងត្បូង។ លោកថា ការបែកបាក់របស់ចលនាយុវជនកូរ៉េខាងត្បូងដែលមានសមាជិកមួយដំបស្វា គឺជារឿងល្អសម្រាប់យុវជននៅកូរ៉េខាងត្បូង និងសង្គមជាតិ ព្រោះគ្មានអ្នកទៅធ្វើចលនាអូសទាញរកអ្នកជង្ហែទណ្ឌិត សម រង្ស៊ី និងមិនប៉ះពាល់ដល់ការបម្រើការងាររបស់ពួកគេ។

## ពលករខ្មែរនៅប្រទេសថៃ អំពាវនាវឱ្យពលករដូចគ្នា កុំចាញ់បោកការភូតកុហករបស់ទណ្ឌិត សម រង្ស៊ី រឿងវិលចូលស្រុក

http://www.freshnewsasia.com/index.php/ 2019-02-11

**(ភ្នំពេញ)៖** ពលករខ្មែរមួយចំនួន ដែលកំពុងធ្វើការងារនៅក្នុងប្រទេសថៃ បានអំពាវនាវដល់ពលករដូចគ្នាទាំងអស់ កុំឱ្យចាញ់បោកការឃោសនាភូតកុហករបស់ ទណ្ឌិត សម រង្ស៊ី មេចលនាសង្គ្រោះជាតិដែលថា នឹងវិលចូលមកប្រទេសកម្ពុជានោះ។ ទន្ទឹមនឹងនេះ ពលករខ្មែរដែលកំពុងធ្វើការងារនៅប្រទេសថៃ ក៏បានស្នើឱ្យពលករទាំងអស់ធ្វើការធម្មតា ដើម្បីរកចំណូលផ្ញើមកកាន់គ្រួសារ។ ការអំពាវនាវនាថ្មីៗនេះ បានធ្វើឡើងបន្ទាប់ពី លោក សម រង្ស៊ី ប្រកាសវិលចូលប្រទេសកម្ពុជា គ្រាដែលតុលាការ និងសមត្ថកិច្ចរបស់រាជរដ្ឋាភិបាល កំពុងត្រៀមចាប់ខ្លួនទណ្ឌិតរូបនេះ មកអនុវត្តទោស បន្ទាប់ពីលោករត់គេចខ្លួនអស់រយៈពេលជាង៣ឆ្នាំ។ ប៉ុន្តែទោះជាយ៉ាងណា ខណៈដែលប្រកាសវិលត្រឡប់នេះ លោក សម រង្ស៊ី បានបង្គាប់ឱ្យសកម្មជនរបស់ខ្លួនរៃអង្គាសថវិកាពីអ្នកគាំទ្រឱ្យបានចំនួន៣០ម៉ឺនដុល្លារ ហើយអះអាងថា ការវិលត្រឡប់របស់លោក គឺដើម្បីផ្លាស់ប្ដូររបបកម្ពុជា។ ពលករខ្មែរមួយចំនួន ដែលកំពុងធ្វើការងារនៅក្នុងប្រទេសថៃ បានបង្ហាញជំហរមិនគាំទ្រចំពោះទង្វើរបស់ លោក សម រង្ស៊ីនេះឡើយ ហើយស្នើឱ្យបងប្អូនប្រជាពលរដ្ឋខ្មែរនៅប្រទេសថៃ ធ្វើការធម្មតា កុំឱ្យចាញ់បោកការឃោសនាដើម្បីរកផលប្រយោជន៍នេះតទៅទៀត។

សូមបញ្ជាក់ថា ទាក់ទឹងនឹងការឃោសនាវិលត្រឡប់ ដើម្បីរៃអង្គាសប្រាក់ពីអ្នកគាំទ្ររបស់ លោក សម រង្ស៊ីនេះ សម្ដេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា កាលពីថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៩ បានសរសេរកំណាព្យចំនួន៤ឃ្លា បង្កប់ដោយអត្ថន័យយ៉ាងជ្រាលជ្រៅ ដើម្បីដាស់អារម្មណ៍ លោក សម រង្ស៊ី ដែលកំពុងសុបិន នៅឯនាយសមុទ្រ ដ្បិតទណ្ឌិតរូបនេះ តែរកវិធីគ្រប់យ៉ាងដើម្បីឱ្យខ្លួនត្រឡប់មកកម្ពុជា ដោយរួចផុតពីការជាប់គុក។ កំណាព្យ៤ឃ្លាដែលសម្ដេចតេជោ ហ៊ុន សែន បានបង្ហោះនៅលើ Facebook មានខ្លឹមសារយ៉ាងដូច្នេះ «ទទាយំឆ្លងត្រយ៉ងបងអើយអត់ឆ្លើយ (ពីរដង) សង្សារបងអើយដល់ពេលហើយឬនៅ?។ ចិត្តអូនចិត្តដាច់ដោយសារចិត្តបងចិត្តខ្មៅ (ពីរដង) ស្ពានក៏បាក់ទឹកក៏ជ្រៅធ្វើម្ដេចបានទៅតាមកិច្ចសន្យា»។

អ្នកតាមដានបញ្ហានយោបាយបានសន្និដ្ឋាន កំណាព្យនេះ គឺសម្ដេចតេជោ ហ៊ុន សែន មានចេតនាយ៉ាងពិតប្រាកដផ្ញើទណ្ឌិតរត់ចោលស្រុក សម រង្ស៊ី គ្រាដែលការភ្នាល់រវាងសម្ដេច និងទណ្ឌិតរូបនេះជិតដល់ឱសានវាទ នាថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៩។

## ជប៉ុនមានបំណងចង់ជួយពង្រឹងសមត្ថភាពពលករកម្ពុជាលើផ្នែកសំណង់

https://kohsantepheapdaily.com.kh/ ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៩ ម៉ោង ០៨:៣០ ឡុង សារ៉េត

រាជធានីភ្នំពេញ ៖ ប្រធានអង្គការសមាគមសហប្រតិបត្តិការកម្ពុជា-ជប៉ុន បានបង្ហាញគោលបំណងចង់ជួយពង្រឹងសមត្ថភាពដល់ពលករកម្ពុជាលើផ្នែកសំណង់ ពិសេសការបង្កើតបាតគ្រឹះមុននឹងសាងសង់អគារ ។ ក្នុងជំនួបពិភាក្សាការងារជាមួយលោកបណ្ឌិត អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ កាលពីពេលថ្មីៗនេះ លោក Yamada ប្រធានអង្គការសមាគមសហប្រតិបត្តិការកម្ពុជា-ជប៉ុន ដែលបានដឹកនាំវិនិយោគិនជប៉ុនជាង ៤០០ក្រុមហ៊ុនមកកម្ពុជា បានលើកឡើងថា ក្រុមហ៊ុនទាំងនេះមានឯកទេសលើការពិនិត្យដី បង្កើតបាតគ្រឹះមុននឹងសាងសង់ និងយកសំណាកដីទៅធ្វើការពិសោធន៍នៅប្រទេសជប៉ុន ហើយពួកគេមានបំណងចង់ជួយដល់ពលករកម្ពុជាលើជំនាញបច្ចេកទេសនេះ ។ លោក Yamada បានមានប្រសាសន៍ថា ៖« ក្រុមហ៊ុនសំណង់ទាំងនេះបានទទួលពលករខ្មែរ ទៅធ្វើការជាង៣០០នាក់ហើយ នៅឯប្រទេសជប៉ុន ។ ពលករខ្មែរនឹងមានជំនាញពិតប្រាកដខាងផ្នែកសំណង់ បន្ទាប់ពីពួកគេទៅធ្វើកម្មសិក្សានៅជប៉ុន ហើយនាំជំនាញនេះមកអភិវឌ្ឍន៍វិស័យសំណង់នៅកម្ពុជាវិញ»។

លោកបណ្ឌិត អ៊ិត សំហេង រដ្ឋ មន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានមានប្រសាសន៍ បច្ចុប្បន្ននេះវិស័យសំណង់របស់កម្ពុជា កំពុងមានការរីកចម្រើនជាខ្លាំង ក្នុងនោះមានក្រុមហ៊ុនសំណង់របស់ជប៉ុន បានរួមចំណែកក្នុងការអភិវឌ្ឍលើវិស័យនេះផងដែរ ។ លោករដ្ឋមន្ត្រី មានប្រសាសន៍ថា ៖«សំណង់មិនអាចប្រហែសបានទេ ប៉ះពាល់ដល់អាយុជីវិតរបស់មនុស្ស បើបច្ចេកទេសមិនល្អគឺមានហានិភ័យដល់ជីវិតរបស់មនុស្ស ដូច្នេះត្រូវយកចិត្តទុកដាក់ខ្ពស់ក្នុងរៀបចំដំណើរការសាងសង់ឲ្យទៅតាមបទដ្ឋានស្តង់ដាសំណង់ »។

ប្រធានគ្រប់គ្រងទូទៅនៃសមាគមសាងសង់កម្ពុជា លោក ជីវ សៀវផេង បានមានប្រសាសន៍ថា ការបង្កើតបាតគ្រឹះសំណង់នេះក្នុងរយៈពេលកន្លងមក ក្រុមហ៊ុនក្នុងស្រុកបានសហការជាមួយក្រុមហ៊ុនបរទេសដើម្បីធ្វើការងារនេះ ហើយបើគម្រោងអគារខ្ពស់ៗ គឺក្រុមហ៊ុនបរទេសជាអ្នកធ្វើតែម្តង »។ លោកបន្តថា ៖« មុននឹងចាប់ផ្តើមសាងសង់គេត្រូវយកដីទៅពិសោធន៍មើលសិនថា តើយើងត្រូវបុកគ្រឹះជម្រៅប៉ុន្មានម៉ែត្រ ទំហំគ្រឹះប៉ុន្មានទើបអាចទ្រអគារបានមួយបាន ហើយទាក់ទងនឹងជំនាញនេះ សម្រាប់កម្ពុជានៅមានកម្រិតនៅឡើយ »។ បើតាមលោកជីវ សៀវផេង នៅថ្ងៃអនាគតបើកម្ពុជា នឹងសម្បូរធនធានមនុស្សដែលមានសមត្ថភាពគ្រប់គ្រាន់លើវិស័យនេះ ដែលអាចឱ្យកម្ពុជាទទួលបានចំណែកទីផ្សារ និងអាចបំពេញតម្រូវការបាន ៕

## ពលរដ្ឋកម្ពុជា៣នាក់ត្រូវភាគីថៃដោះលែងឱ្យវិលមកស្រុកកំណើតវិញ

http://www.rasmeinews.com/ February 11, 2019, 7:28 AM

ដោយៈបាយ័ន/ឧត្តរមានជ័យៈកាលពីថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៩ នៅច្រកអន្តរជាតិជាំស្រងាំក្នុងស្រុកអន្លង់វែងខេត្តឧត្តរមានជ័យមានការប្រគល់ និងទទួលពលរដ្ឋកម្ពុជាចំនួន៣នាក់ពីភាគីថៃ។ បន្ទាប់ពីពួកគេទាំង៣នាក់បានឆ្លងដែនចូលដោយខុសច្បាប់ទៅកាប់ឈើគ្រញូងក្នុងទឹកដីថៃ ហើយត្រូវបានថៃចាប់យកទៅដាក់ពន្ធនាគារនៅខេត្តស៊ីសាកេតចាប់ពីពេលនោះមក។

សមត្ថកិច្ចនគរបាលប្រចាំច្រកអន្តរជាតិជាំស្រងាំបាននិយាយថាពលរដ្ឋកម្ពុជាដែលត្រូវបានភាគីថៃបញ្ជូនមកស្រុកកំណើតវិញ បន្ទាប់ពីដោះលែងពីពន្ធនាគារគឺមានទី១ឈ្មោះ ប៉ូវ កប ភេទប្រុស៣០ឆ្នាំ ត្រូវបានចាប់ខ្លួននៅថ្ងៃទី៧ខែកុម្ភៈឆ្នាំ២០១៧កន្លងទៅពីបទឆ្លងដែនកាប់ឈើគ្រញូង។ ទី២ឈ្មោះ សំ រឹម ភេទប្រុស អាយុ៣៧ឆ្នាំ ត្រូវបានចាប់ខ្លួនថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៧ពីបទឆ្លងដែនកាប់ឈើគ្រញូង។ ទី៣ឈ្មោះ ឡាយ អឿន ភេទប្រុស អាយុ៣៩ឆ្នាំត្រូវចាប់ខ្លួននៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៧ ពីបទឆ្លងដែនកាប់ឈើគ្រញូង។ជនទាំងបីចូលតាមច្រកទឹកជប់ហើយ

យកទៅដាក់ពន្ធនាគារនៅខេត្តស៊ីសាកេតប្រទេសថៃ។ សមត្ថកិច្ចបានបន្តថាចាប់តាំពីថ្ងៃចាប់ខ្លួនរហូតដល់ទី១០ខែកុម្ភៈ ឆ្នាំ២០១៩នេះជនទាំង៣នាក់ត្រូវបានថៃដោះលែងឱ្យមានសេរីភាពរួចបានប្រគល់មកឱ្យអាជ្ញាធរកម្ពុជាដើម្បីវិលត្រឡប់មកកាន់លំនៅស្ថានវិញ។ ក្រោយពីទទួលពីភាគីថៃរួចមកខាងសមត្ថកិច្ចកម្ពុជាបានអប់រំណែនាំនិងឱ្យធ្វើកិច្ចសន្យាបញ្ឈប់ការឆ្លងដែនដោយខុសច្បាប់បែបនេះតទៅទៀត៕S/

## ដោយសារតែលោកឧត្តមសេនីយ៍ត្រីប៉ុកសុផល ត្រូវរ៉ូវគ្នាជាមួយមេឈ្មួញឈើទើប ពលករម្នាក់ក្នុងចំណោមគ្នាបីនាក់ត្រូវបានសមត្ថកិច្ចថៃចាប់ខ្លួន

https://www.facebook.com/cpnnews.info/ សារព័ត៌មាន ចក្រភពព័ត៌មាន CPN News 11-02-2019

ឧត្តរមានជ័យៈ ប្រភពពីសង្កាត់អូរស្មាច់ក្រុងសំរោងខេត្តឧត្តរមានជ័យបានអោយដឹងនៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៩នេះមកថា លោក ឧត្តមសេនីយ៍ត្រី ប៉ុក សុផល មេបញ្ជាការវរៈការពារព្រំដែន៤០២នៃយោធភូមិភាគទី៤ បានត្រូវរ៉ូវគ្នាជាមួយពួកឈ្មួញរកស៊ីឈើប្រណិតបានគាងគរពលករឆ្លងដែនចូលកាប់ឈើក្រញ៉ូងតាមច្រក់ភ្នំតាថងជាកន្លែងឈរជើងរបស់វរព្រំដែនគោកលេខ៤០២ចំណុច២៧៨ គ៣ ស្ថិតនៅសង្កាត់អូរស្មាច់ក្រុងសំរោងខេត្តឧត្តរមានជយ័។ ជាក់ស្តែងកាលពីយប់ថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១៩ នៅវេម៉ោង៨:45នាទី ពលករមួយនាក់ក្នុងចំណោមពលករ៣នាក់ត្រូវបានយោធាថៃចាប់ខ្លួន រួមទាំងវត្ថុតាងឈើក្រញូងមួយចំនួនស្ថិតនៅក្នុងស្រុកកាប់ជើង ខេត្តសុរិនប្រទេថៃ ជាប់ព្រំប្រទល់ សង្កាត់អូស្មាច់ក្រុងសំរោងខេត្តឧត្តរមានជ័យ។ ពលករដែលត្រូវបានចាប់ខ្លួនពីសំណាក់សមត្ថកិច្ចចំរុះរបស់ថៃមានឈ្មោះហម ពេជ្រ ភេទប្រុសអាយុ ៤៧ឆ្នាំរស់នៅ ភូមិអភិវឌ្ឍន៍សង្កាត់អូស្មាច់ក្រុងសំរោង។

ប្រភពពីសមត្ថិច្ចបានអោយដឹងថាលោកប៉ុក សុផលគឺអ្នកនៅពីក្រោយខ្នងពួកឈ្មួញឈើក្រញូងឆ្លងដែន និងដែលបានគាងគរពលករឆ្លងដែនទៅកាប់ឈើក្រញូង ច្រើនឆ្នាំមកហើយនៅក្នុងតំបន់ចាប់ពីបង្គោលស៊ីម៉ាលេខ១៣រហូតនៅក្នុងទឹសទី៣ទាំងមូលតែម្តង។ ដែលសកម្មភាពចរាចរណ៍អត់ឈប់ឈរជាច្រើនឆ្នាំមកនេះ គឺដោយសារតែមានការត្រូវរ៉ូវគ្នាជាមួយកងកំលាំងឈរជើងខាងលើជាពិសេស នៅតំបន់វរៈការពារព្រំដែន៤០២ ដែលបច្ចុប្បន្ន គ្រប់គ្រងដោយលោកឧត្តមសេនីយ៍ត្រីប៉ុកសុផល។ជុំវិញករណីខាងលើក្រុមការងារយើងមិនអាចស្វែងរកសុំការបំភ្លឺពីលោកឧត្តមសេនីយ៍ត្រីប៉ុកសុផលបានទេ ព្រោះស្វែងរកការទំនាក់ទំនងមិនទាន់បាន៕ ដោយៈសាន់រិទ្ធ

# ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៩

## សង្គមស៊ីវិលរកឃើញថាអំពើហិង្សាផ្លូវភេទលើកុមារីនៅតែជាបញ្ហាប្រឈម

https://wmc.org.kh/ ថ្ងៃអង្គារ ទី១២ ខែកុម្ភៈ ឆ្នាំ២០១៩ កែវ សុខា

ភ្នំពេញ៖ តាមរយៈកិច្ចសន្ទនាថ្នាក់ជាតិ ស្តីអំពី«អំពើហិង្សាផ្លូវភេទលើកុមារី»ក្រុមអង្គការសង្គមស៊ីវិលបង្ហាញថា ការប្រើអំពើហិង្សាផ្លូវភេទ ការបំពានរូបរាងកាយកុមារី និងកង្វះយន្តការក្នុងការដោះស្រាយនៅតែជាបញ្ហាប្រឈមនៅឡើយ ខណៈមន្ត្រីរដ្ឋាភិបាលលើកឡើងថា អាជ្ញាធរពាក់ព័ន្ធបាន នឹងកំពុងដោះស្រាយបញ្ហានេះដោយមិនបានព្រងើយកន្តើយឡើយ។ ការលើកឡើងនេះធ្វើឡើងនៅក្នុងកិច្ចសន្ទនាមួយរវាងមន្ត្រីរាជរដ្ឋាភិបាល និងក្រុមអង្គការសង្គមស៊ីវិលដែលធ្វើការងារពាក់ព័ន្ធនឹងបញ្ហាកុមារនៅថ្ងៃទី១១ កុម្ភៈនេះ នៅសណ្ឋាគារសាន់វេ ក្រុងភ្នំពេញ។

## ឧត្តមសេនីយ៍ឯក ប៉ុល ភិធេយ្យ៖ សកម្មភាពជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទនៅកម្ពុជា នៅតែជាបញ្ហាត្រូវយកចិត្តទុកដាក់ខ្ពស់

https://kmnnews.com/kmnnews/ ចេញផ្សាយ ថ្ងៃទី 11 ខែ កុម្ភៈ ឆ្នាំ 2019

**ភ្នំពេញ៖** ឧត្តមសេនីយ៍ឯក ប៉ុល ភិធេយ្យ ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានលើកឡើងថា សកម្មភាពជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារនៅកម្ពុជានៅតែជាបញ្ហាដែលត្រូវយកចិត្តទុកដាក់រួមគ្នា ដើម្បីប្រយុទ្ធប្រឆាំងក្នុងនោះរួមមាន បញ្ហាពេស្យាចារ ជួញដូរព្រហ្មចារី អាជីវកម្មផ្លូវភេទ ការពពោះជំនួស និងការជួញដូរសរីរាង្គជាដើម ។ លោកឧត្តមសេនីយ៍ឯក ប៉ុល ភិធេយ្យ បានថ្លែងបែបនេះធ្វើឡើងខណៈដែលលោកបានអញ្ជើញជាតំណាងនាយឧត្តមសេនីយ៍សន្តិបណ្ឌិត នេត សាវឿន អគ្គស្នងការនគរបាលជាតិ ក្នុងពិធីបើកវគ្គបណ្តុះបណ្តាល ស្តីពីយុទ្ធវិធីប្រតិបត្តិការ និងការប្រើប្រាស់អាវុធដល់នគរបាលរាជធានី នៅព្រឹកថ្ងៃទី១១ កុម្ភៈ ឆ្នាំ២០១៩នេះ នៅនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ។

ឧត្តមសេនីយ៍ឯក ប៉ុល ភិធេយ្យ បានបន្ថែមថា ការធ្វើចំណាកស្រុកស្វែងរកការងារនៅក្រៅប្រទេសដោយខុសច្បាប់ក៏នៅតែជាបញ្ហាប្រឈមដូចជា សុំទាន នេសាទសមុទ្រ បំរើការងារតាមផ្ទះ និងអាពាហ៍ពិពាហ៍ផ្ទុយពីធន្ទះ។ ក្នុងនោះបុរសត្រូវបានគេនាំចេញទៅធ្វើការងារខុសច្បាប់នៅប្រទេសថៃ ចិន ម៉ាឡេស៊ី ឥណ្ឌូនេស៊ី សឹង្ហបុរី ប៉ាគីស្ថាន សូម៉ាលី ជប៉ុននិង អារ៉ាប់ប៊ីសាអូឌីតជាដើម ។ វគ្គបណ្តុះបណ្តាល នៅពេលនេះមានគោលបំណងសំខាន់គឺដើម្បីពង្រឹងសមត្ថភាពមន្ត្រីជំនាញបន្ថែមទៀតក្នុងពេលប្រតិបត្តការបង្ក្រាបបទល្មើសលើបច្ចេកទេស ចាប់ជនសង្ស័យ ការកាពារខ្លួន និងការប្រើប្រាស់អាវុធ រួមទាំងការសង្គ្រោះបឋមពេលដែលមានការទទួលរងរបួស ។ តាមរយៈវគ្គបណ្តុះបណ្តាលនេះនឹងផ្តល់នៅបទពិសោធន៍ និងចំណេះដឹងបន្ថែមទៀតសំដៅរកភាពរីកចម្រើនក្នុងការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មលើផ្លូវភេទលើស្ត្រី និងកុមារ ។

សូមជម្រាបថា វគ្គបណ្តុះបណ្តាលនេះមានរយៈពេល៥ថ្ងៃចាប់ពីថ្ងៃទី១១ ដល់ថ្ងៃទី១៥ ខែកុម្ភៈ ដោយមានការចូលរួមពីសំណាក់អង្គការចំនួនពីរ គឺអង្គការមេត្រីអន្តរជាតិ (AIM SWAT) និង(SUMMIT CHURCH) ដែលមានគ្រូឧទ្ទេសនាមដែលមានបទពិសោធខ្ពស់មកពីសហរដ្ឋអាមេរិក ព្រមទាំងមានការចូលរួមពីសិក្ខាកាមជានាយ នាយរងនគរបាល មកពីនាយកដ្ឋាន និងស្នងការដ្ឋានរាជធានីភ្នំពេញ ៕

## ប្រជាពលរដ្ឋគ្រោងផ្តិតមេដៃប្តឹងលោក ខឹម ចិត្រា មេប៉ុស្តិ៍ថ្មីច្រកទ្វារអន្តរជាតិប៉ោយប៉ែត និងឈ្មោះ ចិន មេអន្តោប្រវេសន៍ថៃ ពីបទចាប់ជម្រិត និងប្រព្រឹត្តអំពើពុករលួយ

https://www.facebook.com/neakmeasnews/ ថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៩ ដោយ ជីវ័ន្ត គេហទំព័រ នាគមាស

(ក្រុងប៉ោយប៉ែត): លោក ខឹម ចិត្រា មេប៉ុស្តិ៍ច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត ដែលទើបឡើងកាន់តំណែងថ្មីបានបង្កើនអំពើពុករលួយយ៉ាងខ្លាំង អំពើពុករលួយទាំងនោះមានដូចជាៈ ១- ជម្រិតយកប្រាក់ពីប្រជាពលរដ្ឋម្នាក់ៗ ៥០ បាទ ឬ ស្មើនឹង៧០០០រៀល នៅពេលវាយត្រាប័ណ្ណព្រំដែនចេញពីប្រទេសកម្ពុជា ឆ្លងទៅប្រទេសថៃ តាមច្រកប៉ោយប៉ែត។ ២-ធ្វើលិខិតបញ្ជាក់មួយសន្លឹក២០០បាទ សម្រាប់ប្រជាពលរដ្ឋនៅប៉ោយប៉ែត ដើម្បីថតកាតចូលថៃ ៣-ធ្វើលិខិតបញ្ជាក់ ១សន្លឹក២០០បាទ និង ៤០០បាទផ្សេងទៀត សម្រាប់ថតកាតចូលប្រទេសថៃ ចំពោះប្រជាពលរដ្ឋមកពីខេត្តផ្សេងៗ ក្រៅពីក្រុប៉ោយប៉ែត ៤-ជម្រិតយកលុយ៣០០បាទក្នុង១ខែ ពីអ្នករត់ម៉ូតូឌុបនៅគល់ស្ពានមិត្តភាពកម្ពុជាថៃ សូមបញ្ជាក់ថាការជម្រិតយកលុយនេះ ជាអំពើខុសច្បាប់យ៉ាងធ្ងន់ធ្ងរ ដែលត្រូវមានទោសជាប់គុកពីបទឧក្រិដ្ឋ ដែលមានចែងនៅក្នុងច្បាប់ស្តីពីប្រឆាំងអំពើពុករលុយ ឈ្មោះ ខឹម ចិត្រានេះជាចោរឧក្រិដ្ឋកម្មឆ្លងដែន ចាប់ជម្រិត ពលករ កម្មករ អាជីវករ ដែលបានឆ្លងដែន តាមច្រក១នេះ ពីព្រោះវាបានទៅចចារជាមួយមេអន្តោប្រវេសន៍ឈ្មោះ ចិន ដើម្បីជួយសហការគ្នាធ្វើជាចោរចាប់ជម្រិតប្រជាពលរដ្ឋខ្មែរ។ រដ្ឋាភិបាល ខ្មែរ និងរដ្ឋាភិបានថៃមិនបានអនុ

ញាត អោយឈ្មោះ ខឹម ចិត្រា និង ឈ្មោះ បិនយកប្រាក់ពីប្រជាពលរដ្ឋខ្មែរឡើយ ពួកគេទាំងពីរនាក់ជាមេចោរចាប់ជម្រិតអន្តរជាតិយកលុយដាក់ហោប៉ៅផ្ទាល់ខ្លួន និងបក្សពួកតែប៉ុណ្ណោះ។ លេខទូរស័ព្ទ 0977007424/ 077997095

## ជួយស៊ើជាបន្ទាន់សំរាប់ពលករខ្មែរនៅប្រទេសថៃ

https://www.facebook.com/ 11-02-2019 ទឹកចិត្ត-ពលករ-ឆ្លងដែន

យោងតាមសេចក្តីប្រកាសរបស់ក្រសួងការងារថៃនៅខេត្តឈាងម៉ៃ នៅប្រទេសថៃ បានចេញសេចក្តីប្រកាសនៅថ្ងៃច័ន្ទ ទី11 ខែកុម្ភៈ ឆ្នាំ2019 បានឲ្យដឹងថា..មានថៅកែថៃនិងពលករបរទេសមួយចំនួនបានចាញ់បោកសារពត៌មានមួយចំនួនបានបង្ហោះថា នៅប្រទេសថៃមានការបើកចុះឈ្មោះធ្វើប័ណ្ណធ្វើការឲ្យអ្នកថ្មី.ដូច្នេះហើយសូមបងប្អូនពលករខ្មែរដែលធ្វើការនៅប្រទេសថៃកុំជឿរសារពត៌មានបែបនេះអោយសោះ ប្រយ័ត្នចាញ់បោកជនខិលខូចមួយចំនួននេះឲ្យសោះប្រយ័ត្នអស់លុយអត់ប្រយោជ៏។ នៅរាល់ថ្ងៃនេះមិនមានការបើកចុះឈ្មោះអ្នកថ្មីអ្វីឡើយ.នឹងបងប្អូនពលករបរទេសដែលមានបែអនុញ្ញាតធ្វើការអស់អាយុ នៅថ្ងៃទី31-3-2020 សូមបងប្អូនរងចាំសេចក្តីប្រកាសពីក្រសួងការងារថៃសិន កុំទាន់ជ្រួលច្របល់ជឿរសារពត៌មានអ្វីឡើយនៅពេលនេះមិនមានការបើកចុះឈ្មោះអ្វីឡើយ។

បើបងប្អូនពលរដ្ឋខ្មែរ និងពលករខ្មែរទាំងអស់មានការឆ្ងល់ក្នុងករណីនេះ សូមទូស័ព្ទសួរពត៌មានបន្ថែមពីក្រសួងការងារថៃ ប្រចាំខេត្តឈាងម៉ៃបាន លេខទូរស័ព្ទ 0531129114 រឺ Line.ID.@doecmi។

## ១រយកោដិសំឡេង៖ អំពើហិង្សាលើស្ត្រីកំពុងកើតមានក្នុងទម្រង់បែបថ្មីនៃសម័យបច្ចេកវិទ្យាទំនើប

http://km.rfi.fr/ ដោយ អេង គីមហុង10/02/2019

បណ្ដាអង្គការសង្គមស៊ីវិលនៅរសៀលនេះនឹងរៀបចំយុទ្ធនាការ ១រយកោដិសំឡេងលើកទី៦ ដើម្បីបញ្ចប់អំពើហិង្សាលើស្ត្រី។ អំពើហិង្សាលើស្ត្រីត្រូវបានអង្គការសង្គមស៊ីវិលមើលឃើញថា កំពុងកើតមានឡើងនៅក្នុងទម្រង់បែបថ្មីនៃសម័យបច្ចេកវិទ្យាទំនើប ខណៈអំពើហិង្សាដោយកម្លាំងមានការថយចុះ។ នេះបើតាមអង្គការយេឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា។

អំពើហិង្សាលើស្ត្រីនៅក្នុងរង្វង់គ្រួសារបានធ្លាក់ចុះ ប៉ុន្តែអំពើហិង្សាលើស្ត្រីបានប្តូរទម្រង់បែបថ្មី ដែលទម្រង់ថ្មីនេះកំពុងតែកើតមានតាមប្រព័ន្ធអនឡាញ ជាពិសេសបណ្ដាញសង្គមហ្វេសបុកតែម្តង។ ដាក់ស្លែង ការបង្ហោះ និងថតរូបស្ត្រីដោយគ្មានការអនុញ្ញាត ហើយធ្វើការចែកចាយបន្តលើបណ្ដាញសង្គមតាមរយៈប្រើប្រាស់ពាក្យសម្តីលេងសើចមាក់ងាយ ឬគម្រាមកំហែង ជាដើមគឺសុទ្ធតែរាប់បញ្ចូលទៅក្នុងទម្រង់អំពើហិង្សាបែបថ្មី។ ក្នុងនោះ ករណីជួលស្ត្រីឲ្យពពោះជំនួស ក៏ត្រូវបានចាត់ទុកជាទម្រង់បែបថ្មីនៃអំពើហិង្សាដែរ ខណៈសង្គមស៊ីវិលកំពុងធ្វើការស្រាវជ្រាវនិងពិភាក្សាបន្ថែមលើករណីពពោះជំនួសនេះ ថាតើវាស្ថិតនៅក្នុងការជួញដូរស្ត្រីឬយ៉ាងណា។

អ្នកស្រី សុវណ្ណ រដ្ឋវត្តី ប្រធានកម្មវិធីអភិវឌ្ឍន៍សមត្ថភាពនៃអង្គការយេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា បានថ្លែងប្រាប់វិទ្យុបារាំងអន្តរជាតិនៅថ្ងៃអាទិត្យនេះថា ការផ្តល់និយមន័យចំពោះអំពើហិង្សាលើស្ត្រី តាំងពីអតីតកាលនិងបច្ចុប្បន្ន គ្មានការប្រែប្រួលទៅតាមការវិវត្តនៃសង្គមទេ។ គេចាត់ទុកថាជាអំពើហិង្សាលើស្ត្រី លុះត្រាតែជាការ វាយ ដំ ច្រំ ធាក់។ ហើយនេះគឺជារឿងព្រួយបារម្ភមួយកម្រិតទៀតនៅពេលដែលសង្គមមិនបានចាប់អារម្មណ៍ទម្រង់ថ្មីនៃអំពើហិង្សាដែលកំពុងកើតមាន។ បន្ថែមលើនេះ ការមិនផ្តល់ឱកាសនិងសិទ្ធិសេរីភាពស្មើគ្នារវាងស្ត្រីនិងបុរស ក៏ត្រូវបានរាប់ជាអំពើហិង្សាដែរ។ ការលើកឡើងពីអំពើហិង្សាទម្រង់ថ្មីដូច្នេះ ត្រូវបានធ្វើឡើងក្នុងឱកាសដែលសង្គមស៊ីវិលកំពុងរៀបចំយុទ្ធការ១កោដិសំឡេង ដើម្បីបញ្ចប់អំពើហិង្សាលើស្ត្រី។ ជាយុទ្ធនាការលើកទី៦ ដែលរៀបចំឡើងក្រោមប្រធានបទ ពីយុទ្ធនាការ ក្លាយជារស់នៅប្រចាំថ្ងៃដើម្បីក្លាយជាមនុស្សម្នាក់ដែលបញ្ចប់អំពើហិង្សាលើស្ត្រី។ យុទ្ធនាការ

នេះ បានបង្ហាញពីចាប់ផ្ដើមនៃការផ្លាស់ប្ដូរផ្នត់គំនិតមួយសម្រាប់បុរស ដែលត្រូវសួរខ្លួនឯងថា ទង្វើណាមួយជាអំពើហិង្សា ខណៈស្ត្រីនៅតែជាជនរងគ្រោះទីមួយនៃអំពើហិង្សាបុរស។ នេះបើតាម អ្នកស្រី សុវណ្ណ វឌ្ឍវត្តី។

ផ្អែកតាមរបាយការណ៍ដោយឡែករបស់អង្គការលីកាដូ រយៈពេល ១០ខែ ឆ្នាំ២០១៨ ករណីអំពើហិង្សាលើស្ត្រីមានចំនួន ៥៨ករណី បណ្ដាលឱ្យជនរងគ្រោះជាស្ត្រី ១០នាក់ស្លាប់ ហើយការរំលោភសេពន្ទវៈលើស្ត្រី និងកុមារីមានចំនួន ១២៧ករណី បណ្ដាលឱ្យជនរងគ្រោះ៨ នាក់ស្លាប់ ក្នុងនោះក្មេងស្រីមានចំនួន៣នាក់៕

## បង់ក្លាដែស ឃាត់ខ្លួនរ៉ូហ៊ីងយ៉ាជាច្រើននាក់ដែលព្យាយាមទៅប្រទេស ម៉ាឡេស៊ី

https://www.postkhmer.com/ Publication date 11 February 2019 | 14:30 ICT

**ទីប្រជុំជនតេកណាហ្វៈ** ក្រុមមន្ត្រីបង់ក្លាដែស បាននិយាយថា កងកម្លាំងសន្តិសុខបង់ក្លាដែស បានឃាត់ខ្លួនជនភៀសខ្លួនរ៉ូហ៊ីងយ៉ា ៣០ នាក់មិនឲ្យគេរត់ពន្ធទៅកាន់ម៉ាឡេស៊ី ដោយធ្វើដំណើរតាមទូក ខណៈការភ័យខ្លាច បានកើនឡើងថា សមុទ្រជាច្រើនស្ងប់ អាចធ្វើឲ្យអ្នកដែលរស់នៅតាមជំរំកខ្វក់ខ្លះព្យាយាមធ្វើដំណើរទៅប្រទេសនៅតំបន់អាស៊ីអាគ្នេយ៍។

ក្រុមមន្ត្រីបាននិយាយថា អ្នកជួញដូរមនុស្ស ២ នាក់ ដែលគេសង្ស័យ ត្រូវគេឃាត់ខ្លួននៅក្នុងកិច្ចប្រតិបត្តិការរបស់កងកម្លាំងការពារព្រំដែន (BGB) នៅក្នុងស្រុកបាហ្សារកាលពីល្ងាចថ្ងៃព្រហស្បតិ៍។ ជនរ៉ូហ៊ីងយ៉ាប្រហែល ៧៤ ម៉ឺននាក់ បានភៀសខ្លួនពីមីយ៉ាន់ម៉ាទៅបង់ក្លាដែសបន្ទាប់ពីការបង្ក្រាបរបស់យោធានៅខែសីហា ឆ្នាំ ២០១៧។ ពួកគេបានចូលរួមជាមួយជនភាគតិចមូស្លីមប្រហែល ៣០ ម៉ឺននាក់នៅក្នុងប្រទេសនេះស្រាប់ ជាទីដែលពួកគេត្រូវកំណត់ឲ្យនៅតាមជំរំនានាដែលនាំឲ្យបង់ក្លាដែសកំណត់ធនធានរបស់ខ្លួននោះ។

BGB និយាយថា ស្ត្រី ១៧ នាក់ ក្មេង ៦ នាក់ និងបុរស ៧ នាក់ ត្រូវបានឃាត់ខ្លួននៅលើឆ្នេរ ១ នៅក្បែរទីប្រជុំជនតេកណាហ្វដែលមានព្រំប្រទល់ជាប់រដ្ឋរ៉ាក់ឃីនដែលហែកហួរដោយហិង្សានៅមីយ៉ាន់ម៉ា។ នេះគឺជាលើកទី ៣ ហើយចាប់តាំងពីខែវិច្ឆិកាដែលជនរ៉ូហ៊ីងយ៉ាត្រូវចាប់បានខណៈព្យាយាមទៅឲ្យដល់ម៉ាឡេស៊ីភាគច្រើនកាន់មូស្លីម។ ទូកជាច្រើនគ្រឿង ក៏ត្រូវបានចាប់ នៅពេលព្យាយាមចាកចេញពីប្រទេស មីយ៉ាន់ម៉ា។ លោកវរសេនីយ៍ទោ Asadud Zaman Chowhury បានថ្លែងប្រាប់ AFP ថា ជនភៀសខ្លួនរ៉ូហ៊ីងយ៉ា ៣០ នាក់ចាញ់បោកអ្នកជួញមនុស្សនៅក្រុងបាហ្សារ៕ AFP/PSA

## ស្វាមីភរិយាសិង្ហបុរីមួយគូត្រូវកាត់ទោសដាក់ពន្ធនាគារ ក្រោយបង្ខំឲ្យអ្នកបម្រើជាជនជាតិមីយ៉ាន់ម៉ា «ផឹកទឹកជូតផ្ទះ» និងប្រព្រឹត្តអំពើឃោរឃៅជាច្រើនទៀតលើនាង

http://www.freshnewsasia.com/index.php/en/internationalnews/ 2019-02-11-11

**(សិង្ហបុរី)៖** តុលាការសិង្ហបុរីបានផ្តន្ទាទោសគូស្វាមីភរិយាមួយគូ ដែលបានបង្ខំឲ្យស្ត្រីអ្នកបម្រើតាមផ្ទះជាជនជាតិមីយ៉ាន់ម៉ាមួយរូប ងូតទឹកក្តៅស្រោចខ្លួន រួចបោចសក់នាង ហើយបញ្ច្រកទឹកជូតសម្អាតផ្ទះឲ្យនាងផឹកថែមទៀតនោះ ឲ្យជាប់ពន្ធនាគារម្នាក់ ០៣ឆ្នាំ និងម្នាក់ទៀត ០៦សប្តាហ៍ ព្រមទាំងពិន័យជាប្រាក់ ៩ពាន់ដុល្លារសិង្ហបុរី ឬស្មើនឹងជាង ៦.៦ពាន់ដុល្លារអាមេរិកផងដែរ។ នេះបើតាមការចេញផ្សាយដោយ Channel News Asia នាល្ងាចថ្ងៃចន្ទ ទី ១១ ខែកុម្ភៈ ឆ្នាំ២០១៩។

គូស្វាមីភរិយាខាងលើនេះ បានទទួលរងការចោទប្រកាន់ដោយតុលាការសិង្ហបុរី ក្រោយពីបានរួមគ្នាប្រព្រឹត្តទង្វើសាហាវព្រៃផ្សៃខាងលើនេះ ចាប់តាំងពីឆ្នាំ២០១៦ ទៅលើអ្នកបម្រើក្នុងផ្ទះរបស់ខ្លួនដែលជាស្ត្រីជនជាតិមីយ៉ាន់ម៉ាមានឈ្មោះថា ព្យូព្យូ ម៉ា (Phyu Phyu Mar ដែលបានធ្វើឲ្យនាងបន្សល់ទុកស្លាកស្នាមរបួសពាសពេញខ្លួនជាភស្តុតាងជាក់ស្តែង។

គួរបញ្ជាក់ថា នៅចំពោះមុខតុលាការសិង្ហបុរី គូស្វាមីភរិយាមួយគូនេះបានសារភាពថា ពួកគេពិតជាមិនពេញចិត្តនោះឡើយ ចំពោះការបំពេញការងារយឺតយ៉ាវរបស់ Mar ប៉ុន្តែសម្រាប់អ្នកដែលបង្កហិង្សាខ្លាំងជាងគេទៅលើ Mar នោះគឺស្ត្រីជាភរិយាអាយុ ៣៩ឆ្នាំ ដែលត្រូវបានតុលាការផ្តន្ទាទោសដាក់ពន្ធនាគារ ០៣ឆ្នាំ ខណៈប្តីនាងដែលមានអាយុ ៤៤ឆ្នាំ ត្រូវជាប់គុកតែ ០៦សប្តាហ៍ប៉ុណ្ណោះ។

តុលាការសិង្ហបុរីបានកាត់សេចក្តីថា ទោះបីជា Mar មានភាពយឺតយ៉ាវក្នុងបំពេញការងារក្តី ក៏ប្តីប្រពន្ធទាំងពីរនាក់នេះ គ្មានសិទ្ធិក្នុងការធ្វើទារុណ្ណកម្មលើរូបរាងកាយនាងនោះដែរ។ ក្រៅពីទារុណ្ណកម្ម Mar ក៏ត្រូវបានគេបង្អត់អាហារ និងមិនបើកប្រាក់ខែឲ្យថែមទៀត។ ដោយឡែករឿងរ៉ាវនៃទារុណ្ណកម្មនេះត្រូវបានបែកធ្លាយ ក៏ព្រោះស្ត្រីជាប្រពន្ធបាននាំអ្នកបម្រើឈ្មោះ Mar ទៅកាន់ហាងសាឡនរបស់ខ្លួន ហើយអ្នកបម្រើក្នុងហាងសាឡនានោះបានសួរនាំពីអាការៈរបស់ Mar រួចសម្រេចក៏ប្តឹងទៅសមត្ថកិច្ចសង្ហបុរីតែម្តង ពីអំពើឃោឃៅដែលថៅហ្វាយស្រីខ្លួន បានប្រព្រឹត្តលើអ្នកបម្រើជនជាតិមីយ៉ាន់ម៉ានោះ៕

# ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៩

## សិក្ខាសាលាលើកទី១ក្រោមប្រធានបទ ‘ការជួញដូរមនុស្សនាសម័យទំនើបប្រារព្ធធ្វើឡើងក្រោមកិច្ចសហការពីប្រទេសអង់គ្លេស

http://cambodiapolice.com/policekh/ 10:05 am 13 កុម្ភៈ 2019

ភ្នំពេញ៖ ឯកឧត្តម ឧត្តមសេនីយ៍ទោ ប៉ាក់ យូលាង ប្រធានស្តីទី នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនបានលើកឡើងថា សកម្មភាពជួញដូរមនុស្សនិងអាជីវកម្មផ្លូវភេទលើស្ត្រីនិងកុមារនៅកម្ពុជានៅតែជាបញ្ហាដែលត្រូវយកចិត្តទុកដាក់រួមគ្នាដើម្បីប្រយុទ្ធប្រឆាំងក្នុងនោះរួមមាន បញ្ហាពេស្យាចារ ជួញដូរព្រហ្មចារី អាជីវកម្មផ្លូវភេទ ការពពោះជំនួសនិងការជួញដូរសរីរាង្គជាដើម។ មានប្រសាសន៍ខណៈដែលឯកឧត្តម ឧត្តមសេនីយ៍ទោ ប៉ាក់ យូលាង ប្រធានស្តីទី នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន តំណាង អោយឯកឧត្តមនាយឧត្តមសេនីយ៍សន្តិបណ្ឌិតនេត សាវឿន អគ្គស្នងការនគរបាលជាតិ អញ្ជើញជាអធិបតីភាព ក្នុងកម្មវិធីសិក្ខាសាលាស្តីពី ‘ការជួញដូរមនុស្សនាសម័យទំនើប’ នៅព្រឹកថ្ងៃទី១៣ កុម្ភៈ ឆ្នាំ២០១៩នេះ ។

ឯកឧត្តម ឧត្តមសេនីយ៍ទោ ប៉ាក់ យូលាង បានបន្ថែមអោយដឹងថា៖ការធ្វើចំណាកស្រុកស្វែងរកការងារនៅក្រៅប្រទេសដោយខុសច្បាប់ក៏នៅតែជាបញ្ហាប្រឈមដូចជា សុំទាន នេសាទសមុទ្រ បំរើការងារតាមផ្ទះនិងអាពាហ៍ពិពាហ៍ផ្ទុយពីធន្ទះ។ឯកឧត្តមបន្ថែមអោយដឹងថាតាមរយៈសិក្ខាសាលាដែលលប្រារព្ធធ្វើនៅពេលនេះកំលាំងនគរបាលប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជននិងបានទទួលនៅបទពិសោធន៍ថ្មីមួយទៀតពីគ្រូឧទ្ទេស ដែលអញ្ជើញមកពីចក្រភពអង់គ្លេសធ្លាប់មានបទពិសោធន៍ក្នុងការងារអនុវត្តប្រយុទ្ធប្រឆាំងបទល្មើសឧក្រិដ្ឋ បទល្មើសជួញដូរមនុស្ស មកចែលរំលែកដល់នគរបាលជំនាញបន្ថែមទៀត។ គួរបញ្ជាក់ថា នេះជាសិក្ខាសាលាលើកទី១ក្រោមកិច្ចសហការរវាងអគ្គស្នងការដ្ឋាននគរបាលជាតិនៃក្រសួងមហាផ្ទៃជាមួយអង្គការក្តីសង្ឃឹម និងយុត្តិធ៌ម (Hope For Justice Organization) ។សិក្ខាសាលាមានរយៈពេលពីរថ្ងៃស្តីពី ‘ការជួញដូរមនុស្សនាសម័យទំនើប’ ចាប់ផ្តើមពីថ្ងៃទី១៣ដល់ថ្ងៃទី១៤ខែកុម្ភៈ មានការចូលរួមពីសំណាក់ សិក្ខាកាមជាស្នងការរង ទទួលបន្ទុកនិងនាយការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន តាមបណ្តាស្នងការដ្ឋានរាជធានី ខេត្ត ដែលកំពុងអនុវត្តផ្ទាល់ក្នុងការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស៕

## លើកអំពូលភ្លើងបង្វិល...ឆក់យកជីវិតពលករម្នាក់លើទឹកដីថៃ

https://kohsantepheapdaily.com.kh/ ថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០១៩ ម៉ោង ១៤:៣៦ ម៉ុត សារុន

ខេត្តបន្ទាយមានជ័យ ៖ សពពលករម្នាក់ត្រូវបានភាគីថៃធ្វើការបញ្ជូនមកឲ្យសាច់ញាតិតាមច្រកទ្វារអន្តរជាតិប៉ោយប៉ែតកាលពីល្ងាចថ្ងៃទី១១ កុម្ភៈ ឆ្នាំ២០១៩ បន្ទាប់ពីឆ្លងចរន្តអគ្គិសនី បណ្តាលឱ្យធក់ជនរងគ្រោះស្លាប់នៅក្រុងបាងកកលើទឹកដីថៃ ។ ជនរងគ្រោះដែលស្លាប់ឈ្មោះធេត ឆាវ ភេទប្រុស អាយុ២៧ឆ្នាំ ជាកម្មករសំណង់ធ្វើការនៅក្រុងបាងកក និងមានស្រុកកំណើតនៅភូមិតាសល់ ឃុំចំណោម ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ ។ តាមប្រភពពីសាច់ញាតិរបស់ជនរងគ្រោះបានប្រាប់ឱ្យដឹងថា ជនរងគ្រោះត្រូវចរន្តអគ្គិសនីធក់ បណ្តាលឱ្យស្លាប់កាលពីម៉ោង៧យប់ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៩ ខណៈជនរងគ្រោះឡើងបង្វិលអំពូលភ្លើងធំមួយនៅកន្លែងធ្វើការទាំងសម្លៀកបំពាក់សើម ។ ក្រោយពីបញ្ជូនសពជនរងគ្រោះមកដល់ច្រកទ្វារអន្តរជាតិប៉ោយប៉ែត សាច់ញាតិបានជួលរថយន្តដឹកបន្តទៅលំនៅដ្ឋានដើម្បីធ្វើបុណ្យតាមប្រពៃណី ៕

## ដំណឹងល្អសំរាប់ពលករដែលធ្វើការនៅក្នុងប្រទេសថៃ

https://www.facebook.com/ ទឹកចិត្ត ពលករ ឆ្លងដែន ថ្ងៃទី 12-02-2019

នៅថ្ងៃច័ន្ទទី11 ខែកុម្ភះ ឆ្នាំ2019 ក្រសួងការងារថៃ បានបើកអង្គប្រជុំជាមួយក្រសួងដែលពាក់ព័ន្ធនិងពលករបរទេសទាំងអស់ ដើម្បីពិភាគសារគ្នាស្តីពីរឿងបើកឱកាសអោយពលករកម្ពុជា ពលករភូមានិងពលករឡាវ ពលករទាំងបីប្រទេសនេះ.ក្នុងអង្គប្រជុំបានអោយឃើញថា.ពលករបរទេសដែលធ្វើការនៅក្នុងប្រទេសថៃដោយស្របច្បាប់ ពលករអាចធ្វើដំណើរទៅលេងស្រុកកំណើតនៅក្នុងឱកាសបុណ្យចូលឆ្នាំខ្មែរខាងមុខនេះ ពលករអាចចេញ-ចូលច្រកព្រំដែនដោយសេរី ចាប់តាំងតែថ្ងៃទី5-4-2019 រហូតដល់ថ្ងៃទី30-4-2019 ពលករទាំងបីប្រទេសនេះត្រូវមានឯកសារស្របច្បាប់ដែលឯកសារពលករមិនទាន់ដាច់អាយុ ពលករអាចចេញ-ចូលច្រកព្រំដែនដោយសេរីដោយមិនបង់ថ្លៃសេវាអ្វីទាំងអស់។

## ឃាត់ខ្លួនពលករខុសច្បាប់ ២៧នាក់ លួចធ្វើការកាត់ដេរ ដោយគ្មានច្បាប់អនុញ្ញាត

http://www.pheaktraofficial.com/ 12-02-2019

ប្រទេសថៃ:កាលពីម៉ោង៣រសៀល ថ្ងៃអង្គារ ទី១២ ខែកុម្ភៈ ឆ្នាំ២០១៩ នេះ កម្លាំងសមត្ថកិច្ចចម្រុះថៃនៃតំបន់បាងប៉ន ទីក្រុងបាងកក ប្រទេសថៃ ធ្វើការចុះត្រួតពិនិត្យទីតាំងកាត់ដេរមួយកន្លែង ស្ថិតនៅក្នុងអាគារបួនជាន់ លេខ ៦៥/៤២ (ច្រក)អេកកាឆៃ៨៦ ស្ថិតនៅក្នុងសង្កាត់ខ្លងបាងប្រាន ខ័ណ្ឌបាងប៉ន ជាយក្រុងបាងកក ប្រទេសថៃ។ ក្នុងការចុះត្រួតទីតាំងកាត់ដេរខាងលើ កម្លាំងសមត្ថកិច្ចថៃ បានរកឃើញពលករខុសច្បាប់សរុបចំនួន ២៧ នាក់ ប្រុស ១៦នាក់ ស្រី ១១នាក់ គ្មានឯកសារស្គាល់ខ្លួនទាំង២៧នាក់ សមត្ថកិច្ចថៃបានធ្វើការឃាត់ខ្លួន ម្ចាស់កន្លែងកាត់ដេរម្នាក់ ឈ្មោះ កុជធាផន ដេធាស៊ិន អាយុ ៦១ ឆ្នាំ សញ្ជាតិថៃ តាមការសាកសួរស្ត្រីជនជាតិថៃខាងលើបានសារភាពថាគាត់បានជួលអាគារនេះបើកកន្លែងកាត់ដេររយៈពេល ៧ខែមកហើយ ដោយជួលពលករបរទេសមកធ្វើការ ដោយគិតប្រាក់ខែ ៩០០០បាត ក្នុងខែ។ បច្ចុប្បន្នម្ចាស់កន្លែងកាត់ដេរខាងត្រូវសមត្ថកិច្ចថៃធ្វើការចោទប្រកាន់ពីបទទទួលពលករបរទេសខុសច្បាប់អោយធ្វើការដោយគ្មានច្បាប់អនុញ្ញាត រួចកសាងសំណុំរឿងដើម្បីចាត់វិធានការតាមច្បាប់។

## ពលករជាច្រើននាក់ ត្រូវបានយោធាថៃចាប់ខ្លួននៅតំបន់ នគបាលវរៈការពារព្រំដែនគោក ៧០២ ក្រោមការគ្រប់គ្រងរបស់វរៈសេនីយ៍ឯក គង់ សុខាន់

https://www.chnchannel.com/ អត្ថបទដោយ Asmatt កាលបរិច្ឆេទ ថ្ងៃទី 13 ខែ កុម្ភៈ ឆ្នាំ 2019

**ឧត្តរមានជ័យៈ** នៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៩នេះ មានសេចក្ដីរាយការណ៍ពីពលរដ្ឋនៅសង្កាត់អូរស្មាច់ ក្រុងសំរោង ខេត្តឧត្តរមានជ័យមកថា រយៈពេលមួយខែកន្លះកមហើយ បើគិតចាប់ពីដើមខែមករា មកដល់ពាក់កណ្ដាលខែកុម្ភៈ ឆ្នាំ២០១៩នេះ នៅតំបន់នគបាលវរៈការពារព្រំដែនគោក លេខ៧០២ ដែលគ្រប់គ្រងដោយលោកវរសេនីយ៍ឯក គង់ សុខាន់ មានពលករកាប់ឈើក្រញូងចំនួន៨នាក់ហើយ ត្រូវយោធាថៃចាប់ខ្លួនបញ្ជូនយកទៅផ្ដន់ទាទោសទៅតាមច្បាប់ប្រទេសថៃ។

ប្រភពច្បាស់ការបានបង្ហើបឱ្យដឹងថា ដើមហេតុ នឹងជាមូលហេតុ នៅពីក្រោយនៃការចាប់ខ្លួន ពលករខ្មែរជាញឹកញាប់ពីសំណាក់យោធាថៃជាញឹកញាប់នោះ គឺមានមេឈ្មួញដុះស្លែម្នាក់ ឈ្មោះ ឈឿង ស័ក្ក បានប្រមូលទិញឈើប្រណិតផ្ដាច់មុខនៅតំបន់ នគបាលវរៈការពារព្រំដែនគោក៧០២ ដែលគ្រប់គ្រងដោយលោកវរៈសេនីយ៍ឯក គង់ សុខាន់។ ដោយសារតែមានមេឈ្មួញប្រមូលទិញឈើក្រញូងឈ្មោះ ឈឿង ស័ក្ក នៅតំបន់នគបាលវរៈការពារព្រំដែលគោក៧០២ ដោយមិនមានការទទួលខុសត្រូវ និងមិនខ្វល់អ្វីទាំងអស់ពីសំណាក់លោកលោកវរៈសេនីយ៍ឯក គង់ សុខាន់ មេបញ្ជាការនគបាលវរៈការពារព្រំដែនគោក៧០២ នោះ ទើបបណ្ដាលឱ្យប្រជាពលរដ្ឋរស់នៅក្នុងសង្កត់អូស្មាច់ ក្រុងសំរោង ខេត្តឧត្តរមានជ័យ ទទួលរងគ្រោះដោយសារអាជ្ញាធរថៃចាប់ខ្លួនជាញឹកញាប់។ ជាក់ស្ដែង មួយខែកន្លះមកនេះ ត្រូវបានចាប់ខ្លួនរហូតដល់ចំនួន៨នាក់មកហើយ។

មេឈ្មួញប្រម៉ូលទិញឈើក្រញូងផ្ដាច់មុខ នៅតំបន់នគបាលវរៈការពារព្រំដែនគោ៧០២ ឈ្មោះឈឿង ស័ក្ក កាលពីឆ្នាំ២០១៨ ត្រូវបានសមត្ថកិច្ចស្រុកអន្លង់វែង ចាប់បង្រ្កាបបានរថន្តដឹកឈើនាងនួនមួយលើករួចមកហើយ នៅគ្រាដែលដឹកឈើចូលស្រុកអន្លង់វែង។ រហូតទល់និងពេលនេះ ឈ្មោះឈឿងស័ក្ក នៅតែល្បីឈ្មោះនៅតំបន់ខាងលើដ៍ដែល ដែលគេសង្ស័យថាបានត្រូវរ៉ូវគ្នា ជាមួយលោក វរសេនីយ៍ឯក គង់ សុខាន់ មេបញ្ជាការវរៈ៧០២ ច្រើនឆ្នាំមកហើយ ហើយក៏មិនដែលមានករណីបង្រ្កាបឈើរបស់មេឈ្មួញនេះទេ។

លោកវរសេនីយ៍ឯក គង់ សុខាន់ មេបញ្ជាការនគបាលវរៈការពារព្រំដែនគោកលេខ៧០២ បានឱ្យដឹងថា ពលករភាគច្រើននាំគ្នាចូលតាមកន្លែងដែលគ្មានកងកម្លាំងឈរជើង ហើយជាពិសេសដឹកតាមរថយន្តចូលតាមច្រកទ្វារអន្តរជាតិអូស្មាច់តែម្ដង ដែលមិនមែនជាកន្លែងលោកទទួលខុសត្រូវនោះទេ៕ ប៊ុនរិទ្ធី

# ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៩

## ឧទ្ធរណ៍ជម្រះក្ដីបុរសជប៉ុន និងស្ត្រីខ្មែរ រឿងនាំនារីទៅបម្រើផ្លូវភេទនៅជប៉ុន

https://www.postkhmer.com/ គីម សារុំ | Publication date 14 February 2019 | 09:12 ICT

**ភ្នំពេញៈ** សាលាឧទ្ធរណ៍កាលពីម្សិលមិញបានជំនុំជម្រះបុរសជប៉ុនម្នាក់ និងស្ត្រីខ្មែរម្នាក់ពាក់ព័ន្ធនឹងការនាំនារីខ្មែរ ៦ នាក់ទៅបម្រើផ្លូវភេទនៅប្រទេសជប៉ុនប្រព្រឹត្តកាលពីឆ្នាំ ២០១៦ ជាសំណុំរឿងដែលតុលាការថ្នាក់ក្រោមផ្ដន្ទាទោសដាក់ពន្ធនាគារម្នាក់ៗ ៧ ឆ្នាំ។ នៅក្នុងបន្ទប់សវនាការកាលពីម្សិលមិញបុរសជាប់ចោទឈ្មោះ FUKUI SUSU MU អាយុ ៥២ ឆ្នាំ បានប្រាប់ចៅក្រមថា លោកបានមកកម្ពុជានៅមុនឆ្នាំ ២០១៦ និងបានបើកហាងអាហារមួយនៅម្ដុំវត្តភ្នំ ក្នុងរាជធានីភ្នំពេញ។ រីឯស្ត្រី ឈ្មោះ លឹម លក្ខិណា អាយុ ២៩ ឆ្នាំជាអ្នកធ្វើការក្នុងហាងនោះហើយក៏ជាមិត្តស្រីរបស់លោកដែរ។

លោក FUKUI SUSU MU ប្រាប់ចៅក្រមបន្តថា ជាមួយគ្នានេះ លោកបានស្គាល់នារីជប៉ុនម្នាក់ឈ្មោះ ណាហ្គារិ នៅជប៉ុនហើយឈ្មោះនេះក៏ធ្លាប់បានស្គាល់ស្ត្រីខ្មែរម្នាក់ ឈ្មោះ ឡាំ សាត នៅកម្ពុជាផងដែរ។ បន្ទាប់មក ស្ត្រីជនជាតិ

ជប៉ុនរូបនេះបានណែនាំលោកឲ្យស្គាល់ស្ត្រីខ្មែរឈ្មោះ ឡាំ សាត នេះ។ ក្រោយពីស្គាល់គ្នា ស្ត្រីឈ្មោះឡាំ សាត ឧស្សាហ៍ទៅហាងរបស់លោកញឹកញាប់ ហើយក៏បានស្គាល់ឈ្មោះ លឹម លក្ខិណា ដែរទៅ។ លុះដល់ខែសីហា ឆ្នាំ ២០១៦ ស្ត្រីជនជាតិជប៉ុនឈ្មោះណាហ្គារិ បានឲ្យឈ្មោះ ឡាំ សាត រើសនារីខ្មែរមួយចំនួនយកទៅហាត់ការពីរបៀបបម្រើការក្នុងភោជនីយដ្ឋានមួយនៅប្រទេសជប៉ុនដោយសន្យាថា ពេលរៀនចេះនឹងឲ្យនារីខ្មែរទាំងនោះមកបម្រើការនៅភោជនីយដ្ឋាននៅភ្នំពេញវិញ ព្រោះស្ត្រីជប៉ុននោះក៏មានបំណងមកបើកហាងអាហារនៅភ្នំពេញដែរ។ លោក FUKUI SUSU MU បន្តថា បន្ទាប់មកឈ្មោះ ឡាំសាត រកបាននារីខ្មែរពេញវ័យ ៦ នាក់ ដោយឲ្យលោកជាអ្នករត់ឯកសារលិខិតឆ្លងដែននិងវីសាឲ្យនារីទាំងនោះ រីឯការចំណាយគឺស្ត្រីជប៉ុនឈ្មោះ ណាហ្គារិ ជាអ្នកចេញ ក្នុងនោះលោកត្រូវស្ត្រីជប៉ុនរូបនោះ សន្យាឲ្យឈ្នួល ១៨០០ ដុល្លារ។ បន្ទាប់ពីរត់ការរួច លោកបាននាំនារីខ្មែរទាំង ៦ នាក់នោះទៅព្រលានយន្តហោះអន្តរជាតិភ្នំពេញដើម្បីឡើងយន្តហោះទៅជប៉ុន។

ក៏ប៉ុន្តែតាមកំណត់ហេតុតុលាការបង្ហាញថា ពេលនារីរងគ្រោះទាំងនោះទៅដល់ជប៉ុនក្នុងឆ្នាំ ២០១៦ ក៏ត្រូវបានគេឲ្យបម្រើផ្លូវភេទ ហើយក្រោយមកក្រុមនារីរងគ្រោះបានប្តឹងស្ថានទូតកម្ពុជា ទើបត្រូវបានជួយឲ្យត្រឡប់កម្ពុជាវិញ ហើយបន្ទាប់មកសមត្ថកិច្ចកម្ពុជាក៏បានស្រាវជ្រាវចាប់ខ្លួនឈ្មោះ FUKUI SUSU MU និងស្ត្រីខ្មែរឈ្មោះ លឹម លក្ខិណា តែម្តង។ សំណុំរឿងនេះ ត្រូវសាលាដំបូងរាជធានីភ្នំពេញកាលពីថ្ងៃទី ១០ ខែឧសភា ឆ្នាំ ២០១៨ ផ្តន្ទាទោសជនទាំង ២ នាក់ដាក់ពន្ធនាគារម្នាក់ៗ ៧ ឆ្នាំចោទពីបទការជ្រើសរើសដោយមិនស្របច្បាប់សម្រាប់កេងប្រវ័ញ្ចតាមមាត្រា ១២ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងបានបង្គាប់ឲ្យជនជាប់ចោទទាំង ២ នាក់រួមគ្នាសងទៅក្រុមនារីរងគ្រោះក្នុងម្នាក់ៗ ២ ម៉ឺនដុល្លារ។

ជនជាប់ចោទឈ្មោះ FUKUI SUSU MU បានបញ្ជាក់ប្រាប់ចៅក្រមពីម្សិលមិញថា៖ «រឿងនេះខ្ញុំមិនបាននាំនារីខ្មែរទាំង ៦ នាក់នោះទៅបម្រើផ្លូវភេទទេប៉ុន្តែខ្ញុំបានរត់ការធ្វើឯកសារឲ្យពួកគេមែន រីឯលុយក៏ខ្ញុំមិនទាន់បានទទួលពីស្ត្រីជប៉ុននោះដែរ។ទោះយ៉ាងណាខ្ញុំសុំឲ្យតុលាការបន្ថយទោសដល់ខ្ញុំព្រោះខ្ញុំមានជំងឺសួតហើយមានម្តាយចាស់ជរាកំពុងសម្រាកក្នុងមន្ទីរពេទ្យនៅប្រទេសជប៉ុន»។

ដោយឡែកស្ត្រីជាប់ចោទឈ្មោះ លឹម លក្ខិណា បានប្រាប់ចៅក្រមពីម្សិលមិញដែរថា គាត់គ្រាន់តែជាអ្នកធ្វើការក្នុងហាងលោក FUKUI SUSU MU ប៉ុណ្ណោះ ហើយក៏មិនបានស្គាល់មុខនារីរងគ្រោះឬមានទំនាក់ទំនងគ្នាដែរ។ ស្ត្រីរូបនេះបាននិយាយថា៖ «ខ្ញុំស្នើដល់តុលាការឲ្យដោះលែងខ្ញុំវិញព្រោះម្តាយខ្ញុំជាជនពិការគ្មានអ្នកណារកស៊ីចិញ្ចឹមគាត់ទេ ខ្ញុំមិនបានពាក់ព័ន្ធរឿងនេះទេ»។

លោក ជុំ សែនសុទ្ធា តំណាងមហាអយ្យការសន្និដ្ឋានថា ក្រោយស្តាប់ចម្លើយរបស់ជនទាំង ២ នាក់ លោកយល់ថា ក្នុងសវនាការជនជាប់ចោទ FUKUI SUSU MU ថា គាត់គ្រាន់តែរត់ការឯកសារឲ្យនារីរងគ្រោះ ប៉ុន្តែពេលទៅដល់ប្រទេសជប៉ុននារីរងគ្រោះត្រូវគេឲ្យបម្រើផ្លូវភេទជាមួយបុរសជាតិជប៉ុន។ លោកថា៖ «ទោះយ៉ាងណាក្រុមជនជាប់ចោទធ្វើការជ្រើសរើសមនុស្សទៅប្រទេសជប៉ុននេះ មិនមែនជាលក្ខណៈក្រុមហ៊ុនមានច្បាប់ត្រឹមត្រូវទេ។ដូច្នេះខ្ញុំសូមតម្កល់សាលក្រមរបស់តុលាការថ្នាក់ក្រោមទុកជាបានការ»។ ក្រោយជំនុំជម្រះ លោក សំរិទ្ធិ សុផល ប្រធានក្រុមប្រឹក្សាជំនុំជម្រះថ្លែងថា សាលដីកាសំណុំរឿងនេះនឹងប្រកាសនៅថ្ងៃទី ៧ ខែមីនា ខាងមុខ៕

## ថៃចាប់បញ្ជូនពលករខ្មែរខុសច្បាប់ចំនួន៩៣៩នាក់ នេះគ្រាន់តែអំឡុងខែមករាឆ្នាំ២០១៩

https://kohsantepheapdaily.com.kh/ ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១៩ ម៉ោង ១០:១៣ ប៊ុន ធឿន

ខេត្តបន្ទាយមានជ័យ ៖ នៅអំឡុងខែមករា ឆ្នាំ២០១៩ អ្នកដំណើរចេញចូលតាមច្រកទ្វារអន្តរជាតិប៉ោយប៉ែតមានចំនួន១.១៨១.៤៩៧នាក់ ថៃចាប់បញ្ជូនពលករខ្មែរខុសច្បាប់មានចំនួន៩៣៩នាក់ បញ្ជូនសាកសពខ្មែរចំនួន១៧នាក់ ។

លោកវរសេនីយទោ ខឹម ចិត្រា នាយប៉ុស្តិ៍នគរបាលច្រកទ្វារអន្តរជាតិប៉ោយប៉ែត បានប្រាប់ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៩នេះថា ដោយយោងតាមរបាយការប្រចាំខែមករា ឆ្នាំ២០១៩ កន្លងទៅអ្នកដំណើរចេញ-ចូលមានចំនួន ១.១៨១.៤៩៧នាក់ ស្រី៥៣០.៩៨១នាក់ ក្នុងនោះមានសញ្ជាតិខ្មែរចំនួន៦០៧.១៦៤នាក់ ស្រី៤៨៤.៦៨០នាក់ សញ្ជាតិបរទេសមានចំនួន៨៤.៣៣៣នាក់ ស្រី៤៦.៣០១នាក់ ភ្ញៀវទេសចរណ៍បរទេសចំនួន៨០.៥២២នាក់ ។ លោកបានបញ្ជាក់ថា ពលករចេញទៅធ្វើការនៅបរទេសចំនួន៤.០១៨នាក់ ស្រី១.៧២៣នាក់ តាមរយៈ៣៧ក្រុមហ៊ុន និងពលរដ្ឋថៃចូលមកលេងកាស៊ីណូ សរុបចំនួន៣៨.៩៨៦នាក់ ស្រី២០.១៤៧នាក់ ពលរដ្ឋថៃចេញពីលេងកាស៊ីណូ សរុបចំនួន៥៥២.៨៩៧នាក់ ស្រី២៤៦.៨៧០នាក់ ។ លោកវរសេនីយទោ ខឹម ចិត្រា បានបញ្ជាក់ថា ពលករខ្មែរឆ្លងដែនខុសច្បាប់ដែលអាជ្ញាធរថៃចាប់បញ្ជូនមកវិញ តាមច្រកទ្វារអន្តរជាតិប៉ោយប៉ែតមានចំនួន៤៧លើក មានមនុស្សសរុបចំនួន៩៣៩នាក់ ស្រី៣២២នាក់ កុមារចំនួន១២០នាក់ ។ អាជ្ញាធរថៃបញ្ជូនសាកសពប្រជាពលរដ្ឋខ្មែរដឹកចូលតាមច្រកទ្វារអន្តរជាតិប៉ោយប៉ែតមានចំនួន១៧នាក់ មានស្រី៤នាក់ ។ ប្រថាប់ត្រាលើប័ណ្ណព្រំដែនជូនប្រជាពលរដ្ឋខ្មែរក្នុងខេត្តបន្ទាយមានជ័យមានចំនួន១២.៧១៤នាក់ និងសហការជាមួយថៃផ្តល់សំបុត្រព្រំដែនជូនប្រជាពលរដ្ឋខ្មែរឆ្លងចូលទៅផ្សាររោងក្លឿមានចំនួន៤៧៥.០៤៨នាក់ ៕

## កម្ពុជា-ថៃ ចេញសេចក្តីថ្លែងការណ៍រួមអំពីលទ្ធផលកិច្ចប្រជុំគណៈកម្មាធិការព្រំដែនទូទៅ (GBC) លើកទី១៤

http://ppd-news.net/ Posted By: admin *February 14, 2019*

**ភ្នំពេញ ៖** បន្ទាប់ពីបញ្ចប់កិច្ចប្រជុំគណៈកម្មាធិការព្រំដែនទូទៅ (GBC) កម្ពុជា-ថៃ លើកទី១៤ ដែលបានដឹកនាំដោយសហប្រធាន សម្តេចពិជ័យសេនា ទៀ បាញ់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិកម្ពុជា និងនាយឧត្តមសេនីយ៍ ប្រាវីត វង្សសុវណ្ណ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារប្រទេសថៃ នៅនៅព្រឹកថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៩នេះ ភាគីទាំងពីរបានចេញសេចក្តីថ្លែងការណ៍រួមពីកិច្ចការព្រំដែនប្រទេសទាំងពីរ។ ប្រមុខការពារជាតិកម្ពុជា-ថៃបានចេញសេចក្តីថ្លែងការណ៍រួម នៅក្នុងកិច្ចប្រជុំនេះត្រូវបានរៀបចំឡើងដោយយោង ទៅតាមកិច្ចព្រមព្រៀងនៃការបង្កើតកិច្ចសហប្រតិបត្តិការព្រំដែនរវាងព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រថៃ ក្នុងគោលបំណងបង្កើតកិច្ចសហប្រតិបត្តិការ ដើម្បីសន្តិភាព និងសន្តិសុខក្នុងតំបន់ព្រំដែន ក៏ដូចជាពង្រឹងបន្ថែមទៀតនូវ ទំនាក់ទំនងរវាងកងទ័ព និងកងឯកភាពសន្តិសុខពាក់ព័ន្ធដ៏ទៃទៀតរបស់កម្ពុជា និង ថៃ។

កិច្ចប្រជុំនេះបានបញ្ជាក់អំពីសារៈសំខាន់នៃការប្រជុំគណៈកម្មាធិការព្រំដែនទូទៅ (GBC) លើកទី 14 ដែលបានផ្តល់នូវការណែនាំ និងទិសដៅបដើម្បីជម្រុញឲ្យទំនាក់ទំនងល្អដែលមានស្រាប់ និងកិច្ចសហប្រតិបត្តិការដ៏មានសារៈប្រយោជន៍រវាងកងទ័ពទាំងពីរនៅគ្រប់កំរិតទាំងអស់ឲ្យកាន់តែប្រសើរឡើងថែមទៀត សម្រាប់ជាការលើកកម្ពស់ដល់សន្តិភាព ស្ថិរភាព និងសន្តិសុខតាមបណ្តោយព្រំដែន។ កិច្ចប្រជុំក៏បានស្វាគមន៍ចំពោះវឌ្ឍនៈភាពនៃកិច្ចសហប្រតិបត្តិការតាមបណ្តោយព្រំដែន ហើយភាគីទាំងពីរបានពិនិត្យឡើងវិញ នូវលទ្ធផលនៃការអនុវត្តកម្មវិធីកិច្ចសហប្រតិបត្តិការផ្សេងៗ ដែលដាក់ចេញដោយកិច្ចប្រជុំគណៈកម្មាធិការព្រំដែនទូទៅ លើកទី១៣ កាលពីថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៨ នៅទីក្រុងបាងកក ព្រះរាជាណាចក្រថៃ ដូចជា ៖ កិច្ចសហប្រតិបត្តិការ លើការឆ្លងកាត់ព្រំដែន បញ្ហាពលករ ការទប់ស្កាត់នឹងបង្ក្រាបការជួញដូរគ្រឿងញៀន ការលើកកម្ពស់កិច្ចសហប្រតិបត្តិការរវាង កងទ័ពកម្ពុជាជាមួយបណ្តាអង្គភាពសន្តិសុខថៃ ក្នុងតំបន់ព្រំដែន បញ្ហាកសិកម្ម បញ្ហាសុខភាពសាធារណៈ ការអភិវឌ្ឍជីវភាព រស់នៅការអប់រំសាសនា និងវប្បធម៌។

កិច្ចប្រជុំបានឯកភាពជំរុញភាគីទាំងពីរ ឲ្យបន្តនូវភារកិច្ចក្នុងការថែរក្សាសន្តិភាព ស្ថិរភាពតាមបណ្តោយព្រំដែននៃប្រទេសទាំងពីរ ដោយស្របតាមគោលការណ៍ និងវិធានការដែលបានកំណត់ក្នុងកំណត់ហេតុព្រមព្រៀងនៃ

កិច្ចប្រជុំលើកទី១៤ នេះលើគ្រប់ ទិដ្ឋភាពទាំងអស់។ ភាគីថៃនឹងទទួលធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំគណៈកម្មាធិការព្រំដែន ទូទៅ (GBC) កម្ពុជា-ថៃលើកទី១៥ ហើយនឹងធ្វើការជូនដំណឹងទៅភាគីកម្ពុជាអំពីកាលបរិច្ឆេទ និងទីកន្លែង នៅពេលក្រោយ៕

## ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៩

## សម្តេចតេជោដាក់អនុសាសន៍៨ចំណុចក្នុងពិធីបិទសន្និបាតក្រសួងមហាផ្ទៃ

https://cambodiapolice.com/policekh/ 9:03 pm 14 កុម្ភៈ 2019

ភ្នំពេញ៖ សម្តេចនាយករដ្ឋមន្ត្រី បានមានប្រសាសន៍នៅថ្ងៃទី១៤ កុម្ភៈនេះ អំពាវនាវដល់កងកម្លាំងនគរបាលជាតិ ត្រូវបន្ត ខិតខំរក្សាសន្តិសុខ ប្រឆាំងបដិវត្តពណ៌ ដែលសេចក្តីអំពាវនាវនេះ បានធ្វើឡើងក្នុងឱកាសចូលរួមផ្តល់អនុ សាសន៍បិទមហាសន្និបាតការងាររបស់ក្រសួងមហាផ្ទៃឆ្នាំ២០១៨និងការលើកទិស ដៅឆ្នាំ២០១៩។ អនុសាសន៍៨ចំណុចរបស់សម្តេចនាយករដ្ឋមន្ត្រី មានដូចទៅ៖

ទី១-ត្រូវបន្តថែរក្សាសុខសន្តិភាព ស្ថេរភាពនយោបាយ អធិបតេយ្យ បូរណភាពទឹកដីប្រឆាំងដាច់ខាតនៅបដិវត្ត ពណ៌ និងរាល់សកម្មភាពដែលប៉ុនប៉ងជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងរបស់ជាតិយើង។ កងកម្លាំងរបស់នគរបាលជាតិ និងគណៈបញ្ជាការឯកភាពរដ្ឋបាលគ្រប់ជាន់ថ្នាក់ ត្រូវសហការជាមួយក្រសួងស្ថាប័ន និងសមត្ថកិច្ចពាក់ព័ន្ធ ដទៃទៀត ការពារសន្តិភាព សន្តិសុខជាតិ ទប់ស្កាត់និងបង្រ្កាបឲ្យទាន់ពេលវេលារាល់សកម្មភាពចលាចល និង ភាពហ៊ឹកហ៊ូរក្នុងសង្គម។

ទី២-អគ្គស្នងការនគរបាលជាតិ នឹងបញ្ជាការឯកភាពគ្រប់ថ្នាក់ត្រូវបន្តរក្សាសន្តិសុខសណ្តាប់ធ្នាក់ សារធារណៈ និងសុវត្ថិភាពសង្គម តាមរយៈការពង្រឹងសមត្ថភាពជំនាញ វិន័យ និងក្រមសីលធម៌វិជ្ជាជីវៈ ដល់កងកម្លាំងនគរបាលជាតិ ប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព។ ក្រសួងស្ថាប័ន អាជ្ញាធរថ្នាក់ក្រោមជាតិ សង្គមស៊ីវិល វិស័យឯកជន ប្តូ្រប្រជាពលប៉ស្រទាប់ជាន់ថ្នាក់ រួមគ្នាទប់ស្កាត់ បង្រ្កាបបទល្មើសគ្រឿងញៀន ខុសច្បាប់ សកម្មភាពលួចឆក់ប្លន់ និងបន្តពង្រឹងច្បាប់ស្តីពីចរាចរផ្លូវគោក បន្តទប់ស្កាត់អគ្គីភ័យ ដើម្បីអនុវត្ត គោលនយោបាយភូមិឃុំ មានសុវត្ថិភាព និងការរស់នៅរបស់ប្រជាជន ប្រកបដោយសុខសន្តិភាព និងសុវត្ថិ ភាព។

ទី៣-ត្រូវបន្តកិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរ កងកម្លាំងមានសមត្ថកិច្ច និងប្រទេសជិតខាងក្នុងតំបន់ និងអន្តរជាតិដើម្បីរួមគ្នាទប់ស្កាត់ និងបង្រ្កាបឲ្យបានទាន់ពេលវេលា សកម្មភាពភេរវកម្ម ឧក្រិដ្ឋកម្មអន្តរជាតិ ឧក្រិដ្ឋកម្មព័ត៌មានវិជ្ជា និងបទល្មើសឆ្លងដែនគ្រប់ប្រភេទ ដើម្បីពង្រឹងសន្តិសុខនិងសណ្តាប់ធ្នាប់ក្នុង សង្គម។

ទី៤-ត្រូវពង្រឹងការទទួលខុសត្រូវ ក្នុងការព្រប់គ្រងជនអន្ត្រេព្រប់គ្រងជនអន្តោយកចិត្តទុកដាក់ និងការលើកម្ពស់ការគ្រប់គ្រង ការចេញចូលតាមច្រកព្រំដែនទាំងផ្លូវគោក ផ្លូវទឹកនិងផ្លូវអាកាស ទទឹមនិងនេះត្រូវបង្កើន កិច្ចសហការក្នុងការ គ្រប់គ្រងក្នុងការស្នាក់នៅ ការប្រកបមុខរបរ និងសកម្មភាពជនបរទេស ជនអន្តោប្រ វេសន៍នៅក្នុងប្រទេស ស្របតាមចស្របតាមច្បាប់ជនអន្តោ ច្បាប់ការងារ និងលិខិតបទដ្ឋាននានាជាធរមាន នៃព្រះរាជណាចក្រកម្ពុជា។

ទី៥-អំពីការកែទម្រង់វិមជ្ឈការនិងសហវិមជ្ឈការ ត្រូវបន្តការយកចិត្តទុកដាក់ជម្រុញការផ្ទេរ មុខងារ ធនធានពីក្រសួងស្ថាប័ននានាទៅរដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈការប្រគល់ ការធ្វើប្រតិគួកម្មអំណាច ការធ្វើចាត់ ចែងអនុវត្តមុខងារដែលបានផ្ទេរប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនាយ្យភាព ដើម្បីឆ្លើយតបទៅ នឹងសេចក្តីត្រូវរបស់ប្រជាពលរដ្ឋតាមមូលដ្ឋាននីមួយៗ ទន្ទឹមនឹងនេះនៅថ្ងៃទី២៦ ខែឧសភា ខាងមុខ កម្ពុ ជា នឹងរៀបចំបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ លើកទី៣ ស្របតាមអាណត្តិ ដែល បានកំណត់ក្នុងច្បាប់ ។ ខ្ញុំសូមឲ្យក្រសួងនិងស្ថាប័ននានា រដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធនានា ចូលរួមក្នុងដំណើរការបោះឆ្នោតឲ្យបានពេញលេញ ត្រឹមត្រូវតាមច្បាប់កំណត់។

ទី៦-ត្រូវធ្វើឲ្យមានប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព ក្នុងការផ្តល់សេវាសាធារណៈ ដែលស្ថិតក្រោមដែន សមត្ថកិច្ចរបស់ក្រសួងមហាផ្ទៃ និងរដ្ឋបាលថ្នាក់ ក្រោមជាតិ តាមរយៈការពង្រីកការផ្តល់សេវាថ្នាក់ក្រោមជាតិ តាមយន្តការឃុំ សង្កាត់ ច្រកចេញចូលតែមួយនៅថ្នាក់ ក្រោមជាតិ ឲ្យបានកាន់តែទូលំទូលាយថែមទៀត ដើម្បី បង្កិតការផ្តល់សេវានានា ឲ្យកៀកជិតប្រជាពលរដ្ឋ។

ទី៧-ផ្អែកតាមការព្យាករណ៍ ប្រទេសយើងនិងអាចមានអាកាសធាតុក្តៅ ហួតហែង ហើយរដូវប្រាំងត្រូវអូសបន្លាយយូរជាងឆ្នាំមុន ដូច្នេះសូមឲ្យក្រសួងធនធានទឹក ត្រូវសហការជាមួយរដ្ឋបាលរាជធានីខេត្ត ដើម្បីត្រួត ពិនិត្យប្រព័ន្ធទឹក នៅតាមមូលដ្ឋាន ទាំងប្រភពទឹកសម្រាប់ប្រើប្រាស់ក្នុងជីវភាពប្រចាំថ្ងៃ និងបង្ករបង្កើនផល រដូវប្រាំង ដើម្បីមានវិធានការ ការពារនិងប្រើប្រាស់ប្រភពទឹកដែលនៅសេសសល់សម្រាប់ប្រើប្រាស់ក្នុងជីវភាព ប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ។ ក្រសួងស្ថាប័ននានា ដែលរដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់លំដាប់ថ្នាក់ រួមទាំងកង កម្លាំងប្រដាប់អាវុធ ត្រូវត្រៀមលក្ខណៈអន្តរាគមន៍ ដើម្បីដឹកជញ្ជូនទឹកជូនប្រជាជននៅមូលដ្ឋាន ដោយមិនទុក ឲ្យប្រជាជនរងគ្រោះដោយសារការខ្វះខាតទឹកប្រើប្រាស់ប្រចាំថ្ងៃនោះឡើយ។ ក្រសួងសុខាភិបាល ក្រសួងកសិ កម្ម ត្រូវ សហការជាមួយរដ្ឋបាលរាជធានី ខេត្ត ណែនាំអប់រំប្រជាជន នៅតាមមូលដ្ឋាន ឲ្យថែរក្សាសុខភាព ការពារជំងឺឆ្លងរាតត្បាត តាមកសិដ្ឋាននានា និងត្រូវមានវិធានការជួយអន្តរាគមន៍ ក្នុងការព្យាបាលជំងឺទាំង មនុស្សនិងសត្វឲ្យបានទាន់ ពេលវេលា។

ទី៨-យើងត្រូវរួមគ្នាធ្វើការដើម្បីការលូតលាស់ ខាងសេដ្ឋកិច្ចដើម្បី បន្តពង្រឹងឯករាជ្យភាព ខាងនយោបាយរបស់យើង យើងមិនត្រូវយកអធិបតេយ្យភាពរបស់យើងទៅ ដោះដូរ ជាមួយ ជំនួយណាមួយនោះឡើយ ប្រទេសមួយបើមិនអាចអនុវត្តច្បាប់របស់ខ្លួនបាន មិនចាំបាច់ហៅថា រដ្ឋ អធិបតេយ្យនោះទេ៕

## លោក ហង់ ជួនណារ៉ុន៖ ការពង្រឹងវិស័យអប់រំ អាចដោះស្រាយបញ្ហាចំណាកស្រុក

https://www.postkhmer.com/ វ៉ន ដារ៉ា | Publication date 14 February 2019 | 10:31 ICT

**ភ្នំពេញៈ** ខណៈដែលពលរដ្ឋខ្មែរ ជាង ១ លាននាក់ បានធ្វើចំណាកស្រុកទៅធ្វើការនៅក្រៅប្រទេសលោក ហង់ ជួនណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា ថ្លែងថា ការពង្រឹងវិស័យអប់រំ គឺជាកត្តាចម្បងដើម្បីឲ្យយុវជនកម្ពុជាអាចបង្កើតការងារក្នុងស្រុកដោយខ្លួនឯងបាន និងអាចដោះស្រយបញ្ហាការធ្វើចំណាកស្រុក។ លោករដ្ឋមន្ត្រីបានថ្លែងបែបនេះនៅក្នុងសិក្ខាសាលាផ្សព្វផ្សាយស្តីពីរបាយការណ៍ពិនិត្យតាមដានការអប់រំសកលឆ្នាំ ២០១៩ ដែលធ្វើឡើងកាលពីម្សិលមិញ នៅសណ្ឋាគារកាំបូឌីយ៉ាណា។

ពាក់ព័ន្ធនឹងបញ្ហាចំណាកស្រុកនេះតាមរយៈរបាយការណ៍ស្តីពីលទ្ធផលការងារឆ្នាំ ២០១៨ និងលើកទិសដៅការងារឆ្នាំ ២០១៩ របស់ក្រសួង មហាផ្ទៃដែលចេញផ្សាយកាលពីម្សិលមិញ បានបង្ហាញថា ពលរដ្ឋខ្មែរដែលអាផ្ទាធរបរទេសចំនួន១៨ប្រទេសចាប់បញ្ជូនត្រឡប់មកវិញ ដោយមូលហេតុស្នាក់នៅឬធ្វើការខុសច្បាប់មានចំនួន ៣១ ៦០៩ នាក់ស្រីចំនួន ១០ ៨២៨ នាក់ និងកុមារចំនួន ២ ៩១៤ នាក់ (ច្រើនជាងគេមកពីប្រទេសថៃ ៣០៦៣៦ នាក់ កូរ៉េខាងត្បូង ២៧០ នាក់ ម៉ាឡេស៊ី ១៧២ នាក់ចិន ១៥៦ នាក់ជប៉ុន ៩២ នាក់ វៀតណាម ៨៤ នាក់...) និងពលករខ្មែរទៅធ្វើការដោយស្របច្បាប់នៅក្រៅប្រទេសតាមរយៈក្រុមហ៊ុនមានចំនួន ១០៤ ៤៣៤ នាក់ (ស្រី ៤២ ៥៣៧ នាក់)។

បើតាមលោក ហេង សួរ អ្នកនាំពាក្យក្រសួងការងារបានប្រាប់ភ្នំពេញប៉ុស្តិ៍កាលពីពេលថ្មីៗនេះថា គិតត្រឹមខែមិថុនា ឆ្នាំ ២០១៨ គ្រាន់តែនៅក្នុងប្រទេសថៃ ១ មានពលករខ្មែរស្របច្បាប់ប្រមាណជាង ១ លាននាក់។

លោក ជួនណារ៉ុន បានថ្លែងថា ការដោះស្រាយបញ្ហាចំណាកស្រុក គឺត្រូវដោះស្រាយពីដើមទីមានន័យថា គឺការធានាឲ្យបាននូវសន្តិសុខសន្តិភាព នៅក្នុងប្រទេស ដើម្បីបង្កលក្ខណៈឲ្យមានការវិនិយោគឲ្យកាន់តែច្រើន ការបណ្តុះបណ្តាលធនធានមនុស្សដែលអាចបង្កើតសេដ្ឋកិច្ចថ្មីបាន ពង្រឹងការបណ្តុះបណ្តាលនៅតាមសាលារៀនជំនាន់ថ្មីសាលារៀនគំរូដើម្បីឲ្យសិស្សចេះនូវបច្ចេកវិទ្យា និងអាចបង្កើតនូវវិស័យបច្ចេកវិទ្យាថ្មី នៅកម្ពុជាដែលនេះជាបញ្ហាមួយ

ក្នុងការដោះស្រាយបញ្ហាចំណាកស្រុក។ លោកបន្តថា៖ «ដូច្នេះគឺត្រូវដោះស្រាយបញ្ហានេះពីដើមទី ហើយជាតួនាទីរបស់វិស័យអប់រំដើម្បីធ្វើការឆ្លើយតប និងដោះស្រាយបញ្ហាចំណាកស្រុកនេះ ពីដើមទីទៅតែម្តង។ មានតែការពង្រឹងវិស័យអប់រំទេ ដែលអាចដោះស្រាយនូវបញ្ហាផ្សេងៗជាពិសេសបញ្ហាចំណាកស្រុក»។ លោកបន្ថែមថា ការគ្រប់គ្រងតាមសាលារៀនដើម្បីពង្រឹងគុណភាពអប់រំ ការផ្តោតទៅលើការបណ្តុះបណ្តាលគ្រូ ការផ្តោតទៅលើការបណ្តុះបណ្តាលខាងផ្នែកបច្ចេកវិទ្យា ការពង្រឹងការបណ្តុះបណ្តាលក្នុងវិស័យ STEM គឺជាការឆ្លើយតបទៅនឹងការចំណាកស្រុក នឹងដើម្បីឲ្យយុវជននៅកម្ពុជា ចេះបង្កើតការងារធ្វើនៅក្នុងប្រទេសជាជាងទៅធ្វើការនៅក្រៅប្រទេស។

បើតាមលោករដ្ឋមន្ត្រី ខេត្តខ្លះមានអត្រាបោះបង់ការសិក្សាខ្ពស់រហូតដល់ ២៣ ភាគរយ ខណៈអត្រាថ្នាក់ជាតិបានធ្លាក់ចុះមកនៅត្រឹម ១៨ ភាគរយប៉ុណ្ណោះ។ លោកឲ្យដឹងថា ការធ្វើចំណាកស្រុកនេះ ភាគច្រើនបានកើតឡើងនៅតាមខេត្តនៅជាប់ព្រំដែនថៃ មានដូចជាខេត្តបាត់ដំបង បន្ទាយមានជ័យឧត្តរមានជ័យជាដើម។ លោកបានលើកឡើងថា គ្រូប្រឹក្សាអាជីព អាចផ្តល់ការប្រឹក្សាដល់សិស្ស ទៅលើការរៀនតាមមុខវិជ្ជាផ្សេងៗ ក៏ដូចជាជួយដោះស្រាយបញ្ហារបស់សិស្សទាំងនោះ ពិសេសជួយកាត់បន្ថយ ការបោះបង់ចោលការសិក្សារបស់សិស្សដែលមានឪពុកម្តាយទៅធ្វើការនៅក្រៅស្រុក។ លោក ណារ៉ុន បានប្រាប់ទៅនាយកដ្ឋានបណ្តុះបណ្តាលគ្រូឲ្យយកបញ្ហានៃការបណ្តុះបណ្តាលគ្រូប្រឹក្សាអាជីពនេះ ទៅពិភាក្សា ហើយចាប់ផ្តើមបណ្តុះបណ្តាលគ្រូ បន្ទាប់មកស្នើសុំទៅវិទ្យាល័យ និងអនុវិទ្យាល័យនៅខេត្តដែលមានការធ្វើចំណាកស្រុកខ្ពស់នោះ ដើម្បីបង្កើតឲ្យមានបន្ទប់ពិគ្រោះយោបល់ និងដាក់ឲ្យមានគ្រូដែលមានការបណ្តុះបណ្តាលសម្រាប់ផ្តល់ប្រឹក្សាដល់សិស្ស ព្រោះគ្រូប្រឹក្សាអាជីពនេះ បានជួយដល់សិស្សនារីផងដែរ ដើម្បីកុំឲ្យបោះបង់ការសិក្សា។ លោករដ្ឋមន្ត្រីបញ្ជាក់៖ «ដូច្នេះគោលដៅយើង គឺកាត់បន្ថយការបោះបង់ចោលការសិក្សា និងផ្តល់ព័ត៌មានឲ្យបានគ្រប់គ្រាន់ដល់សិស្សក្នុងការជ្រើសរើសវិថីនៃជីវិតរបស់គាត់»។ លោកបន្តថា៖ «សរុបមកវិញ ការបណ្តុះបណ្តាលគ្រូនេះ គឺជាឆ្អឹងខ្នងសម្រាប់ប្រព័ន្ធអប់រំរបស់យើង សម្រាប់ការដោះស្រាយបញ្ហាចំណាកស្រុក និងការពង្រឹងវិស័យអប់រំ»។

លោកស្រី Pauline Tamesis អ្នកសម្របសម្រួលអង្គការសហប្រជាជាតិប្រចាំកម្ពុជា បានថ្លែងថា ប្រជាជនកម្ពុជាជាច្រើន បានធ្វើចំណាកស្រុកពីទីជនបទ មកទីក្រុង ឬទីប្រជុំជននិងផ្លាស់ទីទៅប្រទេសផ្សេងទៀត ដើម្បីស្វែងរកការងារធ្វើ។ លោកស្រីបន្តថា អក្ខរកម្ម គឺជាជំនាញមួយ ក្នុងចំណោមជំនាញជាមូលដ្ឋាន ដែលជួយឲ្យជនចំណាកស្រុក មានការរីកចម្រើន នៅក្នុងតំបន់ប្រជុំជនប៉ុន្តែលោកស្រីបញ្ជាក់ថា ជនចំណាកស្រុកជាច្រើនដែលមកធ្វើការនៅទីក្រុង នៅតែមិនទាន់ទទួលបានការសិក្សាអប់រំជំនាញអក្ខរកម្មបន្ថែមនៅឡើយ។ លោកស្រីបញ្ជាក់ថា៖ «ខ្ញុំសូមបញ្ជាក់ម្តងទៀតថា ការអប់រំ គឺជាកត្តាគន្លឹះសម្រាប់ ការការពារអ្នកទាំងនេះ (ជនចំណាកស្រុក)»។ លោកស្រីបន្ថែមថា៖ «ផលប៉ះពាល់នៃការធ្វើចំណាកស្រុក ក៏កើតឡើងតជំនាន់ផងដែរ។ កុមារដែលមានឪពុកម្តាយធ្វើចំណាកស្រុក ហើយទុកពួកគេចោល អាចទទួលបាននូវស្ថិរភាពនៃប្រាក់ដែលឪពុកម្តាយគេផ្តល់មកវិញ ប៉ុន្តែការអប់រំ និងសុខុមាលភាពពួកគេ តែងតែទទួលរងនូវផលប៉ះពាល់ដោយកុមារត្រូវបានគេទុកចោល ជាពិសេសកុមារីច្រើនតែបោះបង់ចោលការសិក្សា»។

របាយការណ៍ពិនិត្យតាមដានការអប់រំសកលឆ្នាំ ២០១៩ របស់យូណេស្កូ ក្រោមប្រធានបទ «ការធ្វើចំណាកស្រុក ការផ្លាស់លំនៅដោយបង្ខំ និងការអប់រំ» បានបង្ហាញថា ចំនួនកុមារជាជនចំណាកស្រុក និងជនភៀសខ្លួន ដែលដល់អាយុចូលរៀនជុំវិញពិភពលោក កើនឡើង ២៦ ភាគរយ ចាប់តាំងពីឆ្នាំ ២០០០ មក ដែលចំនួននេះ អាចបំពេញបន្ទប់រៀនដល់ទៅជាងកន្លះលានបន្ទប់៕

## សមត្ថកិច្ចបានចុះពិនិត្យ និងបិទទីតាំងបញ្ចាំងកុនមួយកន្លែង យីហោ Home Cinema នៅក្នុងខណ្ឌចំការមន ព្រោះតែ

https://khmer.social/ Pheak Tra February 14, 2019

ភ្នំពេញៈ កាលពីពេលថ្មីៗនេះ កម្លាំងសមត្ថកិច្ចបានចុះពិនិត្យ និងបិទទីតាំងបញ្ចាំងកុនមួយកន្លែង យីហោ Home Cinema នៅក្នុងខណ្ឌចំការមន ដោយមានការឯកភាពពីព្រះរាជអាជ្ញារង អមសាលាដំបូងរាជធានីភ្នំពេញ លោកស្រី កែវ សុគន្ធា ព្រោះតែបានរកឃើញនៅខាងក្នុងបន្ទប់មើលកុននីមួយៗ មានសុទ្ធតែដាក់ពូកដេកទៀតផង។ កន្លែងបញ្ចាំងកុន Home Cinema ភាគច្រើនបំផុតនោះ ជាកន្លែងប្រមូលផ្តុំដោយក្រុមយុវវ័យ ជាសិស្សសាលា ទាំងស្រីទាំងប្រុស និងខ្លះទៀតជាសង្សារ បានចូលទៅមើលកុន ក្នុងបន្ទប់បិទជិតនេះ។

យ៉ាងណាក៏ដោយ សម្រាប់ក្រុមយុវវ័យមិនទាន់គ្រប់អាយុ ដែលសមត្ថកិច្ចបានធ្វក់ចូលទៅឃើញនោះ មិនមានចាត់ការអ្វី ក្រៅតែពីហៅអាណាព្យាបាលឲ្យមកជានា រួចអនុញ្ញាតឲ្យត្រឡប់ទៅផ្ទះវិញ។ លោក ហ៊ាង ថារ៉េត អធិការរងនគរបាលខណ្ឌចំការមន បានឲ្យដឹងថា ប្រតិបត្តិការចុះបិទទីតាំងបញ្ចាំងកុន Home Cinema នេះ គឺបន្ទាប់ពីរកឃើញថា មានភាពមិនប្រក្រតី ដោយមានការចម្លែកត្រង់ថា មិនមានកៅអីសម្រាប់អង្គុយមើលទេ ប៉ុន្តែគេបែរជាដាក់គ្រែពូកសម្រាប់មនុស្សពីនាក់ដេកមើលទៅវិញ។ ជាមួយគ្នានោះដែរ លោកអធិការរង ក៏បានអំពាវនាវដល់ក្រសួងស្ថាប័នពាក់ព័ន្ធ មេត្តាជួយពិនិត្យឲ្យបានល្អិតល្អន់សិន មុននិងចេញអាជ្ញាប័ណ្ណឲ្យប្រកបរបរអាជីវកម្មនេះ ជាពិសេសពាក់ព័ន្ធដល់ក្រសួងវប្បធម៌ ព្រោះថា ការបើកទីតាំងបញ្ចាំងកុន Home Cinema នេះ មិនមានមនុស្សចាស់ ឬក្មេងតូចៗទៅមើលទេ ភាគច្រើនមានតែក្មេងប្រុសស្រីវ័យជំទង់ៗតែពីរនាក់ចូលទៅមើល ហើយក្នុងទីតាំងបញ្ចាំងនេះ គេដាក់ពូកឲ្យដេក ដែលពួកគេអាចប្រព្រឹត្តិរឿងអ្វីផ្សេងៗខុសប្រពៃណី ៕

## សមត្ថកិច្ចថៃចុះចំបែកសម្បុកក្រុមហ៊ុនដំណើរការឯកសារក្លែងក្លាយជូនដល់ពលករ:

https://www.facebook.com/ ទីប្រឹក្សាទទួលបន្ទុកពលករប្រចាំប្រទេសថៃ 15-02-2019

កាលពីថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៩ អាជ្ញាធរថៃ បានចុះឆែកឆេរក្រុមហ៊ុនថៃ ដែលបំរើសេវាដំណើរការឯកសារស្របច្បាប់ជូនពលករ ឈ្មោះForeign Worker Employment Agency CBS World Co., Ltd មានទីតាំងនៅ ផ្ទះលេខ216/6 ផ្លូវលំចែងវឌ្ឍនៈ សង្កាត់បាងខេន ខណ្ឌឡាក់ស៊ី ទីក្រុងបាងកក ។ ក្នុងការចុះឆែកឆេរនេះ សមត្ថកិច្ចបានរកឃើញលិខិតឆ្លងដែន ត្រាប្រថាប់វីសាក្លែងក្លាយ និងបណ្ណ័អនុញ្ញាតការងារក្លែងក្លាយជាច្រើន។ ដូច្នេះសូមជម្រាបជូនដល់បងប្អូនពលករកម្ពុជា ដែលធ្លាប់បានដំណើរការឯកសារផ្សេងៗ ជាមួយក្រុមដែលមានឈ្មោះដូចខាងលើ សូមប្រញាប់រួសរាន់អោយនិយោជកនាំទៅត្រួតពិនិត្យឯកសារនៅការិយាល័យនគរបាលអន្តោប្រវេសន៍ជាបន្ទាន់។

# ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៩

## សម្តេចតេជោ ផ្តល់អនុសាសន៍១១ ចំណុចដល់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី

http://khmer.peoplenews.asia/ ដោយ ៖ រិទ្ធី ថ្ងៃទី18 ខែ02 ឆ្នាំ2019 ម៉ោង 1:19 PM

នៅព្រឹកថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៩ នៅក្នុងកម្មវិធីបូកសរុបលទ្ធផលការងារ ឆ្នាំ២០១៨ និងលើកទិសដៅផែនការសកម្មភាពការងារឆ្នាំ២០១៩ របស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានផ្តល់អនុសាសន៍សំខាន់ៗចំនួន ១១ចំណុចក្នុងការចូលរួមអភិវឌ្ឍន៍ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រីរួមមាន៖

១)ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី គ្រប់ក្រសួង ស្ថាប័ន អាជ្ញាធរដែនដី និងសង្គមស៊ីវិល បន្តផ្សព្វផ្សាយអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ និងឯកសារពាក់ព័ន្ធ តាមព្រះរាជានុសាសន៍សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ព្រះប្រធានកិត្តិយសនៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី និងបន្តចុះតាមដានការអនុវត្តច្បាប់ និងបទបញ្ញត្តិពាក់ព័ន្ធនានា ដើម្បីលើកអនុសាសន៍ជូនរាជរដ្ឋាភិបាល។ គ្រប់ក្រសួង ស្ថាប័ន ត្រូវបន្តជំរុញការអនុវត្តផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ របស់ខ្លួនឲ្យកាន់តែមានប្រសិទ្ធភាព។

២)ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ត្រូវបន្តចុះសិក្សាស្វែងយល់អំពីឧបសគ្គរាំងក្នុងការបំពេញតួនាទី និងភារកិច្ចរបស់ស្ត្រី ដែលមានតួនាទីក្នុងការធ្វើសេចក្តីសម្រេចទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងបន្តសិក្សាស្វែងយល់អំពីគោលការណ៍សំខាន់ៗដែលចាំបាច់សម្រាប់ការពង្រឹងសម្ថភាពរបស់ស្ត្រី។

៣)គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ របស់ក្រសួងមហាផ្ទៃ ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងកិច្ចការនារី និងក្រសួងមុខងារសាធារណៈ ត្រូវបង្កើនកិច្ចសហការក្នុងការបន្តអភិវឌ្ឍន៍សមត្ថភាពដល់ស្ត្រីជាថ្នាក់ដឹកនាំនៅថ្នាក់ក្រោមជាតិទាក់ទងនឹងផ្នែកមគ្គុទេសន៍ភាព ច្បាប់ និងបទប្បញ្ញត្តិនានា និងរៀបចំវគ្គបណ្តុះបណ្តាលជំនាញបច្ចេកទេសសម្រាប់ថ្នាក់ដឹកនាំនារី ដើម្បីជួយឲ្យពួកគេអាចបំពេញតួនាទី និងភារកិច្ចដែលរាជរដ្ឋាភិបាលប្រគល់ជូនឲ្យកាន់តែប្រសើរឡើង ព្រមទាំងរៀបចំវគ្គពិសេស សម្រាប់ស្ត្រី និងស្ត្រីវ័យក្មេង ហើយវាយតម្លៃលទ្ធផលឲ្យបានជាក់លាក់។

៤)ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ត្រូវបន្តស្វែងយល់អំពីស្ថានភាពសេដ្ឋកិច្ច និងផលិតកម្មរបស់ស្ត្រីនៅជនបទក្នុងការរក្សាស្ថិរភាពសេដ្ឋកិច្ចគ្រួសារដោយត្រូវយកមាត្រាទី១៤ នៃអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ (CEDAW) មកធ្វើជាគោលដើម្បីពិនិត្យ និងតាមដាន។

៥) ក្រសួងមហាផ្ទៃ និងក្រសួងយុត្តិធម៌បន្តពង្រឹងកិច្ចសហការល្អ រវាងមន្ត្រីនគរបាល និងតុលាការក្នុងការអនុវត្តច្បាប់ឱ្យបានត្រឹមត្រូវទៅតាមសមត្ថកិច្ច និងតួនាទីដែលបានកំណត់ក្នុងនីតិវិធីច្បាប់ជាធរមាន ដើម្បីធានាបានការស្វែងរកយុត្តិធម៌ជូនភាគីពាក់ព័ន្ធហើយត្រូវបន្តបង្កើនការផ្សព្វផ្សាយច្បាប់ស្តីពីការបង្ក្រាបការជួញដូរមនុស្សនិងអំពើអាជីវកម្មផ្លូវភេទព្រមទាំងបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធទៅនឹងសិទ្ធិរបស់ស្ត្រី និងកុមារដល់ចៅក្រមព្រះរាជអាជ្ញា និងមន្ត្រីអនុវត្តច្បាប់ដើម្បីធានានូវភាពយុត្តិធម៌ និងពន្លឿនការដោះស្រាយរឿងក្តីឲ្យបានឆាប់រហ័សជាពិសេសសំណុំរឿងក្តីដែលពាក់ព័ន្ធទៅនឹងស្ត្រី។ ដោយឡែកក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ត្រូវបន្តខិតខំជួយសម្របសម្រួលក្នុងការស្វែងរកសេវាផ្លូវច្បាប់ និងសេវាផ្សេងទៀត សម្រាប់ផ្តល់ជូនដល់ស្ត្រីក្រីក្ររងគ្រោះដោយអំពើហិង្សាទាំងក្នុងករណីមានបណ្តឹង និងក្នុងករណីមិនមានបណ្តឹង។

៦) ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវបន្តគ្រប់គ្រងឲ្យបានហ្មត់ចត់ចំពោះក្រុមហ៊ុនដែលបញ្ជូនពលករ ពលការិនីទៅធ្វើការនៅប្រទេសក្រៅប្រទេស ដោយត្រូវសហការអោយបានល្អជាមួយក្រសួងពាក់ព័ន្ធក្នុងគណៈកម្មាធិការប្រឆាំងអំពើជួញដូរមនុស្ស ជាពិសេសក្រសួងមហាផ្ទៃ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ អ្នកតំណាងពីក្រៅប្រទេស ក្រសួង ស្ថាប័ន ពាក់ព័ន្ធនិងអាជ្ញាធរដែនដី ក្នុងការការពារសិទ្ធិនិងផលប្រយោជន៍របស់ពលករ ពលការិនីព្រមទាំងពង្រឹងការអនុវត្តច្បាប់និង វិធានការនានាក្នុងគោលដៅបង្កើនសុវត្ថិភាពសម្រាប់ប្រជាពលរដ្ឋដែលធ្វើចំណាកស្រុកស្វែងរកការងារធ្វើនៅក្រៅប្រទេស។

៧) ក្រសួងសង្គមកិច្ចអតីតយុទ្ធជននិងយុវនីតិសម្បទា ត្រូវបន្តរៀបចំនិងបង្កើនគម្រោងកម្មវិធីដើម្បីជួយអភិវឌ្ឍន៍ជនពិការជាពិសេសស្ត្រីនិងកុមារដើម្បីឆ្លើយតបទៅនឹងគោលនយោបាយរាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍកម្ពុជា និងយកចិត្តទុកដាក់លើការថែទាំជនរងគ្រោះដោយអំពើហិង្សា និងអំពើជួញដូរមនុស្សជាពិសេស កុមារា កុមារី ក្នុងមណ្ឌលនិងសហគមន៍ដោយសហការជិតស្និទ្ធជាមួយអង្គការមនុស្សធម៌ដែលមានធន្ទៈ និងលទ្ធភាព និងតាមដានជាប្រចាំ។

៨) ដើម្បីរក្សានូវវប្បធម៌ ប្រពៃណីដ៏ល្អរបស់ជាតិ ក្រសួងពត៌មានក្រសួងវប្បធម៌ និងវិចិត្រសិល្បៈត្រូវបន្តត្រួតពិនិត្យតាមដានជាប្រចាំនូវខ្លឹមសាររូបភាព និងការសំដែងនូវកម្មវិធីនីមួយៗដែលបានផ្សព្វផ្សាយតាមរយៈទូរទស្សន៍ និងវេទិកាផ្សេងៗទៀត។ ទន្ទឹមនេះ ក្រសួងព័ត៌មាន ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងក្រសួងពាក់ព័ន្ធត្រូវពិនិត្យឲ្យបានម៉ត់ចត់ និងមានវិធានការយ៉ាងម៉ឺងម៉ាត់បំផុតចំពោះខ្លឹមសារ និងរូបភាពដែលបាននិងកំពុងចាក់បញ្ចាំងតាមទូរទស្សន៍ហើយមានលក្ខណៈរើសអើងចំពោះស្ត្រីបន្ទាបបន្ថោកប្រពៃណីវប្បធម៌និងតម្លៃស្ត្រីខ្មែរ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ត្រូវរៀបចំគណៈកម្មាធិការចម្រុះអន្តរក្រសួងដោយចាត់វិធានការក្នុងការទប់ស្កាត់ការផ្សព្វផ្សាយរូបភាពអាសអាភាសតាមរយៈបច្ចេកវិទ្យា។ ក្រសួងធម្មការ និងសាសនា ត្រូវបន្តសកម្មភាពអប់រំឲ្យបានទូលំទូលាយទូទាំងប្រទេស តាមរយៈនាទីព្រះពុទ្ធសាសនាផ្សារភ្ជាប់នឹងសង្គម។

៩)ក- គ្រប់ក្រសួងស្ថាប័នអាជ្ញាធរដែនដីត្រូវបន្តយកចិត្តទុកដាក់ក្នុងការបង្កើនចំនួនមន្ត្រីរាជការជាស្ត្រីបន្ថែមទៀត និងការតែងតាំងមុខតំណែងឲ្យមានតំណាងស្ត្រីនៅគ្រប់រចនាសម្ព័ន្ធទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ព្រមទាំងជួយឧបត្ថម្ភគាំទ្រទាំងស្មារតី មធ្យោបាយ ថវិកានិងផ្តល់ឱកាសឲ្យមានសំឡេងស្ត្រីចូលរួមផ្តល់យោបល់ក្នុងការសម្រេចតែងតាំង។ ពិនិត្យការតែងតាំងមន្ត្រីរាជការជាស្ត្រីដែលមានសមត្ថភាពជំនួសមន្ត្រីជាស្ត្រីចូលនិវត្តន៍ដែលរួមចំណែករក្សាបាននូវកំណើនចំនួនស្ត្រីក្នុងតួនាទីមានសិទ្ធិសម្រេច។ បង្កើនសមត្ថភាពមន្ត្រីរាជការស៊ីវិលជាស្ត្រីតាមរយៈវគ្គបណ្តុះបណ្តាលទាំងក្នុងនិងក្រៅប្រទេស។ យកចិត្តទុកដាក់ជ្រើសរើសមន្ត្រីរាជការស៊ីវិលជាស្ត្រីសម្រាប់បន្តវេនលើគ្រប់វិស័យជាពិសេសនៅថ្នាក់ក្រោមជាតិ។ យកចិត្តទុកដាក់ចំពោះស្ត្រីមន្ត្រីរាជការស៊ីវិលជាស្ត្រីមុនចូលនិវត្តន៍ដោយដំឡើងឋានន្តរស័ក្តិ និងថ្នាក់ក្នុងប្រភេទក្របខណ្ឌរបស់ខ្លួនតាមអតីតភាពការងារឲ្យស្របតាមគោលការណ៍។

ខ-ស្ថាប័នតុលាការ និងរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ គួរបន្តខិតខំបង្កើនចំនួនក្រឡាបញ្ជីមេធាវីចៅក្រម និងនិស្សិតជាស្ត្រីដើម្បីរួមចំណែកផ្តល់សេវាយុត្តិធម៌ ប្រកបដោយសមធម៌និងប្រសិទ្ធភាពចំពោះករណីមានអំពើហិង្សាលើស្ត្រីនិងកុមារ។

១០) ក្រសួងអប់រំ យុវជននិងកីឡាត្រូវបន្តពិនិត្យស្រាវជ្រាវស្ថានភាពនិស្សិតជានារីទាំងការលំបាកនិងការងារ និងការងាយស្រួលទាំងក្នុងកម្រិតឧត្តមសិក្សា និងក្រោយឧត្តមសិក្សានៅក្នុងគ្រឹះស្ថានរបស់រដ្ឋនិងគ្រឹះស្ថានឯកជនដោយត្រូវធ្វើរបាយការណ៍ដោយឡែក ដើម្បីមានវិធានការដោះស្រាយ។

១១) ក្នុងការអនុវត្តគោលនយោបាយវិមជ្ឈការ ក្រសួងស្ថាប័នទាំងអស់គប្បីយកចិត្តទុកដាក់ជំរុញ និងលើកកម្ពស់ការចូលរួមរបស់ស្ត្រីនៅគ្រប់កំរិតទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីធានាថាស្ត្រីត្រូវទទួលបានផលប្រយោជន៍ពីការផ្តល់សេវាសង្គម សេដ្ឋកិច្ច សេវារដ្ឋបាលនិងសាធារណៈប្រកបដោយសមធម៌ព្រមទាំងជំរុញ និងលើកកម្ពស់តួនាទីក្នុងការចូលរួម និងការទទួលបាននូវសុវត្ថិភាពពីការអនុវត្តគោលនយោបាយ ភូមិ ឃុំ មានសុវត្ថិភាពដែលមានក្រសួងមហាផ្ទៃជាស្នូលក្នុងការដឹកនាំនិងសម្របសម្រួល៕

## ជំនួបពិភាក្សាការងារជាមួយ ឯកឧត្តម Hidehisa Horinouchi អគ្គរាជទូតជប៉ុនប្រចាំកម្ពុជា ពាក់ព័ន្ធនឹងកិច្ចព្រមព្រៀងសហប្រតិបត្តិការរវាងកម្ពុជា-ជប៉ុន ស្តីពី "ពលករជំនាញ"

http://www.mlvt.gov.kh/index. Monday, 18 February 2019 12:34 Written by MLVT

ទីស្តីការក្រសួង៖ នៅក្នុងជំនួបពិភាក្សាការងារជាមួយ ឯកឧត្តម Hidehisa Horinouchi អគ្គរាជទូត ជប៉ុនប្រចាំកម្ពុជា នៅទីស្តីការក្រសួងការងារ ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៩ ពាក់ព័ន្ធនឹងកិច្ចព្រមព្រៀងសហប្រតិបត្តិការរវាងកម្ពុជា-ជប៉ុន ស្តីពី "ពលករជំនាញ"។ ឯកឧត្តមរដ្ឋមន្ត្រី បានថ្លែងអំណរគុណដែលប្រទេស ជប៉ុន ផ្តល់ឱកាសការងារដល់ប្រជាពលរដ្ឋកម្ពុជា តាមរយៈការកែសម្រួលច្បាប់ថ្មីរបស់ជប៉ុន ដែលអនុញ្ញាតិឱ្យពលករអាចដាក់ពាក្យទទួលបានទិដ្ឋាការការងារ (Working Visa) ដែលពីមុនពលករទទួលបានត្រឹមតែជាកម្មសិក្សាការីប៉ុណ្ណោះ។ ប្រព័ន្ធថ្មីនេះ និងផ្ត

ល់ឱកាសដល់ពលករកំរិតជំនាញ និងកំរិតបច្ចេកទេស អាចចូលទៅបំពេញតម្រូវការកង្វះខាតកម្លាំងពលកម្មទៅប្រទេសជប៉ុនបន្ថែមទៀត។ នៅក្នុងជំនួបនេះដែរ ឯកឧត្តម អ៊ិត សំហេង បានថ្លែងអំណរគុណដល់រាជរដ្ឋាភិបាលជប៉ុនក្នុងការជួយអភិវឌ្ឍន៍ប្រទេសកម្ពុជា ជាពិសេសផ្តល់ឱកាសដល់កម្មសិក្សាការីកម្ពុជាទៅហាត់ការនៅប្រទេសជប៉ុនដែលមកដល់បច្ចុប្បន្ននេះ ប្រមាណជាង ៩ពាន់នាក់។

ជាមួយគម្រោងដែលជប៉ុន នឹងដាក់ឱ្យដំណើការនៅប្រព័ន្ធថ្មី ក្នុងទទួលយកពលករពីប្រទេសនានា ទៅធ្វើការនៅជប៉ុន នាខែមេសា ឆ្នាំ២០១៩ នេះ ឯកឧត្តមរដ្ឋមន្រ្តី បញ្ជាក់ថា កម្ពុជាត្រៀមខ្លួនជាស្រេចក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការ លើវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ព្រោះថាជាឱកាសដ៏ល្អមួយ ដែលប្រទេសទាំងពីរនឹងទទួលបាននូវផលប្រយោជន៍ទៅវិញទៅមក ខាងជប៉ុននឹងទទួល បាននូវកម្លាំងពលករពីកម្ពុជាទៅបំពេញនូវតម្រូវការក្នុងវិស័យជាច្រើន ហើយកម្ពុជានឹងមានលទ្ធភាព ក្នុងការផ្តល់ឱកាសបន្ថែមទៅដល់ប្រជាពលរដ្ឋក្នុងការជ្រើសរើសនូវការងាររបស់ខ្លួនតាមចំណង់ចំណូលចិត្តរបស់ពួកគេ ដើម្បីទទួលបាននូវការងារដែលមានប្រាក់ខែខ្ពស់ រួមទាំងចំណេះដឹងនិងវិជ្ជាជីវៈជូនដល់ពួកគាត់ ក្នុងការចូលរួមក្នុងការអភិវឌ្ឍន៍ប្រទេសជាតិ របស់យើងឱ្យកាន់តែរីកចំរើនថែមទៀត។ ភាគីទាំងពីរបានឯកភាពជំរុញឱ្យក្រុមការងារបច្ចេកទេស ពិនិត្យកែសម្រួលសេចក្តីព្រាង អនុស្សរណៈយោគយល់គ្នាលើកិច្ចសហប្រតិបត្តិការ (MOC) ឱ្យបានឆាប់ ក្នុងគោលបំណងដើម្បីបង្កើនទីផ្សារការងារ និងឱកាសការងារដល់ប្រជាជនកម្ពុជា។ តាមការគ្រោងទុក ឯកឧត្តមរដ្ឋមន្ត្រីនឹងដឹកនាំគណៈប្រតិភូកម្ពុជាទៅចូលរួមពិធីចុះហត្ថលេខា អនុស្សរណៈយោគយល់គ្នាលើកិច្ចសហប្រតិបត្តិការ (MOC) នៅទីក្រុងតូក្យូ ក្នុងកំឡុងសប្តាហ៍ទី៣ ខែមីនា ឆ្នាំ២០១៩៕

## សង្គមស៊ីវិលស្នើសមត្ថកិច្ចតាមចាប់អ្នកពាក់ព័ន្ធករណីឆបោកម៉ាឡេស៊ី៤៧នាក់មកធ្វើការខុសច្បាប់នៅកម្ពុជា

https://www.rfa.org/khmer/news/ ដោយ សុ ជីវី 2019-02-16

មន្ត្រីអង្គការសង្គមស៊ីវិលធ្វើការងារផ្នែកការពារសិទ្ធិមនុស្សនៅខេត្តបន្ទាយមានជ័យ ស្នើឲ្យសមត្ថកិច្ចតាមចាប់មេខ្យល់ និងអ្នកពាក់ព័ន្ធដែលឆបោកជនជាតិម៉ាឡេស៊ីចំនួន៤៧ ក្រោយពីតុលាការ ដោះលែងជនរងគ្រោះទាំងនោះកាលពីថ្ងៃទី១៥ កុម្ភៈ។ មន្ត្រីសម្របសម្រួលសមាគមការពារសិទ្ធិមនុស្សអាដហុក (Adhoc) ខេត្តបន្ទាយមានជ័យ លោក ស៊ុំ ច័ន្ទគា លើកឡើងថា អ្នកពាក់ព័ន្ធនឹងករណីឆបោកជនរងគ្រោះត្រូវនាំមកផ្តន្ទាទោស ព្រោះជនសង្ស័យធ្វើឲ្យខូចមុខមាត់របស់ប្រទេសកម្ពុជាលើឆាកអន្តរជាតិ៖ «ហើយក៏ជាការចាប់ផ្តើមនៃប្រទេសមានអំណាច និងប្រទេសជឿនលឿនយកកម្ពុជាធ្វើជាទីកន្លែងសម្រាប់ធ្វើការបោកប្រាស់ជួញដូរមនុស្សដែរ។ ដូច្នេះយើងត្រូវទប់ស្កាត់កុំឱ្យកេរ្តិ៍ឈ្មោះរបស់ប្រទេសធ្លាក់ទៅតាមគេលើកឡើងដូច្នេះ ដែលគេមកមកកម្ពុជាជាប្រទេសមានច្បាប់ដែរ ប៉ុន្តែមិនអនុវត្តច្បាប់»។ កាលពីថ្ងៃទី១៥ កុម្ភៈ សាលាដំបូងខេត្តបន្ទាយមានជ័យបានដោះលែងជនជាតិម៉ាឡេស៊ីចំនួន ៤៧នាក់ ឲ្យមានសេរីភាពឡើងវិញ បន្ទាប់ពីពួកគេជាប់ពន្ធនាគារក្នុងខេត្តនេះអស់ជាង១ខែ។

កាសែតក្នុងស្រុកបានសម្ភាសន៍ជនជាតិម៉ាឡេស៊ីម្នាក់ក្នុងចំណោម ៤៧នាក់ បានឲ្យដឹងថា មេខ្យល់បានល្បួងលោមឲ្យគេមកធ្វើការនៅកម្ពុជាដោយសន្យាផ្តល់ប្រាក់ខែល្អ និងសំបុត្រយន្តហោះមកកម្ពុជាដោយឥតថ្លៃ ប៉ុន្តែ ជនរងគ្រោះមិនបានបញ្ជាក់ថា មេខ្យល់ ជាជនជាតិខ្មែរ ឬជាជនបរទេសនោះទេ។ ជនរងគ្រោះបន្ថែមទៀតថា នៅពេលមកដល់កម្ពុជា មេខ្យល់ក៏បានចាប់បង្ខាំងពួកគេនៅក្នុងផ្ទះមួយកន្លែងក្នុងខេត្តសៀមរាប ហើយកាលពីថ្ងៃទី១១ ធ្នូ សមត្ថកិច្ចបានចាប់ជនជាតិម៉ាឡេស៊ីទាំង៤៧នាក់បញ្ជូនទៅឃុំខ្លួននៅពន្ធនាគារខេត្តបន្ទាយមានជ័យ ដោយចោទប្រកាន់ចូលមកកម្ពុជាខុសច្បាប់។

អ្នកនាំពាក្យក្រសួងយុត្តិធម៌លោក ជិន ម៉ាលីន មានប្រសាសន៍ប្រាប់អាស៊ីសេរីនៅរសៀលថ្ងៃទី១៦កុម្ភៈ ថា ការធ្វើដោះលែងជនបរទេសទាំងនេះធ្វើឡើងតាមនីតិវិធីរបស់តុលាការ។ លោកបន្តថា ការដោះលែងនេះគ្រាន់តែជា

ដំហានដំបូង ហើយសមត្ថកិច្ចនឹងតាមរកអ្នកពាក់ព័ន្ធមកទទួលទោសតាមច្បាប់បន្តទៀត៖ «ហើយបើសិនរឿងនេះពាក់ព័ន្ធអ្នកផ្សេង ធម្មតានីតិវិធីរបស់តុលាការ គេនឹងស៊ើបសួរបន្តទៀត ប៉ុន្តែអ្នកដែលស្ថិតនៅក្នុងរបាយការណ៍នីតិវិធីរកទៅអត់មានមូលដ្ឋានបទល្មើសដូច្នេះហើយបានជាគេធ្វើការដោះលែង»។

លោក ស៊ុំ ច័ន្ទគា លើកឡើងថា រឿងនេះសមត្ថកិច្ចត្រូវចាប់អ្នកពាក់ព័ន្ធដាក់ទោសឲ្យបានធ្ងន់ធ្ងរ និងឲ្យបានឆាប់រហ័ស ដើម្បីកុំឲ្យជនទាំងនោះជួញដូរមនុស្សខុសច្បាប់នៅថ្ងៃក្រោយទៀត៕

## ពលករខ្មែរ១២នាក់ជួបគ្រោះថ្នាក់ចរាចរណ៍នៅថៃ

https://www.vodhotnews.com/ លោក ពេជ្រ ចំរុង ១៧ កុម្ភៈ ២០១៩ ម៉ោង ៤:៣៩ ល្ងាច

ពលករខ្មែរចំនួន ១២នាក់ ត្រូវបានរាយការណ៍ថា បានរងរបួស បន្ទាប់ពីពួកគេជួបគ្រោះថ្នាក់ចរាចរណ៍នៅពេលធ្វើដំណើរទៅកាន់ខេត្តជាប់ព្រំដែនកម្ពុជា-ថៃ ដើម្បីបន្តទិដ្ឋាការរបស់ពួកគេ។ សារព័ត៌មានថៃបាងកកប៉ុស្តិ៍ បានចុះផ្សាយថា ពលករខ្មែរ ១២នាក់ និងអ្នកបើកជាជនជាតិថៃម្នាក់ បានរងរបួស បន្ទាប់ពីរថយន្តរបស់ពួកគេបុកជាមួយរថយន្តដឹកទំនិញមួយគ្រឿង នៅលើកំណាត់ផ្លូវជាតិលេខ ៣៥៩ ក្នុងស្រុកស៊ីមហាផូ ស្ថិតក្នុងខេត្តស្រះកែវ នៅព្រឹកថ្ងៃអាទិត្យ វេលាម៉ោង ៥កន្លះ។ សារព័ត៌មានថៃបាងកក ប៉ុស្តិ៍ ចុះផ្សាយបន្តថា គ្រោះថ្នាក់ចរាចរណ៍នេះ បានកើតឡើងនៅពេលពលករខ្មែរទាំង ១២នាក់ ធ្វើដំណើរទៅស្រុកអរញ្ញប្រះថេត ក្នុងខេត្តស្រះកែវ ដែលជាខេត្តជាប់ព្រំដែនជាមួយប្រទេសកម្ពុជា ដើម្បីបន្តទិដ្ឋាការរបស់ពួកគេ។ សារព័ត៌មានថៃបានដកស្រង់សម្ដីអាជ្ញាធរថៃមកចុះផ្សាយថា ក្រោយហេតុការណ៍គ្រោះថ្នាក់ចរាចរណ៍នេះ ពលករខ្មែរទាំង ១២នាក់ ត្រូវបានបញ្ជូនទៅសម្រាកព្យាបាលនៅមន្ទីរពេទ្យស៊ីមហាផូ ស្ថិតក្នុងខេត្តស្រះកែវ ប្រទេសថៃ៕

## ពលរដ្ឋខ្មែរ៧៣នាក់ត្រូវនគរបាលថៃចាប់ខ្លួន និងចោទពីបទល្មើសផ្សេងៗគ្នា

https://www.rfa.org/khmer/news/ ដោយ សុ ជីវី 2019-02-16

ប៉ូលិសថៃ ចាប់ពលរដ្ឋខ្មែរ ៧៣នាក់ បន្ទាប់ពីចុះឆែកឆេរទីតាំងចំនួន ២២០កន្លែង នៅក្នុងទីក្រុងបាងកក និងតាមខេត្តមួយចំនួន កាលពីព្រឹកថ្ងៃទីសុក្រ ទី១៥ ខែកុម្ភៈ។ ជនជាតិខ្មែរ ៤នាក់ ត្រូវបានចាប់ខ្លួនពីបទស្នាក់នៅហួសទិដ្ឋាការ ៣៨នាក់ ជាប់ចោទពីបទចូលក្នុងប្រទេសថៃដោយខុសច្បាប់ ហើយ ៣១នាក់ផ្សេងទៀតជាប់ចោទពីបទប្រព្រឹត្តបទល្មើស។

អនុប្រធាននៃអគ្គនាយកដ្ឋាននគរបាលអន្តោប្រវេសន៍ថៃ លោក អ៊ិតធិពល អ៊ិតធីសានរ៉ុនណាឆៃ ( Itthipol Itthisarnronnachai ) ប្រាប់សារព័ត៌មានថៃថា អ្នកត្រូវចាប់ខ្លួន នឹងត្រូវប្រឈមមុខច្បាប់ ដោយសារប្រព្រឹត្តបទល្មើសក្នុងទឹកដីថៃ។ រដ្ឋាភិបាលថៃប្រើប្រាស់កម្លាំងនគរបាលចម្រុះ មាននគរបាលអន្តោប្រវេសន៍ នគរបាលទេសចរណ៍ និងភ្នាក់ងារសំងាត់ផ្សេងទៀតក្នុងយុទ្ធនាការ X Ray។ ប៉ូលិសទាំងនោះ ត្រូវបានដាក់ពង្រាយនៅទីក្រុងបាងកក និងនៅតាមបណ្ដាខេត្តទូទាំងប្រទេស។ ទីតាំងដែលចុះត្រូវឆែកឆេរ ភាគច្រើនធ្វើឡើងនៅតាមសាលារៀន ក្រុមហ៊ុនឯកជន ភោជនីយដ្ឋាន និងក្លឹបកម្សាន្ត៕

## លោក ឈាង ធុំ អគ្គនាយកមជ្ឈមណ្ឌល បណ្តុះបណ្តាលភាសាជប៉ុន ស៊ីអិល បញ្ជាក់ថា មិនបានបោកប្រាស់ លុយនិស្សិត ជាថ្នូរសន្យាបញ្ជូន ទៅធ្វើការនៅជប៉ុននោះទេ

https://www.dap-news.com/ ByID:114 Posted on 18 February 2019 | 13:56

ភ្នំពេញ៖ លោក ឈាង ធុំ ប្រធានក្រុមប្រឹក្សាភិបាល ក្រុមហ៊ុនស៊ីអិល និងអគ្គនាយកមជ្ឈមណ្ឌល បណ្ដុះបណ្ដាលភាសាជប៉ុន ស៊ីអិល នៅថ្ងៃទី១៨ ខែ កុម្ភៈ ឆ្នាំ ២០១៩នេះ បានចេញមុខបំភ្លឺ និងអះអាងបញ្ជាក់ថា លោក

មិនបានបោកប្រាស់យកលុយ របស់សិស្ស និស្សិតក្រីក្រ ជាថ្នូរសន្យាបញ្ជូនទៅធ្វើការ នៅប្រទេសជប៉ុន ដូចការចោទប្រកាន់នានានោះទេ។ លោក ឈាង ធុំ ប្រធានក្រុមប្រឹក្សាភិបាល ក្រុមហ៊ុនស៊ីអិល និងអគ្គនាយកមជ្ឈមណ្ឌល បណ្តុះបណ្តាលភាសាជប៉ុនស៊ីអិល បានចេញមុខបំភ្លឺបែបនេះ បន្ទាប់ពីមានការចោទប្រកាន់ថា មជ្ឈមណ្ឌលបណ្តុះបណ្តាលភាសាជប៉ុនស៊ីអិល បោកប្រាស់និស្សិតក្រីក្រ មកពីតាមបណ្តាខេត្តជាច្រើននាក់ គិតជាទឹកប្រាក់រាប់ម៉ឺនដុល្លារ តាមរយៈការសន្យាបញ្ជូន ទៅធ្វើការនៅប្រទេសជប៉ុន ប៉ុន្តែមិនធ្វើតាមពាក្យសន្យានោះឡើយ។

យោងតាមលិខិតបំភ្លឺ របស់ក្រុមហ៊ុនស៊ីអិល បានបញ្ជាក់ថា "កាលពីថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៨ ក្រុមហ៊ុនយើងខ្ញុំ បានដាក់ពាក្យបណ្តឹង ប្តឹងឈ្មោះ ជា វីរៈ អតីតបុគ្គលិកផ្នែកទីផ្សារ ដែលបានកេងប្រវ័ញ្ចលុយក្រុមហ៊ុនអស់ ៨៣០០ដុល្លារ និងលួចយករថយន្តម៉ាកកាមេរី ពណ៌ទឹកមាសមួយគ្រឿង។ ដោយមានការខឹងសម្បា និងមានចេតនាចង់បង្ខូចកេរ្តិ៍ឈ្មោះ កិត្តិយសរបស់ក្រុមហ៊ុន កាលពីថ្ងៃទី៤ ខែ មករា ឆ្នាំ ២០១៩ឈ្មោះ ជា វីរៈ បានញុះញង់ដល់អតីតសិក្ខាកាមចំនួន៩នាក់ ដែលបានបោះបង់ការសិក្សាចោល ឲ្យដាក់ពាក្យបណ្តឹង ប្តឹងតំណាងក្រុមហ៊ុន ទៅសាលាដំបូងរាជធានីភ្នំពេញ។ ចំពោះពាក្យបណ្តឹងនេះ ក្រុមហ៊ុនសូមធ្វើការ បដិសេធចោលទាំងស្រុង និងសូមបំភ្លឺ ជូនសាធារណជនជាតិ និងអន្តរជាតិ កុំឲ្យមានការភ័ន្តច្រឡំដូចខាងក្រោម៖

១.ចំពោះសិក្ខាកាមឈ្មោះ វ៉ាញ បូរី , រៀន សុជា , យូ វេងហេង ,ស៊ន ដាវ៉ា ,និងអ៊ិចិន្តា រដ្ឋបាលមជ្ឈមណ្ឌលបណ្តុះបណ្តាល ភាសាជប៉ុនស៊ីអិល បានធ្វើការជូនដំណឹង ជាសាធារណៈ ស្តីពីការបោះបង់ចោលការសិក្សា តាំងពីខែកក្កដា ឆ្នាំ ២០១៨មកម្ល៉េះ។

២.ចំពោះសិក្ខាកាមឈ្មោះ ងួន ប្រុសពៅ និងម៉េង ស្រីល័ក្ខរដ្ឋបាលមជ្ឈមណ្ឌល បណ្តុះបណ្តាលភាសាជប៉ុនស៊ីអិល ក៏បានធ្វើសេចក្តីជូនដំណឹងជាសាធារណៈ ស្តីពីការបោះបង់ចោលការសិក្សា តាំងពីខែ វិច្ឆិកា ឆ្នាំ២០១៨ មកម្ល៉េះ។

សេចក្តីបំភ្លឺដដែលបញ្ជាក់ថា ចំពោះករណីឈ្មោះ ជា វីរៈ ដែលបានកេងប្រវ័ញ្ច យកលុយក្រុមហ៊ុនអស់ ៨៣០០ដុល្លារ និងលួចយករថយន្ត ម៉ាកកាមេរី ពណ៌ទឹកមាសមួយគ្រឿង ក្រុមហ៊ុនកំពុងមានចំណាត់ការតាមផ្លូវច្បាប់ នៅឯសាលាដំបូងរាជធានីភ្នំពេញ។ ចំពោះករណីអតីតសិក្ខាកាមទាំង៩នាក់ ក្នុងមជ្ឈមណ្ឌលបណ្តុះបណ្តាលភាសាជប៉ុន ស៊ី.អិល នៃក្រុមហ៊ុនស៊ី.អិល នឹងធ្វើការ សម្របសម្រួល ដោយការ ទទួលខុសត្រូវទាំងស្រុង ឬចាត់ការទៅតាមផ្លូវច្បាប់ តាមការដាក់ស្តែង។ បុគ្គលទាំងឡាយណា បានផ្តល់នូវព័ត៌មានមិនពិត ធ្វើឲ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរ ដល់កិត្តិយសរបស់ក្រុមហ៊ុន សូមបញ្ឈប់ជាបន្ទាន់ ពុំដូច្នោះទេ ក្រុមហ៊ុននឹងចាត់ការតាមនិតិវិធីច្បាប់ ។ លោក ឈាង ធុំ ក៏បានលើកឡើងផងដែរថា កាលពីថ្ងៃទី១៣ ខែកុម្ភៈកន្លងទៅ មជ្ឈមណ្ឌលបណ្តុះបណ្តាល ភាសាជប៉ុនស៊ីអិល បានបញ្ជូនសិក្ខាកាមចំនួន៩នាក់ ទៅធ្វើការនៅប្រទេសជប៉ុន ហើយគ្រោងនឹងបញ្ជូនចេញ ៤នាក់បន្ថែមទៀត នៅថ្ងៃទី២១ កុម្ភៈខាងមុខនេះ។

គួរបញ្ជាក់ថា មជ្ឈមណ្ឌលបណ្តុះបណ្តាល ភាសាជប៉ុនស៊ី.អិល នៃក្រុមហ៊ុនស៊ីអិល គឺជាក្រុមហ៊ុនឯកជនស្របច្បាប់ ក្នុងការជ្រើសរើស បណ្តុះបណ្តាលបញ្ជូន និងគ្រប់គ្រងពលករ ដែលទទួលស្គាល់ដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានលិខិតអនុញ្ញាត ឲ្យបើកបណ្តុះបណ្តាល ពីការិយាល័យច្រកចេញចូលតែមួយ ក្នុងខណ្ឌដង្កោនិងមាន វិញ្ញាបនបត្រចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម ពីក្រសួងពាណិជ្ជកម្ម ហើយលោក ឈាង ធុំ ជាម្ចាស់គ្រប់គ្រងយ៉ាងពិតប្រាកដ មិនមែនឈរឈ្មោះតំណាងឲ្យនរណាម្នាក់ ដូចការចោទប្រកាន់នោះទេ៕

# ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៩

## លោក ហ៊ុន សែន ជំរុញទៅមន្ត្រីក្រោមឱវាទឲ្យការពារសិទ្ធិ និងផលប្រយោជន៍ពលករចំណាកស្រុក

https://www.vodhotnews.com/ លោក យុត សុគន្ធ ១៩ កុម្ភៈ ២០១៩

លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន កាលពីថ្ងៃម្សិលមិញនេះ បានជំរុញទៅស្ថាប័នពាក់ព័ន្ធ ឲ្យសហការគ្នាឲ្យបានល្អ ដោយថា ដើម្បីការពារសិទ្ធិ និងផលប្រយោជន៍របស់ពលករចំណាកស្រុក។ សរសេរផ្សព្វផ្សាយលើទំព័រហ្វេសប៊ុកផ្ទាល់ខ្លួនកាលពីល្ងាចម្សិលមិញនេះ លោក ហ៊ុន សែន បានបញ្ជាទៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវគ្រប់គ្រងឲ្យបានហ្មត់ចត់ចំពោះក្រុមហ៊ុនដែលបញ្ជូនពលករទៅធ្វើការងារក្រៅប្រទេស និងត្រូវសហការឲ្យបានល្អជាមួយក្រសួងមហាផ្ទៃ ក្រសួងការបរទេស រួមទាំងមន្ត្រីតំណាងកម្ពុជានៅក្រៅប្រទេស ដើម្បីពង្រឹងការអនុវត្តច្បាប់ និងដាក់វិធានការនានាក្នុងគោលដៅបង្កើនសុវត្ថិភាពសម្រាប់ពលរដ្ឋដែលធ្វើចំណាកស្រុក។

លោក ហ៊ុន សែន សរសេររៀបរាប់បន្ថែមថា៖ «**ត្រូវសហការឲ្យបានល្អជាមួយក្រសួងពាក់ព័ន្ធក្នុងគណៈកម្មាធិការប្រឆាំងអំពើជួញដូរមនុស្ស ជាពិសេសក្រសួងមហាផ្ទៃ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ អ្នកតំណាងពីក្រៅប្រទេស ក្រសួងស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដី ក្នុងការការពារសិទ្ធិ និងផលប្រយោជន៍របស់ពលករ ពលការិនី ព្រមទាំងពង្រឹងការអនុវត្តច្បាប់ និងវិធានការនានា ក្នុងគោលដៅបង្កើនសុវត្ថិភាពសម្រាប់ប្រជាពលរដ្ឋ ដែលធ្វើចំណាកស្រុកស្វែងរកការងារធ្វើនៅក្រៅប្រទេស**»។

នាយកប្រតិបត្តិមជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស លោក មឿន តុលា ទទួលស្គាល់ថា កន្លងមកក្រសួងការងារបានធ្វើការងារជាច្រើន ដើម្បីសម្រួលដល់ពលករចំណាកស្រុក ប៉ុន្តែ លោកនៅតែមើលថា បញ្ហារបស់ពលករចំណាកស្រុកទាំងនោះ នៅតែបន្តកើតមាន។ លោក មឿន តុលា លើកឡើងថា ពលរដ្ឋខ្មែរបង្ខំចិត្តធ្វើចំណាកស្រុកទៅធ្វើការងារទាំងខុសច្បាប់នោះ ដោយសារតែនីតិវិធីដើម្បីទទួលបានភាពស្របច្បាប់នោះ មានភាពស្មុគស្មាញ ការចំណាយលុយច្រើន និងការរង់ចាំយូរ ខណៈបញ្ហាផ្សេងៗទៀតកើតឡើងដោយខ្សោយការអនុវត្តច្បាប់ និងខ្វះយន្តការទប់ស្កាត់។ លោក មឿន តុលា មានប្រសាសន៍ថា៖ «**នីតិវិធីហ្នឹង យើងគួរតែធ្វើវាឲ្យសាមញ្ញ។ ទី២ រឿងតម្លៃ តម្លៃគួរតែប្រកាសជាសាធារណៈ ដូចជា តម្លៃ Passport [លិខិតឆ្លងដែន] តម្លៃជួសឈាម តម្លៃពិនិត្យសុខភាពរបស់ពលករ។ល។ និងដាក់ឲ្យវាមានតម្លាភាព និងកុំឲ្យមានអំពើពុករលួយក្នុងហ្នឹង។ តែកាលណាយកថែមពីលើតម្លៃដែលរដ្ឋចេញឲ្យទៀត អាហ្នឹងខាងក្រុមហ៊ុននឹងយកហួសជាងហ្នឹងទៀតហើយ។ ទី៣ កុំតម្រូវឲ្យក្រុមហ៊ុនចុះឈ្មោះពលករដោយឲ្យរង់ចាំយូរពេក ចាំមាន Order [ការបញ្ជា] ចាំចុះ។ បើសិនអត់មានទេ កុំចុះ យើងដឹងហើយពលរដ្ឋខ្មែរតែពេលទៅចុះឈ្មោះគាត់ត្រូវបង់លុយ បើបង់លុយ គាត់ត្រូវខ្ចីលុយគេ។ អញ្ចឹង កាលណារង់ចាំកាន់តែយូរ គាត់ជំពាក់ការប្រាក់កាន់តែច្រើន**»។

របាយការណ៍នៃសន្និបាតបូកសរុបការងាររបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចេញកាលពីថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៨ បង្ហាញថា រដ្ឋាភិបាលកម្ពុជាបានផ្តល់សេវាស្វែងរកការងារធ្វើនៅក្រៅប្រទេសដល់ពលរដ្ឋចំនួនជាង ១លាន ២សែននាក់ ខណៈនៅឆ្នាំ២០១៩នេះ កម្ពុជាគ្រោងបញ្ជូនពលករខ្មែរចំនួន ៥ពាន់នាក់ទៀត ឲ្យទៅបម្រើការងារនៅប្រទេសគុយវ៉ែត។

របាយការណ៍របស់ក្រសួងមហាផ្ទៃឲ្យដឹងថា រយៈពេល ៦ខែក្នុងឆ្នាំ២០១៨ ពលករខ្មែរចំនួន ១៩ ៨៦៩នាក់ត្រូវបានជួយសង្គ្រោះ និងបញ្ជូនត្រឡប់មកពីប្រទេសចំនួន ១៨ បន្ទាប់ពីពួកគេចាញ់បោកមេខ្យល់ និងក្រុមហ៊ុននាំពលករទៅធ្វើការដោយខុសច្បាប់ ខណៈពលករខ្មែរ ១៨៥នាក់បានស្លាប់ ដោយបញ្ជូនត្រឡប់មកកម្ពុជាវិញតាមច្រកព្រំដែនផងដែរ។ របាយការណ៍ដដែលនេះ បញ្ជាក់ថា ពលករខ្មែរបម្រើការងារនៅឯបរទេស បានរងការរំលោភបំពានពីសំណាក់និយោជក ការជួញដូរផ្លូវភេទ ការរៀបការក្លែងក្លាយ និងការកេងប្រវ័ញ្ចកម្លាំងពលកម្ម៕

# មន្ត្រីជំនាញត្រូវការពេលវេលាបន្ថែមទៀត ដើម្បីកែលម្អសេចក្ដីព្រាងច្បាប់ស្ដីពីការពរពោះជំនួស

https://www.rfa.org/khmer/news/ ដោយ សុ ជីវី 2019-02-19

ក្រុមការងារអន្តរក្រសួង ដឹកនាំដោយក្រសួងកិច្ចការនារីកំពុងរួមគ្នាចងក្រងច្បាប់ ស្ដីពីការពរពោះជំនួសក្នុងគោលបំណងទប់ស្កាត់អំពើជួញដូរមនុស្ស និងបទល្មើស ដែលកើតឡើងក្នុងវង្វង់បញ្ហានេះ។ មន្ត្រីផ្នែកទប់ស្កាត់អំពើជួញដូរមនុស្សឲ្យដឹងថាច្បាប់នេះនៅមិនទាន់អាចចេញរួចនៅឡើយ គឺត្រូវរង់ចាំការផ្ទៀងផ្ទាត់បន្ថែមទៀត។ ស្ត្រីខ្មែរជាច្រើននាក់បានក្លាយជាជនរងគ្រោះដោយសារអាជីវកម្មពរពោះជំនួស។ មកដល់ពេលនេះមានស្ត្រីជាង៣០នាក់កំពុងស្ថិតក្រោមការត្រួតពិនិត្យរបស់តុលាការ ដើម្បីធានាថាពួកគេនឹងមិនលក់ដូរកូនៗ ទៅឲ្យក្រុមបរទេស ដែលជួលពួកគេឲ្យពរពោះ។ អ្នកការពារសិទ្ធិមនុស្សស្នើដល់មន្ត្រីជំនាញពាក់ព័ន្ធអោយពិនិត្យអោយបានដិតដល់ ដើម្បីធានាថាច្បាប់នេះមានវិសាលភាពគ្រប់គ្រាន់នឹងការពារសិទ្ធិស្ត្រី និងកុមារពាក់ព័ន្ធនឹងការពរពោះជំនួស។

រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍របស់គណៈកម្មាធិការប្រឆាំងការជួញដូរមនុស្ស អ្នកស្រី ជូ ប៊ុនអេង អោយដឹងថា ក្រុមការងារពិភាក្សាសេចក្ដីព្រាងច្បាប់ ស្ដីពីការពរពោះជំនួសកំពុងពិនិត្យបន្ថែមទៀតទៅលើគោលបំណងនៃច្បាប់នេះ «ព្រោះឥឡូវហ្នឹងកំពុងតែជជែកគ្នាថា សេចក្ដីព្រាងច្បាប់នេះមានគោលដៅយ៉ាងម៉េច? បើសិនជានិយាយអំពីបទល្មើសបានន័យថា ត្រូវហាមឃាត់ គឺជាច្បាប់ដែលមានទំនោរទៅរកការហាមឃាត់មិនឲ្យធ្វើ។ អញ្ចឹងកំពុងតែយកមកមើលឡើងវិញ»។

សេចក្ដីព្រាងច្បាប់មួយមានកម្រាស់ ២៧ទំព័រ ៨ជំពូក រៀបចំដោយក្រសួងយុត្តិធម៌ ដែលអាស៊ីសេរីទទួលបានបង្ហាញថា គោលដៅនៃច្បាប់នេះ គឺធានាការអនុវត្តឲ្យបានត្រឹមត្រូវនូវការពរពោះជំនួស ដើម្បីការពារសិទ្ធិរបស់ជនដែលពាក់ព័ន្ធទៅនឹងការពរពោះជំនួស ជាពិសេស ស្ត្រី និងកុមារអោយបានស្របតាមបញ្ញត្តិច្បាប់ និងការពារ ទប់ស្កាត់ មិនឲ្យមានអាជីវកម្មតាមរយៈសេវាពរពោះជំនួស។ ច្បាប់នេះគ្របដណ្ដប់ទៅលើការពរពោះជំនួស ដោយផ្អែកលើពាក្យសុំធ្វើនៅក្នុងប្រទេសកម្ពុជា។ សេចក្ដីព្រាងច្បាប់នេះមានគោលការណ៍មូលដ្ឋានសំខាន់ចំនួន ៤រួមមានគោរពសេរីភាពឆន្ទៈបុគ្គល ដែលពាក់ព័ន្ធនឹងការពរពោះជំនួសផ្ដល់លទ្ធភាពចំពោះប្ដីប្រពន្ធ ដែលពុំអាចពរពោះដោយខ្លួនឯងបានហាមឃាត់ការធ្វើអាជីវកម្មក្នុងរឿងពរពោះជំនួស គោរពសិទ្ធិសេរីភាព សេចក្ដីថ្លៃថ្នូរ និងលើកកម្ពស់សុខុមាលភាព សុវត្ថិភាពរបស់ស្ត្រីជាពិសេសស្ត្រីពរពោះជំនួស និងគាំពារសុខុមាលភាព ឧត្តមប្រយោជន៍នៃកុមារកើតដោយការពរពោះជំនួស។ បើតាមសេចក្ដីព្រាងច្បាប់ដដែលនេះ គេនឹងបង្កើតឲ្យមានគណៈកម្មាធិការជាតិគ្រប់គ្រងការពរពោះជំនួស គណៈកម្មការជំនាញ និងការិយាល័យទទួលពាក្យសុំ។ ច្បាប់នេះក៏នឹងសម្រេចពីបុគ្គលភាព ដែលកំណត់ថានរណាជាឪពុក និងម្ដាយរបស់កូនដែលកើតដោយការពរពោះជំនួស និងសុំកូន ដែលនិយាយពីការស្នើសុំកូនដែលកើតមកនោះយកទៅចិញ្ចឹម។ ក្រៅពីនេះ ច្បាប់ស្ដីពីការពរពោះជំនួស ក៏មានចែងពីទោសបញ្ញត្តិនានាទាក់ទងនឹងការទិញដូរមេជីវិតញី ឈ្មោល ឬអំប្រ៊ីយ៉ុង ដែលបង្កជាកំណើតកូន អំពើអន្តរការី ការធ្វើអាជីវកម្មការពរពោះ ការពរពោះជំនួសដោយមិនបានចុះបញ្ជីតាមច្បាប់ និងការផ្សព្វផ្សាយជាសាធារណៈទាក់ទងនឹងការពរពោះ។

អ្នកស្រី ជូ ប៊ុនអេង អោយដឹងទៀតថា សេចក្ដីព្រាងច្បាប់ស្ដីពីការពរពោះជំនួសនៅមានចំណុចត្រូវកែលម្អដែលអាចនឹងចំណាយពេលយូរបន្ថែមទៀត៖ «ដោយសារតែវានៅជាសេចក្ដីព្រាងច្បាប់នៅឡើយ ហើយបទល្មើសក៏កំពុងតែកើតមានថ្មី អញ្ចឹងយើងមិនប្រញាប់ប្រញាល់ពេកទេ»។ អ្នកស្រីបន្តថានៅពេលដែលច្បាប់នេះពុំទាន់អាចចេញរួចអាជ្ញាធរនៅតែអាចប្រើច្បាប់ព្រហ្មទណ្ឌ ដែលមានស្រាប់ចំពោះការប្រព្រឹត្តល្មើសដល់ការជួញដូរមនុស្សកើតពីករណីពរពោះជំនួសនេះ។

កាលពីឆ្នាំ២០១៧ តុលាការរាជធានីភ្នំពេញបានកាត់ទោសកាលពីពេលកន្លងទៅបានកាត់ទោសស្ត្រីជនជាតិអូស្ត្រាលី ឈ្មោះ ថាំមី ដាវីស ឆាស៍(Tammy Davis- Charles) និងខ្មែរ ២នាក់ទៀតដាក់ពន្ធនាគារម្នាក់ៗ មួយឆ្នាំកន្លះ ពិន័យប្រាក់ ៤លានរៀល ករណីអន្តរការីរវាងអ្នកសុំកូន និងស្ត្រីពរពោះ និងផ្ដល់ឯកសារដោយទុច្ចរិត តាមមាត្រា

៣៣២ និង មាត្រា៦៣២ នៃក្រមព្រហ្មទណ្ឌ។ ស្ត្រីជនជាតិអូស្ត្រាលីរូបនេះ បានជួលស្រីខ្មែរ ២នាក់ឱ្យពពោះកូនជំនួស និងបញ្ជូនក្មេងដែលកើតទៅឱ្យអតិថិជននៅក្រៅប្រទេស។ ក្នុងនោះអាជ្ញាធរបានរកឃើញថាមានការបន្លំឯកសារមួយចំនួនរួមមានឯកសារបញ្ជាក់អត្តសញ្ញាណរបស់ទារក មានសំបុត្រកំណើតជាដើម។

ក្នុងឆ្នាំ២០១៨ តុលាការក្រុងភ្នំពេញសម្រេចឃុំខ្លួនមនុស្ស ៥នាក់ មានជនជាតិចិនដែរ ដោយចោទប្រកាន់ពីបទជួញដូរមនុស្សដោយឆ្លងដែន និងបទអន្តរការីជាមួយស្ត្រីពពោះនេះដែរ។ ក្នុងសំណុំរឿងនេះស្ត្រីខ្មែរជាង ៣០នាក់ដែលសុទ្ធសឹងតែជាស្ត្រីមានផ្ទៃពោះ ដែលគេជួលអោយពរពោះជំនួសក៏ត្រូវអាជ្ញាធរឃាត់ខ្លួនពីបទ«ការជួញដូរមនុស្សដោយឆ្លងដែន»ក្រោមមាត្រា ១៦ នៃច្បាប់ស្តីពីការបង្ក្រាបការជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្ម។ ពួកគេប្រឈមនឹងទោសទណ្ឌនៃអំពើជួញដូរមនុស្សតាមរយៈការការលក់ដូរកូនក្នុងផ្ទៃ។ ពេលនេះពួកគេបាននៅក្រៅឃុំ ប៉ុន្តែស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ។ ពួកគេធានាអះអាងថាចិញ្ចឹមកូនដែលកើតពីផ្ទៃពួកគេ ដោយមិនយកកូននោះធ្វើអាជីវកម្មទេ។

ប្រធានគ្រប់គ្រងការិយាល័យឃ្លាំមើលសិទ្ធិមនុស្សនៃអង្គការសិទ្ធិមនុស្ស លីកាដូ លោក អំ សំអាត លើកឡើងថា ច្បាប់នេះមានភាពចាំបាច់នៅក្នុងពេលដែលបទល្មើសជួញដូរមនុស្សក្រោមរូបភាពពរពោះជំនួសនេះកើតឡើង។ លោកថាពេលនេះក្រុមស្ត្រីបានក្លាយជាជនរងគ្រោះនៃអាជីវកម្មនេះ ចំណែកកុមារក៏ទទួលរងផលប៉ះពាល់ដោយផ្ទាល់ដែរ។ លោក បន្តទៀតថាក្នុងន័យការពារសិទ្ធិមនុស្សច្បាប់នេះគួរតែបានឆ្លងកាត់ការពិភាក្សាផ្លាស់ប្តូរយោបល់អោយបានពេញលេញ ដើម្បីធានាការពារសិទ្ធិស្ត្រី និងកុមារ ដែលងាយនឹងរងគ្រោះ៖ «ដើម្បីអោយច្បាប់ហ្នឹងល្អមានប្រសិទ្ធភាព គឺអនុវត្តទៅកុំឲ្យមានចម្រូងចម្រាស ហើយធានាថា ច្បាប់ហ្នឹង គឺដើម្បីការពារផលប្រយោជន៍របស់កុមារ និងផលប្រយោជន៍អ្នកដែលពាក់ព័ន្ធ»។

អ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជាអ្នកស្រី រ៉ូណា ស្មីត (Rhona Smith) នៅក្នុងបេសកកម្មរបស់អ្នកស្រីនៅកម្ពុជាកាលពីចុងឆ្នាំ២០១៧ បានជំរុញអោយរដ្ឋាភិបាលកម្ពុជាពិភាក្សាបង្កើតច្បាប់ស្តីពីការពរពោះជំនួស ក្នុងន័យការពារសិទ្ធិស្ត្រី និងកុមារទប់ស្កាត់អំពើជួញដូរមនុស្ស។ មន្ត្រីរដ្ឋាភិបាលធ្លាប់បញ្ជាក់ថាចង់អោយច្បាប់នេះមានស្តង់ដារកម្រិតអន្តរជាតិផង។

ទាក់ទងដល់បទល្មើសក្នុងការពរពោះជំនួស នៅពេលមិនទាន់មានច្បាប់នេះ អនុប្រធានអចិន្ត្រៃយ៍របស់គណៈកម្មាធិការប្រឆាំងការជួញដូរមនុស្ស អ្នកស្រី ជូ ប៊ុនអេង បារម្ភពីបទល្មើសថានៅមិនទាន់បញ្ចប់នៅឡើយ ដ្បិតក្រុមអ្នក ដែលចង់បានកូននោះនៅតែមិនព្រមចេញមុខ ដើម្បីធ្វើយ៉ាងណាអោយស្របតាមច្បាប់៖ «ដោយសារតែវានៅតែមានទំនាក់ទំនងជាមួយអ្នកដែលចង់បាន ចង់យកកូនទៅ ប៉ុន្តែយើងអោយគាត់ដាក់បណ្តឹង ដើម្បីអះអាងថាគាត់ជាឪពុកមែនអត់អីហ្នឹងគាត់អត់មក ហើយជាពិសេសយើងមិនអាចសន្និដ្ឋានថាជាឪពុកមែន ឬមិនមែនទេ ដោយសារតែរបៀបដែលគាត់ធ្វើនៅតែលាក់លៀមៗ ដែលយើងចាត់ទុកថា ជាចេតនានៃការប្រព្រឹត្តបទល្មើសច្រើនជាង»។

មន្ត្រីជំនាញការិយាល័យប្រឆាំងការជួញដូរធ្លាប់ឲ្យដឹងថា ស្ត្រីខ្មែរត្រូវមេខ្យល់បានជួលឲ្យពពោះជំនួស អោយជនបរទេសក្នុងតម្លៃ ១ម៉ឺនដុល្លារម្នាក់ ដោយពួកគេទទួលបានប្រាក់កក់ដំបូងពេលមានផ្ទៃពោះចំនួន ៥០០ដុល្លារ ហើយពេលកូនកើតមកពួកគេទទួលបាន ៣០០ដុល្លារក្នុងខែរហូតគ្រប់ចំនួន។ បើទោះជាយ៉ាងណាក្នុងជំនួញពរពោះជំនួសនេះមេខ្យល់បានប្រាក់ចំណេញកប់ក្តោងពីលើក្រុមស្ត្រីខ្មែរក្រីក្រ ដែលប្តូរផ្សងគ្រោះថ្នាក់ពរពោះជំនួស ដើម្បីប្រាក់ដោះស្រាយជីវភាព។ លើសពីនេះពួកគេទំនងមិនបានគិតដល់ថានេះជាទង្វើខុសច្បាប់ទៅទៀត។

អ្នកស្រី ជូ ប៊ុនអេង ផ្តាំផ្ញើដល់ស្ត្រីខ្មែរអោយចៀសវាងប្រើប្រាស់មធ្យោបាយពរពោះជំនួស ដើម្បីរកប្រាក់នេះដ្បិតគឺជាបទល្មើស។ ចំពោះស្ត្រីទាំងជាង៣០នាក់ដែលត្រូវមេខ្យល់ជួលអោយពរពោះនោះពេលនេះភាគច្រើនបានឆ្លងទន្លេ ពួកគេធ្លាប់ទទួលបានការជួយទំនុកបម្រុងពីអង្គការមេត្រីអន្តរជាតិ ហៅកាត់ថា AIM ប្រចាំនៅកម្ពុជា។ ពួក

គេក៏កំពុងជួបប្រទះការលំបាកដែរព្រោះត្រូវទទួលបន្ទុកចិញ្ចឹមកូន ដែលពួកគេធ្លាប់គិតថាត្រឹមតែជួយពរពោះដើម្បីបានប្រាក់ដោះស្រាយជីវភាព៕

## ប្រធានស្តីទីសហគមន៍អេកូទេសចរណ៍ជីផាត៖ ការធ្វើចំណាកស្រុក ត្រូវកាត់បន្ថយស្ទើរ១០០%

http://kleykley.sabay.com.kh/ ថ្ងៃនេះ ម៉ោង 09:18

ថ្លែងប្រាប់ក្រុមការងារ «Mercedes-Benz និងកំណប់អាថ៌កំបាំង» ដែលជាអ្នកតាមប្រមាញ់តំបន់ទេសចរថ្មីៗនៅកម្ពុជា កាលពីថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៩ លោក សូ លីហៀង ប្រធានស្តីទីសហគមន៍អេកូទេសចរណ៍ជីផាត បានថ្លែងយ៉ាងដូច្នេះថា «សម្រាប់បញ្ហាចំណាកស្រុក គឺកាត់បន្ថយបានសឹងតែ ១០០ភាគរយតែម្តង»។ នេះបើយោងតាមអត្ថបទព័ត៌មាន ដែលចុះផ្សាយដោយក្រសួងទេសចរណ៍ កាលពីថ្ងៃទី១៩កុម្ភៈ។ លោក សូ លីហៀង បានឲ្យដឹងថា ប្រជាពលរដ្ឋនៅក្នុងឃុំជីផាត ស្រុកថ្មបាំង ខេត្តកោះកុង បានងាកមកប្រកបរបរដាំដំណាំ នាំភ្ញៀវទេសចរដើរកម្សាន្តនិងប្រកបរបរផ្សេងៗទៀត ដើម្បីបំពេញតម្រូវការភ្ញៀវទេសចរ។ លោក សូ លីហៀង បានបន្តថា អ្វីដែលកាន់តែពិសេសជាងនេះទៀតនោះ សហគមន៍អេកូទេសចរណ៍ជីផាត បានបែងចែកប្រាក់វិភាគទានសម្រាប់កសាងប្រព័ន្ធលូជួសជុលផ្លូវ និងបែងចែកដល់សមាជិកសហគន៍ ដែលបម្រើការសេវាជូនភ្ញៀវទេសចរ នៅក្នុងសហគន៍ផងដែរ។

បើតាមប្រធានស្តីទីរូបនេះ សព្វថ្ងៃឃុំជីផាត មានប្រជាពលរដ្ឋជាង ៦០០គ្រួសារ ហើយមានពលរដ្ឋ ៣៦២គ្រួសារ ជាសមាជិករបស់សហគមន៍ ដូច្នេះពួកគាត់អាចទាញប្រយោជន៍ពីសហគន៍ដូចជា៖ ធ្វើជាចុងភៅភូមិ ចុងភៅព្រៃ មគ្គុទ្ទេសក៏នាំភ្ញៀវដើរទស្សនាកន្លែងកម្សាន្តនានា នៅក្នុងតំបន់អេកូទេសចរណ៍ជីផាត។ លោក សូ លីហៀង បានបញ្ជាក់ថា នៅឆ្នាំ១៩៩៨ នៅជីផាត មានសកម្មភាពកាប់បំផ្លាញព្រៃឈើ ការទន្ទ្រានព្រៃយកដីធ្វើស្រែ និងបរបាញ់សត្វព្រៃ យ៉ាងអនាធិបតេយ្យ ប៉ុន្តែដោយមានការមើលឃើញ និងជួយជ្រោមជ្រែងពីអង្គការ វ៉ាយឡៃហ្វ ឡាយអ៊ិន បានកាត់បន្ថយ និងលុបបំបាត់សកម្មភាពទាំងនេះជាបណ្តើរៗ រហូតដល់មានការចងក្រងឯកសារមួយចំនួនជាមួយអាជ្ញាធរដែនដី និងប្រជាពលរដ្ឋចំនួន ៤ភូមិ នៅក្នុងឃុំជីផាតនេះ បង្កើតទៅជាសហគមន៍ឡើង។

សូមជម្រាបថា សហគមន៍អេកូទេសចរណ៍ជីផាត ត្រូវបានបង្កើតឡើងតាំងពីឆ្នាំ២០០៧ ក្នុងគោលបំណងចូលរួមថែរក្សាការពារបរិស្ថាន ធនធានធម្មជាតិ ព្រៃឈើ និងសត្វព្រៃជាដើម៕

## ពលរដ្ឋខ្មែរ១៨នាក់ ត្រូវបានទាហានថៃចាប់ខ្លួនឆ្លងដែន ចូលកាប់ឈើគ្រញូង ក្នុងប្រទេសថៃខុសច្បាប់

http://nokorwatnews.com/ ថ្ងៃទី19 ខែ02 ឆ្នាំ2019

ប្រទេសថៃ ៖ បើតាមការដកស្រង់ចេញពីកាសែតថៃឲ្យដឹងថា មានពលរដ្ឋខ្មែរ ១៨ នាក់មកពីបណ្តាខេត្តចំនួន ៦ ក្នុងប្រទេសកម្ពុជាត្រូវបាន កម្លាំងទាហានថៃ សហការជាមួយមន្រ្តីជំនាញរក្សាព្រៃឈើថៃ បានចាប់ឃាត់ខ្លួនបានជាបន្តបន្ទាប់ និងយកទៅចាត់ការតាមផ្លូវច្បាប់នោះហើយ ខណៈដែលពលរដ្ឋខ្មែរទាំង១៨នាក់នោះ ឆ្លងដែនខុសច្បាប់ចូលទៅកាប់ឈើគ្រញូងក្នុងទឹកថៃឧទ្យានជាតិ «ថាប់ឡានទី៣ និងទី៤ចំណុចខ្លងណាំម៉ាន់ស្ថិតនៅស្រុកខនបុរីខេត្តនគររាជសីម៉ា ប្រទេសថៃកាលពីល្ងាចថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៩ ។

បើតាមការសែតថៃឲ្យដឹងទៀតថា នៅក្នុងកិច្ចប្រតិបត្តិការដែលកម្លាំងសមត្ថកិច្ចចម្រុះបង្ក្រាបចាប់ឃាត់ខ្លួនទន្ទឹមដែលពលរដ្ឋខ្មែរជាច្រើននាក់បានកំពុងធ្វើដំណើរមានសម្ភារជាមធ្យោបាយដូចជារណាយន្ត ស្បៀងអាហារ និងមានកាំភ្លើងបាញ់ខ្យល់ហ្គាសផងដែរ ត្រូវបានសមត្ថកិច្ចចម្រុះថៃឡើមព័ទ្ធចាប់បានជាបន្តបន្ទាប់ និងមានមួយចំនួនទៀតរត់គេចខ្លួនបានដោយសុវត្ថិភាព ខណៈដែលពួកគេដើរសំដៅកាត់ព្រៃ និងភ្នំឆ្ពោះលបចូលទៅកាប់ឈើគ្រញូង

ក្នុងតំបន់ឧទ្យានជាតិថាប់ឡាន ។ ពលរដ្ឋខ្មែរទាំង១៨នាក់មកពីខេត្តបាត់ដំបង បន្ទាយមានជ័យ ឧត្តរមានជ័យ សៀមរាប កំពង់ចាម និងតាកែវ ។

សូមបញ្ជាក់ថា ជុំវិញនៃការឆ្លងដែនខុសច្បាប់ ពីពលរដ្ឋខ្មែរចូលកាប់ឈើគ្រញូងខុសច្បាប់ នៅក្នុងទឹកដីថៃកន្លងមកសេចក្តីរាយការណ៍ឲ្យដឹងថា គឺមានពលរដ្ឋខ្មែរ មួយចំនួនត្រូវរងការបាញ់សម្លាប់ចាប់ដាក់គុកពីសំណាក់សមត្ថកិច្ចថៃជាបន្តបន្ទាប់ ។

ពលរដ្ឋខ្មែរទាំងនោះត្រូវបានឈ្មួញរកស៊ីជំនួញឈើគ្រញូងជនជាតិថៃ និងឈ្មួញខ្មែរសហការគ្នាជួលពួកគេឆ្លងដែនចូលកាប់ឈើគ្រញូង ក្នុងទឹកដីថៃទាំងប្រថុយប្រហាន ។ ការលួចឆ្លងដែនខុសច្បាប់ចូលទៅកាប់ឈើគ្រញូងក្នុងទឹកដីថៃត្រូវគេរាយការណ៍ឲ្យដឹងថា ពលរដ្ឋខ្មែរធ្វើដំណើរជាក្រុមៗយ៉ាងហោចណាស់១ក្រុម មានគ្នាចាប់ពី៥០នាក់ឡើងទៅផងដែរ ៕ សំ វិច្ឆិកា

## ការបញ្ជូនពលករកម្ពុជាទៅបំរើការងារនៅប្រទេសជប៉ុន ងាយស្រួលជាងមុន

http://mekong-post.com/ ដោយ មេគង្គ ប៉ុស្តិ៍ ចេញផ្សាយ ថ្ងៃទី 18 February, 2019

ភ្នំពេញ ៖ មន្ត្រីជាន់ខ្ពស់កម្ពុជាបានបញ្ជាក់ នៅព្រឹកថ្ងៃទី១៨ ខែកុម្ភៈ នេះថា ច្បាប់ថ្មី របស់រដ្ឋាភិបាលជប៉ុនសម្រាប់ការបញ្ជូនពលករពីកម្ពុជា ទៅកាន់ប្រទេសជប៉ុន មិនមែនជាកម្មសិក្សាការីទៀតទេគឺជាកម្រិតពលកម្មជំនាញដែលមានសិទ្ធិដូចពលករដទៃទៀត ក្នុងនោះក៏ទាមទារឲ្យមានទាំងជំនាញ និង ភាសាផងដែរ។

មានប្រសាសន៍ប្រាប់ ក្រុមអ្នកសារព័ត៌មានក្រោយជំនួបការងាររវាង លោក ហ៊ិដេហ៊ីសា ហ៊ូរីណូអ៊ូជិ (Hidehisa HORINOUCHI) ឯកអគ្គរាជទូត ជប៉ុនប្រចាំប្រទេសកម្ពុជា ពាក់ព័ន្ធនឹងច្បាប់ថ្មី ស្តីពី ការទទួលបានសិទ្ធិក្នុងការស្នាក់នៅ របស់ពលករជំនាញ នៅទីស្តីការក្រសួង លោក បណ្ឌិត អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានបញ្ជាក់ឱ្យដឹងថា នេះជាឱកាសថ្មីមួយ ដែលជប៉ុន បានបើកទូលាយ ការបញ្ជូនពលករយ៉ាងដូច្នេះពីកម្ពុជា ក៏ដូចជាប្រទេសដៃគូនានា ដើម្បីឲ្យទៅធ្វើការនៅជប៉ុន ហើយម្យ៉ាងទៀតក៏ដើម្បីបំពេញតម្រូវការ នៃការខ្វះខាតកម្លាំងពលកម្មរបស់ជប៉ុន និងសម្រាប់កម្ពុជា ក៏ដូចជាប្រទេសនានា ក្នុងការផ្តល់ឱកាសការងារ និង ការហ្វឹកហ្វឺនជំនាញវិជ្ជាជីវៈ ដែលមានកម្រិតខ្ពស់ នៅក្នុងប្រព័ន្ធនៃការងារ ក៏ដូចជាប្រព័ន្ធសេដ្ឋកិច្ច ឧស្សាហកម្ម និង សេវាកម្ម នៅឯប្រទេសជប៉ុនផងដែរ។ លោករដ្ឋមន្ត្រី មានសុទិដ្ឋិនិយមថា នេះជាឱកាសថ្មីមួយ ហើយក៏ជាកិច្ចសហប្រតិបត្តិការ ឡើងមួយកម្រិតទៀត រវាង រដ្ឋាភិបាលប្រទេសទាំងពីរ។ ដើម្បីអនុវត្តន៍កិច្ចការនេះ ភាគីជប៉ុនបានបញ្ជាក់ពីប្រព័ន្ធថ្មីនេះ នឹងចាប់អនុវត្តន៍ ចាប់ពី ខែមេសា ឆ្នាំ២០១៩ តទៅ ខណៈដែលប្រទេសទាំងពីរ បានធ្វើការជាមួយគ្នាដើម្បីរៀបចំអនុស្សារណៈ នៃកិច្ចសហប្រតិបត្តិការ ជាមួយគ្នា ទាក់ទងនឹងការជ្រើសរើសបណ្តុះបណ្តាលនិងបញ្ជូនពលករទៅប្រទេសជប៉ុន។

សូមបញ្ជាក់ថា គិតត្រឹមខែធ្នូ ឆ្នាំ២០១៨ កម្ពុជាបានបញ្ជូនកម្មសិក្សាការី សរុបជាង៩ពាន់នាក់ ទៅធ្វើកម្មសិក្សា និងធ្វើការនៅប្រទេសជប៉ុន ដោយពលករម្នាក់ៗ ទទួលបានប្រាក់ឈ្នួល ជាមធ្យមប្រមាណ ១,៥០០ដុល្លារសហរដ្ឋអាមេរិកឡើងទៅក្នុងមួយខែៗ៕

## ឯណាទៅតំលៃជីវិតពលករខ្មែរ! ហួសចិត្ត តុលាការម៉ាលេស៊ីកាត់ទោស ប្តីប្រពន្ធពីរនាក់ ដែលបង្ខាំង ស្ត្រីបម្រើខ្មែរ រហូតដល់ស្លាប់ ជាប់គុកត្រឹមតែ១០ឆ្នាំប៉ុណ្ណោះ

http://isharetoday.com/archives/ POSTED BYBRID DONFEBRUARY 18, 2019

យោងតាមរបាយការណ៍អង្គការសិទ្ធិមនុស្សម៉ាឡេស៊ីកន្លងទៅបានឲ្យដឹងថា តុលាការបានសម្រេចដាក់ពន្ធនាគារប្តីប្រពន្ធជនជាតិម៉ាឡេស៊ីចំនួន១០ឆ្នាំពីបទឃុំខ្លួនអ្នកបំរើស្រីជនជាតិខ្មែរម្នាក់រហូតដល់ឃ្លានដាច់ពោះស្លាប់។

ជនជាប់ចោទ Chin Chui Ling និងស្វាមីរបស់នាង Soh Chew Tong ត្រូវបានគេរកឃើញកស្តុតាងអំពើមនុស្សឃាតនេះនៅឆ្នាំ 2013 ប៉ុន្តែតុលាការឧទ្ធរណ៍បានកាត់ទោសពួកគេក្នុងឆ្នាំ 2015 ។

អ្នកស្រី Mey Sichan ម៉ីស៊ីចាន់ បានទៅដល់ម៉ាលេស៊ីក្នុងឆ្នាំ២០១១ ហើយត្រូវបានគេរកឃើញថា ស្លាប់ក្នុងឆ្នាំ២០១២ ដោយរាងកាយគាត់មានទម្ងន់តែ ២៦.១ គីឡូក្រាមតែប៉ុណ្ណោះ។

លោកស្រី Glorene Das នាយកប្រតិបត្តិនៃអង្គការសិទ្ធិមនុស្សម៉ាឡេស៊ី Tenaganita បានប្រាប់ក្រុមអ្នកយកព័ត៌មានថាខណៈដែលអង្គការរបស់នាងមិនគាំទ្រការកាត់ទោសប្រហារជីវិតការកាត់ទោស 10 ឆ្នាំនេះមិនអាចទទួលយកបានទេ។

ដោយឡែកលោកស្រី Naly Pilorge ណាលីពីឡូក នៃអង្គការសិទ្ធិមនុស្សកម្ពុជាលីកាដូបាននិយាយថានាង "វិលវល់និងឈឺចាប់" ពេលដឹងអំពីការកាត់បន្ថយទោសលើជនល្មើសចំពោះការស្លាប់របស់អ្នកស្រីម៉ីស៊ីចាន់បែបនេះ ៕

## ថៃដោះលែងពលរដ្ឋកម្ពុជាម្នាក់ឱ្យវិលត្រឡប់មកស្រុកកំណើតវិញ

http://www.rasmeinews.com/ February 20, 2019, 12:02 PM

ដោយៈបាយ័ន/ ឧត្តរមានជ័យៈអាជ្ញាធរប្រទេសថៃ បានដោះលែងពលរដ្ឋកម្ពុជាម្នាក់ឱ្យមានសេរីភាពបន្ទាប់ពីជនរូបនោះបានជាប់ពន្ធនាគារនៅខេត្តស៊ីសាកេតប្រទេសថៃពីបទឆ្លងដែនខុសច្បាប់ចូលក្នុងទឹកដីថៃ។ការប្រគល់ និងទទួលពលរដ្ឋខ្មែរនេះបានធ្វើឡើងនៅច្រកអន្តរជាតិជាំស្រងាំ ក្នុងស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យកាលពី ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៩ ។

សមត្ថកិច្ចនគរបាលប្រចាំច្រកអន្តរជាតិជាំស្រងាំ បាននិយាយថា ប្រជាពលរដ្ឋខ្មែរដែលត្រូវ បានភាគីថៃបញ្ជូនមកស្រុកកំណើតវិញគឺមានឈ្មោះ ជ័យ រិទ្ធី ភេទប្រុស អាយុ២៥ឆ្នាំ រស់នៅភូមិតំណាក់ស្វាយ ឃុំស្វាយ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។ សមត្ថកិច្ចបានបន្តថាជនឈ្មោះជ័យរិទ្ធីត្រូវបានភាគីថៃចាប់ខ្លួនកាលពីថ្ងៃទី១២ខែកុម្ភៈ ឆ្នាំ២០១៩កន្លងទៅនេះ ពីបទឆ្លងដែនចូលដោយខុសច្បាប់ ដោយចូលតាមច្រកចំបក់កោង ហើយត្រូវបានអាជ្ញាធរថៃ យកទៅដាក់ពន្ធនាគារនៅខេត្តស៊ីសាកេត ប្រទេសថៃ ចាប់ពីពេលនោះមក។

រហូតដល់ថ្ងៃទី១៩ខែកុម្ភៈជនរូបនេះត្រូវបានថៃបញ្ជូនមកឱ្យភាគីកម្ពុជាវិញ។បន្ទាប់ពីទទួលពីភាគីថៃរួចមកភាគីកម្ពុជាបានធ្វើការអប់រំណែនាំមិនឱ្យធ្វើកាតឆ្លងដែនដោយខុសច្បាប់បែបនេះទៀតទេរួចឱ្យវិលត្រឡប់ទៅផ្ទះដើម្បីជួបជុំក្រុមគ្រួសារវិញ៕S/

## ថៃបញ្ជូនពលករខ្មែរឆ្លងដែនខុសច្បាប់ ៤នាក់ មកកម្ពុជាវិញ

https://www.facebook.com/ General Department of Immigration – GDI 2019 February 18 at 9:07 PM

កោះកុងៈ កម្លាំងនគរបាលប៉ុស្តិ៍ច្រកទ្វារព្រំដែនអន្តរជាតិចាំយាម នាវេលាម៉ោង ១៦និង២៥នាទី ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៩ បានទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ ៤នាក់ ពីភាគីថៃ។ កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការអប់រំណែនាំពលករខ្មែរទាំង៤នាក់ រួចអនុញ្ញាតឲ្យត្រឡប់ទៅផ្ទះវិញ៕

# ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩

## ពលការនី ២នាក់ទៀតហើយ ត្រូវបានជួយសង្គ្រោះ ឲ្យមកកម្ពុជាវិញ ក្រោយចាញ់បោកមេខ្យល់ ខុសច្បាប់ ទៅធ្វើការ នៅអារ៉ាប៊ីសាអូឌីតជាង ២ឆ្នាំ

http://nokorwatnews.com/ 20-02-2019

ភ្នំពេញ ៖ កាលពីរាត្រីថ្ងៃទី២០ ខែមករា ឆ្នាំ២០១៩ ស្ត្រីពលការិនីខ្មែរឥស្លាមបម្រើការងារនៅតាមផ្ទះ ចំនួន ២នាក់ ទៀតហើយ បានត្រឡប់មកដល់មាតុប្រទេសវិញ បន្ទាប់ពីត្រូវបាន លោក ឧកញ៉ា អូស្មាន ហាស្សាន់ ទេសរដ្ឋមន្ត្រីទទួលបន្ទុក បេសកកម្មពិសេស បានផ្តល់កិច្ចអន្តរាគមន៍ ជួយដល់ពួកគាត់ ក្រោយពីបានចាញ់បោក មេខ្យល់ ដែលបាន បញ្ជូន នាងទៅបម្រើការងារតាមផ្ទះ ដោយខុសច្បាប់ នៅ ប្រទេស អារ៉ាប៊ីសាអូឌីត អស់រយៈពេលជាង២ឆ្នាំ ដោយមិនបាន ប្រាក់កម្រៃ សម្រាប់ កម្លាំងពលកម្មអ្វីសោះនោះ ។

ស្ត្រីរងគ្រោះទាំងពីរនាក់ខាងលើ ឈ្មោះ តាំ ហ្វាត់ទ្រី អាយុ ២២ ឆ្នាំ រស់នៅភូមិ មេម៉ាយ ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ និង ឈ្មោះ ឆាយ ផៃ អាយុ ២៦ឆ្នាំ មានទីលំនៅភូមិ អំពុក ឃុំក្រែក ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ។ នាង តាំង ហ្វាត់ទី បានរៀបរាប់ថា៖ នាងបានចាញ់បោកមេខ្យល់ម្នាក់ដោយបានមកបបួលឲ្យនាងទៅធ្វើការងារនៅ ប្រទេស អារ៉ាប់ប៊ីសាអូឌីត គឺធ្វើការងារនៅតាមផ្ទះនោះនឹងបានប្រាក់ខែខ្ពស់ ពេលខ្ញុំទៅដល់ធ្វើការងារតាមផ្ទះនៅ គេបាន ប្រើកម្លាំងពលកម្មរបស់ខ្ញុំហួតដោយមិនឃើញឲ្យប្រាក់ខែសោះ អស់រយៈពេលជាងពីរឆ្នាំមកនេះ ថែមទាំងដក់ប៉ាស្ព័ពីខ្ញុំទៀត ។ ដោយមូលហេតុនេះហើយ ទើបខ្ញុំសម្រេចចិត្តឲ្យរត់ទៅប្តឹងស្ថានទូត និងដឹងដល់លោកឧកញ៉ា អូស្មាន ហាស្សាន់ ទើបលោកទំនាក់ទំនងទៅស្ថានទូត ឲ្យជួយអន្តរាគមទើបខ្ញុំបានវិញត្រឡប់មកមាតុប្រទេសវិញនៅរាត្រីថ្ងៃទី ២០កុម្ភៈ ឆ្នា២០១៩នេះ ។

សូមបញ្ជាក់ថា៖ នេះគឺជាលើកទី៦ ហើយដែល លោកឧកញ៉ា អូស្មាន ហាស្សាន់ បានដោះស្រាយអោយបាន វិលត្រឡប់មកកម្ពុជាវិញ ដោយសុវត្ថិភាព ដែលស្ត្រីរងគ្រោះទី១ ឈ្មោះ ម៉ាត់ សាណាស់ (សុះ រ៉ទស់) បានមកដល់មាតុ ប្រទេសវិញកាលពីថ្ងៃទី ២៨ ខែសីហា ឆ្នាំ២០១៧, ទី២ ឈ្មោះ អេង ពៅ បានមកដល់នៅថ្ងៃទី១១ ខែមករា ឆ្នាំ ២០១៨, ទី៣ ឈ្មោះ ម៉ាន គីរ៉ស់ បានមកដល់កាលពីថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៨, ទី៤ ឈ្មោះ កែន ចន្ថា បានមក ដល់ថ្ងៃទី ០៤ ខែកក្កដា ឆ្នាំ២០១៨, និង ទី៥ ឈ្មោះ លី សំរ៉ោះ បានមកដល់ថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៨៕ សំរិត

## សមត្ថកិច្ចម៉ាឡេស៊ីស្រាវជ្រាវរកចាប់មេខ្យល់ឆបោកពលរដ្ឋខ្លួន ៤៧នាក់នៅកម្ពុជា

https://www.rfa.org/khmer/news/ 2019-02-20

នាយកដ្ឋានស៊ើបអង្កេតឧក្រិដ្ឋកម្មផ្នែកពាណិជ្ជកម្មប្រទេសម៉ាឡេស៊ី បានចុះផ្សាយនៅថ្ងៃទី២០ កុម្ភៈឲ្យដឹងថា ស្ថាប័នមួយនេះបានកំណត់មុខសញ្ញាជនសង្ស័យ ពាក់ព័ន្ធនឹងការបោកបញ្ឆោតជនជាតិម៉ាឡេស៊ី៤៧នាក់ទៅធ្វើការ នៅកម្ពុជានោះហើយ។ បច្ចុប្បន្នស្ថាប័ននេះ ក៏កំពុងស្វែងរកចាប់ខ្លួនមេខ្យល់ដែលឆបោកនោះដែរ។

ស្នងការរងនគរបាលខេត្តបន្ទាយមានជ័យ ទទួលបន្ទុកផ្នែកព្រហ្មទណ្ឌ លោក សិទ្ធ ឡោះ មានប្រសាសន៍ ប្រាប់អាស៊ីសេរីនៅរសៀលថ្ងៃទី២០កុម្ភៈថា ខាងលោកមិនទាន់ទទួលដំណឹងអំពីការឆកបោកនេះនៅឡើយទេ។ទោះ ជាយ៉ាងណាលោកថា បើសិនជាមានតម្រុយច្បាស់លាស់ប៉ូលិសនឹងតាមចាប់អ្នកពាក់ព័ន្ធបន្តទៀត ដើម្បីយកទៅផ្តន្ទាទោសតាមច្បាប់៖ «ដូច្នោះការសួរពីរឿងឆបោកអីគឺខ្ញុំអត់បានសួរទេ ដោយយើងកំណត់បានតែការប្រើទីតាំងបើកបន ល្បែងគ្មានច្បាប់ ត្រង់ថារឿងឆបោកអីខ្ញុំអត់ដឹងទេ ដោយសារពេលវេលាខ្លី ហើយខ្ញុំត្រូវការអ្នកបកប្រែដើម្បីសួរដេញ ដោល ដូច្នេះហើយបានជាយើងមិនបានសួរល្អិតល្អន់ដល់ដំណាក់ការនេះ គឺខ្ញុំមើលតែបទល្មើសជាក់ស្តែង»។ លោក សិទ្ធ ឡោះ បន្តទៀតថា ជនជាតិម៉ាឡេស៊ីទាំងនោះបានលួចបើកបនល្បែងស៊ីសងតាមប្រព័ន្ធអ៊ីនធឺណិតខុសច្បាប់ នៅក្រុងប៉ោយប៉ែត ហើយក្នុងនោះមានប្រមាណ ៦នាក់បានចូលមកធ្វើការងារនៅកម្ពុជាគ្មានលិខិតឆ្លងដែន។

ប៉ុន្តែកាសែតខ្លះចុះផ្សាយថា ពួកគេត្រូវបានមេខ្យល់លួងលោមយកទៅធ្វើការនៅកម្ពុជាដោយសន្យាផ្តល់ប្រាក់ខែល្អ និងសំបុត្រយន្តហោះមកកម្ពុជាដោយឥតថ្លៃ ប៉ុន្តែនៅពេលមកដល់កម្ពុជា មេខ្យល់ក៏បានចាប់បង្ខាំងពួកគេនៅក្នុងផ្ទះមួយកន្លែងក្នុងខេត្តសៀមរាប ហើយកាលពីថ្ងៃទី១១ ធ្នូ សមត្ថកិច្ចបានចាប់ពួកគេបញ្ជូនទៅឃុំខ្លួននៅពន្ធនាគារខេត្តបន្ទាយមានជ័យ។ កាលពីថ្ងៃទី១៥ កុម្ភៈ សាលាដំបូងខេត្តបន្ទាយមានជ័យបានដោះលែងជនជាតិម៉ាឡេស៊ីចំនួន ៤៧នាក់នោះ ឲ្យនៅក្រៅឃុំបណ្តោះអាសន្ន បន្ទាប់ពីពួកគេជាប់ពន្ធនាគារក្នុងខេត្តនេះអស់ជាង ១ខែ ដោយសារមានកិច្ចអន្តរាគមន៍ពីស្ថានទូតម៉ាឡេស៊ីប្រចាំនៅទីក្រុងភ្នំពេញ៕

## បុណ្យចូលឆ្នាំថ្មីខាងមុខនេះ បងប្អូនពលករខ្មែរដែលធ្វើការនៅប្រទេសថៃ អាចធ្វើដំណើរចេញ-ចូលបាន ចាប់ពីថ្ងៃទី៥-៣០ ខែមេសា ឆ្នាំ២០១៩

https://www.facebook.com/ ពលករកម្ពុជា 20-02-2019

យោងតាមផេករបស់ក្រសួងការងារថៃ បានអោយដឹងថា នៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៩ លោកឧត្តមសេនីយ៍ឯក អាឌុល សែងសិងកែវ( Pol Gen Adul Sangsingkeo ) រដ្ឋមន្ត្រីក្រសួងការងារថៃ បានដឹកនាំកិច្ចប្រជុំពិភាក្សា និងពិចារណា ស្តីពីការអនុគ្រោះឱ្យបងប្អូនពលករខ្មែរ ដែលកំពុងធ្វើការនៅក្នុងប្រទេសថៃ អាចធ្វើដំណើរឆ្លងដែនចេញ-ចូល ដើម្បីទៅចូលរួមបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ នៅប្រទេសស្រុកកំណើតរបស់ខ្លួនបាន ចាប់ពីថ្ងៃទី៥-៣០ ខែមេសា ឆ្នាំ២០១៩ ដោយមិនចាំបាច់ត្រូវបង់ថ្លៃសេវាកម្មត្រារក្សាសិទ្ធិវីសា(Re-Entry)តម្លៃ១,០០០នោះទេ។ ចំណែកបងប្អូនពលករដែលធ្វើដំណើរ ចូលមកប្រទេសថៃវិញក្រោយថ្ងៃទី៣០ មេសា ឆ្នាំ២០១៩ នឹងត្រូវផាកពិន័យតាមច្បាប់ជាទឹកប្រាក់ចំនួន២,០០០បាត។

# ខែកុម្ភៈ ឆ្នាំ២០១៩

## ហាងវៃសិច ជាច្រើនកន្លែង តាមបណ្តោយផ្លូវព្រះស៊ីសុវត្ថិ មុំផែថ្ម បើកយ៉ាងគគ្រឹកគគ្រេង អាជ្ញាធរពាក់ព័ន្ធមិនបង្រ្កាប

https://www.tnb-news.com/articles/ ចេញផ្សាយ ថ្ងៃទី21 ខែកុម្ភៈ ឆ្នាំ2019

ភ្នំពេញ៖ ប្រជាពលរដ្ឋធ្វើដំណើរតាមបណ្តោយផ្លូវមាត់ទន្លេមុំផែថ្ម ក្នុងសង្កាត់វត្តភ្នំ ខណ្ឌដូនពេញ ឃើញហាងបើកវៃសិចយ៉ាងគគ្រឹកគគ្រេងមិនឃើញអាជ្ញាធរពាក់ព័ន្ធណាហ៊ានបង្រ្កាបសោះ សង្ស័យទុកជាទាំងបាយដើម្បីចំអែតក្រពះខ្លួនអត់គិតដល់ប្រទេសជាតិកំពុងតែរីកចម្រើនសោះ។ ទោះបីជាបទបញ្ជារបស់សម្តេចក្រឡាហោម ស ខេង នាយរដ្ឋមន្ត្រីស្តីទី និងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ព្រមទាំងឯកឧត្តម ឃួង ស្រេង អភិបាលរាជធានីភ្នំពេញ ហាក់ដូចជាគ្មានប្រសិទ្ធិភាពអ្វីសោះ ខណៈដែលមន្ត្រីក្រោមឱវាតរបស់ខ្លួនមិនយកចិត្តទុកដាក់គោរពតាមបទបញ្ជារ ថែមទាំងផ្តើនរក្សាទុកនូវទីតាំងទាំងនោះ មិនចុះបង្រ្កាបព្រោះខ្លាចបាត់លាភសក្ការៈចូលហោប៉ៅ និងសូម្បីតែលោក ស ថេត ដែលជាស្នងការនគរបាលរាជធានីភ្នំពេញទើបតែឡើងកាន់តំណែងថ្មីកន្លងមកនេះក៏ស្ងាត់ដែរ ។

ឯកឧត្តម ឃួង ស្រេង អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ បានក្រើនរំលឹកនិងដាក់បញ្ជាអោយអជ្ញាធរពាក់ព័ន្ធគ្រប់បណ្តាខណ្ឌទាំង១២ អោយយកចិត្តទុកដាក់ទប់ស្កាប់បង្រ្កាបអោយអស់នូវទីតាំងបំរើសេវាផ្លូវភេទនិងល្បែងសុ ីសងគ្រប់ប្រភេទដែលមានក្នុងមូលដ្ឋានរបស់ខ្លួន តែផ្ទុយទៅវិញអជ្ញាធរខណ្ឌដូនពេញបែជារក្សាទុកទីតាំងបង្កប់សេវាផ្លូវភេទនិងល្បែងស៊ីសងយ៉ាងរលូនទៅវិញ។

ប្រជាពលរដ្ឋបានលើកឡើងថា ទីតាំងដែលបើកសេវាបំរើផ្លូវភេទ និងលេងល្បែងស៊ីសងខុសច្បាប់បានយ៉ាងរលូនបែបនេះ បើមិនមានការត្រូវរ៉ូវគ្នាពីអាជ្ញាធរ និងម្ចាស់ទីតាំងទេគឺមិនអាចបើកយ៉ាងយូរដូច្នេះទេ។ ប្រជាពលរដ្ឋកើតការងឿងឆ្ងល់ដល់អជ្ញាធរពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់ ជាពិសេសលោក ស ថេត ដែលជាស្នងការនគរបាលរាជធានី

ភ្នំពេញ ទើបតែឡើងកាន់តំណែងថ្មីៗអាចប្រើឥទ្ធិពលរបស់ខ្លួនឲ្យមន្ត្រីក្រោមថ្នាក់ចុះបង្ក្រាបទីតាំង បំរើសេវាផ្លូវភេទ និងបង្កប់ល្បែងស៊ីសងនេះបានដែរឬទេ? ៕

## បង្ក្រាបទីតាំងពេស្យាចារ ធ្វើអាជីវកម្មដោយជនជាតិចិន ៣កន្លែង នៅក្រុងព្រះសីហនុ!

https://www.kmnnews.com/kmnnews/ កែប្រែចុងក្រោយ ថ្ងៃទី 22 ខែ កុម្ភៈ ឆ្នាំ 2019

ក្រុងព្រះសីហនុ- នគរបាលខេត្តព្រះសីហនុកាលពីយប់រំលង អាធ្រាតឈានចូលថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩ នៅចំណុច ភ្នំខៀវ ស្ថិតក្នុងភូមិ០១ សង្កាត់លេខ០២ ក្រុងព្រះសីហនុ ឃាត់ខ្លួនជនសង្ស័យចំនួន៣៨នាក់ក្នុងនោះ មានជនជាតិចិនចំនួន២៣នាក់(បុរសចំនួន១១នាក់) និងស្ត្រីជនជាតិថៃចំនួន១៥នាក់។

មន្ត្រីនគរបាលប្រឆាំងបទល្មើសជួញដូរមនុស្ស នៃស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុអោយដឹងថា ដោយ យោងតាមបទបញ្ជារបស់លោកឧត្តមសេនីយ៍ទោ ជួន ណារិន្ទ ស្នងការនគរបាលខេត្តព្រះសីហនុ កម្លាំងការិយាល័យ ប្រឆាំងបទល្មើសជួញដូរមនុស្ស ស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ បានសហការជាមួយកម្លាំងអធិការដ្ឋាន នគរបាលក្រុងព្រះសីហនុ និងកម្លាំងប៉ុស្តិ៍រដ្ឋបាលសង្កាត់លេខ០២ រួមជាមួយកម្លាំងអន្តរាគមន៍បានធ្វើការឆ្មក់ចូលទី តាំងជួញដូរផ្លូវភេទចំនួន០៣ទីតាំង ដែលជារបស់ជនជាតិចិន ដោយឃាត់ខ្លួនបានជនសង្ស័យចំនួន៣៨នាក់ ក្នុង នោះមានបុរសចំនួន១១នាក់ និងបានរកឃើញវត្ថុតាងមួយចំនួនដែលបានបំរើអោយបទល្មើសខាងលើ ក្នុងនោះ មានស្រោមអនាមយ័ប្រើប្រាស់រួចហើយ និង ស្រោមអនាមយ័មិនទាន់ប្រើជាច្រើនផងដែរ។ បើតាមនគរបាលបញ្ជាក់ ថា ចំពោះមេក្លោងក្នុងបទល្មើសជួញដូរផ្លូវភេទនេះ សមត្ថកិច្ច កំពុងធ្វើការស្រាវជ្រាវ និង កំណត់មុខសញ្ញា ដើម្បី បញ្ជូនខ្លួនទៅកាន់សាលាដំបូងខេត្ត បើទោះជាបុរសជនជាតិចិនដែលនគរបាលបានឃាត់ខ្លួនទាំង១១នាក់នោះ ពុំ ទាន់ឆ្លើយសារភាពយ៉ាងណាក្តី៕ (ម៉េង)

## ចិនបញ្ជូនស្ត្រីខ្មែរម្នាក់ មកកម្ពុជាវិញ ដែលត្រូវចាញ់បោកមេខ្យល់យកទៅលក់

https://www.facebook.com/ General Department of Immigration - GDI 22-02-2019

សៀមរាប៖ កម្លាំងនគរបាលប៉ុស្តិ៍ច្រកទ្វារអាកាសយានដ្ឋានអន្តរជាតិសៀមរាប បានទទួល និងសម្រួលបែប បទចូលប្រទេស ជូនស្ត្រីរងគ្រោះពលរដ្ឋខ្មែរម្នាក់ ដែលត្រូវសមត្ថកិច្ច រៀបចំបែបបទបញ្ជូនមកពីប្រទេសចិន នាវេលា ម៉ោង ០២និង៣៥នាទី ទៀបភ្លឺ ថ្ងៃសុក្រ ៣រោច ខែមាឃ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ ២០១៩ តាមជើងយន្តហោះ LQ911 (CSX-REP) មកពីទីក្រុង CHANGSHA ប្រទេសចិន។

សមត្ថកិច្ចបានឲ្យដឹងថា ស្ត្រីរងគ្រោះមានឈ្មោះ ចេន ស្រីណិត CHEN SREYNIT ភេទស្ត្រី អាយុ២២ឆ្នាំ ដោយសារស្ត្រីរងគ្រោះ បានរត់គេចអំពីការធ្វើបាប ពីសំណាក់ប្តីជនជាតិចិន ដែលត្រូវមេខ្យល់នាំយកទៅលក់។ ស្ត្រីរង គ្រោះបានចេញពីប្រទេសកម្ពុជាតាម ច្រកទ្វារអន្តរជាតិបាវិតក្នុងឆ្នាំ២០១៧ ឆ្លងកាត់តាមប្រទេសវៀតណាម ហើយ ចូលប្រទេសចិនតាមច្រករបៀង នៃទីក្រុងហាណូយ ប្រទេសវៀតណាម និងខេត្តហ៊ូណាន ប្រទេសចិន។ បច្ចុប្បន្នស្ត្រី រងគ្រោះ ត្រូវបានកម្លាំងនគរបាលប៉ុស្តិ៍ ធ្វើការអប់រំ និងបំពេញបែបបទចូលប្រទេសជាធម្មតា ហើយត្រូវបានអង្គការ មេត្រីអន្តរជាតិ មកទទួលគាំពារ៕

## ពលករខ្មែរសាទរនឹងក្រសួងការងារថៃដែលស្នើរដ្ឋាភិបាលខ្លួនឲ្យពលករត្រឡប់ទៅលេងបុណ្យចូលឆ្នាំ មិនយកថ្លៃទិដ្ឋាការចេញចូល

https://www.rfa.org/khmer/news/ ដោយ ជាតិ ចំណាន 2019-02-21

ក្រសួងការងារថៃត្រៀមស្នើសុំទៅរដ្ឋាភិបាលខ្លួន ដើម្បីសម្រួលឲ្យពលករបរទេសអាចឆ្លងដែនទៅលេងបុណ្យ ចូលឆ្នាំប្រពៃណីជាតិរបស់ខ្លួន ចាប់ពីថ្ងៃទី៥រហូតដល់ថ្ងៃទី៣០ មេសា ដោយមិនបាច់បង់ប្រាក់ធ្វើទិដ្ឋាការចេញចូល

តាមព្រំដែន។ ពលករខ្មែរ និងមន្ត្រីអង្គការសង្គមស៊ីវិល សាទរចំពោះវិធានការនេះ ដែលអាចជួយកាត់បន្ថយការចំណាយក្នុងការធ្វើដំណើររបស់ពលករត្រឡប់ទៅស្រុកកំណើត។

ពលករខ្មែរធ្វើការនៅប្រទេសថៃលោក ហឿន ស ថ្លែងប្រាប់អាស៊ីសេរីនៅព្រឹកថ្ងៃទី២១ កុម្ភៈថា ការជួយសម្រួលនេះជារឿងល្អចំពោះពលករ ដើម្បីបានត្រឡប់ទៅលេងស្រុកកំណើតដោយមិនចំណាយថវិកាច្រើន។ លោកបន្តថាកន្លងមក ការធ្វើដំណើរត្រឡប់ទៅលេងស្រុកកំណើតច្រើនតែចេញតាមច្រកព្រំដែនអន្តរជាតិប៉ោយប៉ែត ព្រោះងាយស្រួលរកឡានឈ្នួលធ្វើដំណើរទៅផ្ទះ៖ «មិនថាកន្លែងណាទេខ្ញុំលឺគេថា បានគេឲ្យចេញចូលសេរីមិនដូចមុនល្អ បើពីមុនសមត្ថកិច្ចយកលុយគ្រប់ច្រកព្រំដែន ដល់ក្រសួងការងារថៃមិនយកលុយខ្ញុំត្រេកអរ ដែលគេផ្តល់តម្លៃឲ្យពលករ ដែលធ្វើការនៅស្រុកគេ ដូចថា ពេលមានបុណ្យទានយើងអាចត្រឡប់ទៅលេងបងប្អូនបានស្រួល»។

ចំណែកពលករម្នាក់ទៀតថ្លែងឲ្យដឹងថា បុណ្យចូលឆ្នាំខាងមុខនេះ លោកមិនបានទៅលេងស្រុកខ្មែរនោះទេ ក៏ប៉ុន្តែលោកសប្បាយចិត្តនឹងវិធានការនេះ ព្រោះសង្ឃឹមថា នឹងបានជួយសម្រួលដល់ពលករឲ្យឆាប់បានត្រឡប់ទៅដល់ផ្ទះលឿនជាងមុនផងពេលទៅដល់ច្រកព្រំដែន៖ «អត់មានលិខិតឆ្លងដែនទៅតាមផ្លូវកាត់គេយកលុយជាង ១៣ពាន់បាត ឬប្រហែល ១៣ម៉ឺនរៀល (១៣០.០០០)។ ខ្ញុំចេះតែចង់ទៅស្រុកហើយ ប៉ុន្តែចិត្តមួយមិនចង់ទៅដោយសារឃើញស្ថានការណ៍នៅស្រុកខ្មែរកាន់តែយ៉ាប់យុឺនទៅ ព្រោះនៅស្រុកខ្ញុំអាជ្ញាធររំលោភយកដីពលរដ្ឋ ហើយដេញចាប់ពលរដ្ឋដែលតវ៉ាប្រឆាំងនឹងអាជ្ញាធរ»។

គេហទំព័រក្រសួងការងាររបស់ថៃ បានចុះផ្សាយនៅពីថ្ងៃទី២០ កុម្ភៈថា រដ្ឋមន្ត្រីក្រសួងការងារថៃ លោក អាឌុល សែងសិងកែវ (Adhol Saeng Sing Keo) បានសម្រេចអនុញ្ញាតឲ្យពលករបរទេស រួមមាន កម្ពុជា លាវ(Lao) និងភូម៉ា ឬ មីអែនម៉ា (Myanmar) អាចធ្វើដំណើរត្រឡប់ទៅលេងបុណ្យចូលឆ្នាំប្រពៃណីជាតិរបស់ខ្លួន ចាប់ពីថ្ងៃទី៥ ដល់ថ្ងៃទី៣០ មេសា ដោយមិនបាច់បង់ប្រាក់ធ្វើទិដ្ឋាការចេញចូលតាមច្រកព្រំដែនដែលបានមានតម្លៃ ២ពាន់បាត ឬប្រមាណ ៦៥ដុល្លារអាមេរិក។ ទោះជាយ៉ាងណាក្តី សេចក្តីសម្រេចនេះមិនទាន់បញ្ជូនទៅរដ្ឋាភិបាលថៃនៅឡើយទេ ដោយក្រសួងការងារថៃត្រៀមបញ្ជូនរឿងនេះដាក់ទៅរដ្ឋាភិបាលរបស់ខ្លួន ដើម្បីអនុម័តក្នុងពេលឆាប់ៗ ខាងមុខ។ នៅពេលរដ្ឋាភិបាលថៃអនុម័តលើរឿងនេះហើយ ក្រសួងការងារថៃ នឹងបញ្ជូនមន្ត្រីរបស់ខ្លួនផ្សព្វផ្សាយដំណឹងនេះនៅខេត្តជាប់ព្រំដែន និងជួយសម្រួលដល់ពលករនៅតាមច្រកព្រំដែន ដើម្បីកុំឲ្យមានការប្រព្រឹត្តអំពើពុករលួយជុំវិញបញ្ហានេះទៀតផង។

នាយកប្រតិបត្តិមជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស ហៅថា សង់ត្រាល់ (CENTRAL) លោក មឿន តុលា មានប្រសាសន៍ប្រាប់អាស៊ីសេរីនៅព្រឹកថ្ងៃទី២១ កុម្ភៈថា ការមិនឲ្យពលករបង់ប្រាក់ធ្វើទិដ្ឋាការចេញចូល គឺជារឿងមួយមានប្រយោជន៍សម្រាប់ពលករ ធ្វើឲ្យពួកគាត់ចំណាយថវិកាតិចជាងមុន។ លោកបន្តថា ជារឿយៗ ពលករខ្មែរទៅលេងបុណ្យប្រពៃណីជាតិម្តងៗ ត្រូវចំណាយប្រាក់ក្នុងការធ្វើដំណើរ ចន្លោះពី ១០០ ទៅ ២០០ដុល្លារអាមេរិក ដោយសាររថយន្តឡើងថ្លៃនិងចំណាយធ្វើទិដ្ឋាការនៅច្រកព្រំដែន៖ «កន្លងមកយើងតែងតែស្នើសុំភាគីពាក់ព័ន្ធទាំងរដ្ឋាភិបាលថៃនិងរដ្ឋាភិបាលកម្ពុជា ឲ្យសហការគ្នាលើកលែងថ្លៃធ្វើទិដ្ឋាការចេញចូលប្រទេសថៃ ពីព្រោះវាជាចំណាយធំមួយ។ក្រៅពីនេះយើងស្នើសុំឲ្យភាគីទាំង២ មេត្តាសម្របសម្រួលឲ្យមានការចេញចូល កុំឲ្យមានការយកលុយក្រៅផ្លូវការនៅច្រកព្រំដែន ព្រោះជាទូទៅពលករត្រឡប់មកលេងស្រុកកំណើតច្រើនធ្វើដំណើរតាមផ្លូវគោក ហើយមានការអ៊ូរទាំការយកលុយយកកាក់នៅច្រកព្រំដែនច្រើន»។

សព្វថ្ងៃពលករខ្មែរធ្វើការងារនៅប្រទេសថៃមានជាង ១លាននាក់ ខណៈដែលក្រសួងការងារថៃប៉ាន់ប្រមាណថា ពលករដែលត្រឡប់ទៅលេងបុណ្យចូលឆ្នាំនៅពេលខាងមុខមានប្រមាណពី២០ទៅ៣០ម៉ឺននាក់(៣០០.០០០)៕

## ក្រសួងការងារថៃ សូមរំលឹកម្តងទៀត ពុំមានគោលនយោបាយចុះបញ្ជីថ្មី សម្រាប់ពលករបរទេសទៀតឡើយ

https://www.facebook.com/cambodialabour/ 21-02-2019

ក្រសួងការងារថៃ សូមរំលឹកនិយោជកកុំឱ្យជឿថា អ្នកក្លែងបន្លំបានចេញផ្សាយព័ត៌មានអំពីការចុះឈ្មោះជនបរទេសថ្មី ឬពលករបរទេសដែលបានទទួលលិខិតអនុញ្ញាតការងារ និងលិខិតបញ្ជាក់ការងារបានបញ្ចប់។ ដូច្នេះការព្រមានដល់និយោជក / គ្រឹះស្ថាន និងពលករបរទេស សូមកុំជឿជាដាច់ខាត ដោយសារតែអ្នកអាចបាត់បង់លុយដោយឥតគិតថ្លៃ។ ទោះយ៉ាងណាក៏ដោយនិយោជក ទីតាំងប្រកបការងារ និងពលករបរទេស ត្រូវគោរពតាមច្បាប់អោយបានត្រឹមត្រូវ នៅពេលជួលពលករបរទេស ហើយប្រសិនបើពលករបរទេសចាកចេញពីការងាររបស់ពួកគេឬត្រូវបញ្ឈប់ចេញពីការងារ ចំពោះនិយោជក / គ្រឹះស្ថាន ប្រញាប់ជូនដំណឹងដល់មន្ទីរការងារក្នុងរយៈពេល 15 ថ្ងៃ សម្រាប់ពលករបរទេសដែលចាកចេញពីការងារ ត្រូវប្រញាប់ស្វែងរកនិយោជកថ្មី ហើយជូនដំណឹងអំពីនិយោជកថ្មីដល់មន្ទីរការងារអោយបានជ្រាបក្នុងរយៈពេល 15 ថ្ងៃផងដែរ បើមិនដូច្នោះទេពលកបរទេសនឹងមិនអាចធ្វើការនិងស្នាក់នៅក្នុងប្រទេសថៃបានទៀតឡើយ។ សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនង កានក្រសួងការងារថៃ, ការិយាល័យការងារគ្រប់ខេត្តក្រុងទាំងអស់, ការិយាល័យការងារនៅទីក្រុងបាងកកតំបន់ 1-10 រឺ # ក្រសួងការងារ 1506 ចុចលេខ 2។

## ពលករចំណាកស្រុកចំនួន ៣០០,០០០នាក់ នៅក្នុងប្រទេសថៃ នឹងត្រូវអនុញ្ញាឱ្យមកលេងស្រុកកំណើតដោយមិនគិតថ្លៃលើទិដ្ឋាការ

https://khmernote.com/news/ February 22, 2019

ពលករចំណាកស្រុកជិត ៣០០,០០០នាក់ នៅក្នុងប្រទេសថៃដូចជា៖ កម្ពុជា ឡាវ និងភូមា ត្រូវបានគេរំពឹងទុកថា នឹងមកលេងស្រុកកំណើតក្នុងឱកាសសង្ក្រាន្តឆ្នាំថ្មី ចាប់ពីថ្ងៃ ទី៥ ដល់ ទី៣០ ខែមេសា ខាងមុខនេះ។ រដ្ឋមន្ត្រីក្រសួងការងារលោក Adul Sangsingkeo បន្ទាប់ពីកិច្ចប្រជុំនៃអនុគណៈកម្មការគ្រប់គ្រងពលករចំណាកស្រុក និងប្រឆាំងការជួញដូរមនុស្ស កាលពីថ្ងៃពុធ បានប្រាប់ក្រុមអ្នកសារព័ត៌មានថា ក្នុងជំនួបកិច្ចប្រជុំនោះ ពួកគេបានសម្រេចដើម្បីអនុញ្ញាតឱ្យពលករកម្ពុជា ឡាវ និងភូមា ដែលមានទិដ្ឋាការ L-A (មិនមែនជាជនអន្តោប្រវេសន៍) មានសុពលភាពយ៉ាងហោចណាស់ រហូតដល់ថ្ងៃ ទី៣០ ខែមេសា ដើម្បីត្រលប់ទៅផ្ទះវិញក្នុងអំឡុងពេលសង្ក្រានឆ្នាំថ្មីដោយឥតគិតថ្លៃ។ លោករដ្ឋមន្ត្រីបានបន្ថែមថា ក្មេងដែលមានអាយុក្រោម ១៨ឆ្នាំ ក៏អាចធ្វើដំណើរជាមួយពួកគេទៅស្រុកកំណើតបានផងដែរ។ យ៉ាងណាក៏ដោយលោកបានផ្តាំថា ប្រសិនបើកម្មករវិលត្រឡប់មកប្រទេសថៃក្រោយពីថ្ងៃ ទី ៣០ ខែមេសា ពួកគេនឹងត្រូវបានផ្តល់នូវត្រាទិដ្ឋាការ ដែលមានសុពលភាពហូតដល់ថ្ងៃផុតកំណត់នៃទិដ្ឋាការចាស់ ហើយពួកគេត្រូវបង់ថ្លៃឈ្នួលចំនួន២ពាន់បាត(ជាង៦០ដុល្លារអាមេរិក)៕ អត្ថបទ៖លីជាប្រភព៖ nationmultimedia

## ថៃចាប់បញ្ជូនខ្មែរឥស្លាម៣៤នាក់ ដោយសង្ស័យថាលួចធ្វើដំណើរទៅធ្វើការនៅភាគខាងត្បូងនិងម៉ាឡេស៊ីដោយខុសច្បាប់

http://www.rasmeinews.com/ February 22, 2019, 9:48 AM

ប៉ូលិសថៃបានចាប់បញ្ជូនត្រឡប់មកកម្ពុជាវិញនូវជនឥស្លាមកម្ពុជា៣៤នាក់ ដោយបដិសេធសំណើធ្វើដំណើររបស់ពួកគេទៅធ្វើការនៅចុងខាងត្បូងថៃ ដោយសារមិនបំពេញលក្ខខណ្ឌអន្តោប្រវេសន៍គ្រប់គ្រាន់។នេះបើតាមការផ្សាយរបស់សារព័ត៌មានបាងកកប៉ុស្ត៍កាលពីថ្ងៃសុក្រទី២២កុម្ភៈ។ ក្រុមដែលរួមមាន បុរស៣២នាក់និងស្ត្រី២នាក់ ត្រូវបានប្រាប់អោយវិលមកកាន់ក្រុងប៉ោយប៉ែតរបស់កម្ពុជាវិញ កាលពីថ្ងៃព្រហស្បត៍បន្ទាប់ពីពួកគេបានឆ្លងព្រំដែនថៃ-កម្ពុជាចូលខេត្តសាកែវ។

ពួកមន្ត្រីថៃបាននិយាយថា ជនចំណាកស្រុកទាំងនេះត្រូវបានឃុំខ្លួនទុកបណ្ដោះអាសន្នមួយរយៈពេលខ្លី ក្រោយពីបានដឹងអំពីគោលបំណងពិតរបស់ពួកគេដើម្បីបញ្ចៀសការយល់ខុសណាមួយ។បន្ទាប់មកមេប៉ូលិសខេត្តសាកែវ បានស្នើសុំអាជ្ញាធរកម្ពុជា ចូលរួមស៊ើបអង្កេតអំពីឋានៈរបស់អ្នកដំណើរទាំងនេះ។

សារព័ត៌មានខាងលើអះអាងថា ពួកគេទាំងអស់បានធ្វើដំណើរតាមទិដ្ឋាការទេសចរណ៍តែភាគច្រើនក្នុងចំណោមពួកគេបាននិយាយថាពួកគេមានបំណងទៅធ្វើការនៅបណ្ដាខេត្តភាគខាងត្បូងថៃ។ខ្លះទៀតអះអាងថា ថៃគ្រាន់តែជាចំណុចឆ្លងកាត់សំរាប់ពួកគេបន្តទៅធ្វើការនៅម៉ាឡេស៊ី ដោយត្រូវឆ្លងកាត់ច្រកព្រំដែននៅខេត្តណារ៉ាតធីវ៉ាត។ តាមច្បាប់ថៃ ជនបរទេសមកពីបណ្ដាប្រទេសជិតខាងអាចធ្វើការនៅថៃបាន តែតាមរយៈMoUរវាងរដ្ឋាភិបាលរៀងៗខ្លួន។មន្ត្រីថៃកាលពីថ្ងៃ២១កុម្ភៈបានពិនិត្យឃើញថា ជនអ៊ីស្លាមកម្ពុជា៣៤នាក់នេះមិនបានបំពេញលក្ខខណ្ឌនេះទេ។ សារព័ត៌មានដដែលបាននិយាថា កាលពីថ្ងៃព្រហស្បត៍នេះដែរ ប៉ូលិសអយស្ម័យយាននៅស្រុកហាតយ៉ៃនៃខេត្តសុងក្លាភាគខាងត្បូងក៏បានរកឃើញអ្នកដំណើរកម្ពុជាស្រី៣នាក់មិនមានឯកសារធ្វើដំណើរត្រឹមត្រូវ។ពួកគេបានប្រាប់ប៉ូលិសថា ពួកគេធ្វើដំណើរទៅពីប៉ោយប៉ែតនិងតំរង់ទៅកាន់ម៉ាឡេស៊ី។

នៅខែនេះដែរ យុវជនកម្ពុជា៣នាក់ដែលរៀននៅសាលាឥស្លាមមួយនៅក្នុងខេត្តភាគខាងត្បូងប៉ាតតានីត្រូវប៉ូលិសថៃចាប់ខ្លួនក្នុងចំណោមសិស្សបរទេស១១នាក់ ដោយសារមិនមានទិដ្ឋាការត្រឹមត្រូវ៕ ដោយៈ*វាសនា*

# ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៩

## ពលករខ្មែរចុះទូកមួយចំនួននៅថៃថា ខ្លួនមិនបានទៅលេងបុណ្យចូលឆ្នាំដោយសាររវល់ការងារ

https://www.rfa.org/khmer/news/ ដោយ សួន អមរា 2019-02-24

ពលករខ្មែរអះអាងថា ពួកគេទៅធ្វើការងារនៅលើទូកនេសាទរបស់ថៃមួយចំនួនដោយសារជីវភាពក្រីក្រខំប្រឹងធ្វើការ ដើម្បីរកប្រាក់ផ្ញើទៅក្រុមគ្រួសារនៅឯស្រុកខ្មែរ សម្រាប់ដោះស្រាយជីវភាពគ្រួសារ ដោយមិនបានត្រឡប់ទៅលេងស្រុកកំណើតក្នុងឱកាសបុណ្យចូលឆ្នាំប្រពៃណីជាតិនៅខែមេសាខាងមុខនោះទេ។ ពួកគាត់មានការសោកស្ដាយដែលមិនអាចទៅជួបជុំបងប្អូននៅក្នុងថ្ងៃបុណ្យជាតិ ព្រោះជាប់រវល់បំពេញការងារនៅកណ្ដាលសមុទ្រ ដែលមិនអាចត្រឡប់ទៅដល់ដីគោកឱ្យបានទាន់ពេលថ្ងៃបុណ្យចូលឆ្នាំ។ ពលករខ្មែរមានអារម្មណ៍ក្ដុកក្ដួលក្នុងចិត្ត ចង់ទៅលេងស្រុកខ្មែរដើម្បីបានកម្សាន្តជួបជុំក្រុមគ្រួសារនៅឯស្រុកកំណើត ប៉ុន្តែបែរជាអាក់ខានដោយសារ ថ្ងៃបុណ្យឆ្នាំនេះចំវេនចុះទូកទៅយកត្រីនៅកណ្ដាលសមុទ្រចម្ងាយរាប់ពាន់គីឡូម៉ែត្រត្រឡប់មិនទាន់ថ្ងៃបុណ្យចូលឆ្នាំ។

ពលករម្នាក់រស់នៅខេត្តកំពង់ធំ លោក ហឿន ស រៀបរាប់ប្រាប់ឱ្យដឹងអាស៊ីសេរី កាលពីថ្ងៃទី២១ កុម្ភៈថា ដោយសារជីវភាពក្រីក្រ ជំរុញឱ្យលោកចាកចេញពីផ្ទះទៅធ្វើការជាពលករនៅប្រទេសថៃ និងបានធ្វើការនៅលើទូកនេសាទក្នុងខេត្តសមុត្រប្រាកាន ជិតទីក្រុងបាងកក ចំនួន ៧ឆ្នាំហើយ។ ពលកររូបនេះបន្តថា ជារៀងរាល់ឆ្នាំលោកតែងតែត្រឡប់ទៅលេងបុណ្យចូលឆ្នាំខ្មែរនៅឯស្រុកកំណើតមិនដែលខាននោះទេ ប៉ុន្តែឆ្នាំនេះថៅកែមិនអនុញ្ញាតឱ្យលោកឈប់សម្រាកក្នុងថ្ងៃបុណ្យចូលឆ្នាំឡើយ ព្រោះត្រូវវេនចុះទូកទៅយកត្រីនៅកណ្ដាលសមុទ្រជាប់ប្រទេសម៉ាឡេស៊ី។ លោកថា ពលកររួមការងារនៅលើទូកនេសាទមានគ្នាជាង ១០នាក់ ត្រូវធ្វើដំណើរផ្សងព្រេងនៅលើទឹកសមុទ្ររួមគ្នា ក្នុងមួយជើងៗមានរយៈពេលប្រមាណ២០ថ្ងៃ ទើបត្រឡប់មកដល់ដីគោកវិញ ព្រោះមានចម្ងាយដល់ទៅជាង១ពាន់គីឡូម៉ែត្រឯណោះ៖ «ខ្ញុំអង្គុយតែគិតថា គេទៅលេងស្រុកមិនដឹងសប្បាយយ៉ាងណាទេ តែខ្ញុំវិញអង្គុយអើតមើលមេឃមើលផ្កាយមើលទឹកសមុទ្រនឹងឯង ខ្ញុំស្រណោះស្រណោកខ្លួនដែរ តែធ្វើមិចព្រោះតែជីវភាពក្រីក្រ យើងត្រូវតែតស៊ូដើម្បីជីវភាពរបស់យើង។ ក្នុងចិត្តចង់តែទៅនៅខ្មែរវិញ តែដោយសារចង់សន្សំលុយមួយរយៈយកទៅប្រកបរបរខ្លួនឯងនៅស្រុកខ្មែរ ខ្ញុំមិនចង់នៅធ្វើពលករដូច្នេះទេ ព្រោះរស់នៅមិនមានការជួបជុំគ្រួសារ ព្រោះមនុស្សគ្រប់រូបត្រូវមានប្រពន្ធកូន គ្មានអ្នកណាចង់បែកពីប្រពន្ធកូនមកធ្វើការស្រុកគេទេ តែគ្រាន់តែយើងមិនទាន់មានមុខរបរអី»។ ពល

កររូបនេះបន្តទៀតថា អំឡុងពេលធ្វើការនៅលើទូកកន្លងមក លោកមិនធ្លាប់ជួបគ្រោះថ្នាក់ធំដុំនោះទេ ដោយគ្រាន់តែពុលទឹករលកនៅពេលដែលមានខ្យល់ខ្លាំងបក់បោកមកចំទូកនេសាទរបស់ខ្លួន។ លោកថា ពេលនោះនឹកក្រុមគ្រួសារនៅផ្ទះ ហើយចង់ឈប់ធ្វើការត្រឡប់ទៅខ្មែរវិញដែរ ក៏ប៉ុន្តែដោយសារជីវភាពខ្វះខាត និងគ្មានការងារធ្វើនៅឯស្រុកកំណើត ក៏សម្រេចចិត្តតស៊ូធ្វើការនៅលើទូករហូតមកទល់សព្វថ្ងៃ៖ «គ្រោះថ្នាក់តែកើតមានជារឿយៗ ដែលយើងមិនដឹងវាកើតនៅណា ជួលកាលយប់ព្រលប់យើងធ្វើការមិនបានប្រុងប្រយ័ត្នក៏របូតដៃធ្លាក់ទឹកខ្ញុំឃើញកើតមានច្រើនករណី តែចំពោះខ្លួនខ្ញុំមិនធ្លាប់កើតមានទេ។ អ្នកខ្លះក៏ធ្លាក់ទឹកបាត់សូន្យ កាលពីមុនច្បាប់មិនទាន់រឹងប៉ឹងដូចសព បាត់ក៏បាត់ចប់បណ្ដោយ ជួនកាលយើងមិនដឹងថា វាធ្លាក់ដោយរបៀបណាទេ ដល់ព្រឹកឡើងបានយើងដឹងថាបាត់មនុស្ស»។

ចំណែកពលករធ្វើការនៅលើទូកនេសាទថៃម្នាក់ទៀតលោក ជា ខន មានប្រសាសន៍ថា ការងារនៅលើទូកនេសាទមិនស្រួលដូចធ្វើការក្នុងម៉ាស៊ីនត្រជាក់នោះទេ ព្រោះធ្វើការលំបាកត្រូវកម្ដៅថ្ងៃ ភ្លៀងទទឹក ហើយប្រឈមនឹងពុលទឹករលកជាប្រចាំ ដោយមិនសូវបានដេកលក់ស្រួលដូចនៅក្នុងផ្ទះនោះទេ ព្រោះជាការងារនៅកណ្ដាលសមុទ្រមើលមិនឃើញកោះត្រើយនោះឡើយ។ លោកបន្តថា ពេលខ្លះធ្វើការមិនបានត្រឡប់ឡើងគោកក្នុងប្រទេសថៃនោះទេ ដោយឈប់សម្រាកនៅប្រទេសម៉ាឡេស៊ីក៏មានដែរ រហូតដល់ពួកគាត់ធ្វើការយូរទៅស៊ាំនឹងការងារ ដោយមិនខ្វល់ពីការនឿយហត់នោះទេ គឺធ្វើយ៉ាងណាឱ្យតែបានប្រាក់ផ្ញើទៅឱ្យក្រុមគ្រួសារនៅឯស្រុកខ្មែរ។ លោកថា ចូលឆ្នាំខ្មែរខាងមុខនេះមិនបានត្រឡប់ទៅលេងស្រុកកំណើតនោះទេ ព្រោះត្រូវវេនចុះទូកទៅយកត្រីនៅកណ្ដាលសមុទ្រ៖ «គ្រោះថ្នាក់តែកើតមានជារឿយៗ ដែលយើងមិនដឹងវាកើតនៅណា ជួលកាលយប់ព្រលប់យើងធ្វើការមិនបានប្រុងប្រយ័ត្នក៏របូតដៃធ្លាក់ទឹកខ្ញុំឃើញកើតមានច្រើនករណី តែចំពោះខ្លួនខ្ញុំមិនធ្លាប់កើតមានទេ។ អ្នកខ្លះក៏ធ្លាក់ទឹកបាត់សូន្យ កាលពីមុនច្បាប់មិនទាន់រឹងប៉ឹងដូចសព បាត់ក៏បាត់ចប់បណ្ដោយ ជួនកាលយើងមិនដឹងថា វាធ្លាក់ដោយរបៀបណាទេ ដល់ព្រឹកឡើងបានយើងដឹងថា បាត់។ បើកាលពីសម័យមុនវិញពេលទូកឡើងមកដល់ដីគោកម្ដងៗ ពលករខ្មែរនាំគ្នាដើរផឹកស៊ីចាយវាយ អើតមើលមុខគ្នាមិនបានទេ គឺដេញវាយដេញកាប់គ្នាជាប្រចាំ កាលពីមុនសំបូរពលករខ្មែរចុះទូកច្រើន តែឥឡូវមិនសូវមានទេ។ និយាយទៅបើមានការងារល្អៗនៅខ្មែរខ្ញុំធ្វើការនៅខ្មែរហើយបានជួបម៉ែឪបងប្អូនផងប៉ុន្តែដូចដឹងស្រាប់ហើយខាងខេត្តកំពង់ធំខ្ញុំ គ្រាន់តែគេរំលោភយកដីខ្លះមិនហ៊ាននៅស្រុកទេ ព្រោះតវ៉ាគេចាប់វាយធ្វើបាប»។ លោកបន្តថា ធ្វើការមួយខែលោកបានឡើងមកជួបប្រពន្ធនៅដីគោក ក្នុងខេត្តសមុត្រប្រាកាន ប្រហែល១០ថ្ងៃក៏ត្រូវចុះទូកនេសាទវិញ ស្ទើរតែជារៀងរាល់ខែ ប៉ុន្តែពួកគាត់មិនរួញរានឹងការងារនេះទេ ព្រោះធ្វើការទាំង២នាក់ប្ដីប្រពន្ធ សល់ប្រាក់ចន្លោះពី ១ម៉ឺន ៥ពាន់ទៅ ២ម៉ឺនបាតថៃ ឬប្រមាណ ៦៥០ដុល្លារអាមេរិកក្នុងមួយខែ។ លោកថា ពលករខ្មែរធ្វើការលើទូកនេសាទថៃនៅតំបន់ដែលពួកគាត់ធ្វើនេសាទ មានមិនតិចជាង ២០នាក់ទេ ដែលរវល់ការងារមិនបានទៅលេងបុណ្យចូលឆ្នាំខ្មែរនោះ ព្រោះប្រសិនបើឈប់សម្រាកគ្មានអ្នកធ្វើការងារជំនួស ហើយអាចថៅកែបញ្ឈប់ពីការងារនាំឱ្យលំបាកដល់ក្រុមគ្រួសារ ដោយសារគ្មានប្រាក់ចំណូលផ្ញើទៅឱ្យបងប្អូនប្រើប្រាស់នៅស្រុកកំណើត។

ឆ្លើយតបនឹងបញ្ហានេះ អាស៊ីសេរីមិនអាចសុំអត្ថាធិប្បាយពីមន្ត្រីស្ថានទូតខ្មែរ ប្រចាំទីក្រុងបាងកកទទួលបន្ទុកផ្នែកពលករ លោក ចិន សំណាង បាននៅឡើយទេ ដោយជំនួយការទទួលទូរស័ព្ទជំនួសប្រាប់ថា លោកជាប់រវល់ប្រជុំ៖ «អត់ទេបងខ្ញុំគ្រាន់តែប្រាប់ព័ត៌មានផ្សេងៗ ដូចជាករណីប្រកាន់សង្គម អីផ្សេង បើទាក់ទងរឿងពលករធ្វើការថ្ងៃបុណ្យជាតិមិន បានឈប់សម្រាកខ្ញុំអត់ដឹងដែរ»។

អាស៊ីសេរីមិនទាន់អាចទាក់ទងអ្នកនាំពាក្យក្រសួងការបរទេស លោក កេត សុផាន់ ដើម្បីសាកសួរពីក្ដីបារម្ភរបស់ពលករបាននៅឡើយទេ ដោយសារតែលោកមិនលើកទូរស័ព្ទ។ រីឯអគ្គកុងស៊ុលខ្មែរប្រចាំខេត្តស្រះកែវ លោក ហ៊ុន សារឿន មានប្រសាសន៍យ៉ាងខ្លីថា លោកមិនអាចអត្ថាធិប្បាយជុំវិញបញ្ហានេះបានទេ៖ «ព្រោះខ្ញុំអត់មានសិទ្ធិនិយាយសូមអធ្យាស្រ័យផង បងសួរទៅអ្នកនាំពាក្យក្រសួងការបរទេសទៅគាត់ក្ដាប់បានព័ត៌មានទាំងអស់នេះ សូមអធ្យាស្រ័យផងបង»។

នាយកប្រតិបត្តិមជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស ហៅថា សង់ត្រាល់ (CENTRAL)លោក មឿន តុលា មានប្រសាសន៍ប្រាប់អាស៊ីសេរីថា ការបង្ខំឱ្យពលករធ្វើការនៅថ្ងៃបុណ្យជាតិ គឺជាការរំលោភច្បាប់ការងាររបស់ប្រទេសថៃ ព្រោះច្បាប់ថៃ បានកំណត់ឱ្យកម្មករ ឬពលករ ឈប់សម្រាកនៅថ្ងៃបុណ្យជាតិ បើទោះបីជាពួកគេត្រឡប់ទៅលេងស្រុកកំណើត ឬមិនទៅក៏ដោយ ក៏ពួកគេត្រូវបានឈប់សម្រាកដែរ៖ «ទោះជាយ៉ាងណាក៏ដោយនេះជាភស្តុតាងមួយថ្មីទៀត ដែលបង្ហាញថា រដ្ឋាភិបាលថៃមិនទាន់បានអនុវត្តអ្វីដែលខ្លួនបានសន្យាជាមួយសហគមន៍អឺរ៉ុប ពាក់ព័ន្ធការកែសម្រួលលក្ខខ័ណ្ឌការងាររបស់ពលករនៅលើទូកនេសាទ បានពេញលេញនៅឡើយទេ កន្លងមកយើងតែងតែបានលើកឡើងពីបញ្ហានេះ ហើយយើងឃើញមានការប្រែប្រួលចំនួន ដូចថៃបានផ្តល់សច្ចាប័នទៅលើអនុសញ្ញាស្តីពីការពារសិទ្ធិពលករនៅលើទូក នេសាទក៏ដោយ ក៏ប៉ុន្តែការអនុវត្តជាក់ស្តែងនៅមានរឿងច្រើនទៀត តាំងពីលក្ខខ័ណ្ឌការងារ លក្ខខ័ណ្ឌសុខភាព សុវត្ថិភាព និងអនាម័យនៅលើទូកជាដើម»។

កន្លងមកធនាគារពិភពលោករាយការណ៍ថា ប្រទេសថៃមានចំនួនកម្មករចំណាកស្រុកខ្ពស់ជាងគេក្នុងតំបន់អាស៊ីអាគ្នេយ៍ គឺជិត ៤ លាននាក់ (៣.៧៦) នៅក្នុងឆ្នាំ២០១៥ ក្នុងនោះ ៥៣ ភាគរយមកពីប្រទេសភូមា ២៦ ភាគរយមកពីប្រទេសឡាវ និង ២១ ភាគរយមកពីកម្ពុជា។ ចំណែកទិន្នន័យរបស់រដ្ឋាភិបាលថៃវិញ បង្ហាញថា ពលករចំណាកស្រុកកម្ពុជា ឡាវ និងភូមាដែលបានចុះឈ្មោះរួចរាល់គិតត្រឹមខែវិច្ឆិកា ឆ្នាំ២០១៧ មានចំនួនជិត ២លាននាក់ (១.៧២៦.៤១៥) ក្នុងនោះជិត ៥ម៉ឺននាក់ ចុះឈ្មោះធ្វើការក្នុងឧស្សាហកម្មនេសាទ។

កន្លងមកអង្គការឃ្លាំមើលសិទ្ធិមនុស្សអន្តរជាតិ យូមែន រ៉ៃត៍ វ៉ច្ឆ (Human Rights Watch) អំពាវនាវដល់រដ្ឋាភិបាលកម្ពុជាឱ្យគិតគូរ និងចាត់វិធានការជាក់លាក់នានា ដើម្បីការពារ និងជួយសង្គ្រោះពលរដ្ឋរបស់ខ្លួន។ យូមែន រ៉ៃត៍ វ៉ច្ឆ ស្នើរដ្ឋាភិបាលកម្ពុជា ត្រូវស៊ើបអង្កេត និងដាក់ទោសតាមផ្លូវច្បាប់ចំពោះជនណាដែលទទួលខុសត្រូវ និងចូលរួមក្នុងបណ្តាញជួញដូរមនុស្សនៅក្នុងប្រទេសដែលសហការជាមួយឈ្មួញកណ្តាលនៅក្នុងប្រទេសថៃ ប្រើប្រាស់មធ្យោបាយទុច្ចរិតដើម្បីផ្គត់ផ្គង់បុរស និងក្មេងប្រុសទៅកាន់ទូកនេសាទថៃ។ កម្ពុជាត្រូវជួយអាជ្ញាធរថៃក្នុងការកាត់ទោសអ្នកជួញដូរមនុស្ស ជួយបង្កបរិយាកាសធ្វើចំណាកស្រុកដោយសុវត្ថិភាព និងរិះរកយុទ្ធសាស្ត្រផ្សេងទៀតដើម្បីកាត់បន្ថយភាពងាយរងគ្រោះចំពោះពលករចំណាកស្រុកគ្រប់ប្រភេទ។ យូមែន រ៉ៃត៍ វ៉ច្ឆ ក៏ស្នើឱ្យកម្ពុជាត្រូវជំរុញឱ្យរដ្ឋាភិបាលថៃចាត់វិធានការចំពោះការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចកម្លាំងពលកម្មលើទូកនេសាទថៃ ព្រមទាំងដាក់ទោសទណ្ឌដល់ម្ចាស់ទូក និងមន្ត្រីពុករលួយណា ដែលបានប្រព្រឹត្តបទឧក្រិដ្ឋទៅលើកម្មករទូកនេសាទ។

## កម្ពុជា-ឡាវ ឯកភាពគ្នាបន្តសហការទប់ស្កាត់ បទល្មើសឆ្លងដែននានា

https://www.postkhmer.com/ សុទ្ធ គឹមសឿន | Publication date 25 February 2019 | 09:12 ICT

**ភ្នំពេញ:** កម្ពុជា-ឡាវ ប្តេជ្ញារួមគ្នាទប់ស្កាត់ការជួញដូរមនុស្ស និងបទល្មើសនានាឆ្លងតាមព្រំដែននៃប្រទេសទាំង ២ ដោយជំរុញឲ្យលើកកម្ពស់កិច្ចសហប្រតិបត្តិការរវាងកងយោធពលខេមរភូមិន្ទកម្ពុជា និងកងទ័ពប្រជាជនឡាវតាមរយៈការផ្លាស់ប្តូរបទពិសោធ និងទស្សនកិច្ចគ្រប់កម្រិត។ នេះបើយោងតាមសេចក្តីប្រកាសព័ត៌មានក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិកម្ពុជា។

សេចក្តីប្រកាសព័ត៌មាននេះ បានឲ្យដឹងថា សហប្រធានកិច្ចប្រជុំគណៈកម្មការចម្រុះសម្រាប់កិច្ចសហប្រតិបត្តិការទ្វេភាគីកម្ពុជា-ឡាវ លើកទី១៣ កាលពីថ្ងៃទី ២១-២២ ខែកុម្ភៈ ដឹកនាំដោយ លោក ប្រាក់ សុខុន រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិកម្ពុជា និងលោក សាលើមសៃ គុំម៉ាស៊ីត រដ្ឋមន្ត្រីក្រសួងការបរទេសប្រទេសឡាវ នៅរដ្ឋធានីវៀងចន្ទន៍ ប្រទេសឡាវ ហើយភាគីទាំង ២ បានឯកភាពលើកកម្ពស់ការយល់ដឹងរបស់ប្រជាជនខ្លួនលើឯកសារព្រំដែនដែលត្រូវបានព្រមព្រៀងដោយប្រទេសទាំង ២ ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការក្នុងការលើកកម្ពស់សកម្មភាពទប់ស្កាត់ដូចជា ការជួញដូរមនុស្ស អន្តោប្រវេសន៍ខុសច្បាប់ ពាណិជ្ជកម្មខុសច្បាប់ និងការឆ្លងដែនខុសច្បាប់តាមបណ្តោយព្រំដែនជាដើម។

ភាគីទាំង ២ ក៏បានពិភាក្សាអំពីការដោះស្រាយបញ្ហាព្រំដែន និងលើកទឹកចិត្តឱ្យក្រសួងការបរទេសនៃប្រទេសទាំង ២ បញ្ចប់សេចក្ដីព្រាងបែបបទបច្ចេកទេស [Terms of Reference (TOR)] ឲ្យបានឆាប់ ស្របតាមខ្លឹមសារនៃលិខិតរួមរបស់នាយករដ្ឋមន្ត្រីប្រទេសទាំង ២ ចុះថ្ងៃទី ៦ ខែកញ្ញា ឆ្នាំ២០១៧ ផ្ញើជូនប្រធានាធិបតីបារាំង។ កិច្ចប្រជុំក៏បានឯកភាពអំពីការបង្កើនកិច្ចសហប្រតិបត្តិការលើវិស័យផ្សេងៗទៀត ដែលក្នុងនោះរួមមាន អប់រំ ព័ត៌មាន កសិកម្ម ទេសចរណ៍ វប្បធម៌ សុខភាពសាធារណៈ ប្រៃសណីយ៍ និងទូរគមនាគមន៍ច្បាប់និងកិច្ចសហប្រតិបត្តិការតុលាការ និងកិច្ចសហប្រតិបត្តិការកុងស៊ុល។ កិច្ចប្រជុំបានស្វាគមន៍ការរៀបចំបឋមនៃការដឹកជញ្ជូនឆ្លងកាត់ព្រំដែនដោយរថយន្តដឹកអ្នកដំណើររវាងកម្ពុជា និងឡាវ ជាពិសេសរវាងភ្នំពេញប៉ាក់សេ និងសៀមរាបប៉ាក់សេ។ ភាគីទាំង ២ ក៏បានឯកភាពគ្នាពង្រឹងកិច្ចសហប្រតិបត្តិការអាកាសចរណ៍ស៊ីវិលលើផ្នែកសុវត្ថិភាព សន្តិសុខ ការអភិវឌ្ឍផ្លូវអាកាស និងការផ្លាស់ប្ដូរការបណ្ដុះបណ្ដាល និងពិនិត្យលទ្ធភាពបង្កើនការហោះហើរត្រង់បន្ថែមទៀតរវាងប្រទេសទាំង ២។ ក្រៅពីកិច្ចសហប្រតិបត្តិការទ្វេភាគីប្រទេសទាំង ២ បានសម្ដែងការប្ដេជ្ញាចិត្តបន្តកិច្ចសហប្រតិបត្តិការក្នុងយន្តការថ្នាក់អនុតំបន់ និងតំបន់ឆ្ពោះទៅកសមាហរណកម្ម និងការតភ្ជាប់សេដ្ឋកិច្ចប្រកបដោយចីរភាព និងគ្រប់ជ្រុងជ្រោយ។

លោក គិន ភា ប្រធានវិទ្យាស្ថានទំនាក់ទំនងអន្តរជាតិនៃរាជបណ្ឌិត្យសភាកម្ពុជា និងជាអ្នកវិភាគបញ្ហានយោបាយបានយល់ឃើញថា ស្ថានភាពទំនាក់ទំនងកម្ពុជា-ឡាវ សព្វថ្ងៃនេះហាក់ដូចជាបងប្អូនល្អ ឬជាអ្នកជិតខាងល្អ ស្របពេលដែលប្រទេសទាំង ២ មានទំនៀមទម្លាប់ សាសនា និងជីវភាពប្រជាជនប្រហាក់ប្រហែលគ្នាដែរ ប៉ុន្តែទើបតែថ្មីៗនេះ គ្រាន់តែមានការយល់ច្រឡំលើគ្នាបន្តិចបន្តួចពីបញ្ហាព្រំដែននៅជាប់ខេត្តស្ទឹងត្រែងនោះ។ លោកបន្តថា៖ «បញ្ហាដែលភាគីទាំង ២ បានប្ដេជ្ញាលើបញ្ហាបទល្មើសឆ្លងដែននានានោះ គឺល្អ ខ្ញុំគាំទ្រ ព្រោះបទល្មើសដែលភាគីទាំង ២ តែងជួបប្រទះនោះ គឺការជួញដូរគ្រឿងញៀនពីឡាវមកកម្ពុជាយើង។ ដូច្នេះ អាជ្ញាធរកម្ពុជា និងឡាវចាំបាច់ត្រូវពង្រឹងច្បាប់ និងសហការគ្នាឲ្យស្អិតល្មួត ហើយករណីបទល្មើសផ្សេងៗទៀត គឺប្រទេសទាំង ២ មិនសូវជួបប្រទះទេ»។

គួររំឭកដែរថា កាលពីខែកុម្ភៈ ឆ្នាំ ២០១៧ យោធាឡាវរាប់រយនាក់បានចូលមកទឹកដីកម្ពុជាក្បែរតំបន់អូរអាឡៃ និងអូរតាង៉ាវស្រុកសៀមប៉ាង ខេត្តស្ទឹងត្រែងដើម្បីរារាំងកម្លាំងវិស្វកម្មកម្ពុជាមិនឲ្យសង់ផ្លូវតាមក្រវាត់ព្រំដែនក្នុងទឹកដីកម្ពុជា និងបានឈរជើងនៅទីនោះរហូតដល់លោក ហ៊ុន សែន នាយករដ្ឋមន្ត្រីព្រមាន និងបានដាក់ឱសានវាទ ៦ ថ្ងៃឲ្យដកទ័ពចេញពីទឹកដីកម្ពុជា។ កម្ពុជា និងឡាវ មានព្រំដែនជាប់គ្នាប្រវែង ៥៤០ គីឡូម៉ែត្រដែលត្រូវបោះបង្គោលប្រមាណ ១៤៥ ប៉ុន្តែរហូតមកទល់ពេលនេះ ទើបតែបោះបាន ១២១ បង្គោលស្មើនឹង ៨៣ ភាគរយហើយសល់ប្រមាណ ២៤ បង្គោលទៀតនៅក្នុងខេត្តព្រះវិហារ និងខេត្តស្ទឹងត្រែងរបស់កម្ពុជា៕

## ថៃសម្រួលតម្លៃ សម្រាប់ពលករខ្មែរវិលមកចូលឆ្នាំ

https://www.postkhmer.com/ សុទ្ធ គឹមសឿន | Publication date 25 February 2019 | 08:38 ICT

**ភ្នំពេញ:** រដ្ឋាភិបាលថៃបានឯកភាពជួយសម្រួលដល់ពលករកម្ពុជាដែលត្រូវឆ្លងដែនមកស្រុកកំណើតនាឱកាសបុណ្យចូលឆ្នាំដោយមិនគិតថ្លៃការរក្សាសិទ្ធិទិដ្ឋាការ (Re-Entry) ចាប់ពីថ្ងៃទី ៥-៣០ ខែមេសាឆ្នាំនេះ ជាអ្វីដែលសង្គមស៊ីវិលសាទរចំពោះការសម្រេចនេះ។ នេះបើតាមសេចក្ដីប្រកាសព័ត៌មានរបស់ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសថៃ។

សេចក្ដីប្រកាសព័ត៌មានរបស់ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសថៃចុះថ្ងៃទី ២២ កុម្ភៈ ដែលភ្នំពេញប៉ុស្តិ៍ទើបទទួលបានកាលពីម្សិលមិញ បានជូនដំណឹងដល់សាធារណជនជាពិសេសពលករកម្ពុជាដែលកំពុងធ្វើការស្របច្បាប់នៅថៃទាំងអស់ថា ដើម្បីចូលរួមពីធីបុណ្យចូលឆ្នាំប្រពៃណីជាតិខ្មែរនាពេលខាងមុខរដ្ឋាភិបាលថៃបានឯកភាពសម្រួលដល់ពលករកម្ពុជាដែលត្រូវធ្វើដំណើរឆ្លងដែនទៅស្រុកកំណើតនៅកម្ពុជា ដោយអនុគ្រោះមិនគិតថ្លៃការរក្សាសិទ្ធិទិដ្ឋាការ (Re-Entry) ចាប់ពីថ្ងៃទី ៥-៣០ ខែមេសា ឆ្នាំ ២០១៩។ សេចក្ដីប្រកាសព័ត៌មានបន្តថា កន្លងមកបងប្អូនពលករដែលកំពុងស្នាក់នៅនិងធ្វើការស្របច្បាប់ក្នុងប្រទេសថៃដែលមានបំណងឆ្លងដែនទៅកម្ពុជានិងត្រឡប់ចូល

មកធ្វើការនៅថៃវិញត្រូវស្នើសុំរក្សាសិទ្ធិទិដ្ឋាការនិងមានការបង់ថ្លៃមុននឹងធ្វើដំណើរទៅកម្ពុជា។ សេចក្តីប្រកាសព័ត៌មានបានបញ្ជាក់ថា៖ «ការអនុគ្រោះលើកលែងថ្លៃរក្សាសិទ្ធិទិដ្ឋាការនេះ នឹងចាប់ផ្តើមអនុវត្តចាប់ពីថ្ងៃទី ៥-៣០ ខែមេសាឆ្នាំ២០១៩។ បងប្អូនពលករទាំងអស់ត្រូវធ្វើដំណើរត្រឡប់ចូលមកប្រទេស ថៃ វិញយ៉ាងយូរត្រឹមថ្ងៃទី ៣០ ខែមេសា ឆ្នាំ ២០១៩»។

លោក មឿន តុលា នាយកប្រតិបត្តិមជ្ឈមណ្ឌលសម្ព័ន្ធភាពការងារនិងសិទ្ធិមនុស្ស (Central) បានថ្លែងថា ការលើកលែងឬអនុគ្រោះតម្លៃនេះគឺជាការយោគយល់ភាគីថៃ មិនមែនស្នើសុំដោយកម្ពុជាទេ។ លោកបន្តថា វាជារឿងល្អសម្រាប់ពលករខ្មែរដែលកំពុងធ្វើការនៅទីនោះ ព្រោះបុណ្យចូលឆ្នាំ គឺជាថ្ងៃសំខាន់សម្រាប់ថៃក៏ដូចជាកម្ពុជាដែរ។ ដូច្នេះ តាមប្រពៃណីគឺខ្មែរឬថៃត្រូវការជួបជុំបងប្អូន សាច់ញាតិ ទោះបីជាបែកឆ្ងាយប៉ុន្មានឆ្នាំក៏ដោយ។ លោកបន្តថា ការចំណាយថ្លៃការរក្សាសិទ្ធិទិដ្ឋាការនេះ គឺជាបន្ទុក ១ ធំសម្រាប់ពលករខ្មែរ ព្រោះចេញឬចូលម្តងត្រូវចំណាយពី ១ ០០០ បាត ឬលើសពីនេះ។ ប្រសិនបើបានបិទត្រង់ចំណុចនេះ គឺវាអាចជួយកាត់បន្ថយការចំណាយរបស់ពលករច្រើន ប៉ុន្តែរដ្ឋាភិបាលកម្ពុជាក៏ត្រូវពិចារណាឆ្នាំក្រោយៗទៀត។ លោកបន្តថា ការចំណាយលើការដឹកជញ្ជូន សុំកុំឲ្យមានការឡើងថ្លៃទាំងភាគីថៃ និងកម្ពុជា ព្រោះការចំណាយនេះក៏នៅកម្រិតខ្ពស់ដែរ «ចំពោះអាជ្ញាធរកម្ពុជា ក៏ត្រូវតែប្រាកដថា មិនត្រូវគិតលុយពីពលករដែរ ខណៈពួកគាត់ឆ្លងមកពីថៃ ខ្ញុំចង់ឲ្យអាជ្ញាធរខ្មែរត្រូវតាមដានឲ្យបានដិតដល់ ដើម្បីជួយសម្រួលឲ្យពួកគាត់បានមកលេងស្រុកដោយរីករាយទាំងចេញនិងចូលធ្វើការវិញ។ ខ្ញុំក៏ស្នើឲ្យអាជ្ញាធរខ្មែរស្នើទៅថៃចេញសារាចរនេះឲ្យបានទៅដល់ពលករផ្សេងទៀតដូចជា ពលករនេសាទនិងពលករដទៃទៀត»។

ពលករខ្មែរម្នាក់មានស្រុកកំណើតនៅខេត្តបន្ទាយមានជ័យ សុំមិនបញ្ចេញឈ្មោះដែលកំពុងបម្រើការងាររោងចក្រ ១ នៅខេត្តអយុធ្យា ប្រទេស ថៃ បានប្រាប់ភ្នំពេញប៉ុស្តិ៍តាមសារអេឡិចត្រូនិកថា លោកសប្បាយរីករាយចំពោះដំណឹងនេះ ប៉ុន្តែលោកនៅបារម្ភខាងកម្ពុជាដែលអាចនៅបន្តចំណាយដដែល។ លោកបន្តថា ការចំណាយលើឯកសារនៅថៃ មិនសូវអស់លុយប៉ុន្មានទេ ប៉ុន្តែសេវានេះនៅកម្ពុជាពិតជាចំណាយច្រើន ដោយមិនក្រោមពី ១០០ ទៅ ១ ០០០ បាតទេ នៅពេលចេញឬចូលម្តងៗ «នៅថៃឯណោះ ខ្ញុំមិនសូវចំណាយលុយប៉ុន្មានទេ ខ្លាចតែខាងកម្ពុជាយើងទេ គឺត្រូវចំណាយច្រើនផ្នែក សូម្បីតែអ្នកចង្អុលផ្លូវឲ្យទៅស៊ីញ៉េកន្លែងនេះ កន្លែងនោះហ្នឹង ក៏ត្រូវឲ្យលុយគាត់ដែរ»។ លោកស្នើសុំឲ្យភាគីកម្ពុជាបន្ធូរបន្ថយការយកតម្លៃលើផ្នែកសេវាឯកសារចេញឬចូលឲ្យប្រហាក់ប្រហែលនឹងថៃ ព្រោះការចំណាយរបស់ពលករចំណាកស្រុកលើឯកសារទាំងនេះនៅតែជាបន្ទុកធំដដែល។

តាមសេចក្តីប្រកាសព័ត៌មានរបស់ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសថៃដដែលក៏បានបង្ហាញដែរថា តាមច្បាប់អន្តោប្រវេសន៍របស់ថៃការស្នើសុំរក្សាសិទ្ធិទិដ្ឋាការ (Re-Entry Visa) ប្រភេទចេញចូលមួយលើក (Single) មានតម្លៃ ១ ០០០ បាត និងប្រភេទចេញចូលច្រើនលើក (Multiple) មានតម្លៃ ៤ ៨០០ បាត។ យ៉ាងណាក្តី ស្ថានឯកអគ្គរាជទូតថៃប្រចាំកម្ពុជា មិនទាន់អាចទាក់ទងសុំការបញ្ជាក់ជុំវិញករណីនេះបានទេ កាលពីម្សិលមិញ៕

## វេទិកាបញ្ចេញមតិយោបល់ ពលករបទេសលើកទី៣ នៅខេត្តឈុនបុរី

http://www.pheaktraofficial.com/ 24-02-2019

ខេត្តឈុនបុរី៖នៅថ្ងៃអាទិត្យទី២៤ ខែកុម្ភៈ ឆ្នាំ២០១៩ កន្លងទៅនេះ មូលនិធិបណ្តាញលើកកម្ពស់គុណភាពជីវិតពលករ( LPN)ប្រទេសថៃ សហការជាមួយ អាជ្ញាធរពាក់ព័ន្ធ មានដូចជាតម្រួតអន្តោប្រវេសន៍ ,ស្នងការតម្រួតក្រុងប៉ាតាយ៉ា ,កងរក្សាសន្តិសុខផ្ទៃក្នុងក្រសួងមហាផ្ទៃ,មន្ទីរគាំពារសិទ្ធិពលករខេត្តឈុនបុរី បានរៀបចំ វេទិកាបញ្ចេញមតិយោបល់ របស់ពលករចំណាក់ស្រុក ដែលកំពុងធ្វើការរស់នៅក្នុងខេត្តឈុនបុរី វេទិកាបញ្ចេញមតិយោបល់នេះបានរៀបចំឡើងនៅសណ្ឋាគារ Mind Resort Pattaya Tai សារ:ខាន់នៅក្នុងវេទិកាបានផ្តល់ឱកាសអោយបងប្អូនពលករបរទេស ឡើងបញ្ចេញមតិយោបល់ និងសំណួរ ចម្ងល់ របស់ខ្លួនទៅកាន់អាជ្ញាធរពាក់ព័ន្ធ ដើម្បីរកវិធានការដោះស្រាយបញ្ហាទៅថ្ងៃមុខទៀត។

ខ្លឹមសារនៃវេទិកាបញ្ចេញមតិមានដូចខាងក្រោម៖

*អាជ្ញាធរអន្តោប្រវេសន៍ ក្រុងប៉ាតាយ៉ា ធ្វើការណែនាំ ពលករ អោយយល់ដឹងអំពី រឿងវីសាក្លែងក្លាយ ដែរកំពុងរាតត្បាតយ៉ាងខ្លាំងនៅក្នុងវិស័យ ដំណើរការនិតិវិធីស្របច្បាប់ដល់ពលករ។

*មន្ទីរគាំពារសិទ្ធិពលករ បានធ្វើការណែនាំដល់ពលករ អំពីនិតិវិធីក្នុងទាមទារសិទ្ធិ នៅពេលរងការរំលោភបំពានកម្លាំងពលកម្មនិងគេង ប្រវ័ញ្ចប្រាក់ឈ្នួល។

*អាជ្ញធររក្សាសន្តិសុខផ្ទៃក្នុងក្រសួងមហាផ្ទៃ បានធ្វើការពន្យល់អំពី និតិវិធីធ្វើដំណើរវិលត្រឡប់ទៅលេងស្រុកកំណើតក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខាងមុខ និងនិតិវិធីប្តូរថៅកែថ្មីចំពោះពលករចូលមកធ្វើការតាមរយៈប្រព័ន្ធMOU

*ស្នងការតម្រួតក្រុងប៉ាតាយ៉ា បានធ្វើការពន្យល់ណែនាំដល់ពលករ ដែលរងការគំរាមកំហែងដោយអំពើហិង្សាណាមួយ សូមមកដាក់ពាក្យបណ្តឹង ដើម្បីអោយសមត្ថកិច្ចជួយអន្តរាគមន៍ អោយទាន់ពេលវេលា។

៖សមាគមន៍កម្មករបរទេស បានធ្វើការណែនាំពន្យល់ដល់ពលករអំពីការរស់នៅធ្វើការក្នុងប្រទេសថៃ ជាមួយនិយោជកថៃ ដើម្បីបង្កើនទំនុកចិត្តដល់និយោជកនិងពលករ។

*មូលនិធិ (LPN) ប្រទេសថៃ បានធ្វើការពន្យល់ដល់ពលករអំពីសិទ្ធិរស់នៅក្នុងប្រទេសនិង ជំរុញឲ្យពលករចូលរួមបណ្តុះបណ្តាល អប់រំយល់ដឹងអំពីសិទ្ធិរបស់ខ្លួន និងការរួមចំណែកជួយពលករដូចដែលរងគ្រោះដោយសារអំពើជួញដូរមនុស្ស។

*តំណាងសមាគមន៍ពលករភូមា នៅក្នុងប្រទេសថៃ បានអំពាវនាវឲ្យពលករភូមា ដែលធ្វើការក្នុងក្រុងប៉ាតាយ៉ា ខេត្តឈុនបុរី ចេះស្រលាញ់គ្នា និងជួយគ្នានៅពេលជួបបញ្ហា ឈានទៅរកការដោះស្រាយដោយសន្តិវិធី។

*តំណាងពលករកម្ពុជាក្នុងខេត្តឈុនបុរី បានផ្តល់មតិស្នើសុំដល់អាជ្ញាធរពាក់ព័ន្ធ យកចិត្តទុកដាក់អំពីបញ្ហាជំរិតទារប្រាក់ពីពលករនៅពេលធ្វើដំណើរទៅលេងស្រុកកំណើតនៅក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខាងមុខ ។

**កូនៗរបស់ពលករបរទេសក៏ទទួលបានសិទ្ធិចូលរៀននៅក្នុងសាលារដ្ឋ របស់ប្រទេសថៃដែរ**

https://www.facebook.com/ ទីប្រឹក្សាទទួលបន្ទុកពលករប្រចាំប្រទេសថៃ 25-02-2019

យោងតាមប្រកាសរបស់ក្រសួងសិក្សាថៃចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៨ ស្តីអំពីការទទួលសិស្ស និស្សិតដែលមិនមានអត្រា នុកូលដ្ឋាន ឬមិនមានសញ្ជាតិថៃឱ្យចូលរៀននៅតាមស្ថាប័ន សិក្សារបស់ប្រទេសថៃ: ក្រសួងសិក្សាថៃ បានជូនដំណឹងដល់ ដល់ស្ថាប័នសិក្សារដ្ឋ ឱ្យទទួលសិស្ស និសិត្ស ដែលមិនមាន អត្រានុកូលដ្ឋាន ឬមិនមានសញ្ជាតិថៃអាចចូលរៀនក្នុងសាលា រដ្ឋ ដូចពលរដ្ឋថៃដែរ។ ដូច្នេះសូមបងប្អូនពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការ នៅក្នុងប្រទេសថៃ ដែលមានបំណងបញ្ជូនកូនៗ ដែលកំពុង ស្នាក់នៅក្នុងបន្ទុកជាមួយ ឱ្យចូលរៀននៅក្នុងសាលារបស់រដ្ឋ របស់ប្រទេសថៃ សូមទៅទំនាក់ទំនងនៅតាមសាលារៀន ស្ថិតក្នុងខេត្តដែលបងប្អូនធ្វើការ។

# ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៩

**ស្នងការនគរបាលខេត្តកំពង់ស្ពឺ ប្រាប់មន្ត្រីឲ្យ ខិតខំបង្ការ ទប់ស្កាត់ និងបង្ក្រាបរាល់បទល្មើសព្រហ្មទណ្ឌ គ្រឿងញៀន អំពើជួញដូរមនុស្ស**

http://www.cen.com.kh/archives/ February 26, 2019

ខេត្តកំពង់ស្ពឺ ៖ លោកស្នងការនគរបាលខេត្តកំពង់ស្ពឺ បានធ្វើការកត់សម្គាល់គ្រើនរំលឹកដល់បណ្ដាអង្គភាពការិយាល័យជំនាញ អធិការដ្ឋាននគរបាលក្រុង ស្រុក ប៉ុស្តិ៍នគរបាលរដ្ឋបាល ត្រូវបន្តខិតខំបង្ការ ទប់ស្កាត់ និងបង្ក្រាបរាល់បទល្មើសព្រហ្មទណ្ឌ គ្រឿងញៀន អអំពើជួញដូរមនុស្ស។ នាព្រឹកថ្ងៃចន្ទ ទី២៥ ខែកុម្ភៈ ឆ្នាំ២០១៩ នៅ សាល

ប្រជុំស្នងការដ្ឋាននគរបាលខេត្តកំពង់ស្ពឺ មានបើកកិច្ចប្រជុំបូកសរុបលទ្ធផលកិច្ចប្រតិបត្តិការរក្សាសន្តិសុខ សណ្តាប់ធ្នាប់ សង្គម ប្រចាំខែកុម្ភៈ លើកទិសដៅភារកិច្ចអនុវត្តខែមិនានិងផ្សព្វផ្សាយខ្លឹមសារសំខាន់ៗមួយចំនួនដែលដកស្រង់ពីសន្និបាតអគ្គស្នងការនគរបាលជាតិកាលពីថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩ ជូនដល់សមាជិកអង្គប្រជុំជ្រាបនិងអនុវត្ត។ កិច្ចប្រជុំមានកត្តិយសក្រោមអធិបតីភាពលោកឧត្តមសេនីយ៍ទោ សម សាមួន ស្នងការនគរបាល ខេត្តកំពង់ស្ពឺ និងមានការអញ្ជើញចូលរួមពីលោកលោកស្រីស្នងការរង លោកនាយរងផែន លោកនាយ នាយរងការិយាល័យ លោកអធិការ អធិការរង និងមន្ត្រីពាក់ព័ន្ធអ្នកចូលរួមសរុប ៦២នាក់ស្រី ២។

មានប្រសាសន៍បើកអង្គប្រជុំលោកស្នងការបានជម្រាប អំពីសភាពការណ៍វិវត្តន៍ថ្មីៗ និងការធានាបាននូវសន្តិសុខ ស្ថេរភាព សណ្តាប់ធ្នាប់របៀបរៀបរយសង្គមល្អ ទាំងបទល្មើសព្រហ្មទណ្ឌ ចរាចរណ៍ ការបង្កចលាចលសង្គម សកម្មភាពញុះញង់ការតវ៉ាទាមទារនិងបទល្មើសផ្សេងៗទៀតទាំងនេះ គឺដោយសារកិច្ចខិតខំប្រឹងប្រែងជាស្នាដៃរបស់កងកម្លាំងនគរបាលយេ ីងគ្រប់ផ្នែកគ្រប់ថ្នាក់ទាំងអស់គ្នា។ ក្រោយកិច្ចផ្សព្វផ្សាយខ្លឹមសារសំខាន់ៗមួយចំនួនរួចមកមានការចូលរួមយោបល់ពីសមាជិកអង្គប្រជុំ លោកអធិការក្រុង ស្រុក លោកនាយការិយាល័យជំនាញពាក់ព័ន្ធ លោកលោកស្រីស្នងការរង ក្នុងកិច្ចធានាការអនុវត្តតាមបទបញ្ជាថ្នាក់ដឹកនាំឲ្យមានប្រសិទ្ធភាពខ្ពស់។ មានមតិចុងក្រោយលោកស្នងការបានធ្វើការកត់សម្គាល់ក្រើនរំលឹកដល់បណ្តាអង្គភាពការិយាល័យជំនាញ អធិការដ្ឋាននគរបាលក្រុងស្រុក ប៉ុស្តិ៍នគរបាលរដ្ឋបាល ត្រូវបន្តខិតខំបង្ការ ទប់ស្កាត់ និងបង្ក្រាបរាល់បទល្មើសព្រហ្មទណ្ឌ គ្រឿងញៀន អំពើជួញដូរមនុស្ស ចរាចរណ៍ ខិតខំបំរើនិងផ្តល់សេវាជូនដល់ប្រជាពលរដ្ឋដើម្បីបំផុសអោយមានការចូលរួមសហការការអនុវត្តគោលនយោបាយភូមិ.ឃុំ មានសុវត្ថិភាព លក្ខណៈសម្បត្តិ ៩យ៉ាង ជម្រុញការផ្សព្វផ្សាយផលប៉ះពាល់ក្រោមឥទ្ធិពលជាតិស្រវឹង គោរពច្បាប់ចរាចរណ៍ផ្លូវគោក ការប្រើប្រាស់គ្រឿងញៀន ពិសេសត្រូវគិតពីបញ្ហាគ្រោះរាំងស្ងួតនាឆ្នាំ២០១៩នេះ តាមការព្យាករណ៍របស់ក្រសួងធនធានទឹកនិងឧត្តុនិយមថាតំបន់ខ្លះជួបការខ្វះទឹក ដូច្នេះត្រូវត្រៀមសម្ភារៈមធ្យោបាយសំរាប់កិច្ចការជួយសង្គ្រោះបន្ទាន់ ជូនដល់ប្រជាពលរដ្ឋ ៕ ដោយ ៖ កូឡាប

## ថៃបញ្ជូនពលរដ្ឋខ្មែរ៣៤នាក់ មកកម្ពុជាវិញ

https://www.facebook.com/ General Department of Immigration - GDI 25-02-2019

បាត់ដំបង៖ កម្លាំងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិព្រំ នាថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៩ បានទទួលពលរដ្ឋខ្មែរ ៣៤នាក់ ដែលនគរបាលអន្តោប្រវេសន៍ច្រកទ្វារបានផាកាត ខេត្តចន្ទបុរី មិនប្រថាប់ត្រាអនុញ្ញាតឲ្យចូលប្រទេស។ កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការសួរនាំ នូវពលរដ្ឋខ្មែរខាងលើ បានឲ្យដឹងថា សមត្ថកិច្ចអន្តោប្រវេសន៍ថៃមិនអនុញ្ញាតឲ្យចូលប្រទេស ពលរដ្ឋទាំងអស់នោះ មានគោលបំណងធ្វើដំណើរទៅប្រទេសម៉ាឡេស៊ី មូលហេតុដោយសារមានភេវរកម្ម និងអសន្តិសុខ នៅក្នុងខេត្តភាគខាងត្បូងប្រទេសថៃ។ បន្ទាប់ពីបានសួរនាំរួច កម្លាំងនគរបាលប៉ុស្តិ៍ បានណែនាំនិងពន្យល់ដល់គាត់ថា សមត្ថកិច្ចខាងកម្ពុជា មិនហាមឃាត់ក្នុងការធ្វើដំណើរចេញពីប្រទេសទេ តែការហាមមិនឲ្យចូលប្រទេសថៃ ជាសិទ្ធិរបស់សមត្ថកិច្ចថៃ៕

## កិច្ចប្រជុំពិភាក្សា សំណេះសំណាលសួរសុខទុក្ខ និងណែនាំតម្រង់ទិសដល់បងប្អូនពលករផ្នែកកសិកម្ម នៅតំបន់ Miryang ប្រមាណជិត ២០០នាក់

https://www.facebook.com/RoyalEmbassyinSeoul/ 26-02-2019

ក្រោយទទួលបានសំណូមពរពីសមាគមនិយោជកនៃតំបន់ Miryang មជ្ឈមណ្ឌលគាំពារពលករបរទេសទីក្រុង Changwon និង Miryang បានសហការជាមួយសមាគមនិយោជកតំបន់ Miryang និងស្ថានទូតកម្ពុជា រៀបចំកិច្ចពិភាក្សា សំណេះសំណាល និងណែនាំតម្រង់ទិសដល់បងប្អូនពលករផ្នែកកសិកម្ម នៅតំបន់ Miryang ប្រមាណជិត

២០០នាក់ នារសៀលថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៩ នៅសាលធំនៃសាលាក្រុង Miryang ។ មុនឈានចូលដល់កម្មវិធីសំណេះសំណាល ឯកឧត្តម ឡុង ឌីម៉ង់ ឯកអគ្គរាជទូតកម្ពុជា បានជួបពិភាក្សា ជាមួយនឹងតំណាងនិយោជកមកពីគ្រប់ឃុំ នៃតំបន់ Miryang ដើម្បីស្តាប់របាយការណ៍ បញ្ហា កង្វល់ និងសំណូមពរ ដើម្បីស្វែងរកដំណោះស្រាយរួមគ្នាលើបញ្ហាដែលកើតមានកន្លងមកជាមួយនឹងពលករកម្ពុជា។ ជាការឆ្លើយតប ឯកឧត្តមឯកអគ្គរាជទូត បានទទួលយករាល់សំណូមពរ និងកង្វល់ទាំងអស់របស់ក្រុមនិយោជក ដើម្បីយកមកអប់រំផ្សព្វផ្សាយដល់បងប្អូនពលករខ្មែរទាំងអស់ដែលបំពេញការងារនៅសាធារណរដ្ឋកូរ៉េ ដើម្បីឱ្យមានការយោគយល់ពីរបៀបរបប និងវិន័យក្នុងការរស់នៅប្រទេសកូរ៉េ និយាយជារួម និងនិយាយដោយឡែករស់នៅធ្វើការជាមួយនឹងនិយោជក។ បន្ថែមពីលើនេះក្នុងកិច្ចសំណេះសំណាល ឯកឧត្តម ឡុង ឌីម៉ង់ ក៏បានរៀបរាប់ពីការយកចិត្តទុក្ខដាក់ពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា ដល់បងប្អូនពលករខ្មែរទាំងអស់ ទោះទៅដល់ទីណាក៏ដោយក៏រាជរដ្ឋាភិបាលកម្ពុជានៅតែនឹងរលឹក យកចិត្តទុកដាក់ និងជួយគាំពារ តាមគ្រប់មធ្យោបាយអស់ពីលទ្ធភាពដែលអាចធ្វើទៅបាន ហើយក៏បានអប់រំផ្សព្វផ្សាយដល់បងប្អូនពលករ នូវរបៀបរបប វិន័យ និងឥរិយាបថនៃការរស់នៅឱ្យបានល្អប្រសើរ រក្សាតម្លៃជាពលករខ្មែរនៅសាធារណៈរដ្ឋកូរ៉េ ជាមួយនឹងនិយោជក៕

## ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៩

### ក្រសួងការងារចាប់ផ្តើមដាក់ឲ្យប្រើប្រាស់រថយន្តមជ្ឍមណ្ឌលការងារចល័តនៅទូទាំងប្រទេស

https://kohsantepheapdaily.com.kh/ ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០១៩ ម៉ោង ០៩:៥៨ អ៊ាង ប៊ុនរិទ្ធ

រាជធានីភ្នំពេញ ៖ ដើម្បីផ្តល់ព័ត៌មាន និងឱកាសការងារកាន់តែខិតជិតដល់សិស្សនិស្សិត និងប្រជាពលរដ្ឋដែលកំពុងស្វែងរកការងារធ្វើនៅគ្រប់ទីកន្លែងទូទាំងប្រទេស ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានដាក់ឲ្យប្រើប្រាស់នូវរថយន្ត មជ្ឈមណ្ឌលការងារចល័ត ដំបូងគេបង្អស់នៅកម្ពុជា ។ ថ្លែងក្នុងសន្និសីទបិទគម្រោងស្តីពី«ការគាំទ្រដល់ការអភិវឌ្ឍជំនាញ និងការងាររបស់យុវជននៅកម្ពុជា និងពិធីសម្ពោធមជ្ឈមណ្ឌលការងារចល័ត» កាលពីរសៀលថ្ងៃទី២៦ ខែកុម្ភៈ លោក អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈមានប្រសាសន៍ថា ការដាក់ឲ្យប្រើប្រាស់នូវរថយន្តមជ្ឈមណ្ឌលការងារចល័តពិតជាមានសារៈសំខាន់ណាស់ក្នុងការចូលរួមចំណែកជាមួយរាជរដ្ឋាភិបាលកម្ពុជាក្នុងអភិវឌ្ឍធនធានមនុស្ស និងទីផ្សារការងារ ជាពិសេសតំបន់ជនបទ និងខេត្តឆ្ងាយៗដែលមិនទាន់មានមជ្ឈមណ្ឌលការងារនៅឡើយ ។ ទន្ទឹមនឹងនេះយុវជនទទួលបានការងារកាន់តែងាយស្រួលឆាប់រហ័ស និងចំណេញពេលវេលា ដែលស្របតាមក្របខណ្ឌគោលនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍវិស័យការងាររបស់រាជរដ្ឋាភិបាលកម្ពុជា ។ លោកបានបន្តថា ក្រសួងការងារបានខិតខំបង្កើតឱកាសការងារកាន់តែច្រើន និងជួយបែងចែកឱកាសទាំងនេះឲ្យបានទៅដល់ប្រជាជនគ្រប់រូបប្រកបដោយតម្លាភាព និងសមធម៌សំដៅប្រែក្លាយឱកាសការងារដែលមានទាំងអស់ឲ្យទៅជាមុខរបរកាន់តែល្អសម្រាប់ប្រជាជនគ្រប់រូប ។

លោកបានបញ្ជាក់ថា«ការអនុវត្តគម្រោង SIDA ទាំងពីរដំណាក់កាលនេះពិតជាមានសារៈសំខាន់ណាស់ ក្នុងការចូលរួមចំណែកជាមួយរាជរដ្ឋាភិបាលកម្ពុជាក្នុងអភិវឌ្ឍធនធានមនុស្សនិងទីផ្សារការងារ ជាពិសេសយុវជនឲ្យទទួលបានការងារកាន់តែងាយស្រួលឆាប់រហ័ស និងចំណេញពេលវេលាដែលស្របតាមក្របខណ្ឌគោលនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍវិស័ យការងាររបស់រាជរដ្ឋាភិបាលកម្ពុជាក៏ដូចជាក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈក្នុងការខិតខំបង្កើតឱកាសការងារកាន់តែច្រើន និងជួយបែងចែកឱកាសទាំងនេះឲ្យបានទៅដល់ ប្រជាជនគ្រប់រូបប្រកបដោយតម្លាភាព និងសមធម៌សំដៅប្រែក្លាយឱកាសការងារដែលមានទាំងអស់ឲ្យទៅជាមុខរបរកាន់តែល្អសម្រាប់ប្រជាជនគ្រប់រូប» ។ លោករដ្ឋមន្ត្រីក៏បានលើកឡើងថា តាមរយៈការអនុវត្តគម្រោងនេះអ្នកទទួលផលផ្ទាល់ដែលភាគច្រើនជាយុវជនសិស្សនិស្សិត ស្ត្រី និងជនពិការបានទទួលការបណ្តុះបណ្តាលអភិវ ឌ្ឍជំនាញ និងទទួលបានឱកាស

ការងារកាន់តែងាយស្រួលមានជាអាទិ៍ការបណ្តុះបណ្តាលជំនាញទន់ និងសហគ្រិនភាពចំនួន៣,៤៥០នាក់ អ្នកចុះឈ្មោះស្វែងរកការងារសរុបចំនួនប្រ មាណ៩ម៉ឺននាក់ អ្នកទទួលបានការងារធ្វើប្រមាណ២ម៉ឺននាក់ សិស្សនិស្សិត និងអ្នកស្វែងរកការងារទទួលការប្រឹក្សាអាជីពចំនួនប្រមាណ១៤ម៉ឺននាក់ យុវជនទទួលបានកម្មសិក្សាចំនួន៧៤៩នាក់ ។

លោកបន្ថែមថា ការដាក់ឲ្យប្រើប្រាស់នូវរថយន្ត«មជ្ឈមណ្ឌលការងារចល័ត»ដំបូងគេបង្អស់នៅកម្ពុជាដែលត្រូវបានរៀបចំបំពាក់នៅក្នុងរថយន្តមីនីវ៉ាន ហើយមានមុខងារផ្តល់នូវសេវាសំខាន់ៗដូចមជ្ឈមណ្ឌលការងារធម្មតាដែរ ដូចជា ការស្វែងរកមើលព័ត៌មានការងារ ការចុះឈ្មោះរកការងារតាមប្រព័ន្ធអ៊ីនធើណិត និងទម្រង់ក្រដាស ការទទួលប្រឹក្សាយោបល់ការងារ និងបណ្ណាល័យការងារជាដើម ។ ប៉ុន្តែចំណុចពិសេសរបស់មជ្ឈមណ្ឌលការងារចល័ត គឺអាចនាំយកសេវាការងារ និងព័ត៌មានឱកាសការងារកាន់តែខិតជិតដល់ប្រជាពលរដ្ឋអ្នកស្វែងរកការងារសិស្សនិស្សិតនៅគ្រប់ទីកន្លែងទូទាំងប្រទេស ជាពិសេសតំបន់ជនបទ និងខេត្តឆ្ងាយៗដែលមិនទាន់មានមជ្ឈមណ្ឌលការងារនៅឡើយ ។ ប៉ុន្តែចំណុចពិសេសរបស់មជ្ឈមណ្ឌលការងារចល័ត គឺអាចនាំយកសេវាការងារ និងព័ត៌មានឱកាសការងារកាន់តែខិតជិតដល់ប្រជាពលរដ្ឋ អ្នកស្វែងរកការងារសិស្សនិស្សិត នៅគ្រប់ទីកន្លែងទូទាំងប្រទេស ជាពិសេសតំបន់ជនបទ និងខេត្តឆ្ងាយៗដែលមិនទាន់មានមជ្ឈមណ្ឌលការងារនៅឡើយ ៕

## អតីតពលករកូរ៉េ លោកឧកញ៉ា ឡេង ណាវ៉ាត់ត្រា នឹងចេះលុយ១លានដុល្លារ ដើម្បីបើកថ្នាក់បង្រៀនភាសាកូរ៉េដល់កូនខ្មែរ

http://www.cambodiawikinews.com/ February 26, 2019

ប្រិយមិត្តពិតជាស្គាល់លោក ឧកញ៉ា ឡេង ណាវ៉ាត្រា រួចមកលោកមានអាជីវកម្មជាមួយអចលទ្រព្យ ជារើយលោកតែងតែជួយដល់បងប្អូនក្រីក្រ ទុគតជន ជាពិសេសផ្តល់ជូនការងារអោយមនុស្សជាច្រើននាក់ទៀតផងយ៉ាងណាមិញមុននេះបន្តិច ប្រភពហ្វេសប៊ុកលោក ឧកញ៉ាបានលើកឡើងថា "#ជួយshareបើមានអ្នកចុះឈ្មោះរៀនភាសាកូរ៉េចាប់ពី1000នាក់ឡើងទៅខ្ញុំនឹងចំនាយប្រាក់1លានដុល្លា ទិញដីនឹងសង់អាគា ជួលគ្រូបង្រៀនដោយឥតគិតថ្លៃ ។ សូមយោបល់បងប្អូនផងតើខ្ញុំធ្វើឬអត់ខ្ញុំសង្កេតឃើញថា បងប្អូនដែលរៀនភាសាកូរ៉េ មានកាលំបាកច្រើន។ ហើយពេលមិនបានទៅខាតទាំងលុយទាំងពេលវេលា ការចំណាយទាំងនោះ អស់ទៅលើទី1 ហូបចុក ទី2 ស្នាក់នៅ ទី 3 ថ្លៃសិក្សា ទី 4 ខ្វះខាត ព័ត៌មាន ចាញ់បោកគេទី 5 ខ្វះពេលវេលាឡើងចុះស្រុកកំណើតបំពេញឯកសារផ្សេងៗ ផលវិបាកទាំងអស់នេះ ធ្វើអោយបងប្អូនដែលមានជីភាពទីទាល់ក្រស្រុកស្រែមិនអាចមានឱកាសទៅបំរើកាងារនៅប្រទេសកូរ៉េបានឡើយ ។ គឺគាត់ទៅថៃ ព្រោះគាត់ត្រូវការលុយដោះស្រាយប្រចាំថ្ងៃឆាបប់ៗហើយ ពិបាករកកាងារដែលមានពេលវេលាសំរាប់រៀនផង ធ្វើការផង និងមិនដឹងរៀបចំជីវិតបែបណាជាមធ្យមអ្នកដែលប្រលងទៅធ្វើការនៅកូរេ តាំងពីរៀនរហូតដល់ប្រឡង បានទៅធ្វើការនៅកូរ៉េចំណាយតិចបំផុត 3000 ដុល្លារ ក្នុងមួយនាក់ និងប្រើពេលពី1ឆ្នាំទៅ3ឆ្នាំទើបបានទៅ ដែលការចំណាយទាំងអស់នេះ សម្រាប់បងប្អូនដែលមានចំណូលតិច។ គ្រួសារខ្វះខាត មិនអាចមានឱកាសក្នុងការចូលរៀន ដើម្បីប្រលងទៅកូរ៉េបានទេ ដូច្នេះខ្ញុំសម្រេចចិត្តថាចង់បើកសាលាបង្រៀនភាសាកូរ៉េដោយមិនគិតថ្លៃ និងមានការងារធ្វើនៅទីតាំងក្បែរសាលារៀនផ្ទាល់ ដើម្បីផ្គត់ផ្គង់ការចំណាយ ការហូបចុក ការស្នាក់នៅ និងប្រាក់សម្រាប់ប្រើប្រាស់ផ្សេងៗ ដូចជាសំបុត្រយន្តហោះជាដើម បើសិនមានអ្នកចុះឈ្មោះចាប់ពី 1.000 នាក់ឡើងទៅ ខ្ញុំនឹងសាងសង់សាលា ភាសាកូរ៉េដោយឥតគិតថ្លៃ និងមានការងារអោយធ្វើ ប្រាក់ប្រចាំថ្ងៃទាបបំផុត 3ម៉ឺនរៀល ដល់ 20 ម៉ឺនរៀលក្នុងមួយថ្ងៃ តាមជំនាញ ។ ហើយនិងសម្របសម្រួលផលលំបាកខាងលើ ដូច្នេះអ្នកដែលធ្វើការ និងរៀនបណ្តើរទោះ មិនបានទៅក៏មានចំណូលនិងមានកាងារធ្វើដែដោយមិនមានការខាតបង់ពេលវេលានិងលុយកាក់ឡើយ។

## ពលរដ្ឋខ្មែរ ធ្វើការនៅកូរ៉េ នឹងទទួលជំនាញ មួយច្បាស់លាស់ និងនាំសេដ្ឋកិច្ចចូលកម្ពុជា

https://www.dap-news.com/ ByID:112 Posted on 27 February 2019 | 11:02

ភ្នំពេញ ៖ លោក ឡុង ឌីម៉ង់ ឯកអគ្គរាជទូតកម្ពុជា ប្រចាំកូរ៉េ បានលើកឡើងថា ពលរដ្ឋខ្មែរធ្វើការនៅកូរ៉េជាច្រើន ជាពិសេសស្ត្រី នឹងទទួលបានជំនាញ ក៏ដូចជានាំសេដ្ឋកិច្ចយកចូលទៅកម្ពុជាវិញ នាពេលខាងមុខ។ យោងតាមបណ្តាញសង្គមហ្វេសប៊ុករបស់លោក ឡុង ឌីម៉ង់ នៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៩បានឲ្យដឹងថា លោកបានធ្វើដំណើរ តាមរថភ្លើងទៅកាន់តំបន់មីលីយ៉ាំង ដែលជាតំបន់កសិកម្មដ៏មមាញឹកមួយ ចម្ងាយជិត៤០០គីឡូម៉ែត ហើយមានពលករខ្មែរជាច្រើន ជាពិសេសស្ត្រី បាននិងកំពុងធ្វើការនៅទីនោះ។ លោកបញ្ជាក់ថា "ពួកគាត់ខំប្រឹងធ្វើការនេះ ដើម្បីទទួលបាននូវជំនាញ ក៏ដូចជាសេដ្ឋកិច្ចយកចូលទៅប្រទេសកម្ពុជាវិញនាពេលខាងមុខ" ។ ជាមួយគ្នានេះ លោកបន្តថា ស្ថានទូតបានជួបពិគ្រោះពិភាក្សាគ្នាលើចំណុចវិជ្ជមាន និងអវិជ្ជមានមួយចំនួនដែលប្រព្រឹត្តដោយពលករ ជាមួយសមាគមនិយោជកកូរ៉េដែលទទួលយកពលករបរទេស ដោយត្រង់ទៅត្រង់មក និងមានលក្ខណៈកែលម្អក្នុងន័យស្ថាបនា។ លោក ឡុង ឌីម៉ង់ ឲ្យដឹងទៀតថា កង្វល់ក៏ដូចជាសំណូមពររបស់ភាគីថៅកែ បានយកមកសម្របសម្រួល និងអប់រំណែនាំជូនពលករ ក្នុងន័យស្រលាញ់ អាណិតលើកតំកើងកិត្តិយសកិត្យានុភាពជាតិសាសន៍ ដោយមិនចង់ឲ្យបរទេសមើលស្រាលដោយសារតែរបៀបរបបរស់នៅ និងចរិកមាយាទប្រចាំថ្ងៃដែលនៅខ្វះចន្លោះនោះទេ៕ ដោយ៖ នឿត សម្ផស្ស

## ពលករខ្មែរ ១០នាក់ ដែលអាជ្ញាធរថៃចាប់បញ្ជូនត្រឡប់មកកម្ពុជាវិញ

https://www.facebook.com/ General Department of Immigration - GDI 26-02-2019

បន្ទាយមានជ័យ៖ កម្លាំងនគរបាលប៉ុស្តិ៍ច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត នៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៩ បានទទួលពលករខ្មែរ ១០នាក់ ដែលអាជ្ញាធរថៃចាប់បញ្ជូនត្រឡប់មកវិញ ក្នុងនោះស្រី ៥នាក់ និងកុមារ ១នាក់៕

## ដំណឹងល្អ ដំណឹងល្អ!ជប៉ុនធ្វើកំណែទម្រង់ច្បាប់ថ្មីឲ្យពលករខ្មែរ ខណៈប្រាក់ខែបានពី ១ ៥០០ ដុល្លារ

http://www.cambodiawikinews.com/ February 26, 2019

រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានអះអាងថា ចាប់ពីខែមេសា ឆ្នាំ២០១៩ ខាងមុខតទៅ ប្រទេសជប៉ុននឹងបើកទីផ្សារទទួលពលករពីកម្ពុជា និងបណ្តាប្រទេសនានាជាដៃគូ ដើម្បីបម្រើការងារ នៅក្នុងប្រទេសជប៉ុន ។ពិតជាដំណឹងរីករាយមួយក្រោយកំណែទម្រង់ច្បាប់ថ្មី ជប៉ុនបានចាប់ផ្តើមបើកទីផ្សារការងារទទួលពលករកម្ពុជា និងបណ្តាប្រទេសមួយចំនួនទៀត ទៅបម្រើការនៅប្រទេសខ្លួន ដោយនឹងក្លាយជាពលករពេញសិទ្ធនិងទទួលបានទិដ្ឋាការការងារ (Working Visa) បានតែម្តង។ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានអះអាងថា កម្ពុជានិងជប៉ុនបានចុះកិច្ចព្រមព្រៀងសហប្រតិបត្តិការស្តីពី «ពលករជំនាញ» ដោយចាប់ពីខែមេសា ឆ្នាំ២០១៩ ខាងភាគីជប៉ុននឹង ចាប់ផ្តើមទទួលពលករកម្ពុជាឱ្យទៅធ្វើការជាលក្ខណៈពលករពេញសិទ្ធិ មិនមែន ជាកម្មសិក្សាការីដូចមុនទៀតទេ។ លោកបញ្ជាក់បន្ថែមថា ប្រព័ន្ធថ្មីនេះត្រូវអនុវត្តន៍ចាប់ពីខែមេ សា ឆ្នាំ ២០១៩ តទៅ ហើយការបញ្ជូនពលករដែលមានជំនាញខ្ពស់ទៅធ្វើការនៅក្នុងប្រទេសជប៉ុន តាមកំណែ ទម្រង់ច្បាប់ថ្មីរបស់ជប៉ុន។

ឯកឧត្តមរដ្ឋមន្ត្រីបន្តថា "នេះជាឱកាសថ្មីមួយដែលជប៉ុន បើកទូលាយក្នុងការទទួលយកពលករពេញសិទ្ធិពីកម្ពុជា ក៏ដូចជាពីបណ្តាប្រទេសជាដៃគូនានា ដើម្បីទៅធ្វើការនៅប្រទេសជប៉ុន"។ ឯកឧត្តមបានបន្តទៀតថា ការធ្វើច្បាប់ថ្មីរបស់ជប៉ុននេះ ក៏ដើម្បីបំពេញតម្រូវការដែលកំពុងខ្វះខាតកម្លាំងពលកម្មនៅក្នុងប្រទេសជប៉ុនដែរ ជាពិសេសការចុះកិច្ចព្រមព្រៀងនេះ ក៏ជាឱកាសសម្រាប់ប្រទេសកម្ពុជានិងបណ្តាប្រទេសនានាក្នុងការបញ្ជូនពលករក្នុងការទទួលបានការងារក៏ដូចជាហ្វឹកហ្វឺនជំនាញវិជ្ជាជីវៈ ដែលមានកម្រិត ខ្ពស់នៅក្នុងប្រព័ន្ធការងារនៅក្នុងឧស្សាហកម្មនៅ

ប្រទេសជប៉ុន។គិតត្រឹមខែធ្នូ ឆ្នាំ២០១៨ កន្លងមក កម្ពុជាបានបញ្ជូនកម្មសិក្សាការីសរុប ជាង៩ ០០០នាក់ ដែលបាន ទៅធ្វើកម្មសិក្សានិងធ្វើការនៅប្រទេសជប៉ុន ដោយពលករម្នាក់ៗ ទទួលបានប្រាក់ឈ្នួលជាមធ្យម ប្រមាណ ១ ៥០០ ដុល្លារ សហរដ្ឋអាមេរិកក្នុងមួយខែ៕

## អាជ្ញាធរថៃ ចាប់បញ្ជូនពលករខ្មែរ ជាង៤០នាក់មកកម្ពុជាវិញ ស្របពេលភាគខាងត្បូង ប្រទេសថៃ កើតមានភេរវកម្ម និងបញ្ហាអសន្តិសុខ

https://www.dap-news.com/ ByID:114 Posted on 26 February 2019 | 16:43

ភ្នំពេញ៖ ក្នុងរយៈពេល២ថ្ងៃអាជ្ញាធរថៃ បានធ្វើការចាប់បញ្ជូនពលករខ្មែរ ចំនួន៤៤នាក់ មកកាន់កម្ពុជាវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត និងច្រកទ្វារព្រំដែនអន្តរជាតិព្រំ ដោយសារមានភេរវកម្ម និងបញ្ហាអសន្តិសុខ នៅខេត្តភាគខាងត្បូងប្រទេសថៃ។

យោងតាមគេហទំព័រ អគ្គនាយកដ្ឋានអន្តោប្រវេសន៍ បានឲ្យដឹងថា កម្លាំងនគរបាលប៉ុស្តិ៍ ច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត នៅថ្ងៃទីថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៩ បានទទួលពលករខ្មែរ ១០នាក់ ដែលអាជ្ញាធរថៃ ចាប់បញ្ជូនត្រឡប់មកវិញ ក្នុងនោះស្រី ៥នាក់ និងកុមារ ១នាក់។

ចំណែកកម្លាំង ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិព្រំ កាលពីថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៩ បានទទួលពលរដ្ឋខ្មែរ ៣៤នាក់ ដែលនគរបាលអន្តោប្រវេសន៍ ច្រកទ្វារបានផាកាត ខេត្តចន្ទបូរី មិនប្រថាប់ត្រាអនុញ្ញាត ឲ្យចូលប្រទេស។

កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការសួរនាំ នូវពលរដ្ឋខ្មែរខាងលើ បានឲ្យដឹងថា សមត្ថកិច្ចអន្តោប្រវេសន៍ថៃ មិនអនុញ្ញាតឲ្យចូលប្រទេស ពលរដ្ឋទាំងអស់នោះ មានគោលបំណង ធ្វើដំណើរទៅប្រទេសម៉ាឡេស៊ី មូលហេតុដោយសារមានភេរវកម្ម និងអសន្តិសុខ នៅក្នុងខេត្តភាគខាងត្បូងប្រទេសថៃ។ បន្ទាប់ពីបានសួរនាំរួច កម្លាំងនគរបាលប៉ុស្តិ៍ បានណែនាំនិងពន្យល់ដល់ពលករថា សមត្ថកិច្ចខាងកម្ពុជា មិនហាមឃាត់ ក្នុងការធ្វើដំណើរចេញពីប្រទេសទេ តែការហាមមិនឲ្យចូលប្រទេសថៃ ជាសិទ្ធិរបស់សមត្ថកិច្ចថៃ៕

## ប៉ូលិសថៃគ្រោងចាត់វិធានការលើសិស្សខ្មែរឥស្លាមរឿងប្រព្រឹត្តខុសច្បាប់អន្តោប្រវេសន៍ថៃ

https://www.rfa.org/khmer/news/ ដោយ មួង ណារ៉េត 2019-02-26

អាជ្ញាធរថៃគ្រោងបើកកិច្ចប្រជុំជាមួយតំណាងសាលាឥស្លាមឯកជនច្រើនជាង ៦០០កន្លែង នៅខេត្តភាគត្បូង ក្នុងរវាងពីរសប្តាហ៍ខាងមុខទៀតនេះ បន្ទាប់ពីទទួលដំណឹងថា មានសិស្សខ្មែរជាច្រើននាក់ កំពុងសិក្សាដោយខុសច្បាប់នៅទីនោះ។ អង្គការសិទ្ធិមនុស្សជំរុញឱ្យរដ្ឋាភិបាលកម្ពុជាអន្តរាគមន៍ករណីនេះឱ្យបានទាន់ពេលវេលា ដោយកុំរង់ចាំរហូតទាល់តែមានការចាប់ខ្លួនពលរដ្ឋខ្មែរទាំងនោះ។ អាជ្ញាធរថៃអះអាងថា មានសិស្សខ្មែរឥស្លាមរាប់រយនាក់មកពីកម្ពុជា កំពុងរៀនសូត្រអំពីសាសនាឥស្លាមដោយខុសច្បាប់ នៅក្នុងខេត្តយ៉ាឡា (Yala) ប៉ាតានី (Patani) ណារ៉ាធីវ៉ាត (Narathiwat) និងខេត្តសុងខ្លា (Songkhla) ស្ថិតនៅភាគត្បូងប្រទេសថៃ ដែលជាកន្លែងប្រឈមមុខដាក់គ្នារវាងទាហានរដ្ឋាភិបាល និងក្រុមឧទ្ទាមផ្តាច់ទឹកដី។ កិច្ចប្រជុំដែលអាជ្ញាធរថៃគ្រោងធ្វើជាមួយនឹងតំណាងសាលាឯកជនឥស្លាមទាំងនោះ គឺដើម្បីស្តាប់មតិយោបល់របស់ពួកគេ និងដើម្បីអប់រំពួកគេឱ្យយល់ដឹងកាន់តែច្បាស់អំពីច្បាប់អន្តោប្រវេសន៍។

មេប៉ូលិសអន្តោប្រវេសន៍ថៃ លោក សុរៈឆេត ហាក់ផាន (Surachate Hakparn) ត្រូវបានកាសែតបាងកកប៉ុស្តិ៍ (Bangkok Post) ស្រង់សម្តីកាលពីពេលថ្មីៗនេះថា អាជ្ញាធររីករាយនៅពេលឃើញសិស្សកម្ពុជាមកទទួលការអប់រំផ្នែកសាសនាឥស្លាមនៅប្រទេសថៃ ពីព្រោះកម្ពុជាមិនទាន់មានសាលាឥស្លាមដែលមានស្តង់ដារត្រឹមត្រូវនៅឡើយ។ ក៏ប៉ុន្តែលោកថា សិស្សគ្រប់គ្នាត្រូវតែចូលមកក្នុងប្រទេសថៃ ដោយមានច្បាប់ទម្លាប់ត្រឹមត្រូវ។ មេប៉ូលិសថៃរូបនេះ

អះអាងថា អាជ្ញាធរថៃមិនមែនចង់និយាយថា ពលរដ្ឋខ្មែរកំពុងចូលមកបង្កបញ្ហានៅក្នុងស្រុកថៃឡើយ ក៏ប៉ុន្តែបើពួកគេស្នាក់នៅលើសកំណត់ ប៉ូលិសអន្តោប្រវេសន៍ត្រូវតែចាប់ខ្លួនពួកគេ និងអនុវត្តទៅតាមច្បាប់។ វិធានការដែលអាជ្ញាធរថៃគ្រោងនឹងដាក់ចេញនេះ គឺនៅបន្ទាប់ពីជនជាតិខ្មែរឥស្លាមជាង ១០នាក់ ត្រូវបានសមត្ថកិច្ចថៃចាប់ខ្លួន កាលពីចុងខែមករា កន្លងទៅ ដោយសង្ស័យថា មានជាប់ពាក់ព័ន្ធនឹងក្រុមចលនាបះបោរមូស្លីមនៅភាគខាងត្បូងប្រទេសថៃ។ ក៏ប៉ុន្តែ ពួកគេត្រូវបានដោះលែងឱ្យត្រឡប់ទៅកម្ពុជាវិញ ដោយសារអាជ្ញាធរថៃរកមិនឃើញពីការជាប់ពាក់ព័ន្ធនឹងក្រុមចលនាបះបោរ។ បទល្មើសដែលអាជ្ញាធរថៃរកឃើញ គឺការចូលមកក្នុងទឹកដីថៃដោយខុសច្បាប់ ការស្នាក់នៅខុសច្បាប់ និងការស្នាក់នៅលើសច្បាប់កំណត់។

ប្រធានគ្រប់គ្រងការិយាល័យឃ្លាំមើលសិទ្ធិមនុស្សនៃអង្គការលីកាដូ (LICADHO) លោក អំ សំអាត ថ្លែងថា រដ្ឋាភិបាលកម្ពុជា តាមរយៈស្ថានទូតខ្មែរនៅទីក្រុងបាងកក គួរតែចុះអន្តរាគមន៍រឿងនេះឱ្យបានទាន់ពេលវេលា ចៀសវាងការចាប់ខ្លួនទ្រង់ទ្រាយធំ នៅពេលសមត្ថកិច្ចថៃចុះទៅពិនិត្យទីតាំងសាលាឥស្លាមទាំងនោះ។ លោកបន្តថា អាជ្ញាធរកម្ពុជាគួរតែសហការជាមួយអាជ្ញាធរថៃ ដើម្បីឱ្យសិស្សខ្មែរឥស្លាមទាំងនោះទទួលបានសិទ្ធិស្នាក់នៅប្រទេសថៃដោយស្របច្បាប់ ទម្រាំពួកគេបញ្ចប់ការសិក្សារបស់ខ្លួន៖ «នៅភាគខាងត្បូងប្រទេសថៃនេះ ជាតំបន់មួយដែលមានភាពប្រទាញប្រទង់រឿងបំបែករដ្ឋ ដូច្នេះជាធម្មតាថៃមានការរឹតបន្តឹងចំពោះការស្នាក់នៅខុសច្បាប់។ នេះជាបញ្ហាចម្បងដែលថៃនឹងមានវិធានការ អ៊ីចឹងដើម្បីកុំឱ្យមានបញ្ហាដល់បងប្អូនខ្មែរឥស្លាមដែលទៅសិក្សាហ្នឹង រដ្ឋាភិបាលតាមរយៈស្ថានទូតខ្មែរប្រចាំប្រទេសថៃ ត្រូវធ្វើយ៉ាងណាដើម្បីឱ្យមានការផ្ដល់ភាពស្របច្បាប់ដល់បងប្អូនខ្មែរឥស្លាមដែលកំពុងបន្តការសិក្សា»។

អាស៊ីសេរីមិនទាន់អាចទាក់ទងមន្ត្រីស្ថានទូតខ្មែរប្រចាំទីក្រុងបាងកកបាននៅឡើយទេ នៅថ្ងៃទី២៦ កុម្ភៈ ចំណែកមន្ត្រីនាំពាក្យរបបក្រុងភ្នំពេញលោក ផៃ ស៊ីផាន ក៏មិនអាចទាក់ទងបានដូចគ្នា ដោយលោកមិនលើកទូរស័ព្ទ។ ក៏ប៉ុន្តែលោកធ្លាប់បានអះអាងប្រាប់អាស៊ីសេរី កាលពីដើមខែកុម្ភៈថា រដ្ឋាភិបាលកម្ពុជាមិនគាំទ្រចំពោះទង្វើល្មើសច្បាប់នេះឡើយ ហើយការអនុវត្តច្បាប់លើពលរដ្ឋខ្មែរដែលប្រព្រឹត្តខុសច្បាប់ថៃនោះ គឺជាការសិទ្ធសម្រេចរបស់អាជ្ញាធរថៃ។ អាស៊ីសេរីក៏បានព្យាយាមទាក់ទងទៅលោក អូស្មាន ហាស្សាន់ ដែលជាទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ដើម្បីសាកសួរព័ត៌មានអំពីការចេញទៅសិក្សារបស់សិស្សខ្មែរឥស្លាមទាំងនោះដែរ ក៏ប៉ុន្តែលោកមិនទទួលទូរស័ព្ទ។

អ្នកការពារសិទ្ធិមនុស្ស លោក អំ សំអាត ស្នើឱ្យពលរដ្ឋខ្មែរមានឯកសារស្របច្បាប់គ្រប់គ្រាន់ មុននឹងចាកចេញពីប្រទេសកម្ពុជា ដើម្បីបញ្ចៀសការចាប់ខ្លួន ឬការធ្វើទុក្ខបុកម្នេញណាមួយនៅក្រៅប្រទេស។ លោកក៏ស្នើឱ្យស្ថាប័នជំនាញយកចិត្តទុកដាក់បន្ថែមទៀតចំពោះជនជាតិខ្មែរឥស្លាមដែលទៅរៀនសូត្រនៅភាគខាងត្បូងប្រទេសថៃ ព្រោះពួកគេអាចស្ថិតក្នុងហានិភ័យខ្ពស់ នៃការចោទប្រកាន់ពាក់ព័ន្ធនឹងការចូលរួមចលនាបះបោរប្រឆាំងនឹងរដ្ឋាភិបាលក្រុងបាងកក៖ «ទោះបីជាខ្មែរឥស្លាមមានឯកសារគ្រប់គ្រាន់ក្នុងការស្នាក់នៅ និងបន្តការសិក្សានៅភូមិភាគខាងត្បូងប្រទេសថៃហ្នឹងក៏ដោយ ក៏មុនពេលដែលចេញទៅ រដ្ឋាភិបាលគួរតែមានការរំឭក និងដាស់តឿនពួកគាត់ហ្នឹងឱ្យបានដឹងហើយមានការប្រុងប្រយ័ត្នពីសុវត្ថិភាពក្នុងការស្នាក់នៅ និងការសិក្សានៅភូមិភាគខាងត្បូងនៃប្រទេសថៃហ្នឹង ដើម្បីចៀសវាងគ្រោះថ្នាក់ដាយថាហេតុ និងបញ្ហាផ្សេងៗចំពោះពួកគាត់»។

គិតត្រឹមពេលបច្ចុប្បន្ន យ៉ាងហោចណាស់ក៏មានមនុស្សប្រមាណ ៧ ពាន់នាក់ដែរ ដែលបានបាត់បង់ជីវិតដោយសារជម្លោះប្រដាប់អាវុធរវាងទាហានរដ្ឋាភិបាលថៃ និងក្រុមចលនាមូស្លីមបះបោរនៅភាគខាងត្បូងប្រទេសថៃជាប់ព្រំប្រទល់ប្រទេសម៉ាឡេស៊ី។ អាជ្ញាធរថៃបានប្រើច្បាប់អាជ្ញាសឹកគ្រប់គ្រងលើដែនដីភាគខាងត្បូងនេះ តាំងតែពីឆ្នាំ ២០០៤ រហូតមក ដោយសារតែអំពើហិង្សា ការបាញ់ប្រហារ និងការកាប់សម្លាប់គ្នាកើតឡើងជាញឹកញាប់នៅតំបន់នោះ៕

# ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៩

## អភិបាលខេត្តស្វាយរៀង ៖ អំពើជួញដូរមនុស្ស គឺជាការគំរាមកំហែង ដោយផ្ទាល់ទៅលើវប្បធម៌ និងប្រពៃណី គ្រួសារ

https://www.dap-news.com/ ByID:114 Posted on 27 February 2019 | 14:04

ស្វាយរៀង៖ លោកម៉ែន វិបុល អភិបាលលខេត្តស្វាយរៀង បានថ្លែងថា អំពើជួញដូរមនុស្ស គឺជាការគំរាមកំហែង ដោយផ្ទាល់ទៅលើវប្បធម៌ និងប្រពៃណីគ្រួសារ តម្លៃសង្គមកម្ពុជា។ ការថ្លែងរបស់អភិបាលខេត្ត បែបនេះនៅក្នុងកិច្ចប្រជុំបូកសរុបលទ្ធផល ការងារប្រចាំឆ្នាំ២០១៨ និងលើកទិសដៅការងារឆ្នាំ២០១៩ របស់គណៈកម្មាធិការខេត្ត ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នាព្រឹកថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៩ ដែលមានអ្នកពាក់ព័ន្ធចូលរួម ប្រមាណជាង២០០នាក់ ។ លោកអភិបាលខេត្ត បានលើកឡើងទៀតថា សមត្ថភាពពាក់ព័ន្ធទាំងអស់ ត្រូវបន្តពិនិត្យមើលទៅលើយន្តការ នៃរចនាសម្ព័ន្ធគ្រប់ថ្នាក់ ទៅលើប្រព័ន្ធនិតិវិធី នៃការអនុវត្តគោលនយោបាយ នៃការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ត្រូវមានផែនការសកម្មភាព ស្របតាមបរិបទសង្គម នៅតាមមូលដ្ឋាន ត្រូវប្រើមធ្យោបាយសរុប កម្លាំងសរុប វិធានការសរុប ដែលជំរុញឱ្យផែនការសកម្មភាព អនុវត្តការងារនេះឱ្យមានប្រសិទ្ធភាព និងទទួលបានជោគជ័យ។ លោកម៉ែន វិបុល ក៏បានជំរុញគាំទ្រ ចំពោះគោលនយោបាយ ជាអាទិភាពរបស់រាជរដ្ឋាភិបាល កម្ពុជាក្នុងការដឹកនាំប្រយុទ្ធប្រឆាំង ការជួញដូរមនុស្ស ដូច្នេះអាជ្ញាធរពាក់ព័ន្ធទាំងអស់ ត្រូវបន្តពង្រឹង គោលនយោបាយភូមិឃុំមានសុវត្ថិភាព ដែលបានអនុវត្តជាប្រចាំបន្ថែមទៀត ដើម្បីតាមដាននូវ សកម្មភាពបទល្មើសជួញដូរមនុស្ស និងត្រូវដាក់ផែនការតាមដានគ្រប់ ក្រុង ស្រុក និងតាមច្រកទ្វារព្រំដែននានា ជាប់ប្រទេសជិតខាង ក្នុងការទប់ស្កាត់ ការបង្ក្រាបការជួញដូរ មនុស្សអោយមានប្រសិទ្ធភាពខ្ពស់៕

## មន្ត្រីសង្គមស៊ីវិលនៅខេត្តឧត្តរមានជ័យបារម្ភអំពីពលរដ្ឋធ្វើចំណាកស្រុកកាន់តែច្រើនដោយសារខ្វះដីដាំដុះ និងដំណាំមិនបានផល

https://www.rfa.org/khmer/news/ 2019-02-27

មន្ត្រីអង្គការសង្គមស៊ីវិលនិងប្រជាពលរដ្ឋនៅខេត្តឧត្តរមានជ័យអះអាងថា មួយរយៈចុងក្រោយនេះបញ្ហាប្រជាពលរដ្ឋនៅក្នុងខេត្តនេះធ្វើចំណាកស្រុកទៅស្វែងរកការងារធ្វើនៅប្រទេសថៃកាន់តែច្រើនឡើង។ ពួកគាត់កត់សម្គាល់ថា បញ្ហាចម្បងដែលបណ្ដាលឲ្យពលរដ្ឋធ្វើចំណាកស្រុកដោយសារឆ្នាំនេះជួបគ្រោះរាំងស្ងួត ដែលធ្វើឲ្យកសិករដាំដុះមិនសូវបានផលហើយលក់ខាតដើមទុន និងបញ្ហាខ្វះដីដាំដុះ។

ប្រជាពលរដ្ឋរស់នៅឃុំចម្ការចេក ស្រុកអូរស្មាច់ខេត្តឧត្តរមានជ័យ អ្នកស្រី ចាន់ សុខេន ឲ្យដឹងអាស៊ីសេរីដឹងកាលពីរសៀលថ្ងៃទី២៥ កុម្ភៈថា ប្រជាពលរដ្ឋនៅតំបន់ដែលអ្នកស្រីរស់នៅ ធ្វើចំណាកស្រុកប្រមាណពី ៥០ទៅ ៦០ ភាគរយនៃចំនួនមនុស្ស ដែលរស់នៅក្នុងភូមិជាប្រចាំ។ ពលរដ្ឋរូបនេះអះអាងទៀតថា សមាជិកក្នុងគ្រួសាររបស់អ្នកស្រីចំនួន ៣នាក់កំពុងធ្វើការនៅប្រទេសថៃ ដោយសារនៅផ្ទះគ្មានការងារធ្វើដែលមានប្រាក់ខែសមរម្យ ដែលជំរុញឲ្យកូនៗ ទាំង៣នាក់ចេញទៅរកការងារនៅក្រៅប្រទេស ដើម្បីបានយកមកទៅដោះបំណុលធនាគារ ដែលបានខ្ចីគេយកមកប្រើប្រាស់ដោះស្រាយជីវភាពប្រចាំថ្ងៃកាលពីឆ្នាំកន្លងមក។ អ្នកស្រីបន្តថា កាលពីឆ្នាំកន្លងទៅក្រុមគ្រួសារអ្នកស្រីបានខ្ចីប្រាក់ពីធនាគារយកធ្វើដើមទុនបើកកន្លែងលក់ដូរតូចតាចនៅក្នុងឃុំ ប៉ុន្តែលក់មិនដាច់ដោយសារនៅក្នុងភូមិមិនសូវមានមនុស្សរស់នៅ ហើយខាត់អស់ដើមទុនរាប់ពាន់ដុល្លារ។អ្នកស្រីបន្ថែមទៀតថា ឆ្នាំនេះក៏កាន់តែលំបាកជាងឆ្នាំមុនៗ ទៀត ព្រោះពលរដ្ឋនៅព្រំដែនតំបន់ពួកគាត់រស់នៅធ្វើចំណាកស្រុកកាន់តែច្រើន ជាពិសេសនៅរដូវប្រាំង ចាប់ពីខែធ្នូរហូតមកទល់សព្វថ្ងៃ៖ «អ្នកដែលគ្នាទៅថៃគាត់ថា មេខ្យល់នាំទៅរត់មកវិញមិនបានលុយផង នាំគ្នាទៅមកៗ ដោយមេខ្យល់ថា ទៅស្រួលមិនអីទេ ខ្ញុំបិះតែទៅជាមួយគេដែរហើយ ដែលគេប្រាប់ថា អូ!ស្រួលណាស់អត់អីទេ ហើយឲ្យប្ដីប្រពន្ធផ្ទះជិតគ្នាទៅមុន រយៈពេលប្រហែលខែមុននេះ ដោយសារខ្ញុំខ្វះខាតពេក ខ្ញុំចង់ទៅថៃជាមួយគេ។ឥឡូវពួកគាត់មកវិញ គាត់ថា រត់ប៉ូលិសច្រើនពេកមិនបានលុយកាក់ទេ ខ្ញុំបិះចាញ់បោកគេដែរ»។ពលរដ្ឋរូបនេះបន្តថា អ្នកដែលធ្វើចំណាកស្រុកនៅតាមព្រំដែនភាគច្រើនទៅរយៈពេលខ្លីចន្លោះពី ៤ ទៅ ៦ខែ ហើយត្រឡប់មកដាំដុះវិញ ព្រោះពួក

គាត់មិនចង់ធ្វើចំណាកស្រុកនោះទេ ដោយចង់រកការងារធ្វើក្នុងស្រុកបានរស់នៅជាមួយក្រុមគ្រួសារ ប្រសើរជាងធ្វើការងារនៅក្រៅប្រទេសប្រថុយប្រថានគ្រោះថ្នាក់ដល់អាយុជីវិត និងប្រឈមនឹងប៉ូលិសថៃចាប់ដាក់គុក ដោយសារពួកគាត់ទៅធ្វើការងារខុសច្បាប់ ព្រោះពួកគាត់ក្រីក្រមិនមានប្រាក់ធ្វើលិខិតឆ្លងដែនទៅធ្វើការស្របច្បាប់នោះទេ។

ចំណែកពលរដ្ឋម្នាក់ទៀតរស់នៅស្រុកអន្លង់វែងលោក ជឹម វណ្ណា អះអាងថា ក្នុងភូមិរបស់លោកប្រមាណ ៥០ ភាគរយបានចំណាកស្រុក ក្នុងនោះមួយចំនួនទៅធ្វើការនៅប្រទេសថៃ និងមួយចំនួនទៀតទៅធ្វើការនៅតាមព្រំដែនជាប់ប្រទេសថៃ ដោយសារឆ្នាំនេះតំបន់ពួកគាត់រស់នៅជួបគ្រោះរាំងស្ងួត ហើយបណ្ដាលឲ្យដំណាំដំឡូងមីមិនសូវបានផលដូចឆ្នាំមុនៗ បើទោះបីឆ្នាំនេះតម្លៃដំឡូងមីបានប្រសើរជាងឆ្នាំមុនបន្តិចក៏ដោយ ក៏មិនអាចទូទាត់ដើមទុន ដែលបានខ្ចីពីធនាគារយកដាំដុះបានដែរ។ ពលរដ្ឋរូបនេះបន្ថែមទៀតថា បញ្ហាមួយទៀត ដោយសារប្រជាពលរដ្ឋខ្វះដីដាំដុះ ជាពិសេសពលរដ្ឋដែលមានទំនាស់ដីធ្លីនៅក្នុងស្រុករាប់រយគ្រួសារ ហើយអាជ្ញាធរមិនបានដោះស្រាយជូនពួកគាត់នៅឡើយទេ ដែលធ្វើឲ្យពួកគាត់កាន់តែក្រីក្រ ហើយបង្ខំចិត្តធ្វើចំណាកស្រុកចោលក្រុមគ្រួសារ៖ «អត់មានអ្នកណាធូរជារទេបង រកមួយថ្ងៃសម្រាប់ចាយមួយថ្ងៃ ហើយដើរស៊ីឈ្នួលដកដំឡូងឲ្យគេ ខ្ញុំចាំមើលអាជ្ញាធរថា មកវាស់វែងដីឲ្យៗ មិនឃើញ រហូតដល់ ២ខែហើយ ដែលអភិបាលស្រុកសន្យាថា មកដោះស្រាយ។ ឥឡូវខ្ញុំចាំបាត់ៗ មិនដឹងយ៉ាងម៉េចទេ»។ លោកបន្តថា ឆ្នាំក្រោយជីវភាពរបស់ពួកគាត់អាចនឹងលំបាកជាងឆ្នាំនេះ ព្រោះពួកគាត់ប្រមាណ ៧០ភាគរយដាំដំឡូងមីដែលមានលើផ្ទៃដីចន្លោះពី ១ ទៅ ៤ហិកតារក្នុងមួយគ្រួសារ ប៉ុន្តែដើមដំឡូងមីឆ្នាំនេះបានក្រៀមស្វិតងាប់អស់ ដែលបណ្ដាលឲ្យខ្វះដើមដំឡូងមីសម្រាប់ធ្វើពូជដាំដុះនៅពេលខាងមុខ។ លោកថា សព្វថ្ងៃកសិករមួយចំនួនបានចេញទៅធ្វើកម្មករនៅតាមព្រំដែន ដើម្បីរកប្រាក់ទិញដើមដំឡូងមីពីប្រទេសថៃយកធ្វើពូជដាំដុះនៅដើមរដូវវស្សាខាងមុខ ដែលធ្វើឲ្យពួកគាត់ត្រូវចំណាយអស់ដើមទុនកាន់តែច្រើនបន្ថែមទៀតទៅការដាំដុះនេះ។

អាស៊ីសេរីមិនទាន់អាចទាក់ទងអភិបាលរងខេត្តឧត្តរមានជ័យ លោក វ៉ាត់ ប៉ា វ៉ានីន ដើម្បីសុំអត្ថាធិប្បាយជុំវិញបញ្ហានេះបានទេនៅថ្ងៃទី២៥ កុម្ភៈ ដោយទទួលទូរស័ព្ទប្រាប់ថាជាប់រវល់នៅព្រំដែន ហើយមិនមានសេវាទូរស័ព្ទ។

ប៉ុន្តែអភិបាលស្រុកអន្លង់វែងលោក ហោ ជិនវីរៈយុទ្ធ មានប្រសាសន៍ប្រាប់អាស៊ីសេរីថា ឆ្នាំនេះកសិករនៅក្នុងស្រុកលោកគ្រប់គ្រងដាំដុះបានផលជាធម្មតា ហើយតម្លៃកសិផលក៏បានប្រសើរជាងឆ្នាំមុនៗដែរ។លោកមានជំនឿទៀតថា ជីវភាពរបស់ពលរដ្ឋនឹងបានប្រសើរជាងឆ្នាំកន្លងទៅ ដោយសារពួកគាត់ភាគច្រើនប្រកបរបរដាំដំឡូងមី ដែលមានផ្ទៃដីសរុបប្រមាណ ៧ពាន់ហិកតារ ហើយគិតត្រឹមថ្ងៃទី២៥ កុម្ភៈកសិករប្រមូលផលដំឡូងអស់ប្រហែល ៨០ភាគរយ ហើយនៅសល់ ២០ភាគរយទៀតមួយចំនួនកំពុងប្រមូលផល និងទុកដើមសម្រាប់ធ្វើពូជដាំដុះបន្តទៀត។ លោកអះអាងទៀតថា ប្រជាពលរដ្ឋធ្វើចំណាកស្រុកជាធម្មតាដូចឆ្នាំមុនៗ ដែរ ដោយមិនមានការកើនឡើងដូចការលើកឡើងរបស់ប្រជាពលរដ្ឋ និងមន្ត្រីអង្គការសង្គមស៊ីវិលនោះឡើយ៖ «អ្នកចំណាកស្រុកគាត់ចេញទៅធ្វើការក្រៅវាជាអាជីពរបស់ពួកគាត់ ហើយសម្រាប់ស្រុកអន្លង់វែងបើជាតួលេខយើងឃើញមានច្រើន តែតាមពិតចំណាកស្រុករបស់គាត់ទៅធ្វើការព្រំដែនប្រទេសថៃទៅព្រឹកហើយវិលល្ងាចមួយចំនួនធំ។ ដូច្នេះការបារម្ភរឿងចំណាកស្រុកអីអត់មានទេ មានតែយើងអំពាវនាវឲ្យអ្នកចំណាកស្រុកត្រឡប់មកវិញ ឥឡូវតម្លៃពលកម្មនៅក្នុងអាចខ្វះខាត ព្រោះកម្មករដែលធ្វើចម្ការស្វាយ និងដកដំឡូងមីអីចង់ពិបាករកកម្មករធ្វើមិនមានផង»។

ទោះជាយ៉ាងណាកាលពីថ្ងៃទី១៣ កុម្ភៈ រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា លោក ហង្ស ជួនណារ៉ុន ថ្លែងថា នៅខេត្តជាប់ព្រំដែនថៃ រួមមានខេត្តបាត់ដំបង បន្ទាយមានជ័យ និងខេត្តឧត្តរមានជ័យ ដែលកុមារបោះបង់ការសិក្សាចំនួន ២៣ភាគរយ គឺចំនួនដែលខ្ពស់ជាងគេបើធៀបនឹងបណ្ដាខេត្តផ្សេងទៀតនៅទូទាំងប្រទេស ដោយសារគ្រួសារក្រីក្រ ហើយឪពុកម្ដាយធ្វើចំណាកស្រុកទៅស្វែងរកការងារធ្វើនៅក្រៅប្រទេស។

មន្ត្រីសម្របសម្រួលសមាគមការពារសិទ្ធិមនុស្ស អាដហុក (Adhoc) ខេត្តឧត្តរមានជ័យលោក ស្រី ណារ៉េន មានប្រសាសន៍ថា នៅតាមឃុំមួយចំនួនក្នុងខេត្តមួយនេះស្ងាត់មិនសូវមានប្រជាពលរដ្ឋនៅផ្ទះដូចឆ្នាំមុនៗ នោះទេ។លោកអះអាងថា ចាប់តាំងពីចុងឆ្នាំ២០១៨ មក ភូមិខ្លះស្ងាត់រហូតដល់លោកចុះអប់រំវិធីការយល់ដឹងផ្នែកសិទ្ធិមនុស្សនៅតាមមូលដ្ឋានស្ទើរតែរកពលរដ្ឋចូលរួមមិនបាន ១០នាក់ផង ដោយសារពួកគាត់ធ្វើចំណាកស្រុក។ លោកបញ្ជាក់ទៀតថា ការធ្វើចំណាកស្រុកនេះបណ្ដាលមកពីដំណាំដាំដុះរបស់កសិករឆ្នាំនេះមិនសូវបានផល និងបញ្ហាខ្វះដីដាំដុះ ជាពិសេសពលរដ្ឋមានទំនាស់ដីធ្លីរ៉ាំរ៉ៃដែលអាជ្ញាធរមិនទាន់ដោះស្រាយ គឺពួកគាត់ធ្វើចំណាកស្រុកច្រើនជាងគេ

៖ «ប្រជាពលរដ្ឋមួយចំនួនពេលដែលធ្វើការទាក់ទងរឿងកសិកម្មរបស់គាត់ គាត់ត្រូវទៅខ្ចីលុយពីធនាគារ ហើយធម្មតាធនាគារគេរកផលប្រយោជន៍របស់គេ ដូច្នេះគេយកការប្រាក់ ហើយបើគាត់ធ្វើកសិកម្មមិនបានផល ដូច្នេះកសិផលដែលទទួលបានក៏មិនរួចនឹងតម្លៃ ដែលគាត់ខ្ចីធនាគារ ហើយពួកគាត់ត្រូវតែបង្ខំចិត្តទៅរកការងារធ្វើនៅប្រទេសថៃ និងតំបន់ផ្សេងៗ ដើម្បីយកតម្លៃពលកម្មមកសងធនាគារវិញ»។ មន្ត្រីសង្គមស៊ីវិលរូបនេះបន្តថា ដើម្បីដោះស្រាយបញ្ហានេះ លុះត្រាតែអាជ្ញាធរពាក់ព័ន្ធបង្កើតប្រព័ន្ធធារាសាស្ត្រនៅតាមឃុំឲ្យបានច្រើន ដើម្បីកសិករយកទឹកដាំដុះបានទាំងរដូវប្រាំងនិងរដូវវស្សា ព្រោះសព្វថ្ងៃកសិករដាំដុះបានតែមួយរដូវ ដោយពួកគាត់រំពឹងទៅលើតែទឹកភ្លៀងក្នុងការស្រោចស្រពផលដំណាំ។ លោកថារដ្ឋាភិបាលក៏ត្រូវជួយរកទីផ្សារសម្រាប់លក់កសិផលរបស់កសិករឲ្យមានតម្លៃប្រសើរជាងបច្ចុប្បន្ន ហើយត្រូវតែបន្ថឹងការនាំចូលបន្លែផ្លែឈើដែលកសិករក្នុងស្រុកដាំដុះបាន និងជួយដោះស្រាយទំនាស់ដីធ្លីជូនពលរដ្ឋដើម្បីពួកគាត់បានដីដាំដុះឲ្យបានគ្រប់គ្នា ដោយមិនមានការភ័យខ្លាចអ្នកមានលុយមានអំណាចបណ្តេញពួកគាត់ចេញពីដីដូចសព្វថ្ងៃទៀត៕

## នគរបាលការិយាល័យប្រឆាំងការជួញដូរមនុស្ស ចុះបង្ក្រាបទីតាំង ម៉ាស្សា បង្កប់សេវាផ្លូវភេទ បម្រើដោយអនីតិជន

http://nokorwatnews.com/ 26-02-2019

ភ្នំពេញ៖ កម្លាំងនគរបាលនៃការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន សហការជាមួយនគរបាលមូលដ្ឋានខណ្ឌចំការមន បានចុះប្រតិបត្តិការបង្ក្រាបទីតាំងម៉ាស្សាឃីហោ ពេជ្របុរាណខ្មែរ មានបង្កប់សេវាផ្លូវភេទ បម្រើដោយអនីតិជន ឃាត់ខ្លួនមនុស្សចំនួន៧នាក់ ក្នុងនោះម្ចាស់ទីតាំង២នាក់ប្តីប្រពន្ធ នារីរងគ្រោះចំនួន៤នាក់ និងភេទទី៣ម្នាក់មើលកូនម្ចាស់ទីតាំង។ ប្រតិបត្តិការនេះធ្វើឡើងកាលពីវេលាម៉ោង១២ និង៣០នាទីថ្ងៃត្រង់នាថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៩ ស្ថិតនៅផ្ទះលេខ១៣៨G ផ្លូវ៤៥០ សង្កាត់ទួលទំពូងទី២ ខណ្ឌចំការមន រាជធានីភ្នំពេញ។ ក្នុងប្រតិបត្តិការនេះ ដោយមានចង្អុលបង្ហាញពី លោកឧត្តមសេនីយ៍ឯក ស ថេត អគ្គស្នងការរងនិងជាស្នងការនគរបាលរាជធានីភ្នំពេញ មានការសម្របសម្រួល ពីលោកស្រី ស៊ី វណ្ណនី ព្រះរាជអាជ្ញារង អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ និងមានការបញ្ជាផ្ទាល់ដោយ លោក ឧត្តមសេនីយ៍ត្រី ចាន់ កិត្តិខុម ស្នងការរងទទួលដឹកនាំការងារការិយាល័យប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ។

នគរបាលបានឲ្យដឹងថា ម្ចាស់ទីតាំងប្តីមានឈ្មោះ ផាន ផេង ភេទប្រុស អាយុ៣១ឆ្នាំ ស្នាក់នៅទីតាំងម៉ាស្សាផ្ទះលេខ១៣៨G ផ្លូវ៤៥០ សង្កាត់ទួលទំពូងទី២ ខណ្ឌចំការមន រាជធានីភ្នំពេញ។ និងប្រពន្ធ ឈ្មោះ អុល សុខុន ភេទស្រី អាយុ២៨ឆ្នាំ ស្នាក់នៅផ្ទះលេខ១៣៨G ផ្លូវ៤៥០ សង្កាត់ទួលទំពូងទី២ ខណ្ឌចំការមន រាជធានីភ្នំពេញ។ កម្លាំងនគរបាលនៃការិយាល័យប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជនបានឲ្យដឹងថាទីតាំងម៉ាស្សាកោសជប់ ឃីហោពេជ្របុរាណខ្មែរ ចាប់ផ្តើមបើកបម្រើសេវាចាប់ពីម៉ោង៨ ព្រឹករហូតដល់យប់ជ្រៅរំលងអធ្រាត្រ ដោយមាននារីក្មេងចាស់ចំនួន៤នាក់រង់ចាំភ្ញៀវ មកម៉ាស្សាធម្មតា តម្លៃ៣ដុល្លារ រយៈពេល១ម៉ោង និងរួមភេទ តម្លៃចាប់ពី ២០ដុល្លារ ទៅ៣០ដុល្លារ ក្នុងមួយដង ។ ក្រោយពេលបញ្ចប់ប្រតិបត្តិការនេះផងដែរ កម្លាំងនគរបាលបានឃាត់ខ្លួនមនុស្សចំនួន ៧នាក់ក្នុងនោះនារីរងគ្រោះចំនួន ៤នាក់(អនីតិជនម្នាក់) ម្ចាស់ទីតាំង២នាក់ប្តីប្រពន្ធ និងភេទទី៣ម្នាក់មើលកូនម្ចាស់ទីតាំង បាននាំខ្លួនយកមកការិយាល័យ ប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនដើម្បីបន្តការសាកសួរ។

សូមបញ្ជាក់ផងដែរ ក្រោយបញ្ចប់ការសាកសួរ ម្ចាស់ទីតាំង២នាក់ប្តីប្រពន្ធត្រូវបាននគរបាលឃុំខ្លួនបណ្តោះអាសន្នដើម្បីចាត់ការតាមនីតិវិធី ។ ជនភេទទី៣ ដែលមិនមានការពាក់ព័ន្ធត្រូវនគរបាលជំនាញធ្វើកិច្ចសន្យាឲ្យទៅផ្ទះវិញ ចំណែកនារីរងគ្រោះទាំង៤នាក់នោះត្រូវបាន នគរបាលប្រគល់ជូនមន្ទីរសង្គមកិច្ចរាជធានីភ្នំពេញ ៕ ស រស្មី

## អាស៊ានបញ្ជ្រាបបញ្ហាជួញដូរមនុស្ស ដល់សិស្សនិស្សិតកម្ពុជា

http://m.freshnewsasia.com/ 2019-02-28

**(ភ្នំពេញ)៖** បញ្ហាប្រឈមចំពោះប្រជាជនអាស៊ាន ដែលកើតចេញពីបទល្មើសជួញដូរមនុស្សនៅតែជាក្ដីព្រួយបារម្ភ សម្រាប់អាស៊ានទាំងមូល ទោះបីកិច្ចខិតខំប្រឹងប្រែងបង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើសទាំងនោះ ត្រូវបានធ្វើឡើងយ៉ាងសកម្មក៏ដោយ។ ដើម្បីចូលរួមចំណែកបញ្ជ្រាបបញ្ហាខាងលើ សាកលវិទ្យាល័យអាមេរិកាំងភ្នំពេញ (AUPP) បានរៀបចំកិច្ចប្រជុំគំរូបែបអាស៊ានដ៏ធំមួយនៅ AUPP ចាប់ពីថ្ងៃទី២២-២៤ ខែកុម្ភៈ ឆ្នាំ២០១៩ ដែលមានការចូលរួមពីសំណាក់សិស្ស-និស្សិតជាង១០០នាក់ មកពីសាកលវិទ្យាល័យ និងវិទ្យាល័យនានាចំនួន១៦ក្នុងរាជធានីភ្នំពេញ។ កិច្ចប្រជុំអាស៊ាននេះបានធ្វើឲ្យសិស្ស-និស្សិត ទទួលបាននូវចំណេះដឹងកាន់តែស៊ីជម្រៅអំពីបញ្ហាជួញដូរមនុស្ស។ កិច្ចប្រជុំនេះក៏ដើរតួនាទីលើកទឹកចិត្តឱ្យអ្នកចូលរួមបើកចិត្តទូលាយ ចែករំលែកគោលគំនិត ទស្សនៈ និងបទពិសោធន៍របស់ពួកគេ។

លោក យៀប សំណាង ដែលត្រូវបានតែងតាំងជាឯកអគ្គរាជទូតកម្ពុជា ប្រចាំនៅអាស៊ាន បានថ្លែងថា «**ប្រជាជនវ័យក្មេង អាស៊ានមិនត្រឹមតែរួមចំណែកដល់គ្រប់ដំណាក់កាល នៃការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមប៉ុណ្ណោះទេ ថែមទាំងជម្រុញកិច្ចសហប្រតិបត្តិការ និងទំនាក់ទំនងរវាងប្រទេសកម្ពុជា និងបណ្ដាប្រទេសដទៃទៀតនៅក្នុងតំបន់ និងផ្នែកផ្សេងទៀតនៃពិភពលោក**»។

និស្សិត AUPP ឆ្នាំទី៤ ផ្នែកកិច្ចការទូទៅ (Global Affairs) កញ្ញា ហៃ ចរិយា បានថ្លែងថា «**ខ្ញុំចាប់ផ្ដើមចូលរួមក្នុងកម្មវិធីកិច្ចប្រជុំគំរូអាស៊ានដំបូងក្នុងឆ្នាំ២០១៧ នៅទីក្រុងម៉ានីលនៃប្រទេសហ្វីលីពីន ក្រោមការរៀបចំដោយអង្គការ ASEAN Foundation**»។ កញ្ញាចរិយា បានបន្តថា៖ «បទពិសោធន៍ដែលខ្ញុំទទួលបានជំរុញឲ្យនាងខ្ញុំ ស្វែងយល់បន្ថែមអំពីកម្មវិធី ហើយចង់ចែករំលែកដល់និស្សិតផ្សេងទៀត ដូច្នេះខ្ញុំ និង និស្សិតដ៏ទៃទៀតនៅ AUPP បានសហការគ្នារៀបចំកម្មវិធីនេះនៅឆ្នាំ២០១៨ និងបន្តមកឆ្នាំ២០១៩ ក្រោមការជួយជ្រោមជ្រែងពី AUPP Community»។

របាយការណ៍របស់ក្រសួងមហាផ្ទៃ បានបង្ហាញថាប្រជាពលរដ្ឋខ្មែរ បានចេញទៅធ្វើការនៅប្រទេសថៃមានចំនួនជាង១លាននាក់ក្នុងនោះ មានពលករជាង៣០ម៉ឺននាក់ នៅមិនទាន់មានឯកសារស្របច្បាប់នៅឡើយ ដែលករណីនេះ គឺជាហានិភ័យខ្ពស់ នៃកំណើនជួញមនុស្ស និងធ្វើឱ្យស្ត្រីក្លាយជាគោលដៅនៃការបំពានផ្លូវភេទ។

AUPP គឺជាសាកលវិទ្យាល័យតែមួយគត់ នៅក្នុងប្រទេសកម្ពុជាដែលបានផ្ដល់សញ្ញាប័ត្រ និង បរិញ្ញាប័ត្រជាន់ខ្ពស់(អនុបណ្ឌិត) ពីសាកលវិទ្យាល័យនៅសហរដ្ឋអាមេរិក។ សិស្សដែលបញ្ចប់ ការសិក្សាពី AUPP នឹងទទួលបានសញ្ញាប័ត្រទ្វេមានន័យថាសញ្ញាបត្រមួយចេញដោយ AUPP និងមួយទៀតចេញដោយសាកលវិទ្យាល័យអារីហ្សូណា (University of Arizona) ដែលមានការទទួលស្គាល់ជាសាកល៕

## វៀតណាមបញ្ជូនពលរដ្ឋខ្មែរ ២៧នាក់ មកកម្ពុជាវិញ ពីបទឆ្លងដែនខុសច្បាប់

https://www.facebook.com/ General Department of Immigration – GDI 27-02-2019

ស្វាយរៀង៖ កម្លាំងស្នងការដ្ឋាននគរបាលខេត្ត ផែនអន្តោប្រវេសន៍ក្រុងបាវិត នាព្រឹកថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៩ សហការជាមួយ ការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនិតិជន លេខាធិការដ្ឋានខេត្ត មន្ទីរសង្គមកិច្ចខេត្ត បានទទួលពលរដ្ឋខ្មែរឆ្លងដែនខុសច្បាប់ ពីភាគីវៀតណាម តាមច្រកទ្វាអន្តរជាតិបាវិតចំនួន ១៨ គ្រួសារ មនុស្ស២៧នាក់ ស្រី១៩នាក់ ក្នុងនោះមានមនុស្សចាស់ចំនួន ១២នាក់ និងក្មេង១៥នាក់ស្រី៨នាក់។ ក្រោយពីប្រគល់ទទួលហើយ សមត្ថកិច្ចបានធ្វើការអប់រំ រួចឲ្យវិលត្រឡប់ទៅលំនៅដ្ឋានវិញ៕